ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

PHNOM PENH WATER SUPPLY AUTHORITY

# របាយការណ៍ប្រចាំឆ្នាំ

២០១៩







www.ppwsa.com.kh

# ទស្សនវិស័យ & បេសកកម្ម



## ទស្សនវិស័យ

រ.ទ.ស.ភ. បានប្តេជ្ញាចិត្តបន្តធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួល ដើម្បីឲ្យប្រជាពលរដ្ឋ រស់នៅក្នុងទីប្រជុំជន ខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា ។

## បេសកកម្ម

បេសកកម្មរបស់ រ.ទ.ស.ភ. គឺជានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ ។ ក្រៅពីនេះ រ.ទ.ស.ភ. បាននឹងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួនដល់បណ្តារដ្ឋាករទឹក ខេត្ត-ក្រុង មួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរ សំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក ។



ស្ថានីយបូមទឹក រោងចក្រជ្រោយចង្វារ

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | ឆ្នាំ ២០១៤ | ឆ្នាំ ២០១៣ | ឆ្នាំ ២០១២ |
|---|---|---|---|
| ស្ថានភាពហិរញ្ញវត្ថុ | | | |
| ក- ទ្រព្យសកម្មសរុប (ពាន់រៀល) | ១.១៦៦.០៥១.០៧៣ | ១.០៩៨.៩៧៦.៧១៦ | ៩៩៩.៦៨១.២៣០ |
| ខ- បំណុលសរុប (ពាន់រៀល) | ៤៣០.៤៦៦.៩៨៨ | ៤០៣.៧៩៥.០៨៦ | ៣៤០.១៧៨.៤៧៣ |
| គ- មូលធនសរុប (ពាន់រៀល) | ៧៣៥.៥៨៤.០៨៥ | ៦៩៥.១៨១.៦៣០ | ៦៥៩.៥០២.៧៥៧ |
| លទ្ធផលហិរញ្ញវត្ថុ | | | |
| ក- ចំណូលសរុប (ពាន់រៀល) | ១៥៦.៥៤២.៨៤៩ | ១៥១.៥៨០.២០៧ | ១៣៥.១១៩.៥១៨ |
| ខ- ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ (ពាន់រៀល) | ៥៦.០៥៦.៣៣៨ | ៤៨.០៨៦.៨០៣ | ៤២.៨៩១.៩៥៣ |
| គ- ចំណេញសុទ្ធក្រោយបង់ពន្ធ (ពាន់រៀល) | ៤៥.៧៤៧.៩១១ | ៣៨.០៨៨.០៣០ | ៣៤.៤២០.៩៦១ |
| អនុបាតហរិញ្ញវត្ថុ | | | |
| ក- អនុសន្ននីយភាព | | | |
| ១- អនុបាតចរន្ត (ចំនួនដង) | ៤,៩២ | ៤,២៨ | ៤,១៣ |
| ២- អនុបាតចរន្តលឿន (ចំនួនដង) | ៤,២៣ | ៣,៤៨ | ៣,១៣ |
| ខ- អនុបាតចំណេញភាព | | | |
| ១- ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម (ភាគរយ) | ៤,០៤ | ៣,៦៣ | ៣,៦៩ |
| ២- ផលចំណេញក្នុងមួយឯកតាមូលធន (ភាគរយ) | ៦,៣៩ | ៥,៦២ | ៥,៥១ |
| ៣- ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៥២៦,០០ | ៤៣៧,៩៣ | ៤១៤,០៩ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១០៥,២០ | ៥៤,៧៤ | ២៧,៧០ |

| ភាគហ៊ុនិក | ចំនួនភាគហ៊ុន | កម្មសិទ្ធិភាព | រយៈពេលឡុកអាប់ |
|---|---|---|---|
| ភាគហ៊ុនប្រភេទ (ក) | | | |
| ១- រដ្ឋ តំណាងដោយ (ស.ហ.វ.) | ៣៩១.១០០.៩៤២ | ១០០% | |
| ភាគហ៊ុនធម្មតា | | | |
| ១- រដ្ឋ តំណាងដោយ (ស.ហ.វ.) | ៧៣.៩២៧.១៨៧ | ៨៥% | ១ឆ្នាំ |
| ២- ESOP | ១.៣០៤.៥៩៨ | ១,៥% | ៣ឆ្នាំ |
| ៣- ភាគហ៊ុនិកឯកជន | ១១.៧៤១.៣៧៧ | ១៣,៥% | ហ្លួតសេរី |
| សរុបភាគហ៊ុនធម្មតា | ៨៦.៩៧៣.១៦២ | ១០០% | |

## ក្នុងឆ្នាំ២០១៤

រ.ទ.ស.ភ. អាចធ្វើការផលិតទឹកស្អាតបាន ១៤៩.៥៥២.០៩៥ម៣ ស្មើនឹង ១០១% នៃផែនការ និងដាក់បណ្តាញ ចែកចាយទឹកក្នុងរាជធានីភ្នំពេញបានប្រវែង ១៦០.៩១២,៦៧ម៉ែត្រ។ តបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋមានចំណូលទាប ដោយអនុវត្តគោលការណ៍ឧបត្ថម្ភធន និងបង់រំលស់របស់អង្គភាពបានចំនួន១.១៤៩គ្រួសារ ក្នុងនោះប្រជាពលរដ្ឋចំនួន១.១៤៧គ្រួសារ យើងបានប្រើប្រាស់ប្រាក់ឧបត្ថម្ភធនចំនួន២៦៨.២២៥.៩២០រៀល ដែលជាថវិការបស់ធនាគារពិភពលោក ចំនួន ៨៤.៧៧៧.២០០រៀល និងមូនិធិរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចំនួន១៨៣.៤៤៨.៧២០រៀល ទ្រព្យសកម្មមានចំនួនរហូតដល់ប្រមាណ ១.១៦៦ពាន់លានរៀល ប្រាក់ចំណូលសរុបមានចំនួន ប្រមាណ ១៥៦ពាន់លានរៀល ក្នុងនោះចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ មានចំនួនប្រមាណ ៥៦ពាន់លានរៀល និងប្រាក់ចំណេញក្នុងការិយបរិច្ឆេទចំនួនប្រមាណ ៤៥ពាន់លានរៀល។

# ក្រាហ្វិកអំពី ព័ត៌មានហិរញ្ញវត្ថុសង្ខេប

## បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងទំហំជួញដូរ




## ប្រាក់ចំណេញតាមបណ្តាឆ្នាំនីមួយៗ (ពាន់លានរៀល)




## ប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤ (ពាន់លានរៀល)




## កម្មសិទ្ធិភាព នៃភាគហ៊ុនធម្មតា







# សមាសភាព ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម សឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ស៊ឹម ស៊ីថា**
សមាជិកក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ម៉ី វ៉ាន់**
សមាជិកក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ឃួន ស្រេង**
សមាជិកក្រុមប្រឹក្សាភិបាល



**លោកស្រី ខិន ចន្ទ្រា**
សមាជិកក្រុមប្រឹក្សាភិបាល



**លោក ចាង យុនហ្វេង**
សមាជិកក្រុមប្រឹក្សាភិបាល



**លោក អោម សេង បូរ៉ា**
សមាជិកក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល



**ឯកឧត្តម សឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

## ក្នុងឆ្នាំ២០១៤នេះ

"ដោយទទួលបានទំនុកចិត្តពីរាជរដ្ឋាភិបាល ជាមួយនឹងការឧបត្ថម្ភ គាំទ្រពី ក្រសួងអាណាព្យាបាលទាំងពីរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានបំពេញកាតព្វកិច្ចដោយជោគជ័យ គ្រប់សកម្មភាពធុរកិច្ចរបស់ខ្លួន។ យើងកំពុងបន្ត អភិវឌ្ឍសេវាទឹកស្អាតជារៀងរាល់ថ្ងៃ ទាំងគុណភាព ទាំងបរិមាណ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ប្រើប្រាស់ របស់ប្រជាជននៃ ទីក្រុងភ្នំពេញ និងទីក្រុងតាខ្មៅ និងចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍របស់ ទីក្រុងទាំងពីរ។"

ក្នុងឆ្នាំ២០១៤ រ.ទ.ស.ភ. បានទទួលចំណូលសរុប ១៥៦.៥៤២.៨៤៩ពាន់រៀល និងប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ ៥៦.០៥៦.៣៣៨ពាន់រៀល។ លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកមានចំនួន ៤៥.៧៤៧.៩១១ ពាន់រៀល។ ចំណេញក្នុងមួយភាគហ៊ុន ជាមូលដ្ឋាន( basic earnings per share ) គឺ៥២៦,00 រៀល។

ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្មស្មើនឹង៤,០៤% ចំណែកឯផលចំណេញក្នុងមួយឯកតាមូលធនស្មើនឹង ៦,៣៩%។

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ។ ប្រើប្រាស់នូវគ្រប់វិធានការដើម្បី បង្កើន ផលិតកម្ម សេវាកម្ម និងធានាគុណភាពទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម-សេវាកម្ម និងឧស្សាហកម្ម។ ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុង ឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោមតាមច្បាប់។ សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូរអភិវឌ្ឍន៍ ក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ. ទៅតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល។ ធនាឲ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុដោយផ្សារភ្ជាប់ជាមួយប្រយោជន៍សង្គម។

គោលដៅយុទ្ធសាស្រ្តចម្បងរបស់ រ.ទ.ស.ភ. គឺ៖

- ពង្រីកការផ្គត់ផ្គង់ទឹកទៅជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារ ដូចគ្នានៅក្នុងរាជធានីភ្នំពេញ
- បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស
- វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក
- ប្រៀបធៀបបែបយុទ្ធសាស្រ្ត ជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក
- តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

## សេវាដ៏មានប្រសិទ្ធភាព

យើងនៅតែបន្តធានានាការផ្គត់ផ្គង់ទឹកស្អាត២៤ម៉ោងលើ២៤ម៉ោង ជាមួយនឹងគុណភាព ដែលអាចទទួលទានបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ។

ក្នុងឆ្នាំ២០១៤នេះ យើងផលិតបាន១៤៩.៥៥២.០៩៥ម៣។ ទន្ទឹមនេះយើងបានប្រើប៉ូលីអាលុយមីញ៉ូមក្លរ៉ាយ(PAC) ជំនួសសាច់ជូរវិញ ដើម្បីបង្កើន គុណភាពទឹក និងកាត់បន្ថយចំណាយលើសារជាតុគីមី។

ជាលទ្ធផលនៅក្នុងឆ្នាំនេះ កំណើនអតិថិជនក្នុងគ្រាបានកើនចំនួន ១៨.៤៩៧បណ្តាញ។ ក្នុងនោះកំណើនអតិថិជនដែលមានចំណូលទាប ចំនួន១.១៤៩ បណ្តាញ ដែលយើងតែងយកចិត្តទុកដាក់ជាទៀងទាត់។ ជាមួយគ្នានេះយើងបានខិតខំយ៉ាងស្វិតស្វាញក្នុងការរក្សាអត្រាទឹកបាត់បង់ ដែលជាសូចនករដ៏សំខាន់ក្នុងវិស័យទឹកស្អាតឲ្យស្ថិតក្នុងកម្រិត លេខមួយខ្ទង់គឺ ៧,៧៦% ប្រសើរជាងគេក្នុងតំបន់អាស៊ី។ យើងបានផ្សព្វផ្សាយពីការងារផ្គត់ផ្គង់ទឹកស្អាតរបស់យើង ដែលយើងតែងធ្វើជា ទៀងទាត់ជូនដល់ប្រជាពលរដ្ឋក្នុង សហគមន៍បានជ្រាប ហើយរាល់សំណើផ្សេងៗ ដែលយើងបានទទួលពីអតិថិជនពាក់ព័ន្ធ នឹងសេវាទឹកស្អាតត្រូវបានដោះស្រាយទាន់ពេលវេលាកំណត់។ បំពង់មេនាំទឹក និងបណ្តាញចែកចាយទឹកស្អាត ត្រូវបានពង្រីកជារៀងរាល់ថ្ងៃ បំពង់ប្រវែង ១៦០.៩១២,៦៧ម៉ែត្រ ត្រូវបានដាក់នៅក្នុងឆ្នាំ២០១៤ នេះ។

## ការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល បានជួបប្រជុំចំនួន០៥លើក ឆ្នាំ២០១៤នេះ៖

ប្រជុំពេញអង្គលើកទី០៨ អាណត្តិទី៥ គឺនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤

- បានពិនិត្យលើសំណើសុំពិនិត្យ-អនុម័តលើរបាយការណ៍លទ្ធផលហិរញ្ញវត្ថុឆ្នាំ២០១៣ (ក្រោយសវនកម្ម) និងសំណើសុំគោលការណ៍ បែងចែកប្រាក់ចំណេញ ឆ្នាំ២០១៣ និងបែងចែកភាគលាភដល់ភាគហ៊ុនិក
- បានពិនិត្យលើសំណើសុំពិនិត្យ-អនុម័តលើពិធីមហាសន្និបាតភាគហ៊ុនិកលើកទី២
- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្ម អនុវត្តត្រីមាសទី១ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី១ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងអភិវឌ្ឍទឹកស្អាតក្រុងកែប
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងផ្គត់ផ្គង់ទឹកស្អាតកោះពេជ្រ
- បានពិនិត្យលើរបាយការណ៍លទ្ធផលផ្សេងៗ

ប្រជុំពេញអង្គលើកទី០៩ អាណត្តិទី៥ គឺនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

- បានពិនិត្យនូវរបាយការណ៍លទ្ធផលការងារត្រីមាសទី២-ឆមាសទី១ និងផែនការត្រីមាសទី៣ ឆ្នាំ២០១៤
- បានពិនិត្យលើសំណើសុំពិនិត្យ-អនុម័តបន្ថែមថវិកាសម្រាប់ទូទាត់បញ្ចប់គម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធ ជំហាន១ ក្រោមថវិកាផ្ទាល់ របស់ រ.ទ.ស.ភ.
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី២ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍ ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី២ ឆមាសទី១ និង ផែនការត្រីមាស ទី៣ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី១ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងអភិវឌ្ឍទឹកស្អាតក្រុងកែប
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងផ្គត់ផ្គង់ទឹកស្អាតកោះពេជ្រ

<u>ប្រជុំពេញអង្គលើកទី១០ អាណត្តិទី៥ គឺនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤</u>

- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារឆ្នាំ២០១៤ (៨ខែបូក៤ខែប៉ាន់ស្មាន) និងសំណើសុំពិនិត្យ-អនុម័ត លើគម្រោងផែនការឆ្នាំ២០១៥
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ និងសំណើសុំពិនិត្យ-អនុម័ត លើគម្រោងកិច្ចលទ្ធកម្ម ឆ្នាំ២០១៥
- បានពិនិត្យលើរបាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ និងលើគម្រោង ប្រើប្រាស់មូលនិធិ សម្រាប់ឆ្នាំ២០១៥
- បានពិនិត្យលើការកែសម្រួលលក្ខន្តិកៈបុគ្គលិក រ.ទ.ស.ភ.
- បានពិនិត្យលើការយកភាគទាន១០% នៃថ្លៃប្រើប្រាស់ទឹកស្អាតរបស់ប្រជាជនក្នុងក្រុងតាខ្មៅ
- បានពិនិត្យរបាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី២ ឆ្នាំ២០១៤

<u>ប្រជុំវិសាមញ្ញលើកទី១១ អាណត្តិទី៥ គឺនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤</u>

- បានពិនិត្យលើរបាយការណ៍លទ្ធផលការចូលរួមដេញថ្លៃ គម្រោងទឹកស្អាតសែនមនោរម្យ របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ
- បានពិនិត្យលើសំណើសុំពិនិត្យលទ្ធភាពក្នុងការតែងតាំងអគ្គនាយករង ទទួលបន្ទុកការងារអាជីវកម្ម និងភាគទានលូទឹកស្អុយ ១០% ក្នុងរាជធានីភ្នំពេញ

<u>ប្រជុំពេញអង្គលើកទី១២ អាណត្តិទី៥ គឺនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤</u>

- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារ១០ខែ បូក២ខែប៉ាន់ស្មានឆ្នាំ២០១៤ និងផែនការត្រីមាសទី១ឆ្នាំ២០១៥
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍លទ្ធផលស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៤
- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី៣ ឆ្នាំ២០១៤
- បានពិនិត្យលើសំណើសុំគោលការណ៍លុបចេញពីបញ្ជីឆ្នាំ២០១៤ នូវអចលនទ្រព្យខូច-បាត់បង់គុណភាព និងធ្វើសំវិធានធន សន្និធិឃ្លាំងនូវ សម្ភារមិន ប្រើប្រាស់ និងប្រកាសលក់ឡៃឡុង
- បានពិនិត្យលើសំណើសុំពិនិត្យ-សម្រេចលើការបោះផ្សាយពាណិជ្ជកម្មពី រ.ទ.ស.ភ. ក្នុងសៀវភៅ myINVESTORguide
- បានពិនិត្យលើរបាយការណ៍ស្តីពីផលប៉ះពាល់ទៅលើរោងចក្រផលិតទឹកស្អាតនិរោធ

## ការរំពឹងទុកសម្រាប់ឆ្នាំខាងមុខ

ដើម្បីឈានឆ្ពោះទៅសម្រេចទស្សនវិស័យរបស់ រ.ទ.ស.ភ. នឹងធ្វើការងារសំខាន់ៗ ដូចខាងក្រោម៖

- ការអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស
- ការអភិវឌ្ឍន៍មធ្យោបាយ និងសម្ភារប្រើប្រាស់
- សូចនករសេវាកម្ម និងសូចនករប្រសិទ្ធភាពការងារ។

បណ្តាសូចនករសំខាន់ៗ ដែលត្រូវតាមដាន និងត្រួតពិនិត្យមានដូចខាងក្រោម៖

- ផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញ: ១០០% នៅឆ្នាំ ២០២០
- អត្រាដំណើរការសហគ្រាស: ទាបជាង ៤០%
- អត្រាទារប្រាក់ថ្លៃប្រើប្រាស់ទឹក: មិនទាបជាង ៩៩%
- អត្រាទឹកបាត់បង់: ក្នុងកម្រិត ៥%
- ថ្លៃប្រើប្រាស់ទឹកមធ្យម (អាស្រ័យដោយស្ថានភាពជាក់ស្តែង) ១.០០០រៀលម៉ែត្រគុប។

ដើម្បីបង្កើនទំនុកចិត្តពីសំណាក់ភាគហ៊ុនិក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានមោទនភាពក្នុងការខិតខំបន្តប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសកកម្ម របស់ខ្លួន។ ក្នុងឆ្នាំបន្ទាប់ យើងរំពឹងថានឹងបានទទួលប្រាក់ចំណេញពិត មិនតិចជាង ៤៤.០៧៧ លានរៀល ដូចដែលបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល និងក្រសួង អាណាព្យាបាលទាំងពីរ។

យើងខ្ញុំសូមថ្លែងសេចក្តីដឹងគុណដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល អាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ដែលបានផ្តល់ទំនុកចិត្ត និងការគាំទ្រចំពោះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

យើងក៏មានមោទនភាព និងសូមថ្លែងអំណរគុណចំពោះមន្ត្រី និងនិយោជិតគ្រប់ថ្នាក់ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបាន ខិតខំបំពេញការងារ ដោយស្មារតីទទួលខុសត្រូវខ្ពស់ ជំរុញឲ្យបានសម្រេចនូវលទ្ធផលដ៏ល្អប្រសើរនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥

**ប្រធានក្រុមប្រឹក្សាភិបាល**

**សឹម ណារ៉ា**

# សេចក្តីថ្លែងរបស់អគ្គនាយក



**ឯកឧត្តម ស៊ឹម ស៊ីថា**
អគ្គនាយក

## សមិទ្ធិផលសម្រេចបានក្នុងឆ្នាំ២០១៤

"តាងនាម រ.ទ.ស.ភ. ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១៤ និង របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ រ.ទ.ស.ភ. បានកត់ត្រានូវរបាយការហិរញ្ញវត្ថុ ដែលប្រកបដោយការរីកចម្រើនមួយទៀតក្នុងគ្រប់វិស័យនៃ ប្រតិបត្តិការរបស់ រ.ទ.ស.ភ.។ ក្នុងឆ្នាំ២០១៤នេះ រ.ទ.ស.ភ. ទទួលបានចំណូលសរុបចំនួនប្រមាណ១៥៦ពាន់លានរៀល និងចំណេញមុនបង់ពន្ធលើប្រាក់ចំណេញចំនួនប្រមាណ៥៦ពាន់លានរៀល និងលទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក ចំនួនប្រមាណ៤៥ពាន់ លានរៀល ។"

## សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៤

ដោយសារតែការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល ក្រសួងអាណាព្យាបាល និងក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងឆ្នាំ២០១៤ នេះ រ.ទ.ស.ភ. នៅតែមានការវិវឌ្ឍន៍ យ៉ាងខ្លាំងក្លា និងកំណើននៃប្រាក់ចំណេញ មានការកើនឡើងជាលំដាប់ លទ្ធផលនេះគឺជាគ្រឹះយ៉ាងរឹងមាំសម្រាប់ការរីកចម្រើនលូតលាស់ របស់ រ.ទ.ស.ភ.។ ដោយការគ្រប់គ្រងហានិភ័យបានល្អប្រសើរ បានប្រើប្រាស់នូវធនធានហិរញ្ញវត្ថុ មានប្រសិទ្ធភាពខ្ពស់ និងគ្រប់គ្រងការចំណាយបានយ៉ាងហ្មត់ចត់ ជាពិសេសដោយការយកចិត្តទុកដាក់ខ្ពស់លើការកាត់បន្ថយអត្រាទឹកបាត់បង់ ទោះបីសកម្មភាពជួសជុល និងពង្រីកថ្នល់ទូទាំងរាជធានីភ្នំពេញ ជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្តាលឲ្យមានការលេចធ្លាយបំពង់ទឹកក៏ដោយ ដូចបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យរួច ក្នុងឆ្នាំ២០១៤ នេះ រ.ទ.ស.ភ. ទទួលបានចំណូល សរុបចំនួន១៥៦.៥៤២.៨៤៩ពាន់រៀល កើនលើសឆ្នាំ២០១៣ ចំនួន៣,២៧% ហើយប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញមានចំនួន ៥៦.០៥៦.៣៣៨ពាន់រៀល និងប្រាក់ចំណេញរបស់ភាគហ៊ុនិកមានចំនួន ៤៥.៧៤៧.៩១១ពាន់រៀល។ នាចុងការិយបរិច្ឆេទនេះ ទ្រព្យសកម្មសរុបបានកើនឡើងរហូតដល់ ចំនួន១.១៦៦.០៥១.០៧៣ ពាន់រៀល។ ដើមទុនដែលរដ្ឋបានផ្តល់ឲ្យពីឆ្នាំ១៩៩៧ មានចំនួន ២៤៩.០៧០.៦០៧ពាន់រៀល បានកើនឡើងរហូតដល់ចំនួន៥៤១.២២៧.២៨២ពាន់រៀល។ ការកើនឡើងនេះគឺដោយសារ រ.ទ.ស.ភ. សម្រេចបានជោគជ័យយ៉ាងធំធេង ក្នុងការកាត់បន្ថយអត្រាបាត់បង់ទឹក ឲ្យនៅក្នុងកម្រិតលេខ១ខ្ទង់ ដែលអត្រាក្នុងឆ្នាំ ២០១៤នេះ មានត្រឹមតែ ៧,៧៦% ខុសឆ្ងាយខ្លាំងពីអត្រានា ឆ្នាំ១៩៩៣ មានរហូតដល់៧២%។ ការកាត់បន្ថយទឹកបាត់បង់ជាកត្តាស្លាប់-រស់ របស់ រ.ទ.ស.ភ. ក្នុងដំណើរការប្រព្រឹត្តកម្ម និងអាជីវកម្មរបស់ខ្លួនប្រកបដោយគុណភាព និងចេរភាព ក៏ដូចជាអាចបង្កលក្ខណៈឲ្យយើងមានទឹកស្អាតសម្រាប់ផ្គត់ផ្គង់ អាចផឹកបានពីក្បាលរ៉ូប៊ីណេ ដល់រាប់ម៉ឺនគ្រួសារ រួមទាំងគ្រួសារមានចំណូលទាបបំផុត ក្នុងតម្លៃមួយដ៏សមស្រប ដើម្បីចូលរួមចំណែក ក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ រ.ទ.ស.ភ. មានសមត្ថភាពផ្គត់ផ្គង់ទឹក២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្តាហ៍។ ដោយក្នុងឆ្នាំ ២០១៤នេះ អាចធ្វើការផលិតបានចំនួន

១៤៩.៥៥២.០៩៥ម³។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកស្អាត ឥតឈប់ឈរក្នុងរាជធានីភ្នំពេញ និងជាយរាជធានី យើងកំពុងរៀបចំដំណើរការសាងសង់រោងចក្រនិរោធជំហាន២ ដែលមានសមត្ថភាពផលិត ១៣០.០០០ម³/ថ្ងៃ រោងចក្រនេះនឹងមានលទ្ធភាពពង្រីកការផ្គត់ផ្គង់ទឹក ជូនអតិថិជននៅតំបន់ជាយរាជធានីភ្នំពេញ ដែលពុំទាន់បានទទួលសេវាកម្មគ្រប់ដណ្តប់នៅឡើយ។ ការប្រព្រឹត្តកម្មទឹកស្អាត គឺគោរពតាមស្តង់ដារគុណភាពទឹកជាតិ និងអង្គការសុខភាពពិភពលោក(WHO) ដោយមានបន្ទប់ពិសោធន៍ គុណភាពទឹកអាចវិភាគបាន៥៣មុខ ជាងនេះទៀតចុងឆ្នាំនេះ យើងមានការវិភាគលើ២១៣មុខ ពីមន្ទីរពិសោធន៍ក្រៅប្រទេស (មន្ទីរពិសោធន៍សិង្ហបុរី និងសៀងហៃ)។ ការយកចិត្តទុកដាក់លើ គុណភាពទឹកនេះធ្វើឲ្យ រ.ទ.ស.ភ. អាចធានាជូនអតិថិជន បាននូវការផឹកដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ ដើម្បីចូលរួមចំណែក ក្នុងការទទួលខុសត្រូវចំពោះសង្គម ក្នុងគោលដៅជំរុញឲ្យប្រជាជនគ្រប់រូបមានទឹកស្អាតប្រើប្រាស់ ដែលជាកម្មវិធីទឹកស្អាតសម្រាប់ ទាំងអស់គ្នា(Water for All) ដោយមានសេវាអនាម័យត្រឹមត្រូវ ដើម្បីការរស់នៅប្រកបដោយសុខុមាលភាព មានជីវភាពល្អប្រសើរ និងមានបរិស្ថានល្អ។ សមិទ្ធផលសម្រេចបានផ្សេងៗទៀតរបស់ រ.ទ.ស.ភ. សម្រាប់ឆ្នាំ២០១៤ គឺការទទួលពានរង្វាន់ថ្នាក់អន្តរជាតិ ចំនួនប្រាំមួយទៀតគឺ (ទី១) ពានរង្វាន់ "International Trophy for Quality" ដែលបានប្រគល់ដោយ Global Trade Leaders' Club នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤ នៅទីក្រុងប៉ារីស ប្រទេសបារាំង ការវាយតម្លៃជ័យលាភី បានផ្អែកជាសំខាន់ទៅលើការគ្រប់គ្រងគុណភាពសរុប (Total Quality Management) ដោយរាប់បញ្ចូលទាំងការសម្រេចបាន និងការលើកម្ពស់ ទស្សនវិជ្ជា ស្តីពីគុណភាព ដែលធ្វើឲ្យសហគ្រាសឧស្សាហកម្មទាំងឡាយទទួលបាននូវឧត្តមភាពខ្ពស់ (ទី២) គឺពានរង្វាន់ "The Diamond Eye Award for Quality Commitment and Excellence" ដែលបានប្រារព្ធធ្វើឡើងកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៣ នៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ ប្រគល់ដោយសមាគម Otherways Management Association Club-Paris ដែលផ្អែកសំខាន់ទៅលើការគ្រប់គ្រងគុណភាពសរុប ដោយរាប់បញ្ចូលទាំងគុណភាពក្នុងការបម្រើអតិថិជន ភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្ត របស់ថ្នាក់ដឹកនាំការកែលម្អឥតឈប់ឈរ សកម្មភាពផ្អែកលើការពិត និងការចូលរួមពីនិយោជិត (ទី៣) ការទទួលពានរង្វាន់ European Award for Best Practices ប្រគល់ដោយ European Society for Quality Research ។ ពានរង្វាន់នេះជាពានរង្វាន់ ថ្នាក់អន្តរជាតិដែលបានបង្កើតឡើងសម្រាប់ប្រគល់ជូន ដល់បណ្តាក្រុមហ៊ុន អង្គការ និងសហគ្រាសសាធារណៈទាំងឡាយលើពិភពលោកដែលត្រូវបានទទួលស្គាល់ថាមានការប្តេជ្ញាចិត្តក្នុងការសម្រេចបាននូវយុទ្ធសាស្ត្រ គ្រប់គ្រងគុណភាពប្រកបដោយលទ្ធផលល្អប្រសើរ។ ការវាយតម្លៃផ្តល់ជ័យលាភីបានផ្អែក ជាសំខាន់ទៅលើយុទ្ធសាស្ត្រគ្រប់គ្រងគុណភាព (Quality Management Strategies) ដោយរាប់បញ្ចូលនូវលទ្ធផលអាជីវកម្មខ្ពស់ ការអនុវត្តការងារបានល្អប្រសើរបំផុត, ការយល់ដឹងអំពី គុណភាព និងសមិទ្ធផលនានា។ កម្មវិធីប្រគល់រង្វាន់បានប្រព្រឹត្តទៅនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤ នៅទីក្រុងប្រ៊ុយសែល ប្រទេសប៊ែលហ្ស៊ិក ដោយ **ឯកឧត្តម ហែម សាឯម** ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសប៊ែលហ្ស៊ិក បានអញ្ជើញចូលរួមនិងទទួលពានរង្វាន់នេះ តំណាងឲ្យ រ.ទ.ស.ភ. (ទី៤) គឺការទទួលពានរង្វាន់ International Europe Award for quality ប្រគល់ដោយ Global trade leader's club (ទី៥) ពានរង្វាន់ Best Quality Leadership Award "Las Vegas" និង(ទី៦) ពានរង្វាន់ "THE BIZZ" ទីក្រុងឌុយបៃ ប្រទេសអារ៉ាប់។ ការទទួលបាន ពានរង្វាន់ទាំងអស់ខាងលើនេះ កាន់តែធ្វើឲ្យ រ.ទ.ស.ភ. រក្សាបាននូវកេរ្តិ៍ឈ្មោះល្បីនៅលើឆាកជាតិ និងអន្តរជាតិ។ នេះជាជោគជ័យ ថ្មីបន្ថែមទៀតរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតរបស់ ប្រមុខរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងការគាំទ្រពី ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយនឹង ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាណាព្យាបាលព្រមទាំងក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ.។

ទិសដៅនៃការពង្រីកបណ្តាញចែកចាយទឹក គឺទៅតំបន់មានសក្តានុពលសេដ្ឋកិច្ច ដោយមិនមើលរំលងប្រជាពលរដ្ឋដែលមានចំណូលទាប ដោយក្នុងឆ្នាំ ២០១៤ នេះ រ.ទ.ស.ភ. ដាក់បំពង់បានប្រវែង ១៦០.៩១២,៦៧ម៉ែត្រ ដែលធ្វើឲ្យប្រវែងបំពង់មេ និងបំពង់ចែកចាយទឹកបច្ចុប្បន្ន សរុបស្មើនឹងប្រមាណ ២.៣១២ គីឡូម៉ែត្រ និងរក្សាសម្ពាធជាមធ្យម២០ម៉ែត្រ ក្នុងបណ្តាញចែកចាយទឹកទាំងមូល ដែល រ.ទ.ស.ភ. បានធ្វើការដាក់បំពង់មេនាំទឹកទំហំ ១៤០០ម.ម. និង ១៦០០ម.ម. ដែលផ្ទុយពីឆ្នាំ១៩៩៣ ដែលមានប្រវែងតែ ២៨៨គីឡូម៉ែត្រ ប៉ុណ្ណោះ។

យើងបានខិតខំធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាព សេវាអតិថិជនដើម្បីស្វែងរក និងបង្កើនចំនួនអតិថិជនធំៗដែលមានតម្រូវការទឹកច្រើន ដើម្បីធានា បាននូវ ប្រសិទ្ធភាពនៃការប្រមូលប្រាក់ថ្លៃទឹក ដែលអត្រាទារប្រាក់ក្នុងឆ្នាំនេះ រក្សាបានជាអតិបរិមា ហើយកំណើនបណ្តាញ អតិថិជនសម្រាប់ចុងឆ្នាំ២០១៤នេះ បានកើនឡើងចំនួន២៧០.៨១២បណ្តាញ ស្មើនឹង១០២,៣៥% នៃផែនការ ដែលមានចំនួន ២៦៤.៦០០បណ្តាញ។

## ការរំពឹងទុកសម្រាប់ឆ្នាំ២០១៥

ចំពោះឆ្នាំខាងមុខ យើងនឹងខិតខំប្រឹងប្រែងព្យាយាមបន្ថែមទៀតដើម្បីធ្វើឲ្យកាន់តែប្រសើរក្នុងការពង្រឹងនូវ អភិបាលកិច្ចសាជីវកម្មល្អរបស់ រ.ទ.ស.ភ. ហើយនៅតែប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសកកម្ម ដែលបានលើកពីបណ្ដាឆ្នាំមុនដដែល។ ជាទិសដៅសម្រាប់ឆ្នាំបន្ទាប់ រ.ទ.ស.ភ. សង្ឃឹមថានឹងទទួលបានប្រាក់ចំណេញពិត មិនតិចជាងចំនួនប្រមាណ ៤៤.០៧៧ លានរៀល ដែលក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលបានអនុម័ត។

រ.ទ.ស.ភ. ក៏នៅតែប្ដេជ្ញាចិត្តផ្ដល់សេវាកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីផ្ដល់ការជឿជាក់ពីអតិថិជន។ ជាងនេះទៅទៀត រ.ទ.ស.ភ. នៅតែខិតខំផ្ដល់បណ្ដាញទឹកជូនប្រជាពលរដ្ឋដែលមានចំណូលទាបតាមរូបភាពឧបត្ថម្ភថ្លៃច្បាប់ជាវទឹក ស្របទៅតាមកម្រិតជីវភាពគ្រួសារនីមួយៗ ពី៣០% ៥០% ៧០% និង ១០០% ដើម្បីអនុវត្តគម្រោងចែកចាយទឹក ពិសេសជូនសហគមន៍ក្រីក្រ ដោយប្រើថវិការបស់ រ.ទ.ស.ភ. ដើម្បីប្រយោជន៍ប្រជាជន។

ជាការបោះជំហានថ្មីមួយទៀតសម្រាប់ រ.ទ.ស.ភ. ដែលពុំធ្លាប់មានពីមុនមក សម្រាប់ឆ្នាំ២០១៥ ខាងមុខនេះ រ.ទ.ស.ភ. បានត្រៀមខ្លួនដើម្បីទទួលនូវ ពានរង្វាន់ចំនួនមួយទៀតគឺៈ ពាន់រង្វាន់ (Leadership Award for Outstanding Contribution to Water Efficiency) ដែលនឹងត្រូវទទួលនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ នៅក្នុងសមាជប្រចាំឆ្នាំ ស្ដីពីការចូលរួមទទួលខុសត្រូវចំពោះសង្គម "The Wold Corporate Social Responsibility (CSR) Day Congress" នារដ្ឋធានីម៉ុមបៃ ប្រទេសឥណ្ឌា ដែលមានអ្នកចូលរួមជាង២០០នាក់ មកពី១៣០ប្រទេស និងវាគ្មិនសរុប៧៩រូប។ ដែលក្នុងសមាជនេះ រ.ទ.ស.ភ. នឹងធ្វើបទបថកថា ស្ដីពី "ទឹកសម្រាប់ទាំងអស់គ្នា ករណីទីក្រុងភ្នំពេញ (Water for All-Phnom Penh Case)"។ ពានរង្វាន់នេះជាពាន់រង្វាន់ខ្នាតអន្តរជាតិដែលបានបង្កើត ឡើងសម្រាប់ប្រគល់ជូនដល់នាយកប្រតិបត្តិ នៃបណ្ដាអង្គភាព-ក្រុមហ៊ុនទាំងឡាយនៅលើពិភពលោក ដែលមានស្នាដៃឆ្នើមក្នុងការដឹកនាំអង្គភាព-ក្រុមហ៊ុន ឲ្យសម្រេចបាននូវជោគជ័យដ៏ត្រចះត្រចង់។ ការវាយតម្លៃផ្ដល់ជ័យលាភី ផ្អែកជាសំខាន់ទៅលើភាពប៉ិនប្រសព្វក្នុងការដឹកនាំរបស់បុគ្គល ដែលរួមមានភាពខ្លាំង ការច្នៃប្រឌិតចំណេះដឹង និងសុភវិនិច្ឆ័យ តាមរយៈជីវប្រវត្តិផ្ទាល់ខ្លួន អត្ថបទសារព័ត៌មាន កិច្ចសម្ភាសន៍ ពានរង្វាន់ផ្សេងៗ ដែលទទួលបាន និងព័ត៌មានលម្អិតពាក់ព័ន្ធ ដទៃទៀត។ ជាមួយនឹងពានរង្វាន់នេះ រ.ទ.ស.ភ. កាន់តែរក្សាបាននូវកេរ្តិ៍ឈ្មោះល្បី នៅលើឆាកជាតិ និងអន្តរជាតិ។ នេះជាជោគជ័យថ្មីស្រឡាងសម្រាប់រូបខ្ញុំបាទ និងជាជោគជ័យថ្មីបន្ថែមទៀត របស់ រ.ទ.ស.ភ. ក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តមទេសរដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយនិង **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុ ជាអាណាព្យាបាល ព្រមទាំងក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ. និងការខ្នះខ្នែងរួមគ្នាធ្វើការអស់ពីកម្លាំងកាយចិត្តរបស់ មន្ត្រី-និយោជិត រ.ទ.ស.ភ.។ ជាកិច្ចឆ្លើយតប នឹងគុណូបការៈគុណនេះ ខ្ញុំបាទផ្ទាល់ និងមន្ត្រី-និយោជិតទាំងអស់ នឹងបន្តខិតខំបំពេញបេសកកម្មរបស់ រ.ទ.ស.ភ. សំដៅបន្តពង្រឹង និងពង្រីកសេវាកម្មទឹកស្អាត ជូនដល់រាល់ប្រជាពលរដ្ឋក្នុងទូទាំងរាជធានីភ្នំពេញ ដើម្បីបន្តចូលរួមចំណែកសម្រេច *គោលដៅទី៧ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា*។

## សេចក្ដីថ្លែងអំណរគុណ

ជាថ្មីម្ដងទៀត រ.ទ.ស.ភ. មានសេចក្ដីសោមនស្សរីករាយ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីរាជរដ្ឋាភិបាល ក៏ដូចជាអាណាព្យាបាល ទាំងពីរ គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសូមសម្ដែង នូវអំណរគុណដល់ក្រុមប្រឹក្សាភិបាល ចំពោះការគាំទ្រ និងការដឹកនាំ ល្អសម្រាប់ឆ្នាំ២០១៤ និងសូមថ្លែងអំណរគុណជូនចំពោះអតិថិជនទាំងអស់ ដែលធ្វើឲ្យ រ.ទ.ស.ភ. បានទទួលជោគជ័យដូចសព្វថ្ងៃនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥

**អគ្គនាយក រ.ទ.ស.ភ.**

**ស៊ឹម ស៊ីថា**



# មាតិកា


ទស្សនវិស័យ និងបេសកកម្ម i
ព័ត៌មានហិរញ្ញវត្ថុ iii
សមាសភាពក្រុមប្រឹក្សាភិបាល vi
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល vii
សេចក្តីថ្លែងរបស់អគ្គនាយក xi

ផ្នែកទី១: ព័ត៌មានពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០២
១- ព័ត៌មានទូទៅអំពីបុគ្គលបោះផ្សាយ ០២
២- ដំណើរការធុរកិច្ចសង្ខេប ០២
៣- ស្ថានភាពទីផ្សារ ០៥
៤- ស្ថានភាពប្រកួតប្រជែង ០៥

ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ០៧
១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ០៧
២- ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច ៣២
៣- រចនាសម្ព័ន្ធចំណូល ៣២

ផ្នែកទី៣: អភិបាលកិច្ចសាជីវកម្ម ៣៤
១- ភាគហ៊ុនិក ៣៤
២- អង្គការលេខ ៣៧
៣- ក្រុមប្រឹក្សាភិបាល ៤០
៤- បុគ្គលិកជាន់ខ្ពស់ ៤៦
៥- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ ៥៤
៦- លាភការ ឬប្រាក់បំណាច់ចំពោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ ៥៥
៧- ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ៥៧

ផ្នែកទី៤: បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ៦១
១- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ៦១
២- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ៦១

ផ្នែកទី៥: ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ ៦១
១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ ៦១
២- ថ្លៃ និងបរិមាណជួញដូរ ៦២

ផ្នែកទី៦: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ៦៣

ផ្នែកទី៧: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ៦៦

ផ្នែកទី៨: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ១២១
- ១- ប្រតិបត្តិការជាមួយភាគហ៊ុនិក ១២១
- ២- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍ ១២១
- ៣- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ១២១
- ៤- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ រ.ទ.ស.ភ. ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ រ.ទ.ស.ភ. ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ រ.ទ.ស.ភ. ១២១
- ៥- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ ១២១
- ៦- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយ ដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១២១
- ៧- ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត ១២១

ផ្នែកទី៩: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ១២៣
- ១- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ១២៣
- ២- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ១២៩
- ៣- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ១៣០
- ៤- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ( Commodity ) ១៣០
- ៥- ផលប៉ះពាល់នៃអតិផរណា ១៣១
- ៦- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាល ១៣១

ផ្នែកទី១០: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន ១៣៣

ហត្ថលេខារបស់អភិបាលរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១៣៤





# ផ្នែកទី១: ព័ត៌មានពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ១- ព័ត៌មានទូទៅអំពី រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.)

### PHNOM PENH WATER SUPPLY AUTHORITY (PPWSA)

- <u>អាសយដ្ឋាន:</u> លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ព្រះរាជាណាចក្រកម្ពុជា
- <u>លេខទូរស័ព្ទ:</u> +៨៥៥(០)២៣ ៤៣០ ៥៤១ / ៧២៤ ០៤៦
- <u>លេខទូរសារ:</u> ៨៥៥(០)២៣ ៤២៧ ៦៥៧
- <u>គេហទំព័រ:</u> www.ppwsa.com.kh
- <u>អ៊ីម៉ែល:</u> sx.relationship@ppwsa.com.kh
- <u>លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម:</u> Co.០៨៣៩Et/២០១២
  <u>កាលបរិច្ឆេទ:</u> ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២
- <u>លេខអាជ្ញាបណ្ណអាជីវកម្ម:</u> អនុក្រឹត្យលេខ ៥២ អនក្រ.បក
  <u>កាលបរិច្ឆេទ:</u> ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦
- <u>សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ:</u> ០១២/១២ គ.ម.ក/ស.ស.រ.
  <u>កាលបរិច្ឆេទ:</u> ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២
- <u>ឈ្មោះបុគ្គលតំណាង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ:</u> **ឯកឧត្តម ស៊ឹម ស៊ីថា**

## ២- ដំណើរការធុរកិច្ចសង្ខេប

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាសហគ្រាសដែលផលិត និងចែកចាយទឹកស្អាត ដូចនេះដំណើរការនៃប្រព័ន្ធប្រព្រឹត្តកម្ម ប្រព័ន្ធចែកចាយទឹកស្អាត និងការងារគ្រប់គ្រងទឹកបាត់បង់តាមតំបន់ ជាដំណើរការដ៏សំខាន់នៃធុរកិច្ចរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

### ២.១- ដំណើរការនៃប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត

បច្ចុប្បន្ន រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានលទ្ធភាពផលិតទឹកស្អាតជាមធ្យមបាន ៤០៩.៧៣២ម៉ែត្រគុប/ថ្ងៃ លើសមត្ថភាពដើមប្រមាណ ៤៦០.០០០ម៉ែត្រគុប/ថ្ងៃ ដោយរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំនួន៤គឺះ

- <u>រោងចក្រភូមិព្រែក:</u> មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ១៧០.០០០ម៉ែត្រគុប/ថ្ងៃ
- <u>រោងចក្រជ្រោយចង្វារ:</u> មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ១៤០.០០០ម៉ែត្រគុប/ថ្ងៃ
- <u>រោងចក្រចំការមន:</u> មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ២០.០០០ម៉ែត្រគុប/ថ្ងៃ
- <u>រោងចក្រនិរោធ:</u> មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ១៣០.០០០ម៉ែត្រគុប/ថ្ងៃ

ប្រព្រឹត្តកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រចាំថ្ងៃ គឺផ្អែកតាមតម្រូវការប្រើប្រាស់ទឹករបស់ប្រជាជនក្នុងផ្ទៃសេវាដែលតម្រូវការនេះអាចកើនឡើង ឬថយចុះមិនទៀងទាត់ ដែលទាក់ទងនឹងកត្តារដូវកាល និងអាកាសធាតុ។ ការចាត់ចែងដំណើរការរោងចក្រនីមួយៗ ដើម្បីបំពេញតម្រូវការប្រើប្រាស់ ត្រូវបានគិតគូរដល់ប្រសិទ្ធភាពសេដ្ឋកិច្ច របស់រោងចក្រនីមួយៗជាចម្បង។

ជារួមសង្វាក់ផលិតកម្មទឹករបស់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតទាំងអស់របស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចែកចេញជា ៣ដំណាក់គឺះ

- ស្ថានីយបូមទឹកល្អក់

ស្ថានីយបូមទឹកល្អក់មានតួនាទីបូមទឹកល្អក់ពីប្រភពដើម (ទន្លេ) ដើម្បីបញ្ជូនទៅកាន់ស្ថានីយប្រព្រឹត្តកម្ម របស់រោងចក្រប្រព្រឹត្តកម្ម តាមបំពង់មេនាំទឹក ដែលក្នុងនោះរោងចក្រភូមិព្រែកបូមយកទឹកពីទន្លេសាប រោងចក្រជ្រោយចង្វារ

# ផ្នែកទី១: ព័ត៌មានពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ២- ដំណើរការធុរកិច្ចសង្ខេប (ត)

### ២.១- ដំណើរការនៃប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត (ត)

បូមយកទឹកពីទន្លេមេគង្គលើ រោងចក្រចំការមនបូមយកទឹកពីទន្លេបាសាក់ និងរោងចក្រនិរោធបូមយកទឹក ពីទន្លេមេគង្គក្រោម។ សំណង់ស្ថានីយបូមទឹកល្អក់របស់រោងចក្រភូមិព្រែក ជ្រោយចង្វារ និងនិរោធ ត្រូវបានសាងសង់ជាអគារបេតុងស្ថិតក្នុងទន្លេ ដោយឡែកស្ថានីយបូមទឹកល្អក់របស់រោងចក្រចំការមន ជាប្រភេទ ស្ថានីយបណ្តែត។

ជាទូទៅ កម្ពស់ទឹកទន្លេទាំង៣ ប្រែប្រួលទៅតាមរដូវកាល ហើយកម្ពស់ទឹកក្នុងឆ្នាំនីមួយៗក៏ពុំដូចគ្នា ដែរ ដោយសារតែកត្តាអាកាសធាតុ និងជាពិសេសអាស្រ័យទៅនឹងរបបទឹកទន្លេមេគង្គ។

- ស្ថានីយប្រព្រឹត្តកម្មទឹក

ប្រព័ន្ធប្រព្រឹត្តកម្មទឹកចែកជា ៦ដំណាក់កាលគឺ (ទី១)អាងទទួលទឹក (ទី២)អាងកូរ (ទី៣)អាងផ្តុំកករ (ទី៤) អាងរង (ទី៥) អាងច្រោះ និង(ទី៦) អាងស្តុកទឹកស្អាត។ ក្នុងការចម្រាញ់ទឹកដើម "ទឹកទន្លេ" ឲ្យទៅជាទឹកស្អាត ចាំបាច់ត្រូវប្រើសារធាតុគីមី សាច់ដូរ/ប៉ូលីអាលុយមីញ៉ូមក្លរ៉ាយ(PAC) កំបោរ និងឧស្ម័នក្លរ ដែលសារធាតុនីមួយៗ មានតួនាទីផ្សេងៗគ្នាក្នុងការសម្អាតទឹក៖

- សាច់ដូរ/ប៉ូលីអាលុយមីញ៉ូមក្លរ៉ាយ (PAC): មានតួនាទីធ្វើឲ្យភាគល្អិតតូចៗនៃកករចាប់ផ្តុំគ្នា ជាដុំកករធំ មានទម្ងន់ធ្ងន់ ដែលអាចរងចុះបាន។ ភាគល្អិតទាំងនេះ រួមមានដីឥដ្ឋ និងដីល្បាប់ សារធាតុគីមីសរីរាង្គ កាកសំណល់ពីដំណើរការប្រព្រឹត្តកម្មផ្សេងទៀត និងសារធាតុ សរីរាង្គ តូចៗជាច្រើនទៀត។
- កំបោរ: សម្រាប់បង្កើន pH នៃទឹក មានន័យថាបន្ថយជាតិអាស៊ីតក្នុងទឹក។
- ក្លរ: មានតួនាទីសម្លាប់មេរោគ និងកម្ចាត់សារធាតុជីវសាស្ត្រ (ពពួកស្លែ) ចេញពីទឹក។

សង្វាក់ប្រព្រឹត្តកម្មទឹកស្អាត ប្រព្រឹត្តទៅតាមដំណាក់ៗ ដូចខាងក្រោម:

ដំបូងបង្អស់ ទឹកល្អក់ដែលបូមចេញពីទន្លេដោយស្ថានីយបូមទឹកល្អក់ ត្រូវបានបញ្ជូនទៅកាន់អាងទទួលទឹក។ នៅក្នុងអាងទទួលទឹក ដែលជាចំណុចចាប់ផ្តើមនៃដំណើរការប្រព្រឹត្តកម្ម សារធាតុគីមីមានសាច់ដូរ/ប៉ូលីអាលុយមីញ៉ូមក្លរ៉ាយ(PAC) កំបោរ និងក្លរ ត្រូវបានបញ្ចូលទៅក្នុងទឹក រួចទើបទឹកហូរចូលទៅអាងកូរ។ ក្នុងអាងកូរ សារធាតុគីមីត្រូវបានកូរឲ្យសព្វជាមួយទឹកដោយម៉ាស៊ីនកូរ(កូរក្នុងល្បឿនលឿន) ឬដោយបម្រែបម្រួលល្បឿននៃលំហូរទឹកក្នុងអាង។ បន្ទាប់ពីកូរសព្វហើយ ទឹកហូរទៅអាងផ្តុំកករ ដែលក្នុងអាងនេះ មានបំពាក់ដោយម៉ាស៊ីនកូរក្នុងល្បឿនយឺតៗ ក្នុងបំណងឲ្យកករជួបគ្នា និងចាប់គ្នាជាដុំកករធំ។

នៅក្នុងអាងរង ដុំកករធំៗ រងធ្លាក់ចុះទៅបាតអាង ហើយទឹកបន្តហូរចូលទៅក្នុងអាងច្រោះ ជាមួយនឹងកករតូចៗ ដែលពុំអាចរងចុះនៅក្នុងអាងរង ដោយកម្រិតល្អក់នៃទឹកដែលហូរចូលទៅក្នុងអាងច្រោះនៅ ត្រូវតែស្ថិតនៅក្នុងចន្លោះ ៤ ទៅ ៨ NTU។

អាងច្រោះមានតួនាទីជាតម្រង ដែលចម្រាញ់ ឬត្រងយកចេញនូវភាគល្អិតនៃកករ ដែលសេសសល់ពីអាងរង និងដកយកសំរាមដែលអណ្តែតចេញពីទឹក។

នៅទីនេះ ភាគល្អិតនៃពពួកស្លែ ក៏ត្រូវបានត្រងយកចេញផងដែរ។

ទឹកដែលចេញពីអាងច្រោះ ត្រូវមានកម្រិតល្អក់មិនលើសពី៥ NTU។ ទឹកដែលច្រោះរួច ត្រូវបានបញ្ចូលសារធាតុក្លរទៅក្នុងទឹកមួយលើកទៀត សម្រាប់កម្ចាត់មេរោគ និងសារធាតុស្លែដែលនៅសេសសល់ និងបម្រុង សម្រាប់កំចាត់មេរោគអាចមាននៅតាមបំពង់ចែកចាយទឹក ជាពិសេសនៅតាមបរិក្ខារទឹកតាមផ្ទះ មានជាអាទិ៍ អាងទឹក និងរូបីណេ ជាដើម។ ការបញ្ចូលក្លរត្រូវបានត្រួតពិនិត្យ ដើម្បីធានាឲ្យមានបរិមាណក្លរសេរីសមល្មម តាមកម្រិតកំណត់នៅក្នុងទឹកស្អាត។ ទឹកដែលចេញពីអាងច្រោះជាទឹកស្អាត ត្រូវបានបញ្ជូនទៅស្តុកក្នុងអាងស្តុកទឹកស្អាត សម្រាប់បូមបញ្ជូនទៅក្នុងប្រព័ន្ធចែកចាយ។

ដោយសារតម្រូវការទឹកស្អាតប្រចាំម៉ោងមិនស្មើគ្នា ហេតុនេះអាងស្តុកទឹកស្អាតក្នុងរោងចក្រមានតួនាទីសម្រប-សម្រួល រវាងបរិមាណទឹកប្រព្រឹត្តកម្ម និងបរិមាណទឹកផ្គត់ផ្គង់ ពោលគឺស្តុកទឹកនៅម៉ោងមានតម្រូវការតិច និងបញ្ចេញទឹក បង្គ្រប់សម្រាប់ម៉ោងមានតម្រូវការទឹកខ្ពស់។ សមត្ថភាពស្តុកទឹកស្អាតរបស់រោងចក្រនីមួយៗមានដូចខាងក្រោម៖

- រោងចក្រភូមិព្រែក មានអាងស្តុកទឹកស្អាត ២៥.០០០ម៉ែត្រគូប
- រោងចក្រជ្រោយចង្វារ មានអាងស្តុកទឹកស្អាត ២៥.០០០ម៉ែត្រគូប
- រោងចក្រចំការមន មានអាងស្តុកទឹកស្អាត ១.៥០០ម៉ែត្រគូប
- រោងចក្រនិរោធ មានអាងស្តុកទឹកស្អាត ២៣.០០០ម៉ែត្រគូប

- ស្ថានីយបូមទឹកស្អាត

មានតួនាទីបូមបញ្ជូនទឹកស្អាតទៅក្នុងប្រព័ន្ធចែកចាយទឹក។ ស្ថានីយនេះបំពាក់ទៅដោយម៉ូទ័របូមទឹក និងប្រព័ន្ធបញ្ជា ព្រមទាំងប្រព័ន្ធសម្របសម្រួលសម្ពាធទឹកស្វ័យប្រវត្តិ ដើម្បីជានាស្ថេរភាពក្នុងការផ្គត់ផ្គង់។

## ២.២- ដំណើរការនៃប្រព័ន្ធចែកចាយទឹកស្អាត

ប្រព័ន្ធចែកចាយទឹកស្អាតត្រូវបានបែងចែកជា ២ផ្នែកគឺ៖

- <u>បំពង់មេនាំទឹក:</u> ជាបំពង់មេធំៗមានទំហំចាប់ពី ២៥០ម.ម. ឡើងទៅ ដែលមានតួនាទីបញ្ជូនទឹកស្អាតពីស្ថានីយបូមទឹកស្អាតទៅបំពង់ចែកចាយ។ បច្ចុប្បន្ន រ.ទ.ស.ភ. មានបំពង់មេទំហំធំ បំផុត ១.៦០០ ម.ម.។ ដោយផ្អែកលើតួនាទី និងសម្ពាធទឹកក្នុងបំពង់ ដូចនេះបំពង់មេនាំទឹក ត្រូវបានកំណត់ឲ្យប្រើប្រាស់បំពង់ប្រភេទដែកស្វិត (Ductile Iron)។
- <u>បំពង់ចែកចាយទឹក:</u> ជាបំពង់មានទំហំចាប់ពី៥០ ម.ម. ដល់ ២០០ ម.ម. ដែលទទួលទឹកស្អាត ពីបំពង់មេនាំទឹក រួចចែកចាយដល់អតិថិជន។ រ.ទ.ស.ភ. កំណត់ឲ្យប្រើប្រាស់បំពង់ចែកចាយជាប្រភេទ HDPE ព្រោះមានតម្លៃថោកសមរម្យ តែមានគុណភាពខ្ពស់សមស្រប លើកលែងតែបំពង់ចែកចាយក្នុងខណ្ឌ៧មករា និងមួយផ្នែកនៃខណ្ឌទួលគោក ដែលស្ថិតក្នុងគម្រោងជំនួយរបស់ប្រទេសជប៉ុន ទើបជាបំពង់ដែកស្វិត។

## ២.៣- ការងារគ្រប់គ្រងទឹកបាត់បង់តាមតំបន់

ការងារដែលមានលក្ខណៈជាគន្លឹះបំផុតនោះគឺ ការងារគ្រប់គ្រងទឹកបាត់បង់តាមតំបន់ ដោយហេតុថា រ.ទ.ស.ភ. បានចាត់ទុកការងារកាត់បន្ថយទឹកបាត់បង់ គឺជាកត្តាស្លាប់-រស់ របស់អង្គភាព ព្រោះការកាត់បន្ថយទឹកបាត់បង់ឲ្យចុះទាប ជាហេតុនាំឲ្យបង្កើនបាននូវអត្រាធ្វើវិក្កយបត្រ និងឈានទៅបង្កើនបាននូវចំណូលថ្លៃទឹក។

លទ្ធផលដែល រ.ទ.ស.ភ. សម្រេចបានជោគជ័យដ៏ធំធេងក្នុងការកាត់បន្ថយអត្រាបាត់បង់ទឹក ឲ្យនៅក្នុងកម្រិតលេខ១ខ្ទង់ គឺដោយ រ.ទ.ស.ភ. បានបង្កើតនូវវិធានការចំនួន ៦ ក្នុងកម្មវិធីកាត់បន្ថយទឹកបាត់បង់ របស់ខ្លួនគឺ៖

- ការងារគ្រប់គ្រងអតិថិជន
- ការងារគ្រប់គ្រងនាឡិកាទឹក
- ការផ្លាស់ប្តូរបំពង់ចាស់ដោយដាក់បំពង់ថ្មី
- ការជួសជុលទឹកធ្លាយទាន់ពេលវេលា
- ការងារគ្រប់គ្រងទឹកជាតំបន់
- ការបង្ការ និងបង្ក្រាបបទល្មើស

# ផ្នែកទី១: ព័ត៌មាន
# ពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ៣- ស្ថានភាពទីផ្សារ

ទីផ្សាររបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺ **"ផ្ទៃសេវា"** ដែលគ្រប់គ្រងដោយ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាជនប្រើប្រាស់ក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ។

រាជធានីភ្នំពេញមានខណ្ឌចំនួន១១ ហើយ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានគូសប្លង់បែងចែកខណ្ឌទាំងនោះទៅជាតំបន់ និងអនុតំបន់ ដោយមានបញ្ជាក់ពីទីតាំងនាឡិកាទឹកអនុតំបន់ ដែលបានដំឡើងក្នុងអនុតំបន់នីមួយៗ។ ក្នុងក្រុងមាន ៤ខណ្ឌ និងជាយក្រុងមាន ៧ខណ្ឌ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានផ្តល់សេវា ១០០% នៅក្នុងក្រុង មានខណ្ឌដូនពេញ ៧មករា ចំការមន និងទួលគោក។ ផ្ទៃសេវាសម្រាប់ខណ្ឌទាំង៧ តាមតំបន់ជាយក្រុងនៅមានកម្រិតជាក់ស្តែងក្នុងខណ្ឌដង្កោ មានជ័យ និងឫស្សីកែវ មានផ្ទៃសេវាប្រមាណត្រឹមតែ ៦០% ប៉ុណ្ណោះ។

| ល.រ | ខណ្ឌ | ចំនួនបណ្តាញអតិថិជន |
|---|---|---|
| ០១ | ដូនពេញ | ១៩.១៤៨ |
| ០២ | ៧មករា | ១៨.៥០៦ |
| ០៣ | ចំការមន | ២៩.៥១៨ |
| ០៤ | ទួលគោក | ២៩.២៨២ |
| ០៥ | ឫស្សីកែវ និងសែនសុខ | ៥៩.២០៥ |
| ០៦ | មានជ័យ | ៥១.៦៣៨ |
| ០៧ | ដង្កោ និងពោធិ៍សែនជ័យ | ៥១.៦២៧ |
| ០៨ | តាខ្មៅ | ១០.៨២៧ |
| ០៩ | អង្គស្នួល | ១.០៦១ |
| | សរុបរួម | ២៧០.៨១២ |

## ៤- ស្ថានភាពប្រកួតប្រជែង

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាអ្នកផ្គត់ផ្គង់ទឹកតែមួយគត់ (ម៉ូណូប៉ូលី) នៅក្នុងរាជធានីភ្នំពេញ និងមិនធ្វើការប្រកួតប្រជែងលើថ្លៃនៅលើទីផ្សារទេ ទោះស្ថិតក្នុងដំណាក់កាលណាក៏ដោយ។

# ផ្ទៃសេវារបស់ រ.ទ.ស.ភ. សម្រាប់ឆ្នាំ ២០១៤







# ផ្នែកទី២: ព័ត៌មានអំពី លទ្ធផលប្រតិបត្តិការធុរកិច្ច

## ១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

### ១.១- លទ្ធផលការងារប្រព្រឹត្តកម្ម ប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់

#### ដំណើរការនៃប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត

បច្ចុប្បន្ន រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានលទ្ធភាពផលិតទឹកស្អាតជាមធ្យមបាន ៤០៩.៧៣២ម៉ែត្រគុប/ថ្ងៃ លើសមត្ថភាពដើមប្រមាណ ៤៦០.០០០ម៉ែត្រគុប/ថ្ងៃ ដោយរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំនួន៤គឺ៖

- រោងចក្រភូមិព្រែក: មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ១៧០.០០០ម៉ែត្រគុប/ថ្ងៃ
- រោងចក្រជ្រោយចង្វារ: មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ១៤០.០០០ម៉ែត្រគុប/ថ្ងៃ
- រោងចក្រចំការមន: មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ២០.០០០ម៉ែត្រគុប/ថ្ងៃ
- រោងចក្រនិរោធ: មានសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតចំនួន ១៣០.០០០ម៉ែត្រគុប/ថ្ងៃ

ប្រព្រឹត្តកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រចាំថ្ងៃ គឺផ្អែកតាមតម្រូវការប្រើប្រាស់ទឹករបស់ប្រជាជនក្នុងផ្ទៃសេវា ដែលតម្រូវការនេះអាចកើនឡើង ឬថយចុះមិនទៀងទាត់ ដែលទាក់ទងនឹងកត្តារដូវកាល និងអាកាសធាតុ ។

ការចាត់ចែងដំណើរការរោងចក្រនីមួយៗ ដើម្បីបំពេញតម្រូវការប្រើប្រាស់ត្រូវបានគិតគូរទៅដល់ប្រសិទ្ធិភាពសេដ្ឋកិច្ចរបស់រោងចក្រនីមួយៗជាចម្បង ហេតុនេះទើបអត្រាដំណើរការរបស់រោងចក្រនីមួយៗ ធៀបនឹងសមត្ថភាពប្រព្រឹត្តកម្មពុំដូចគ្នាទាំងស្រុង ។

ជារួម សង្វាក់ផលិតកម្មទឹករបស់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតទាំងអស់របស់ រ.ទ.ស.ភ. ចែកចេញជា ៣ដំណាក់កាល៖

១- ស្ថានីយបូមទឹកល្អក់ (ទឹកទន្លេ)

២- ស្ថានីយប្រព្រឹត្តកម្មទឹក

៣- ស្ថានីយបូមទឹកស្អាត

#### ប្រព័ន្ធចែកចាយទឹកស្អាត

ប្រព័ន្ធចែកចាយទឹកស្អាតត្រូវបានបែងចែកជា ២ផ្នែកគឺ:

- <u>បំពង់មេនាំទឹក:</u> ជាបំពង់មេធំៗមានទំហំចាប់ពី ២៥០ម.ម. ឡើងទៅ ដែលមានតួនាទីបញ្ជូនទឹកស្អាត ពីស្ថានីយបូមទឹកស្អាតទៅបំពង់ចែកចាយ។ បច្ចុប្បន្ន រ.ទ.ស.ភ. មានបំពង់មេទំហំធំបំផុត ១.៦០០ម.ម.។ ដោយផ្អែកលើតួនាទី និងសម្ពាធទឹកក្នុងបំពង់ដូចនេះបំពង់មេនាំទឹក ត្រូវបានកំណត់ឲ្យប្រើប្រាស់បំពង់ប្រភេទដែកស្វិត (Ductile Iron)។
- <u>បំពង់ចែកចាយទឹក:</u> ជាបំពង់មានទំហំចាប់ពី ៥០ម.ម. ដល់២០០ម.ម. ដែលទទួលទឹកស្អាតពីបំពង់មេនាំទឹក រួចចែកចាយដល់អតិថិជន។ រ.ទ.ស.ភ. កំណត់ឲ្យប្រើប្រាស់បំពង់ចែកចាយ ជាប្រភេទ HDPE ព្រោះមានតម្លៃថោកសមរម្យ តែមានគុណភាពខ្ពស់សមស្រប លើកលែងតែបំពង់ចែកចាយក្នុងខណ្ឌ៧មករា និងមួយផ្នែកនៃខណ្ឌទួលគោក ដែលស្ថិតក្នុងគម្រោងជំនួយរបស់ប្រទេសជប៉ុនទើបជាបំពង់ដែកស្វិត ។

#### ការបាត់បង់ទឹក

ការងារដែលមានលក្ខណៈជាគន្លឹះបំផុតនោះគឺ ការងារគ្រប់គ្រងទឹកបាត់បង់តាមតំបន់ ដោយហេតុថា រ.ទ.ស.ភ. បានចាត់ទុកការកាត់បន្ថយទឹកបាត់បង់ គឺជាកត្តាស្លាប់រស់របស់អង្គភាព ដោយហេតុថាការកាត់បន្ថយទឹកបាត់បង់អោយចុះទាប ជាហេតុនាំឲ្យបង្កើនបាននូវអត្រាធ្វើវិក័យបត្រ និងឈានទៅបង្កើនបាននូវចំណូលថ្លៃទឹក ។

# ក- លទ្ធផលការងារប្រព្រឹត្តកម្ម

## ក.១- ប្រព្រឹត្តកម្ម

រ.ទ.ស.ភ. ដំណើរការនៃប្រព័ន្ធប្រព្រឹត្តកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រចាំថ្ងៃ គឺផ្អែកតាមតម្រូវការប្រើប្រាស់ទឹក របស់ប្រជាជន ក្នុងផ្ទៃសេវា ដែលតម្រូវការនេះអាចកើនឡើង ឬថយចុះមិនទៀងទាត់ ដែលទាក់ទងនឹងកត្តារដូវកាល និងអាកាសធាតុ។ ការចាត់ចែងដំណើរការរោងចក្រនីមួយៗ ដើម្បីបំពេញតម្រូវការប្រើប្រាស់ត្រូវបានគិតគូរទៅដល់ប្រសិទ្ធភាពសេដ្ឋកិច្ចរបស់រោងចក្រនីមួយៗជាចម្បង ហេតុនេះទើបអត្រាដំណើរការរបស់រោងចក្រនីមួយៗ ធៀបនឹងសមត្ថភាព ប្រព្រឹត្តកម្មពុំដូចគ្នាទាំងស្រុង។

ជាទូទៅ ការផលិតទឹកស្អាតរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺបំពេញតម្រូវការជាក់ស្តែង ហើយតាមរយៈការផលិតក្នុងរយៈពេលពេញមួយឆ្នាំ២០១៤នេះ យើងបានផលិតលើស ប្រមាណ១% ធៀបនឹងផែនការដែលបានគ្រោង។ បរិមាណទឹកដែលផលិតលើសនេះ រោងចក្រនិរោធបានផលិតច្រើនជាងគេ ហើយបានជួយផ្គត់ផ្គង់ទឹកទៅប៉ែកខាងត្បូងរាជធានីភ្នំពេញ និងតំបន់ផ្លូវចោមចៅ ដែលកន្លងមក មានសំពាធធ្លាប់ទាបនៅម៉ោងមានតម្រូវការទឹកស្អាតខ្ពស់។

ក្នុងរយៈពេលពេញមួយឆ្នាំ២០១៤ នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានបន្តធានាការផ្គត់ផ្គង់ទឹកស្អាត ស្របទៅតាមតម្រូវការរបស់អតិថិជន ដោយធានាទាំងបរិមាណ និងគុណភាពទឹកស្អាត គ្មានមេរោគ ព្រមទាំងអាចផឹកបានពីបណ្តាញដោយផ្ទាល់។ លទ្ធផលការងារប្រព្រឹត្តកម្មប្រចាំឆ្នាំ២០១៤ មានដូចខាងក្រោម

| **បរិយាយ** | **ផែនការឆ្នាំ** (គិតជា ម៉ែត្រគូប) | **អនុវត្តជាក់ស្តែង** (គិតជា ម៉ែត្រគូប) | **អត្រា** (គិតជា %) |
|---|---|---|---|
| រោងចក្រ ភូមិព្រែក | ៥៦.៥១១.៣០០ | ៥២.៥៣៦.៣៥៧ | ៩៣ |
| រោងចក្រ ជ្រោយចង្វារ | ៥២.៣៩៩.៥០០ | ៤៨.១២៦.១៣០ | ៩២ |
| រោងចក្រ ចំការមន | ៤.០៥២.៨២០ | ៣.៧០០.១៤៩ | ៩១ |
| រោងចក្រ និរោធ | ៣៥.១៣២.៥០០ | ៤៥.១៨៩.៤១៩ | ១២៩ |
| **សរុប** | ១៤៨.០៩៦.១២០ | ១៤៩.៥៥២.០៩៥ | ១០១ |



ទិដ្ឋភាពរោងចក្រផលិតទឹកស្អាតភូមិព្រែក

## កម្ពស់ទឹកទន្លេទាំង៣ តាមរដូវកាល

ស្ថានីយបូមទឹកល្អក់មានតួនាទីបូមទឹកល្អក់ពីប្រភពដើម(ទន្លេ) ដើម្បីបញ្ជូនទៅកាន់ស្ថានីយប្រព្រឹត្តកម្ម របស់រោងចក្រប្រព្រឹត្តកម្ម តាមបំពង់មេនាំទឹក ដែលក្នុងនោះរោងចក្រភូមិព្រៃកបូមយកទឹកពីទន្លេសាប រោងចក្រជ្រោយចង្វារបូមយកទឹកពីទន្លេមេគង្គលើ និងរោងចក្រចំការមន បូមយកទឹក ពីទន្លេបាសាក់ រោងចក្រនិរោធ បូមយកទឹកពីទន្លេមេគង្គក្រោម។ រ.ទ.ស.ភ. មានសំណង់ស្ថានីយបូម ទឹកល្អក់របស់រោងចក្រភូមិព្រៃក និងជ្រោយចង្វារ និងនិរោធ ត្រូវបានសាងសង់ជាអគារ បេតុងស្ថិតនៅក្នុងទន្លេ ដោយឡែកស្ថានីយបូមទឹកល្អក់របស់រោងចក្រចំការមន ជាប្រភេទស្ថានីយបណ្តែត។ ជាទូទៅកម្ពស់ទឹកទន្លេទាំង៤ ប្រែប្រួលទៅតាមរដូវកាល ហើយកម្ពស់ទឹកក្នុងឆ្នាំនីមួយៗ ក៏ពុំដូចគ្នាដែរ ដោយសារតែកត្តាអាកាសធាតុ និងជាពិសេសអាស្រ័យទៅនឹងរបបទឹកទន្លេមេគង្គ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មិនអាចផ្តល់ការធានាណាមួយថា កម្ពស់ទឹកទាំងនេះមិនមានបម្រែបម្រួលខ្លាំង នាពេលអនាគតខាងមុខនេះទេ។





# ក- លទ្ធផលការងារប្រព្រឹត្តកម្ម (ត)

## ក.១- ប្រព្រឹត្តកម្ម (ត)

បរិមាណនៃការប្រើប្រាស់ PAC សរុបទាបជាងផែនការប្រមាណ២៨% ចំណុចនេះគឺបណ្ដាមកពី ៖

- ភាពល្អក់របស់ទឹកទន្លេ (Turbidity of raw water) នៅដើមឆ្នាំនេះមានលក្ខណៈល្អប្រសើរជាងឆ្នាំកន្លងទៅ ដោយសារទទួលឥទ្ធិពលពីទន្លេមេគង្គលើ។
- សមត្ថភាពនៃការចាប់កករ ជាកាល់ស្យូមកាបូណាត (Alkalinity as $CaCo_3$) មានលក្ខណៈល្អជាងឆ្នាំកន្លងទៅ។

បរិមាណនៃការប្រើប្រាស់ក្លរ័លើសផែនការប្រមាណ៤% ដោយសារកត្តាដូចខាងក្រោម៖

- គុណភាពទឹកទន្លេសាបមានការធ្លាក់ចុះជាពិសេសនៅរដូវប្រាំង ដោយសារយើងសង្កេតឃើញថា សភាពទឹកមានក្លិនស្អុយ មានកករច្រើន មានពពុះច្រើន ដែលបញ្ជាក់ពីវត្តមានឧស្ម័នអាម៉ូញាក់មានការកើនឡើង និងកំរិតលោយរបស់អុកស៊ីសែនក្នុងទឹកមានការថយចុះ។
- បណ្ដាញចែកចាយទឹករបស់យើងកាន់តែច្រើន និងឆ្ងាយ ធ្វើឲ្យឧស្ម័នក្លរ័ងាយបាត់បង់ ដែលតម្រូវឲ្យយើងងាយបង្កើត និងបំពេញបន្ថែមបរិមាណក្លរ័។
- រោងចក្រផលិតទឹកស្អាតនិរោធបានដំណើរការសាកល្បង (Test and Commissioning) ដែលតម្រូវឲ្យប្រើប្រាស់បរិមាណក្លរ័ច្រើន។
- គុណភាពទឹកក្នុងបណ្ដាញចែកចាយ ពេលខ្លះហាក់មិនប្រសើរដែលតម្រូវឲ្យយើងត្រូវបង្កើន នូវបរិមាណក្លរ័ដើម្បីឲ្យគុណភាពទឹកស្អាតរបស់យើង អាចទទួលទានបានដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ។
- ក្នុងឆ្នាំនេះ រោងចក្រនិរោធ បានទទួលឥទ្ធិពលពីរបបទឹកទន្លេសាប ដែលមានលក្ខណៈមិនប្រសើរដែលតម្រូវឲ្យមានការប្រើក្លរ័ច្រើនបន្តិច។
- ក្រៅពីនេះរោងចក្រនិរោធ ក៏បានប្រើប្រាស់កំបោរដែរ ដោយសាររោងចក្រនេះត្រូវធ្វើតេស្តសាកល្បងគុណភាពទឹកក្នុងអំឡុងពេលដំណើរការសាកល្បង។

ការប្រើប្រាស់សាធាតុសាច់ជូរ នៅរោងចក្រចំការមន៖

- បច្ចុប្បន្នសាច់ជូរដែលនៅសេសសល់ក្នុងស្តុក រ.ទ.ស.ភ. មិនមានតម្រូវការប្រើប្រាស់ ដែលជាហេតុធ្វើឲ្យគុណភាពមានការថយចុះ (ទុកយូរ) ព្រមទាំងបាត់បង់ទម្ងន់ (ស្ងួត) ទើបយើងជំរុញឲ្យមានការប្រើប្រាស់សាច់ជូរនៅរោងចក្រចំការមន។

ការប្រើប្រាស់ថាមពលអគ្គិសនី មានការកើនឡើងប្រមាណ២% ធៀបទៅនឹងផែនការ កត្តានេះបណ្ដាមកពី៖

- យើងបានបង្កើនសំពាធទឹកចេញពីរោងចក្រ ដើម្បីឲ្យសំពាធទឹកបានសមស្របនៅចុងបណ្ដាញជាពិសេសរោងចក្រភូមិព្រែក និងរោងចក្រនិរោធ ដែលជាកត្តាធ្វើឲ្យមានការចំណាយលើថាមពលអគ្គិសនីច្រើន។
- រោងចក្រទាំងបួនបានខិតខំប្រឹងប្រែងផលិតទឹកលើសពីសមត្ថភាពដែលខ្លួនមាន (Over nominal capacity)
- ដំណើរការរបស់រោងចក្រនិរោធបច្ចុប្បន្នស្ថិតក្នុងស្ថានភាពផលិតទឹកពេញសមត្ថភាព ដើម្បីបង្កើនការផ្គត់ផ្គង់ទឹកទៅតាខ្មៅ ផ្លូវវែងស្រេង និងតំបន់ប៉ែកខាងលិចរាជធានីភ្នំពេញ ដែលតាមផែនការគ្រោងផលិតប្រមាណ៨៥%ប៉ុណ្ណោះ តែតាមស្ថានភាពជាក់ស្តែង បានផលិតទឹកលើសប្រមាណ២៩% ដែលជាកត្តាធ្វើអោយការប្រើប្រាស់ថាមពលអគ្គិសនី មានការកើនឡើងបើធៀបនឹងផែនការ។
- មានការដាច់ចរន្តអគ្គិសនីនៅតាមរោងចក្រញឹកញាប់ ដែលជាកត្តាត្រូវចំណាយលើសពីធម្មតាក្នុងពេលដំណើរការម៉ូទ័របូមឡើងវិញ។
  - រោងចក្រភូមិព្រែក : ដាច់ចរន្តអគ្គិសនី ២៣ដង ត្រូវជា២៧ម៉ោង ៥៤នាទី
  - រោងចក្រជ្រោយចង្វារ : ដាច់ចរន្តអគ្គិសនី ១៧ដង ត្រូវជា០៤ម៉ោង ៤០នាទី
  - រោងចក្រចំការមន : ដាច់ចរន្តអគ្គិសនី ០៣ដង ត្រូវជា០១ម៉ោង ២៥នាទី
  - រោងចក្រនិរោធ : ដាច់ចរន្តអគ្គិសនី ៨៩ដង ត្រូវជា៣៤ម៉ោង ១០នាទី

### លទ្ធផលការប្រើប្រាស់វត្ថុធាតុដើមក្នុងការប្រព្រឹត្តកម្មទឹកស្អាត ក្នុងឆ្នាំ២០១៤

| បរិយាយ | រោងចក្រ ភូមិព្រែក | | រោងចក្រ ជ្រោយចង្វារ | | រោងចក្រ ចំការមន | | រោងចក្រ និរោធ | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | ផែនការ | ជាក់ស្តែង | ផែនការ | ជាក់ស្តែង | ផែនការ | ជាក់ស្តែង | ផែនការ | ជាក់ស្តែង | ផែនការ | ជាក់ស្តែង |
| PAC (គីឡូក្រាម) | ៦៣៤.៩៥៤ (១១,២៥ក្រ/ម$^{៣}$) | ៤៨៧.៦០០ (៩,២៨ក្រ/ម$^{៣}$) | ២៥០.៨១៣ (៤,៧៩ក្រ/ម$^{៣}$) | ១៨៣.៧៧៥ (៣,៨២ក្រ/ម$^{៣}$) | ៥៦.៣១៧ (១៣,៩០/មម៣) | ២៤.៩២៥ (៦,៧៤ក្រ/ម$^{៣}$) | ២៨៥.៤៥៧ (៨,១៣ក្រ/ម$^{៣}$) | ២៦៤.០០០ (៥,៨៤ក្រ/ម$^{៣}$) | ១.២២៧.៥៤១ (៨,៨៧ក្រ/ម$^{៣}$) | ៩៦០.៣០០ (៦,៨២ក្រ/ម$^{៣}$) |
| កំបោរ (គីឡូក្រាម) | 0 | 0 | 0 | 0 | 0 | 0 | 0 | 0.0២0 (៣,១៥ក្រ/ម$^{៣}$) | 0 | 0.0២0 (៣,១៥ក្រ/ម$^{៣}$) |
| ក្លរ័ (គីឡូក្រាម) | ១៦២.២១៤ (២,៨៨ក្រ/ម$^{៣}$) | ១៩១.៩៩១ (២,៧0ក្រ/ម$^{៣}$) | ៩៨.៧៣៦ (១,៨៨ក្រ/ម$^{៣}$) | ៩១.៩១0 (១,៩១ក្រ/ម$^{៣}$) | ៨.៣៨0 (២,១0ក្រ/ម$^{៣}$) | ៧.៥២៤ (២,0៣ក្រ/ម$^{៣}$) | ៧៧.0៩៥ (២,២១ក្រ/ម$^{៣}$) | ១២៣.១៣៨ (២,៧២ក្រ/ម$^{៣}$) | ៣៤៦.៤២៥ (២,៣៥ក្រ/ម$^{៣}$) | ៣៦៤.៥៦៣ (២,៨៤ក្រ/ម$^{៣}$) |
| សាច់ជូរ (គីឡូក្រាម) | 0 | 0 | 0 | 0 | 0 | ១១.៦៥0 (៣,១៥ក្រ/ម$^{៣}$) | 0 | 0 | 0 | ១១.៦៥0 (៣,១៥ក្រ/ម$^{៣}$) |
| អគ្គិសនី (គ.វ៉.ម) | ១៣.0៣៩.៩៥៧ (២៣១វ៉ាត់/ម$^{៣}$) | ១៣.៨0៣.២៤៨ (២៦៣វ៉ាត់/ម$^{៣}$) | ១៤.0៣៦.៩៦៣ (២៦៨វ៉ាត់/ម$^{៣}$) | ១២.៦0៥.២៤0 (២៦២វ៉ាត់/ម$^{៣}$) | ១.១៥៦.៨៨៦ (២៨៦វ៉ាត់/ម$^{៣}$) | ១.0៩៤.១៩៨ (២៩៦វ៉ាត់/ម$^{៣}$) | ៩.៤២១.៩៤១ (២៦៩វ៉ាត់/ម$^{៣}$) | ១១.៤១៥.៤១៥ (២៥៣វ៉ាត់/ម$^{៣}$) | ៣៧.៦៥៥.៧៤៧ (២៥៥វ៉ាត់/ម$^{៣}$) | ៣៨.៩១៨.0៥១ (២៦0វ៉ាត់/ម$^{៣}$) |

## ក្រាហ្វិកបង្ហាញពីការប្រើប្រាស់វត្ថុធាតុដើម តាមបណ្តាញរោងចក្រនីមួយៗ




## លទ្ធផលគុណភាពទឹកតាមរោងចក្រ និងបណ្តាញចែកចាយ ក្នុងឆ្នាំ២០១៤

| មុខវិភាគ | ឯកតា | WHO | រោងចក្រ ភូមិព្រែក | រោងចក្រ ចំការមន | រោងចក្រ ជ្រោយចង្វារ | រោងចក្រ និរោធ | បណ្តាញចែកចាយ |
|---|---|---|---|---|---|---|---|
| ភាពល្អក់ | NTU | ≤ ៥ | ០,៦៨ | ១,១៧ | ០,៥៣ | ០,៤២ | ១,១៤ |
| តម្លៃប៉េហាស់ | pH | ៦,៥ - ៨,៥ | ៧,១១ | ៧,០២ | ៧,៦៦ | ៧,១៧ | ៧,៣៦ |
| ក្លរសេរី | mg/l | ០,១ - ១ | ០,៧៣ | ០,៦៧ | ០,៧៧ | ០,៦៤ | ០,២៨ |
| ក្លរសរុប | mg/l | < ២ | ០,៩០ | ០,៧៩ | ០,៩០ | ០,៧៩ | ០,៤១ |
| មេរោគកូលីហ្វម | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 |
| មេរោគអ៊ីកូលី | cfu/100ml | 0 | 0 | 0 | 0 | 0 | 0 |

ត្រួតពិនិត្យគុណភាពទឹកតាមរោងចក្រផលិតទឹកទាំងបួនចំនួន ៣ដង/ថ្ងៃ ត្រួតពិនិត្យគុណភាពទឹកនៅតាមបណ្តាញចែកចាយចំនួន ៨០កន្លែង/សប្តាហ៍ យ៉ាងទៀតទាត់ គុណភាពទឹកស្ថិតក្នុងកម្រិតអនុញ្ញាតរបស់ស្តង់ដារគុណភាពទឹកផឹកជាតិ។ ការងារត្រួតពិនិត្យគុណភាពទឹកទាំងនៅតាមរោងចក្រ និងតាមបណ្តាញចែកចាយតាមយន្តការ និងកម្មវិធីមានស្រាប់ បានជាប់លាប់ និងទៀតទាត់ ដោយធានាបាននូវគុណភាពទឹកគ្មានមេរោគ និងផឹកបានដោយផ្ទាល់ពីបណ្តាញ ស្របតាមស្តង់ដារទឹកផឹករបស់អង្គការសុខភាពពិភពលោក។

# ក- លទ្ធផលការងារប្រព្រឹត្តកម្ម (ត)

## ក.២.១- ការងារជួសជុល និងថែទាំប្រព័ន្ធប្រព្រឹត្តកម្ម (រោងចក្រ ភូមិព្រែក)

- ជួសជុលលាបថ្នាំអាងស្តុកថ្មីចំណុះ ១០០០០ម$^{៣}$
- ជួសជុលលាបថ្នាំអាងស្តុកថ្មីចំណុះ ៥០០០ម$^{៣}$
- ជួសជុលកែសម្រួលបន្ទប់អនាម័យក្នុងរោងចក្រ
- ជួសជុលលាបថ្នាំជញ្ជាំងខាងមុខរោងចក្រ
- ជួសជុលកែសម្រួលប្រព័ន្ធបញ្ជាលាងអាងច្រោះចាស់
- ជួសជុលផ្លាស់ប្តូរទុយោស្ពាន់បង្ហូរក្ល័រចំនួន ១ប្រព័ន្ធ
- បូមស្តារដីដែលដុះនៅជុំវិញស្ថានីយបូមទឹកល្អក់
- ជួសជុលលាបថ្នាំរូបសំណាកសឹង្ហនៅស្ថានីយបូមទឹកល្អក់
- ជួសជុលក្តារក្រាលស្ថានីយបូមទឹកល្អក់
- ផ្លាស់ប្តូរអំពូលស៊ីញាល់ប្តូរនៅទូបញ្ជាផ្នែកខាងលើ លាងអាងច្រោះ
- ជួសជុលលាបថ្នាំទឹកស៊ីម៉ង់ត៍លើផ្ទៃអាងរងចាស់
- ជួសជុលលាបថ្នាំម៉ូទ័របូមទឹកល្អក់១៨៥KW លេខ១ និងលេខ២
- ជួសជុលធ្វើគម្របដែកលើប្រឡាយបង្ហូរទឹកអាងច្រោះចាស់
- ជួសជុលប្រព័ន្ធ Vacuum សម្រាប់តភ្ជាប់ទុយោរបស់
- ជួសជុលម៉ូទ័របូមទឹកស្អាត ៣២០kw ម៉ូទ័របូមទឹកស្អាត
- បន្ថែមខ្សាច់ចម្រោះទឹកលើអាងច្រោះចាស់
- ជួសជុលកែសម្រួលប្រព័ន្ធ Chlorine
- ជួសជុលទុយោផ្លិចស៊ីបសម្រាប់បាញ់លាងអាងរង
- កែសសម្រួលប្រព័ន្ធបំពង់ក្ល័រ និង PAC
- ជួសជុលម៉ូទ័របូមទឹកស្អាត ១៨០kw
- ជួសជុលលាបថ្នាំបូមទឹកល្អក់ចំនួន ២គ្រឿង
- ជួសជុលលាបថ្នាំស្លាបកូរ និងម៉ូទ័រកូរយឺតចាស់
- ជួសជុលម៉ូទ័រកូរ PAC
- ជួសជុលដំបូលអគារអាងច្រោះចាស់
- កែសម្រួលប្រព័ន្ធបូមជំនួយក្ល័រនិង PAC
- ជួសជុលដំបូលអគារបូមទឹកស្អាតចាស់
- ជួសជុលកែសម្រួលបន្ទប់ទូភ្លើងចាស់
- ជួសជុលលាបថ្នាំស្លាបកូរ និងម៉ូទ័រកូរយឺតចាស់
- ជួសជុលលាបថ្នាំម៉ូទ័រកូរ PAC ចំនួន១គ្រឿង
- ជួសជុលទូបញ្ជាប្រព័ន្ធលាងអាងច្រោះ
- ជួសជុលដំបូលជ្រាបស្ថានីយបូមទឹកល្អក់



# ក.២.២- ការងារជួសជុល និងថែទាំប្រព័ន្ធប្រព្រឹត្តកម្ម (រោងចក្រ ជ្រោយចង្វារ)

- ជួសជុលប្រព័ន្ធក្លាប់ប៉េបូមទឹកស្អាតលេខ២ និងលេខ៣
- ជួសជុលផ្លាស់ប្តូរប្រព័ន្ធ Rubber Bearing សម្រាប់បូមទឹកល្អក់ លេខ១ និងលេខ៤ ចំនួន២គ្រឿង
- ជួសជុលប្រព័ន្ធម៉ាស៊ីនខ្យល់ និងកុំប្រេះស័រលេខ៣ និងលេខ៤
- ជួសជុលលាបថ្នាំផ្ទៃពិដានក្នុងអគារអាងច្រោះនិងអគារលាយល្បាយជាតិគីមី
- ជួសជុលម៉ូទ័របូមទឹកល្អក់លេខ២ និងប្រព័ន្ធកូរឃើតលេខ២
- ជួសជុលប្រព័ន្ធក្លាប់ប៉េបូមទឹកស្អាតលេខ១ និងលេខ៤
- ជួសជុលម៉ាស៊ីនខ្យល់ និងកុំប្រេះស័រលេខ១ និងលេខ២
- ជួសជុលផ្លាស់ប្តូរសម្ភារនិងគ្រឿងបន្លាស់ប្រព័ន្ធក្ល័រលេខ១
- ជួសជុលផ្លាស់ប្តូរប្រព័ន្ធ Rubber Bearing សម្រាប់បូមទឹកល្អក់
- ជួសជុលលាបថ្នាំគំរបអាងស្តុកទឹកចាស់ និងថ្មី
- ជួសជុលការ៉ូឡា និងចាក់សាបស៊ីម៉ង់ត៍ក្នុងបរិវេណរោងចក្រ
- ជួសជុលប្រព័ន្ធបន្សាបក្ល័រលេខ១ និងម៉ូទ័របូមទឹកសំណល់
- ជួសជុលប្រព័ន្ធសុញ្ញាកាសលេខ ១ និងលេខ ២របស់បូមទឹកស្អាត
- ធ្វើលួសបន្លាព័ទ្ធជុំវិញលើរបងរោងចក្រ
- ជួសជុលផ្លាស់ប្តូរប្រព័ន្ធបំភ្លឺភ្លើងក្នុងបរិវេណរោងចក្រ
- ជួសជុលផ្លាស់ប្តូរគ្រឿងបន្លាស់Rubber Bearing សម្រាប់បូមទឹកល្អក់លេខ១
- ជួសជុលប្រព័ន្ធកៀរភក់អាងរងលេខ ១
- ជួសជុលប្រព័ន្ធលាយ PAC និងប្រព័ន្ធក្ល័រ
- ជួសជុលប្រព័ន្ធកូរឃើតលេខ១
- ជួសជុលប្រព័ន្ធកង្ហាបឺតកំដៅក្នុងរោងចក្រ
- ជួសជុលទ្វារទឹកអាងច្រោះប្រព័ន្ធលេខ២
- ជួសជុលម៉ូទ័របូមទឹកល្អក់លេខ១ និងលេខ២
- ជួសជុលរៀបចំដាក់លួសបន្លាជុំវិញរបងរោងចក្រ
- ជួសជុលដំបូលជ្រាបទឹកនៅស្ថានីយបូមទឹកល្អក់
- ជួសជុលដងអាបម៉ូទ័រ PAC លេខ៤
- ជួសជុលផ្លាស់ប្តូរហ្វុយស៊ីប ( Fuse )
- ជួសជុលផ្លាស់ប្តូរ Power Factor Controller
- ជួសជុលទ្វារទឹកអាងច្រោះប្រព័ន្ធលេខ ១
- ធ្វើរូបសំណាកប្លង់រោងចក្រ
- ជួសជុលម៉ូទ័របូមទឹកភក់និងទ្វារទឹក
- បន្ថែមខ្សាច់ចម្រោះទឹកលើអាងច្រោះ
- ជួសជុល និងលាបថ្នាំបង្កាន់ដៃអាងរងចាស់
- ជួសជុលប្រព័ន្ធកូរឃើត



# ក- លទ្ធផលការងារប្រព្រឹត្តកម្ម (ត)

## ក.២.៣- ការងារជួសជុល និងថែទាំប្រព័ន្ធប្រព្រឹត្តកម្ម (រោងចក្រ ចំការមន)

- ជួសជុលកែសម្រួលប្រព័ន្ធបំភ្លឺភ្លើងនៅក្នុងបរិវេណរោងចក្រ
- ជួសជុលដំបូលអគារឃ្លាំងសាច់ជូរនិងកំបោរ
- ជួសជុលកែសម្រួលបន្ទប់ទឹកអនាម័យ
- ជួសជុលផ្លាស់ប្តូរបំពង់ទឹកលាងអាងរង
- ជួសជុលឥដ្ឋការ៉ូក្នុងអាគាររដ្ឋបាល
- ជួសជុលដំបូលអគារឃ្លាំងសាច់ជូរនិងកំបោរ
- ជួសជុលលាបថ្នាំប្រព័ន្ធកូរយើតអាងរងដែក
- ជួសជុលនិងលាបថ្នាំប្រព័ន្ធបូមទឹកល្អក់
- ជួសជុលនិងលាបថ្នាំអាងដែកទឹកស្អាត
- ជួសជុលលាបថ្នាំរបងនិងទ្វាររោងចក្រ
- ជួសជុលកែសម្រួលប្រព័ន្ធផែបណ្តែត
- ថែមខ្សាច់អាងច្រោះ
- ជួសជុលប្រព័ន្ធម៉ូទ័របូមទឹកស្អាត
- រៀបចំចាក់បង្គោល និងព័ន្ធច្រវ៉ាក់ជុំវិញខឿនការ៉ូឡាផ្នែកខាងមុខរបងរោងចក្រ
- ជួសជុលឧបករណ៍ការពារសំពាធគំហុក
- ជួសជុលប្រព័ន្ធសាច់ជូរ
- ជួសជុល និងលាបថ្នាំប្រព័ន្ធអាងច្រោះ
- ជួសជុលទ្វារទឹក និងម៉ូទ័រក្នុងរោងចក្រ
- កែសម្រួលប្រព័ន្ធលាយសាច់ជូរ និងកំបោរ
- ជួសជុលលាបថ្នាំប្រព័ន្ធកូរយើត
- ជួសជុលកែសម្រួលប្រព័ន្ធភ្លើងបំភ្លឺក្នុងបរិវេណរោងចក្រ ចំការមន
- ជួសជុលនិងលាបថ្នាំម៉ូទ័រកូរយើតអាងរង ថ្មចំនួន២ប្រព័ន្ធ
- ជួសជុលប្រព័ន្ធក្លរ
- ជួសជុលលាបថ្នាំបូមទឹកល្អក់





ទិដ្ឋភាព រោងចក្រ និរោធ

# ក.២.៤- ការងារជួសជុល និងថែទាំប្រព័ន្ធប្រព្រឹត្តកម្ម (ប្រព័ន្ធ Scada និងអាងតម្កល់ទឹក)

- ជួសជុលកែសម្រួលប្រព័ន្ធបញ្ជាលាងអាងច្រោះ រៀបចំផ្លាស់ប្តូរនាឡិកាភ្លើងមេ កែសម្រួលប្រព័ន្ធ Air Compressor ផ្លាស់ប្តូរនាឡិកាម៉ោងរបស់ម៉ូទ័របូមវត្ថុធាតុដើម និងម៉ូទ័របូមទឹកស្អាត រោងចក្រចំការមន
- ជួសជុលប្រព័ន្ធបូមទឹកសំណល់ ជួសជុលប្រព័ន្ធ Motor Valve(ORV)សម្រាប់បិទ-បើកអាងច្រោះលេខ១១ បំពាក់ បន្ថែមលើប្រព័ន្ធបញ្ជា លាងអាងច្រោះលេខ២ និងលេខ៣ ផ្លាស់ប្តូរប្រព័ន្ធការពារទូបញ្ជាម៉ូទ័របូមទឹកស្អាត(ហ្វុយស៊ីប) ជួសជុលផ្លាស់ ប្តូរ Limit switch ម៉ាស៊ីនគៀរកក់ ជួសជុលម៉ូទ័រ Floculatorលេខ១ អាងរងចាស់ ផ្លាស់ប្តូរអំពូលសញ្ញាសម្រាប់ប្តូរនៅ ទូបញ្ជាបូមទឹកស្អាតទូបញ្ជាលាងអាងច្រោះ និងទូបញ្ជាគៀរកក់ចាស់ ផ្លាស់ប្តូរបន្ថែមអេឡិចត្រូតខ្សែដីទៅលើអាងរងចាស់ និងថ្មី ផ្លាស់ប្តូរបន្ថែមអេឡិចត្រូត ខ្សែដីទៅលើស្ថានីយបូមទឹកល្អក់ទាំងពីរ ផ្លាស់ប្តូរបន្ថែមអេឡិចត្រូតខ្សែដីទៅលើស្ថានីយបូមទឹកល្អក់ទាំងពីរ ជួសជុលប្រព័ន្ធបញ្ជា PLC កែសម្រួលប្រព័ន្ធបញ្ជាគៀរកក់អាងរងចាស់ នៅរោងចក្រ ជ្រោយចង្វារ
- ជួសជុលផ្លាស់ប្តូរសម្ភារអគ្គិសនីតាមការិយាល័យ និងអាងតម្កល់ទឹករបស់ រ.ទ.ស.ភ.
- ជួសជុលកែសម្រួលប្រព័ន្ធបញ្ជា អាងច្រោះចាស់ចំនួន ៣ទូ ផ្លាស់ប្តូរMagnetic Contactor ទូបញ្ជាលាងអាងច្រោះចាស់ផ្នែកខាងក្រោម ផ្លាស់ប្តូរឌីស្យុងទ័រនៅទូបញ្ជាមេលាងអាងច្រោះចាស់រោង រៀបចំសម្អាតប្រព័ន្ធអគ្គិសនីដើរ ដោយពន្លឺព្រះអាទិត្យ ផ្លាស់ប្តូរទ្រនាប់ អ៊ីសូឡង់ប្រព័ន្ធខ្សែកាបបូមទឹកល្អក់ កែសម្រួលប្រព័ន្ធបញ្ជាលាងអាងច្រោះចាស់ ផ្លាស់ប្តូរ Time Relay លើប្រព័ន្ធទូ LRP-S1-LRP-S5 ផ្លាស់ប្តូរ Auxiliary Relay លើប្រព័ន្ធទូ LRP-S1-LRP-S5 ផ្លាស់ប្តូរ Auxiliary Relay នៅទូបញ្ជាបូមទឹកល្អក់ ជួសជុលផ្លាស់ប្តូរ MCCB ទូមេសម្រាប់ចែកចាយចរន្តទៅប្រព័ន្ធបញ្ជាចង្វាក់ផលិតកម្ម និងអគារវដ្ឋបាល ជួសជុលផ្លាស់ប្តូរឧបករណ៍ Auxiliary Relay នៅទូបញ្ជាប្រព័ន្ធគីមី ផ្លាស់ប្តូរទ្រនាប់អ៊ីសូឡង់ខ្សែកាបបូមទឹកល្អក់ ជួសជុលទ្រនាប់អ៊ីសូឡង់ប្រព័ន្ធខ្សែកាបបូមទឹកស្អាត ជួសជុលផ្លាស់ប្តូរ Time Relay លើទូបញ្ជាប្រព័ន្ធគីមី ជួសជុលប្រព័ន្ធបញ្ជាម៉ូទ័របូមទឹកស្អាត របស់ រោងចក្រ ភូមិព្រែក
- ជួសជុលប្រព័ន្ធបញ្ជាម៉ូទ័របូមទឹកល្អក់ និងម៉ូទ័របូមទឹកស្អាតរោងចក្រចំការមន
- ជួសជុល និងថែទាំប្រព័ន្ធអគ្គិសនីផ្នែករដ្ឋបាល
- ជួសជុលផ្លាស់ប្តូរ Transceiver ( Icom ) របស់ប្រព័ន្ធស្ការដា RTU 8
- ផ្លាស់ប្តូរ Hard Disk បន្ថែមលើ Computer រោងចក្រនិរោធ
- ជួសជុលប្រព័ន្ធបញ្ជា Motor Valve នៅអាងតម្កល់ទឹកចោមចៅ
- បំពាក់ភ្លើង LED លើគំនូសបំព្រួញប្លង់រោងចក្រផលិតទឹកស្អាត
- ផ្លាស់ប្តូរកង្ហាបឺតខ្យល់ក្នុងទូ RTU ចំនួន ៤ស្ថានីយនៃប្រព័ន្ធ Scada
- ផ្លាស់ប្តូរអាគុយស្ងួតលើប្រព័ន្ធ Control Air Light អាងតម្កល់ទឹកតាខ្មៅ
- ជួសជុលនិងដំឡើង Valve Control N350 និង N500
- ជួសជុលផ្លាស់ប្តូរ Gas detector Sensor ប្រព័ន្ធបិទ-បើក វ៉ានពេលក្លរលេចធ្លាយនៅរោងចក្រនិរោធ
- ជួសជុលប្រព័ន្ធបញ្ជាម៉ូទ័រវ៉ានមេទឹកល្អក់ ជួសជុលទម្រខ្សែភ្លើងពីបន្ទប់បញ្ជា ទៅទូបញ្ជាក្លរយើតចាស់ ជួសជុលនិងផ្លាស់ប្តូរ Ground Direction Relay ជួសជុលរ៉ុអ្នូត្រង់ស្វូរប្រព័ន្ធបញ្ជាលាងអាងច្រោះរោងចក្រភូមិព្រែក
- ជួសជុលផ្លាស់ប្តូរ 3Phase Sequence Voltage Relay នៅទូរប្រព័ន្ធបញ្ជាលាង អាងច្រោះ ជួសជុលប្រព័ន្ធ Level meter អាងស្តុកទឹកស្អាត ផ្លាស់ប្តូរ Current Measurement Relay ចំនួន ២គ្រឿងនៅទូបញ្ជាលាងអាងច្រោះ ផ្លាស់ប្តូរអំពូលស៊ីញាល់នៅទូបញ្ជាបូមទឹកស្អាត បំពាក់បន្ថែមអេឡិចត្រូត ខ្សែដី សម្រាប់ការពាររន្ទះនៅស្ថានីយបូមទឹកស្អាត ជួសជុលទម្រខ្សែកាបបូមទឹកស្អាត និងល្អក់ ជួសជុលលាបថ្នាំបូមទឹកល្អក់ ជួសជុលលាបថ្នាំស្លាបក្លរ និងម៉ូទ័រក្លរយើតចាស់រោងចក្រភូមិព្រែក
- ជួសជុលប្រព័ន្ធបញ្ជាលាងអាងច្រោះ(Back Wash) ជួសជុលផ្លាស់ប្តូរ Overload Relayចំនួន១គ្រាប់លើប្រព័ន្ធម៉ូទ័រ Air Blower កែសម្រួលប្រព័ន្ធបញ្ជាម៉ូទ័រយោងធុងក្លរ ជួសជុលទូបញ្ជាប្រព័ន្ធគីមី ផ្លាស់ប្តូរឌីស្យុងទ័រចំនួន ២នៅទូ LV12 រោងចក្រភូមិព្រែក
- ផ្លាស់ប្តូរឧបករណ៍ 3Phase Monitoring Relay របស់ទូបញ្ជាប្រព័ន្ធបូមកំពោរ PAC ជួសជុលប្រព័ន្ធក្លរយើត ជួសជុលកែសម្រួលខ្សែភ្លើងបញ្ជូនតង់ស្យុងទៅស្ថានីយបូមទឹកល្អក់រោងចក្រចំការមន
- បន្ថែម Over Load Relay លើប្រព័ន្ធបញ្ជាបិទ-បើកវ៉ាន់លាងហ្វីល ជួសជុលប្រព័ន្ធបញ្ជា VSD របស់បូមទឹកស្អាត ជួសជុលប្រព័ន្ធ Transceiver ( Icom) របស់ប្រព័ន្ធស្កាដា RTU 3 ជួសជុលប្រព័ន្ធអគ្គិសនីដកកំដៅបន្ទប់បញ្ជាបូម ជួសជុលផ្លាស់ប្តូរ Contactor លើទូបញ្ជាលាងហ្វីលចាស់ ផ្លាស់ប្តូរ Shunt release Off សម្រាប់បញ្ជាបិទ ទូមេបូមទឹកស្អាត 3KV ជួសជុលប្រព័ន្ធបញ្ជាឧបករណ៍ង្វាស់ ផ្លាស់ប្តូរអាគុយស្ងួតកំលាំង 12V/14A ចំនួន៤គ្រាប់ សម្រាប់បញ្ជាប្រព័ន្ធបិទធុងក្លរនៅ ជួសជុលផ្លាស់ប្តូរ Charging motor សម្រាប់ទូមេបូមទឹកស្អាត 3KV ជួសជុលផ្លាស់ប្តូរ MCB(3P/250A) ចំនួន២គ្រឿង សម្រាប់ផ្លាស់ប្តូរម៉ូទ័របូមទឹកល្អក់លេខ៣ចាស់ ជួសជុលផ្លាស់ប្តូរ Check Valve របស់បូមទឹកល្អក់លេខ៣ចាស់ ជួសជុលកែសម្រួលបន្ទប់ភ្លើងអគ្គិសនីចាស់ទៅជាឃ្លាំងដាក់សម្ភាររបស់រ.ទ.ស.ភ។ ផ្លាស់ប្តូរ Magnetic Contactor សម្រាប់ប្រព័ន្ធបញ្ជាម៉ូទ័របូមទឹកល្អក់លេខ៣ចាស់ ផ្លាស់ប្តូរប្រព័ន្ធMCCB សម្រាប់បញ្ជាម៉ូទ័របូមទឹកស្អាតលេខ៥ រំកិលទីតាំងស្លាក កញ្ចក់បង្ហាញព័ត៌មាន នៃប្រព័ន្ធបំលែងថាមពលព្រះអាទិត្យ ជួសជុលប្រព័ន្ធ Motor Valve (ORV) សម្រាប់បិទ-បើកអាងច្រោះលេខ១០ ជួសជុលផ្លាស់ប្តូរ Solenoid Valve បញ្ជាបញ្ចេញកក់ដោយស្វ័យប្រវត្តិ ជួសជុលប្រព័ន្ធ PLC កែសម្រួលប្រព័ន្ធ Reset សម្រាប់ Priming System ចាស់របស់ រោងចក្រ ជ្រោយចង្វារ
- ផ្លាស់ប្តូរកង្ហាបឺតខ្យល់២គ្រឿងក្នុងបន្ទប់ក្លរ ជួសជុល Transceiver (Icom) របស់ប្រព័ន្ធស្កាដា RTU7 នៅអាងតម្កល់ទឹក ប្រាំងចំរេះ
- ជួសជុលម៉ូទ័របូមជំនួយប្រព័ន្ធក្លរនៅអាងតម្កល់ទឹកតាខ្មៅ
- ជួសជុលប្រព័ន្ធUPS សម្រាប់ប្រព័ន្ធ Telemeteryនៅទីតាំង DP01 ( N2 )
- កែសម្រួលទីតាំងឧបករណ៍វាស់សំពាធរបស់ប្រព័ន្ធ Telemeter (CM05 )
- កែសម្រួលរៀបចំបណ្តាញអគ្គិសនី តភ្ជាប់ពីម៉ាស៊ីនភ្លើងចូលបន្ទប់ ឯកឧត្តមអគ្គនាយក បន្ទប់ប្រជុំក្រុមប្រឹក្សាភិបាល និងបន្ទប់ប្រជុំធំជាន់ទី៤ អាគាររដ្ឋបាលថ្មី
- ជួសជុលប្រព័ន្ធបូមទឹកស្អាត១៨០ Kw
- កែសម្រួលប្រព័ន្ធបំពង់ក្លរ និង PAC
- ជួសជុលម៉ូទ័រក្លរ PAC
- ជួសជុលប្រព័ន្ធ Transceiver ( Icom)របស់ប្រព័ន្ធស្កាដា RTU 7 នៅអាងតម្កល់ទឹកប្រាំងចំរេះ
- ផ្លាស់ប្តូរ Solenoid Valve ចំនួន៤គ្រឿង នៅតាមអាងតម្កល់ទឹកតាខ្មៅ និងអាងតម្កល់ទឹក ប្រាំងចំរេះ
- ផ្លាស់ប្តូរឌីស្យុងទ័រ ( MCCB 3P/250A ) នៅទូបញ្ជាម៉ូទ័របូមទឹកស្អាតលេខ ១ និងលេខ៣ រោងចក្រចំការមន
- ជួសជុលផ្លាស់ប្តូរ Contactor លើទូបញ្ជាបូមទឹកស្អាតលេខ៥ ជ្រោយចង្វារ
- ជួសជុលផ្លាស់ប្តូរ ប្រព័ន្ធ Air blower សម្រាប់បញ្ជាលាងហ្វីល រោងចក្រ ជ្រោយចង្វារ
- ជួសជុលផ្លាស់ប្តូរ MCB សម្រាប់ទូបញ្ជាលាងអាងច្រោះ រោងចក្រជ្រោយចង្វារ

រាល់ការងារថែទាំ និងជួសជុលគ្រឿងចក្រនៃប្រព័ន្ធផលិតកម្មឆ្លើយតបពេញលេញទៅនឹងតម្រូវការ និងលក្ខខ័ណ្ឌ បច្ចេកទេសជាក់លាក់ ។ ផ្អែកលើយន្តការខាងលើ រ.ទ.ស.ភ. បានអនុវត្តនូវកម្មវិធីត្រួតពិនិត្យ-ថែទាំជួសជុល ទទួលបានលទ្ធផល១០០%។

# ខ- លទ្ធផលការងាររៀបចំ ប្រព័ន្ធចែកចាយទឹកស្អាត

## ខ.១- ការងារពង្រីកផ្ទៃសេវា

| បរិយាយ | ផែនការឆ្នាំ (គិតជាម៉ែត្រ) | អនុវត្តជាក់ស្តែង (គិតជាម៉ែត្រ) |
|---|---|---|
| ១- បំពេញច្រកក្នុងខណ្ឌទាំង ៩ | | ១.៤៥៧,៨០ |
| ២- ខណ្ឌឫស្សីកែវ | | ២៣.៦៦១,៦០ |
| ៣- ខណ្ឌមានជ័យ | | ២២.០៤៣,២៧ |
| ៤- ខណ្ឌដង្កោ | | ១៥.៦៨៣,០០ |
| ៥- ក្រុងតាខ្មៅ | | ២៥.៧៦៤,១៣ |
| ៦- ខណ្ឌសែនសុខ | | ៣៦.៥៥៧,៦០ |
| ៧- ខណ្ឌពោធិ៍សែនជ័យ | | ៣៥.៧៤៥,២៧ |
| **សរុប** | | **១៦០.៩១២,៦៧** |

គិតត្រឹមឆ្នាំ១៩៩៣ រ.ទ.ស.ភ. មានប្រព័ន្ធចែកចាយទឹកស្អាតប្រវែងសរុប ២៨៨ គ.ម. ដែលមានបន្ទាត់ផ្ចិត ទំហំចាប់ពី ៦០ម.ម ដល់៧០០ម.ម ។ ដោយមានគុណភាពទ្រុឌទ្រោមបន្សល់ទុកពី របបកម្ពុជាប្រជាធិបតេយ្យ រួមផ្សំនឹងកង្វះខាតថវិកាសម្រាប់ការជួសជុល - ថែរក្សា និងផ្លាស់ប្តូរថ្មី ធ្វើឲ្យប្រព័ន្ធចែកចាយទឹកស្អាតនៅពេលនោះ កាន់តែមានស្ថានភាពទ្រុឌ-ទ្រោមខ្លាំងទៅ ។

ក្រោយពីការផ្លាស់ប្តូរបំពង់ចាស់ និងបំពេញផ្ទៃសេវាចាស់ចប់សព្វគ្រប់ ការដាក់បំពង់ថ្មីដើម្បីពង្រីកផ្ទៃសេវា បានអនុវត្តចាប់ពីឆ្នាំ២០០២ និងបន្តរហូតមកដល់បច្ចុប្បន្ន ក្រោមឥណទានរបស់ធនាគាពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីព្រមទាំងទីភ្នាក់ងារបារាំង សម្រាប់អភិវឌ្ឍន៍ ។

មកដល់ចុងឆ្នាំ២០១៤ នេះ រ.ទ.ស.ភ. មានបំពង់មេ ចែកចាយទឹកសរុបប្រវែង ២.៣១២គីឡូម៉ែត្រ ។

ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ
( គិតជាគីឡូម៉ែត្រ )






# គ- លទ្ធផលការងារកាត់បន្ថយទឹកបាត់បង់

អត្រាទឹកបាត់បង់របស់ រ.ទ.ស.ភ. នៅក្នុងឆ្នាំ១៩៩៣ មានកម្រិតខ្ពស់បំផុតគឺ ៧២% ប៉ុន្តែអត្រានេះបានថយចុះជាលំដាប់រហូតមកនៅក្នុងរង្វង់ ៦% ប៉ុណ្ណោះនៅក្នុងឆ្នាំ២០០៨ ពោលគឺក្នុងរយៈពេលត្រឹមតែ១៥ឆ្នាំប៉ុណ្ណោះ ដែល រ.ទ.ស.ភ. បានបន្ថយទឹកបាត់បង់ពី ៧២% មកនៅត្រឹម ៧.៧៦% ដូចបានបង្ហាញក្នុងក្រាហ្វិចខាងក្រោម។ ការទទួលបានលទ្ធផលល្អប្រសើរក្នុងរយៈពេលខ្លីនេះ បានធ្វើអោយស្ថាប័នអន្តរជាតិធំៗវាយតម្លៃខ្ពស់ចំពោះ រ.ទ.ស.ភ. តាមរយៈការផ្តល់ជ័យលាភី និងពានរង្វាន់លំដាប់ពិភពលោក ដូចមានរៀបរាប់ខាងលើ ។

ជាលទ្ធផលការងារមកដល់ចុងឆ្នាំ២០១៤ នេះ រ.ទ.ស.ភ បានអនុវត្តដោយសម្រេចបានដូចខាងក្រោម៖

## ការងារជួសជុល និងថែទាំឧបករណ៍ប្រព័ន្ធផ្គត់ផ្គង់ទឹក

- ថែទាំទូត្រួតពិនិត្យប្រព័ន្ធទិន្នន័យ ២៨២ កន្លែង
- ជួសជុលថែទាំ បង្គោលពន្លត់អគ្គីភ័យ ១៩៤ គ្រឿង
- ថែទាំប្រអប់វ៉ាន់ស្តុប ១៦០ គ្រឿង
- ថែទាំប្រអប់វ៉ាន់ខ្យល់ ២១៤ គ្រឿង
- ជីករៀបប្រអប់លាងចុងបំពង់ ៣៧ កន្លែង
- ជីកលើកAir Valve ២៧ គ្រឿង
- ការងារលើក Valve Box (ថែទាំ-សម្អាត)១.៣៣៥ កន្លែង
- ជួសជុលថែទាំ រៀបប្រអប់វ៉ាន់ពិដង់ថ្មី ៣៥ កន្លែង
- ប្តូរទីតាំង និងកែសម្រួលបំពង់មេ ប្រវែង ១៧.៤៥០ម៉ែត្រ
  - ទំហំ៦៣ ម.ម.
  - ទំហំ៩០ ម.ម.
  - ទំហំ១១០ ម.ម.
  - ទំហំ១៦០ ម.ម.
  - ទំហំ២២៥ ម.ម.
  - ទំហំ៣០០ ម.ម.
- ថែទាំប្រអប់នាឡិកាតំបន់ ៤៣៣ កន្លែង
- ការងារដាក់ប៊ូសអាក្លេថ្មី (បើកថ្មី) ១៤៧ កន្លែង
- ការងារលាងចុងបំពង់ ៤០៨ កន្លែង
- ការងារជីកដំឡើងនាឡិកា ០៣ កន្លែង
- ការងារជីករៀបប្រអប់សាកសម្ពាធ ១៤ កន្លែង
- ការងារដាក់ Mainhole ថ្មី ៤០ កន្លែង
- ជីកដំឡើងនាឡិកាជាមួយ FH ០៣ កន្លែង
- ការងារជីកកាត់តេបង្ហូរលាងចុងបំពង់ ០២ កន្លែង

| ប្រភេទបំពង់ | គេជីកប៉ះ | បច្ចេកទេស | បច្ចេកទេស | សរុបក្នុងឆ្នាំ ២០១៤ | អត្រាធៀប ២០១៣ |
|---|---|---|---|---|---|
| បំពង់មេ | ៤១ | ៤៨ | ០៣ | ៩២ | ១៣៣% |
| បណ្តាញចូលផ្ទះ | ៤៧១ | ៣៥ | ៤៣៤ | ៩៤០ | ១៥៤% |
| សរុប | ៥១២ | ៨៣ | ៤៣៧ | ១.០៣២ | ១៥២% |

ទោះជាចំនួនលេចធ្លាយមានការកើនឡើង បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៣ ក៏ រ.ទ.ស.ភ. នៅតែបន្តអនុវត្តវិធានការកាត់បន្ថយការលេចធ្លាយ ទាំងលើកត្តាអត្តនោម័ត និងសត្យានុម័ត។ ដោយការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីក្រុង បាននឹងកំពុងរីកដុះដាលជាច្រើនកន្លែង របស់សាលារាជធានីភ្នំពេញ ដូចជាការដ្ឋានឈូសឆាយពង្រីកផ្លូវ ការដ្ឋានដាក់ប្រព័ន្ធលូ រំដោះទឹកភ្លៀងនារដូវវស្សា ការដ្ឋានដាក់បណ្តាញអគ្គិសនី ខ្សែកាបដែលជាកត្តាបង្ក ក្នុងកត្តាបង្កការលេចធ្លាយផ្សេងៗ ដែលធ្វើឲ្យប៉ះពាល់ដល់បំពង់ និងសម្ភារតភ្ជាប់។

## ការគ្រប់គ្រងទឹកបាត់បង់តាមតំបន់

| តំបន់គ្រប់គ្រង | អត្រាកំណត់ | បរិយាយ | លទ្ធផលឆ្នាំ២០១៤ |
|---|---|---|---|
| ១- ខណ្ឌ ដូនពេញ | ៥,០០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- រកឃើញបទល្មើសបំបែកមុខនាឡិកា<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ២៥.១៩២<br>០១<br>៤២<br>០៨ |
| ២- ខណ្ឌ ៧មករា | ៥,៥០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ៤១.១៦៩<br>៣៥<br>០២ |
| ៣- ខណ្ឌ ចំការមន | ៤,៥០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- រកឃើញបទល្មើសបំបែកមុខនាឡិកា<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ៤៤.២៨៣<br>០១<br>៨៣<br>២៥ |
| ៥- ខណ្ឌ ទួលគោក | ៥,០០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ២១.៩៣៣<br>៤៧<br>១៦ |
| ៥- ខណ្ឌ ឫស្សីកែវ | ៤,០០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ១២.៧២៣<br>២០<br>០២ |
| ៦- ខណ្ឌ មានជ័យ | ៤,៥០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- រកឃើញបទល្មើសបំបែកមុខនាឡិកា<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ៩.៤២១<br>០១<br>០២<br>០ |
| ៧- ខណ្ឌ ដង្កោ | ០,០០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ៧.៣០៣<br>០២<br>០ |
| ៨- ក្រុងតាខ្មៅ | ៦,០០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ២៣.៦៤៥<br>៤៣<br>១១ |
| ៩- ខណ្ឌ សែនសុខ | ០,០០% | - អង្កេត និងត្រួតពិនិត្យអតិថិជន<br>- ទឹកធ្លាយ(មុខនាឡិកាស្ទង់)<br>- រកឃើញនាឡិកាងាប់ | ១៤.៩៣០<br>០៩<br>០២ |

## ក្រាហ្វិចបង្ហាញពីអត្រាទឹកបាត់បង់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៤ (គិតជាភាគរយ)





# ផ្នែកទី២: ព័ត៌មានអំពី លទ្ធផលប្រតិបត្តិការធុរកិច្ច (ត)

## ១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ១.២- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម ឆ្នាំ២០១៤

#### តបណ្តាញទឹកជូនអតិថិជន

ក្រោយពីបានរៀបចំបណ្តាញចែកចាយទឹករួច រ.ទ.ស.ភ. នឹងប្រកាសជូនដំណឹងដល់ប្រជាពលរដ្ឋឲ្យមកបំពេញបែបបទតបណ្តាញទឹកចូលផ្ទះរៀងៗខ្លួន ។

ការងារតបណ្តាញទឹកចូលផ្ទះ ត្រូវអនុវត្តតាមបែបបទដំណើរការតាមស្តង់ដារមួយ ដែលមានលក្ខណៈសាមញ្ញ និងងាយអនុវត្តទាំងមន្ត្រី-និយោជិតរបស់ រ.ទ.ស.ភ. និងអតិថិជន។ បណ្តាមន្ត្រី-និយោជិតដែលបំពេញការងារផ្ទាល់ជាមួយអតិថិជនត្រូវបានអប់រំឲ្យមានអាកប្បកិរិយាសុភាពរាបសារ រម្យទម រាក់ទាក់ ម៉ឺងម៉ាត់ និងជួយសម្រួលការងារតបណ្តាញទឹកចូលផ្ទះ ឲ្យបានឆាប់បំផុត។

ក្នុងករណីពិសេស ដូចជាការតបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋនៅតាមសហគមន៍ក្រីក្រ នៅតាមតំបន់ជាយរាជធានីភ្នំពេញ រ.ទ.ស.ភ. បានចល័តមន្ត្រី-និយោជិត ទៅបំពេញការងារនៅសហគមន៍នោះតែម្តង។ គោលបំណងចម្បងរបស់ រ.ទ.ស.ភ. គឺជួយសម្រួលប្រជាពលរដ្ឋក្នុងការបំពេញបែបបទតបណ្តាញទឹកឲ្យបានលឿន ទទួលប្រាក់ថ្លៃជាវទឹកនៅនឹងកន្លែង កាត់បន្ថយការចំណាយលើការធ្វើដំណើររបស់ប្រជាពលរដ្ឋ ។ល។

#### ការងារគ្រប់គ្រងអតិថិជន

នៅមុនឆ្នាំ១៩៩៣ ការគ្រប់គ្រងអតិជនមានកង្វះខាតយ៉ាងខ្លាំង។ ដូចបានរៀបរាប់រួចនៅខាងដើម ចំនួនអតិថិជនក្នុងបញ្ជី ខុសពីចំនួនអតិថិជនពិតប្រាកដយ៉ាងច្រើន ជាងនេះទៅទៀតក្នុងបញ្ជីពុំបានកត់ត្រាអ្នកមានបណ្តាញទឹកទេ តែបែរជាមានឈ្មោះអ្នក ដែលគ្មានបណ្តាណទឹកប្រើប្រាស់ទៅវិញ។ កត្តានេះទើបធ្វើអោយអត្រាប្រមូលប្រាក់ថ្លៃទឹក នៅពេលនោះ មានត្រឹមតែ ៤៨% ប៉ុណ្ណោះ។ ដើម្បីកែតំរូវបញ្ជីនេះអោយត្រឹមត្រូវឡើងវិញ ដោយបានស្នើរសុំកំលាំងអន្តរាគមន៍ ប្រមាណ ១០០នាក់ ពីសាលាក្រុងភ្នំពេញ ជាជំនួយ រ.ទ .ស.ភ. បានបើកយុទ្ធនាការអង្កេតអតិថិជនមួយនៅទូទាំងផ្ទៃសេវា ដោយចាប់ផ្តើមនៅក្នុងខែមីនា ឆ្នាំ ១៩៩៤។ ជាលទ្ធផលនៃយុទ្ធនាការនេះ គឺបានរកឃើញអ្នកមានបណ្តាញទឹកប្រើប្រាស់តែពុំបានកត់ត្រាក្នុងបញ្ជីអតិថិជនចំនួន ១៣.៧២២ អតិថិជន ដោយឡែកក៏បានរកឃើញអ្នកដែលមានឈ្មោះក្នុងបញ្ជី តែជាក់ស្តែងពុំមានបណ្តាញទឹកប្រើប្រាស់ ចំនួន ១២.៩៨០អតិថិជន ។ ក្នុងនេះដែរក៏បានរកឃើញអណ្តូងរួមចំនួន ១.៩៤៥ ដោយពុំដែលមានវិក្កយបត្រទូទាត់ថ្លៃទឹក (ដោយសារសំពាធទាបនៅពេលនោះដែលទឹកពុំអាចឡើងផុតពីផ្ទៃដី គេបាននាំគ្នាជីកអណ្តូង រួចចោះបំពង់មេចែកចាយទឹក ដើម្បីបង្ហូរទឹកពីបំពង់ចូលទៅក្នុងអណ្តូង ហើយប្រើប្រាស់រួមគ្នាច្រើនគ្រួសារ)។ ដំណោះស្រាយចំពោះមុខគឺ (ទី១) តំឡើងនាឡិកាមេលើបំពង់ដែលបង្ហូទឹកចូលអណ្តូង រួចចាត់អោយមានតំណាងដើម្បីទូទាត់ថ្លៃទឹក (ទី២) ក្នុងករណីពុំអាចរកតំណាងបានត្រូវរៀបចំបណ្តាញតាមផ្ទះនីមួយៗ ហើយលុបអណ្តូងនេះចេញ។ អណ្តូងរួមទាំងនេះ ត្រូវបានលុបបំបាត់ជាបន្តបន្ទាប់ រហូតបញ្ចប់ជាស្ថាពរ នៅក្នុងពេលផ្លាស់ប្តូរបំពង់មេចែកចាយទឹកថ្មី ដោយរៀបចំជាបណ្តាញចូលផ្ទះទាំងអស់។

#### ការងារគ្រប់គ្រងនាឡិកាទឹក

ការងារគ្រប់គ្រងនាឡិកាទឹកត្រូវបានចែកចេញជា ៣ផ្នែកគឺៈ (១)ការដាក់នាឡិកាទឹក ១០០% មានន័យថាគ្រប់បណ្តាញចូលផ្ទះទាំងអស់ត្រូវតែមាននាឡិកាទឹក (២)ការជ្រើសរើសប្រភេទនាឡិកាដែលមានសុក្រឹតភាពខ្ពស់ និងគុណភាព សមស្រប និង (៣)កម្មវិធីត្រួតពិនិត្យ និងផ្លាស់ប្តូរ ។ នៅឆ្នាំ១៩៩៣ បណ្តាញទឹកដែលមានបំពាក់នាឡិកាស្ទង់មានចំនួន ៣.៣៩១ ដែលស្មើនឹង ១២,៦១%នៃចំនួនបណ្តាញសរុប ហើយការចេញវិក្កយបត្រ័ថ្លៃទឹកពេលនោះ ត្រូវបានគណនា បរិមាណទឹកតាមការប៉ាន់ស្មាន ។ នៅឆ្នាំ១៩៩៤ រ.ទ .ស.ភ. បានចាប់ផ្តើមធ្វើការដំឡើងនាឡិកាទឹកជាបន្តបន្ទាប់ លើគ្រប់បណ្តាញចូលផ្ទះ ដែលធ្វើអោយបញ្ឈប់បានទាំងស្រុងនូវការប៉ាន់ស្មានបរិមាណទឹកក្នុងវិក្កយបត្រថ្លៃទឹក។ តារាងខាងក្រោមនេះបង្ហាញពីកំណើននាឡិកាទឹកតាមឆ្នាំនីមួយៗធៀបនឹងចំនួនបណ្តាញ ហើយចាប់ពីឆ្នាំ២០០១ បណ្តាញចូលផ្ទះ ទាំងអស់មាននាឡិកាទឹក១០០%។

# ក- ការខារផ្គត់ផ្គង់ទឹកជូន ប្រជាពលរដ្ឋក្រីក្រ

## លទ្ធផលនៃការតបណ្តាញជូនអតិថិជន

បើគិតចាប់ពីពេលអនុវត្តកម្មវិធី "ផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋមានចំណូលទាប" រហូតដល់ចុងឆ្នាំ២០១៤នេះ រ.ទ.ស.ភ. បានផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋមានចំណូលទាបសរុប ៣១.៧២៦បណ្តាញស្មើនឹង១១,៧២% នៃចំនួនបណ្តាញដែលបានតសរុប។ ក្នុងនោះ បានឧបត្ថម្ភធនសរុបចំនួន២០.៩៦៣បណ្តាញ ដែលត្រូវចំណាយទឹកប្រាក់សរុប៥.៣៣៧.៤៩១.៧៦០៖ ស្មើនឹង១.៣៣៤.៣៧៣ដុល្លាអាមេរិក។




## ការវាយតម្លៃ

ការផ្តល់សេវាទឹកស្អាតដល់ប្រជាពលរដ្ឋមានចំណូលទាប ពិសេសប្រជាពលរដ្ឋក្រីក្ររស់នៅមានលក្ខណៈ ប្រមូលផ្តុំក្នុងសហគមន៍ដែលកន្លង មកមិនធ្លាប់បានទទួលទឹកស្អាតប្រើប្រាស់ផ្ទាល់ពីរដ្ឋ ក្នុងតម្លៃមួយ សមស្របថោកជាងឯកជន ផ្គត់ផ្គង់២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍ ធានានូវគុណភាពហូបបានផ្ទាល់ពីក្បាលម៉ាស៊ីន និងមានការឧបត្ថម្ភធនផងនោះ បានធ្វើឱ្យប្រជាពលរដ្ឋមានចំណូលទាប ទាំងនោះសប្បាយរីករាយ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយ ដែលបានយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅរបស់ពួកគាត់។

ការផ្តល់សេវាទឹកស្អាតនេះ បានធ្វើឱ្យប្រជាពលរដ្ឋមានចំណូលទាប អាចសន្សំសំចៃការចំណាយទៅលើថ្លៃទឹកប្រើប្រាស់បានប្រមាណ៣០.០០០រៀល ក្នុង១ខែ ឬ៣៦០.០០០រៀល ក្នុង១ឆ្នាំ ចំណេញពេលវេលាក្នុងការប្រកបមុខរបរប្រចាំថ្ងៃ កុមារៗមាន ពេលគ្រប់គ្រាន់ក្នុងការរៀនសូត្រ និងកំសាន្តសប្បាយ ហើយសុខភាពកាន់តែជានាល្អប្រសើរឡើង ដោយបានកាត់បន្ថយជំងឺផ្សេងៗ ដូចជា កមរមាស់ និងគ្រុនពោះវៀនជាដើម។



| តបណ្តាញជូនប្រជាពលរដ្ឋមានចំណូលទាប | | សរុប (គ្រួសារ) | ក្នុងក្រុង (គ្រួសារ) | ជាយក្រុង (គ្រួសារ) |
|---|---|---|---|---|
| | បង់រំលស់ ១២ខែ | ០២ | - | ០២ |
| ឧបត្ថម្ភធន ៣០% | និង បង់រំលស់ ១២ខែ | ៥០ | ០១ | ៤៩ |
| ឧបត្ថម្ភធន ៥០% | និង បង់រំលស់ ១២ខែ | ៤៥៦ | ០៣ | ៤៥៣ |
| ឧបត្ថម្ភធន ៧០% | និង បង់រំលស់ ១២ខែ | ៣៩៤ | ០៩ | ៣៨៥ |
| ឧបត្ថម្ភធន ១០០% | និង បង់រំលស់ ០៤ខែ | ២៤៧ | ០៣ | ២៤៤ |
| សរុប | | ១.១៤៩ | ១៦ | ១.១៣៣ |

# ខ- ការងារតបណ្តាញចូលផ្ទះ និង ការគ្រប់គ្រងអតិថិជន

## ការងារតបណ្តាញចូលផ្ទះ

ការងារតបណ្តាញចូលផ្ទះ ត្រូវអនុវត្តតាមបែបបទដំណើរការតាមស្តង់ដារមួយដែលមានលក្ខណៈសាមញ្ញ និងងាយអនុវត្ត ទាំងមន្ត្រី-និយោជិតរបស់ រ.ទ.ស.ភ. និងអតិថិជន។ គោលបំណងរបស់ រ.ទ.ស.ភ. គឺជួយសម្រួលប្រជាពលរដ្ឋ ក្នុងការបំពេញបែបបទ តបណ្តាញទឹកឲ្យបានលឿន ទទួលប្រាក់ថ្លៃទឹកនៅនឹងកន្លែង កាត់បន្ថយការចំណាយលើការធ្វើដំណើររបស់ប្រជាពលរដ្ឋ។

ជាលទ្ធផលក្នុងឆ្នាំ២០១៤នេះ យើងបានតបណ្តាញជូនប្រជាពលរដ្ឋ បានចំនួន១៩.៧២០បណ្តាញ ស្មើនឹង១២៣,២៥% នៃផែនការ ១៦.០០០បណ្តាញ ។

## ការងារគ្រប់គ្រងអតិថិជន

ចំនួនអតិថិជនសរុបចុងគ្រា ២៧០.៨១២ អតិថិជន ស្មើនឹង ១០២,៣៥% នៃផែនការ ២៦៤.៦០០អតិថិជន ។

យើងគ្រប់គ្រងអតិថិជនបានល្អ និងមានប្រសិទ្ធភាពដោយ ៖

- បញ្ចូលទិន្នន័យអតិថិជនតបណ្តាញថ្មី និងទិន្នន័យនាឡិកាប្តូរថ្មីទៅក្នុងប្រព័ន្ធបានត្រឹមត្រូវ និងទាន់ពេលវេលា " **មិនលើសពីបីថ្ងៃការងារក្រោយថ្ងៃតបណ្តាញ និងប្តូរនាឡិការួច** " ។
- បញ្ចូលរាល់សំណើកែតម្រូវទិន្នន័យអតិថិជនទៅក្នុងប្រព័ន្ធទាន់ពេលវេលា ។
- ធ្វើ Back Up ទុករាល់ថ្ងៃ និងសប្តាហ៍ ទិន្នន័យអតិថិជននៅក្នុងប្រព័ន្ធ ដើម្បីធានាសុវត្ថិភាពដោយធ្វើការត្រួតពិនិត្យនៅរាល់ចុងត្រីមាសទៀតផង ។
- ធ្វើការថែទាំកុំព្យូទ័រ និង Hardware ទូទាំងអង្គភាពតាមកម្មវិធីដែលបានកំណត់ ។

| ប្រភេទអតិថិជន | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|---|---|
| ជីវភាព | ១៤០.៧២៨ | ១៥២.៩៧២ | ១៦១.៥៤៥ | ១៦៩.៧០០ | ១៨៣.៦៩៤ | ១៩៥.២៦១ | ២០៩.៩៩៧ | ២២៥.៧៣៥ |
| អាជីវកម្ម | ២០.៦៩០ | ២៤.៤៨៦ | ២៨.៧៩១ | ៣២.៤៦៧ | ៣៥.០០១ | ៣៩.០៣៣ | ៤១.៥១០ | ៤៤.២៥៨ |
| អង្គភាពរដ្ឋ | ៦៥៩ | ៦៩៣ | ៧១៨ | ៧៤១ | ៧៨២ | ៧៩៧ | ៧៧៥ | ៧៨៥ |
| អ្នកលក់ទឹក | ៥៤ | ៣៦ | ២៨ | ២០ | ១៨ | ១៧ | ១៣ | ១៤ |
| តំណាងចែកចាយ | ២០ | ១៣ | ១០ | ២១ | ២១ | ២០ | ២០ | ២០ |
| សរុប | ១៦២.១៥១ | ១៧៨.២០០ | ១៩១.០៩២ | ២០២.៩២៩ | ២១៩.៤៩៨ | ២៣៥.១២៨ | ២៥២.៣១៥ | ២៧០.៨១២ |

## ក្រាហ្វិចបង្ហាញពីបំណែងចែកអតិថិជន ឆ្នាំ២០១៤ (អតិថិជនសរុបចំនួន: ២៧០.៨១២អតិថិជន)



# គ- ចំណូលថ្លៃទឹក និង ការងារជួសជុល ប្ដូរនាឡិកាទឹក

## គ.១- ចំណូលថ្លៃទឹក

ដើម្បីជានាប្រសិទ្ធភាព និងទិន្នផលកាន់តែល្អប្រសើរ លើការងារប្រមូលប្រាក់ថ្លៃទឹកប្រើប្រាស់ពីអតិថិជន យើងបានបន្តអនុវត្តយន្តការអានមួយថ្ងៃបោះពុម្ពវិក្កយបត្រមួយថ្ងៃ។ ទន្ទឹមនោះយើងបានបន្តដំណើរការ សាខាទទួលប្រាក់ថ្លៃទឹកចំនួនបួនកន្លែងនៅតាមអាងតម្កល់ទឹកជាយក្រុងទាំងបី និងនៅតាខ្មៅ សំដៅបង្កភាពងាយស្រួលដល់ការទូទាត់ប្រាក់ថ្លៃទឹករបស់អតិថិជន ក៏ដូចជាកាត់បន្ថយការចំណាយក្នុង ការធ្វើដំណើររបស់អតិថិជនផងដែរ។ ពិសេសជាងនេះទៅទៀត យើងបានសហការជាមួយបណ្ដាធនាគារ និងក្រុមហ៊ុន ដាក់ឲ្យដំណើរការសេវាកម្មទទួលប្រាក់ថ្លៃទឹកតាមបច្ចេកវិទ្យាទំនើបថែមទៀត។ ដែលជាក់ស្ដែងក្នុងឆ្នាំនេះ ៖

- ចំនួនទឹកប្រាក់ប្រកាសក្នុងវិក្កយបត្រ មានប្រមាណ ១៣៧.៦៨៥.៦២៦.៥៨១រៀល
- ចំណូលថ្លៃទឹកទារបានស្មើនឹង ៩៩,៩០% នៃទឹកប្រាក់ប្រកាសក្នុងវិក្កយបត្រ ។

បរិមាណទឹកលក់ក្នុងឆ្នាំ លើសផែនការ ០,៣១% ដោយសារបរិមាណទឹកប្រើប្រាស់ជាមធ្យម ក្នុងមួយបណ្ដាញ ក្នុងមួយខែ (៣៩,៦៩ម៣/ប.ណ x ខែ) ទាបជាងផែនការ -២,២២% ប៉ុន្តែចំនួនបណ្ដាញ ជាមធ្យមលើសផែនការ ២,៥៧% ។

ទឹកប្រាក់ប្រកាសលក់លើសផែនការ០,៤៥% ដោយសារបរិមាណទឹកលក់លើសផែនការ ០,៣១% ហើយថ្លៃលក់ ជាមធ្យម ១.០០០,៩៣រៀល/ម៣ លើសផែនការ ៩៩៩,៥៣រៀល/ម$^{៣}$ ។

### ក្រាហ្វិចបង្ហាញពីចំណូលថ្លៃទឹកទារបានស្មើនឹង ៩៩,៩០% ក្នុងឆ្នាំ២០១៤




## គ.២- ការងារជួសជុល និងប្ដូរនាឡិកាទឹក

- ដោះដូរនាឡិកាទឹក ១៧.៤៥៦គ្រឿង ស្មើនឹង ៩៦,៩៨% នៃផែនការឆ្នាំ ក្នុងនោះនាឡិកាមានអាយុកាល លើស១២ឆ្នាំឡើង ១៣.៣១២គ្រឿង។
- ទន្ទឹមនឹងការដោះដូរនាឡិកានេះ យើងបានធ្វើការលើកបរិមាណទឹកដែលលម្អៀង បញ្ចូលទៅក្នុងវិក្កយបត្រ ក្នុងរយៈពេលនាឡិកាខូចចំនួន ៣.៩០០គ្រឿង និងបាត់ ១៧៥គ្រឿង បានប្រមាណ ៤០៦.០៣១ម$^{៣}$ និងនាឡិកាដើរយឺតលើសកម្រិតកំណត់ចំនួន២.៣៩៦គ្រឿង បានប្រមាណ ១២.៤០០ម$^{៣}$។





ទិដ្ឋភាពអាងតម្កល់ទឹកពោធិ៍ចិនតុង និងបញ្ជរបង់ប្រាក់





# ផ្នែកទី២: ព័ត៌មានអំពី លទ្ធផលប្រតិបត្តិការធុរកិច្ច (ត)

## ១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូល ព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ១.៣- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

ផ្អែកលើសំណូមពរចាំបាច់នៃការអភិវឌ្ឍធនន៍ជានមនុស្ស និងដើម្បីបង្កើនគុណភាព ប្រសិទ្ធភាពការងាររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាំបាច់ត្រូវរៀបគម្រោងផែនការច្បាស់លាស់ ដោយមានការសហការ ឧបត្ថម្ភពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍអាស៊ី (ADB) ធ្វើឲ្យ រ.ទ.ស.ភ. មានសមត្ថភាពកាន់តែប្រសើរឡើង ក្នុងការកែសម្រួលចំណុចសំខាន់ៗដូចខាងក្រោម៖

- រៀបចំឲ្យមានមណ្ឌលបណ្តុះបណ្តាល និងដំណើរការជាបណ្តើរៗ ចាប់ពីឆ្នាំ១៩៩៧ ដែលមានគោលការណ៍៖
  - កំណត់នូវគោលការណ៍ស្តីពីការបញ្ជូនមន្ត្រី និយោជិតទៅទទួលការបណ្តុះបណ្តាល។
  - ស្វែងរកគ្រូបណ្តុះបណ្តាលនៅតាមវិទ្យាស្ថាននានា ទាំងក្នុង និងក្រៅប្រទេស សម្រាប់បណ្តុះបណ្តាលជំនាញដល់មន្ត្រី និយោជិត រ.ទ.ស.ភ.។
  - សហការជាមួយម្ចាស់ជំនួយក្នុងការស្នើ និងបញ្ជូនមន្ត្រីទៅទទួលការបណ្តុះបណ្តាលជំនាញចាំបាច់នៅក្រៅប្រទេស។
- ពីឆ្នាំ២០០៥ រហូតដល់បច្ចុប្បន្នមណ្ឌលបណ្តុះបណ្តាលនេះបានដំណើរការពេញសមត្ថភាពដោយបានរៀបចំឲ្យមានគ្រូបង្គោលក្នុងអង្គភាពសម្រាប់ដំណើរការបណ្តុះបណ្តាលជំនាញ សម្រាប់និយោជិតថ្នាក់ក្រោម ដោយផ្តោតជាសំខាន់ទៅលើការបណ្តុះបណ្តាល ទាក់ទងនឹងការអនុវត្តការងារជាក់ស្តែង (បែបបទដំណើរការងារស្តង់ដាការងារ "SOP")។
- បានធ្វើការកែសម្រួលនូវការវាយតម្លៃមន្ត្រី-និយោជិតតាមរយៈព្រឹត្តិបត្រពិន្ទុប្រចាំខែ មកប្រចាំត្រីមាសក្នុងឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ន។
- ខែមិថុនា ឆ្នាំ២០០៧ រ.ទ.ស.ភ. បានរៀបចំឲ្យមានការប្រឡងសមត្ថភាពប្រចាំឆ្នាំ។ ការប្រឡងសមត្ថភាពនេះ បានអនុវត្តសម្រាប់មន្ត្រី-និយោជិត ដើម្បីឲ្យឃើញពីសមត្ថភាព និងការយល់ដឹងក្នុងការអនុវត្តន៍ការងារ។
- បានរៀបចំបែបបទនៃការដំឡើងឋានៈ ការដំឡើងកាំបៀវត្សរ៍ ដំឡើងបៀវត្សរ៍ លើកសរសើរប្រចាំឆ្នាំទៅតាមលទ្ធផលនៃការប្រឡងសមត្ថភាព និងលទ្ធផលនៃការវាយតម្លៃតាមរយៈព្រឹត្តិបត្រពិន្ទុប្រកបដោយតម្លាភាព។

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច (ត)

## ១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ១.៣.១- ការងារគ្រប់គ្រងធនធានមនុស្ស

ក្នុងឆ្នាំ២០១៤ នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានមន្ត្រីនិយោជិតទាំងអស់ចំនួន ៨៥១រូប (នារីៈ ១៣៩រូប) ក្នុងនោះមានៈ

- មន្ត្រីក្របខ័ណ្ឌរដ្ឋ ចំនួន០២រូប គឺ អគ្គនាយក និងអគ្គនាយករង ទទួលបន្ទុកហិរញ្ញកិច្ច និងផ្សារមូលបត្រ
- មន្ត្រី និយោជិតក្របខ័ណ្ឌសហគ្រាស ចំនួន៦៩៦រូប (នារីៈ១១៦រូប)
- និយោជិតសាកល្បងការងារចំនួន ៤០រូប (នារីៈ០១រូប)
- និយោជិតជាប់កិច្ចសន្យា ចំនួន ១១៣រូប (នារីៈ២២រូប)

កម្រិតជំនាញរបស់មន្ត្រី និយោជិត

| កំរិតអប់រំ និងមុខវិជ្ជាជីវៈ | អាយុ ក្រោម ២៦ឆ្នាំ | អាយុ ២៧-៣៤ | អាយុ ៣៦-៤៥ | អាយុ លើសពី៤៦ | សរុប ចំនួន (នាក់) | សរុប អត្រា (%) |
|---|---|---|---|---|---|---|
| បណ្ឌិត | ០ | ០ | ០ | ២ | ២ | ០,២៤ |
| អនុបណ្ឌិត | ០ | ១៦ | ១១ | ១៤ | ៤១ | ៤,៨២ |
| បរិញ្ញាប័ត្រ / វិស្វករ | ៤៣ | ១០៧ | ៣១ | ១២ | ១៩៣ | ២២,៦៨ |
| បរិញ្ញាប័ត្ររង/មធ្យមបច្ចេកទេស | ៦ | ១០ | ២១ | ៨ | ៤៥ | ៥,២៩ |
| មធ្យមសិក្សាទុតិយភូមិ និងទទួលការបណ្តុះបណ្តាលរយៈពេលខ្លី | ១១៣ | ៧៨ | ៣១ | ២២ | ២៤៤ | ២៨,៦៧ |
| អ្នកបច្ចេកទេស និង កម្មករជំនាញ | ២ | ១៤ | ១៣ | ១៤ | ៤៣ | ៥,០៥ |
| អ្នកមានបទពិសោធន៍ការងារលើ១០ឆ្នាំ | ០ | ១០ | ៤៥ | ៥៨ | ១១៣ | ១៣,២៨ |
| កម្មករពលកម្ម | ៥១ | ៩៥ | ១៧ | ៧ | ១៧០ | ១៩,៩៨ |
| **សរុប** | **២១៥** | **៣៣០** | **១៦៩** | **១៣៧** | **៧៥១** | **១០០** |

ក្រាហ្វិចខាងក្រោមបង្ហាញពីកម្រិតជំនាញរបស់មន្ត្រី និយោជិត រ.ទ.ស.ភ.



## ការអនុវត្តន៍លក្ខន្តិកៈបុគ្គលិក និងបទបញ្ជាផ្ទៃក្នុង

- ចំនួនបុគ្គលិកដែលបានប្រើប្រាស់ក្នុងរយៈកាលកន្លងមកក្នុងកម្រិត ៣,១៤ លើ១.០០០អតិថិជន
- ការអនុវត្តន៍តួនាទី ភារកិច្ច វិន័យ ការងារ ពេលម៉ោងធ្វើការ សំលៀកបំពាក់ និងការប្រើប្រាស់សម្ភារការពារសុវត្ថិភាពពលកម្មរបស់ មន្រ្តី និយោជិត កម្មករ កាន់តែប្រសើរ។

## ការលើកទឹកចិត្ត

- បានធ្វើការតែងតាំងដំឡើងឋានៈមន្ត្រីចំនួន១០រូប៖ មន្រ្តីជាន់ខ្ពស់០៣រូប(អគ្គនាយករង០១រូប អគ្គនាយិការង០១រូប និងប្រធាននាយកដ្ឋាន០១រូប) ក្របខ័ណ្ឌនាយកដ្ឋាន០១រូប(អនុប្រធាននាយកដ្ឋាន) និងក្របខ័ណ្ឌអនុវត្តចំនួន ០៦រូប (ប្រធាន ការិយាល័យ០១រូប អនុប្រធានការិយាល័យ០៤រូប ប្រធានផ្នែក០១រូប)
- បានស្នើសុំមេដាយមាសការងារជូនមន្ត្រី និយោជិកចំនួន៦០រូប ដែលបំពេញការងារបានល្អក្នុងឆ្នាំ២០១៤ ជាលទ្ធផលថ្នាក់ដឹកនាំក្រសួង ក៏ដូចជារាជរដ្ឋាភិបាលបានសម្រេចផ្តល់ជូនមន្រ្តី និយោជិក នូវមេដាយសុវត្ថារា ថ្នាក់អស្សឫទ្ធិ ចំនួន០៦រូប និងមេដាយមាស ការងារ ចំនួន៥៤រូប
- បានស្នើសុំផ្តល់គ្រឿងឥស្សរិយយសជូនអគ្គនាយក រ.ទ.ស.ភ. មន្ត្រីថ្នាក់ដឹកនាំចំនួន២០រូប និងមន្ត្រីនិយោជិក ចំនួន ២០៣រូប ដើម្បីជាការលើកទឹកចិត្តចំពោះការខិតខំបំពេញភារកិច្ច
- បានធ្វើការផ្លាស់ប្តូរភារកិច្ច ជូនមន្ត្រី និយោជិកចំនួន០៨រូប តាមតម្រូវការចាំបាច់នៃការងារ។

## ការអនុវត្តន៍លក្ខន្តិកៈបុគ្គលិក និងបទបញ្ជាផ្ទៃក្នុង

ធ្វើការជ្រើសរើសនិយោជិតតាមតម្រូវការជាក់ស្តែងរបស់បណ្តានាយកដ្ឋាន៖

- បញ្ចូលនិយោជិតហ្វឹកហាត់ការងារ ចំនួន៩៣រូប (នារី១៨រូប)
- ពីនិវត្តន៍ជន មកជានិយោជិកជាប់កិច្ចសន្យា ចំនួន០៦រូប (នារី០១រូប)
- បញ្ចូលនិយោជិតជាប់កិច្ចសន្យា ចំនួន១៧១រូប (នារី ២៣រូប)
- បញ្ចូលនិយោជិតសាកល្បងការងារ ចំនួន១៥៦រូប (នារី ១២រូប)
- បញ្ចូលនិយោជិត ក្របខ័ណ្ឌពេញសិទ្ធិ ចំនួន១២៧រូប (នារី ១៦រូប)
- ពន្យារពេលសាកល្បងការងារ ចំនួន០២រូប។

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច (ត)

## ១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ១.៣.២- ការងារអភិវឌ្ឍន៍ ធនធានមនុស្ស

### ការងារបណ្តុះបណ្តាល និងផ្តល់ចំណេះដឹង

- បានបើកវគ្គបណ្តុះបណ្តាលក្នុងអង្គភាព ចំនួន១៩វគ្គ លើមុខជំនាញ១០ (ទី១): បទបង្ហាញស្តីពីមុខងារ នីតិវិធី និងវិធីសាស្ត្រធ្វើសវនកម្ម ដល់មន្ត្រី និងយោជិតចំនួន០៤រូប (ទី២): កម្មវិធី Microsoft Excel ដល់មន្ត្រី និយោជិតចំនួន៣០រូប (ទី៣): កម្មវិធី Microsoft Advance Excel ដល់មន្ត្រី និងយោជិតចំនួន៣៩រូប (ទី៤): កិច្ចការរដ្ឋបាល និងលេខាធិការ ដល់មន្ត្រី និងយោជិតចំនួន៥៤រូប (ទី៥): Hydraulic parameters and WaterCAD install program ដល់មន្ត្រី និងយោជិតចំនួន០៥រូប (ទី៦): បែបបទស្តង់ដារអានលេខនាឡិកាទឹក ដល់មន្ត្រី និងយោជិតចំនួន១២៤រូប (ទី៧): បែបបទស្តង់ដារជាងដោះដូរនាឡិកាទឹក ដល់មន្ត្រី និងយោជិតចំនួន១២៦រូប (ទី៨): បែបបទស្តង់ដារជាងដោះដូរនាឡិកាទឹក ដល់មន្ត្រី និងយោជិតចំនួន៤៣រូប (ទី៩): បែបបទស្តង់ដារតបណ្តាញចូលផ្ទះ ដល់មន្ត្រី និងយោជិតចំនួន២៥រូប (ទី១០): កម្មវិធី Microsoft Access (Basic) ដល់មន្ត្រី និងយោជិតចំនួន១៧រូប (ទី១១): យន្តការស្រាវជ្រាវទឹកបាត់បង់ ដល់មន្ត្រី និងយោជិតចំនួន៥២រូប (ទី១២): ស្តង់ដារដាក់បំពង់មេ-សាកសម្ពាធ ដល់មន្ត្រី និងយោជិតចំនួន៤៩រូប (ទី១២): ស្តង់ដារដាក់បំពង់មេ-សាកសម្ពាធ ដល់មន្ត្រី និងយោជិតចំនួន៤៩រូប (ទី១៣): វិធានការបញ្ចៀសបញ្ហាខ្យាច់ក្នុងបំពង់ ដល់មន្ត្រី និងយោជិតចំនួន២៩រូប (ទី១៤): JICA Capacity Building –Phase 3 (វគ្គបណ្តុះបណ្តាលគណនេយ្យ ដល់មន្ត្រីនិយោជិត រដ្ឋាករទឹកតាមបណ្តាខេត្ត) ដល់មន្ត្រី និងយោជិតចំនួន៣៨រូប (ទី១៥): ការថែទាំគ្រឿងចក្រ និងបរិក្ខារការដ្ឋាន ដល់មន្ត្រី និងយោជិតចំនួន៤៨រូប (ទី១៦): បែបបទដំណើរការស្តង់ដារថែទាំប្រព័ន្ធមេកានិច ដល់មន្ត្រី និងយោជិតចំនួន៦៦រូប (ទី១៧) សុវត្ថិភាពលើប្រពន្ធ័ក្ល័រឧស្ម័ន ដល់មន្ត្រី និងយោជិតចំនួន៧៤រូប(ទី១៨): បែបបទដំណើរការ និងថែទាំប្រព័ន្ធ SCADA ដល់មន្ត្រី និងយោជិតចំនួន៣១រូប (ទី១៩): ឧបករណ៍កំណត់ល្បាយលំហូរ PAC នៅ រោងចក្រភូមិព្រែក ដល់មន្ត្រី និងយោជិតចំនួន២៥រូប។

- បានបញ្ជូនទៅបណ្តុះបណ្តាលក្នុងប្រទេស (ទី១): នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ លើមុខជំនាញ ភាសាអង់គ្លេសទូទៅ ដល់និយោជិតចំនួន០១រូប (ទី២): នៅវិទ្យាស្ថាន CamEd លើមុខជំនាញ Cambodia Tax ដល់មន្ត្រី និយោជិត ចំនួន០១រូប (ទី៣): នៅសាកលវិទ្យាល័យពុទ្ធិសាស្ត្រ លើមុខជំនាញ Microsoft System Center Configuration Manager 2012, Microsoft Exchange Sever, Microsoft Visual Studio2010 ដល់មន្ត្រី និយោជិត ចំនួន០៦រូប (ទី៤): នៅITEC លើមុខជំនាញ Photoshop and CorelDraw ដល់និយោជិតចំនួន០១រូប។

- បានបញ្ជូនទៅបណ្តុះបណ្តាលក្រៅប្រទេស(១) នៅប្រទេសប្រទេសជប៉ុន លើមុខជំនាញ 2013 AUICK / WHO Kobe Centre Data Collection Exercise and 2014 Urban HEART Workshop on Safe Water and Sanitation , Comprehensive Engineering on Water Supply Systems (A) និងMaster Level ដល់និយោជិតចំនួន០៣រូប (២) នៅប្រទេសស៊ុយអ៊ែត លើមុខជំនាញ Efficient Energy Use and Planning ដល់និយោជិតចំនួន០២រូប(៣) នៅប្រទេសម៉ាឡេស៊ី លើមុខជំនាញ Urban Water Safety Plan Training ដល់និយោជិតចំនួន០២រូប (៤) នៅប្រទេសសឹង្ហបូរី លើមុខជំនាញ The Delivering Water from Source to tap និងមុខជំនាញ The Sustainable Water Resources Management ដល់និយោជិតចំនួន០៣រូប(៥) នៅអាហ្វ្រិកខាងត្បូង លើមុខជំនាញ Efficient Energy Use and Planning 2013B ដល់និយោជិតចំនួន០២រូប (៦) នៅប្រទេសឥណ្ឌា លើមុខជំនាញ Solar Energy Technologies and Applications ដល់និយោជិតចំនួន០១រូប។

- ទទួលសិស្ស និស្សិត ចំនួន១២៤រូប មកពីបណ្តាលសាកលវិទ្យាល័យ និងវិទ្យាស្ថាននានា ដើម្បីចុះកម្មសិក្សា (១): មកពីវិទ្យាល័យ Hitotsubasli ទីក្រុង Tokyo ប្រទេសជប៉ុនបានចុះកម្មសិក្សាលើប្រធានបទ Request for Interviews with PPWSA by Mr.Kensaku ICHIKAWA. (២): មកពី វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានចុះកម្មសិក្សាលើប្រធានបទការត្រួត-

## ការងារបណ្តុះបណ្តាល និងផ្តល់ចំណេះដឹង (ត)

ពិនិត្យគុណភាពទឹក, ការចែកចាយទឹក, ការត្រួតពិនិត្យគុណភាពទឹក, ដំណើរការបូម និងការផលិតទឹកស្អាត, ការគ្រប់គ្រងទឹកក្នុងទុយោ និងបែងចែកតាមតំបន់ (៣): មកពី JICA Research Institute បានចុះកម្មសិក្សាលើប្រធានបទ Interviews at PPWSA with Ms Kuwajima Kyoko about "Revisiting Capacity Development Approach the Analysis of Case Studies" & "Project History Study" (៤): មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះកម្មសិក្សាលើ ប្រធានបទ ការត្រួតពិនិត្យគុណភាពទឹក វិធីសាស្ត្រស្រាវជ្រាវ វិភាគ និងគ្រប់គ្រងគុណភាពទឹក ។

- ទទួលសិស្ស និស្សិត ចំនួន៣៨៦រូប មកពីបណ្តាលសាកលវិទ្យាល័យ និងវិទ្យាស្ថាននានា ដើម្បីចុះទស្សនៈកិច្ចសិក្សា (១): មកពីវិទ្យាល័យ Ministry of public works of Timor-Leste បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទ Capacity development of water supply system (២): មកពី Nepal បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទ Third Country Visit for Urban Water Supply Development (៣): មកពី JICA បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទ JICA student study tour and site visit to Japan's ODA Projects with PPWSA និង ទស្សនៈកិច្ចសិក្សាស្វែងយល់ ពីគម្រោងជំនួយរបស់ជប៉ុន និងស្ថានភាពបច្ចុប្បន្ននៃសេវាទឹកស្អាតនៅរាជធានីភ្នំពេញ (៤): មកពី AUPP បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទ ទស្សនៈកិច្ចនៅរោងចក្រផលិតទឹកស្អាត រ.ទ.ស.ភ. (៥): មកពីវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទ ទស្សនៈកិច្ចស្វែងយល់ពីដំណើរការនៃការគ្រប់គ្រងការផលិត (៦): មកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទដំណើរការបច្ចេកទេសផលិត និងបណ្តាញផ្គត់ផ្គង់ទឹកស្អាត (៧): មកពី ISPP បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទ សិស្សថ្នាក់ទី៦សុំទស្សនៈកិច្ចស្វែងយល់ពីការផលិត និងចែកចាយទឹកស្អាតនៅរាជធានី (៨): មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះទស្សនៈកិច្ចសិក្សា លើប្រធានបទ អំពីប្រព្រឹត្តកម្មទឹកស្អាតនៅ រ.ទ.ស.ភ. និងទស្សនៈកិច្ចសិក្សាអំពីការធ្វើប្រព្រឹត្តកម្មទឹក ។

# ២- ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

គិតត្រឹមដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ នេះ គ្មានការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចនោះទេ។

# ៣- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ឆ្នាំ ២០១៤ | | ឆ្នាំ ២០១៣ | | ឆ្នាំ ២០១២ | |
|---|---|---|---|---|---|---|---|
| | | បរិមាណ (ពាន់រៀល) | ភាគរយ | បរិមាណ (ពាន់រៀល) | ភាគរយ | បរិមាណ (ពាន់រៀល) | ភាគរយ |
| ១ | ចំណូលពីការលក់ | ១៤៦.៨៥៧.៣៤៨ | ៩៣,៨១% | ១៣៦.៣៩៩.៨៤៣ | ៨៩,៩៩% | ១២២.៤៥៧.៨៨៩ | ៩០,៦៣% |
| ២ | កម្រៃពីសេវាសាងសង់ | ២០០.៦៣១ | ០,១៣% | ៧.២៤៩.៣៩២ | ៤,៧៨% | ៦.៦៦១.២០២ | ៤,៩៣% |
| ៣ | ចំណូលផ្សេងៗ | ៩.៤៨៤.៨៧០ | ៦,០៦% | ៧.៩៣០.៩៧២ | ៥,២៣% | ៦.០០.៤២៧ | ៤,៤៤% |
| | ចំណូលសរុប | **១៥៦.៥៤២.៨៤៩** | | **១៥១.៥៨០.២០៧** | | **១៣៥.១១៩.៥១៨** | |







# ផ្នែកទី៣:
# អភិបាលកិច្ចសាជីវកម្ម

## ១- ភាគហ៊ុនិក

### ក-ការការពារសិទ្ធិភាគហ៊ុនិក

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ. ត្រូវបានការពារសិទ្ធិដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ. ដែលក្នុងនោះមាន៖

- ភាគហ៊ុនិកអាចស្វែងរកព័ត៌មានទាន់ពេល របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ និងព័ត៌មានផ្សេងទៀត របស់ រ.ទ.ស.ភ. បាន តាមរយៈគេហទំព័រ www.ppwsa.com.kh។

- ភាគហ៊ុនិកអាចចូលរួមកិច្ចប្រជុំ មហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំរបស់ រ.ទ.ស.ភ. ដោយអនុវត្តតាមសេចក្តីណែនាំរបស់ រ.ទ.ស.ភ. សម្រាប់ការចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនីមួយៗ។ នៅក្នុងកិច្ចប្រជុំនេះ ភាគហ៊ុនិកអាចធ្វើការបញ្ចេញយោបល់ និង/ឬ ស្នើសុំកែតម្រូវ និងធ្វើការបោះឆ្នោតលើរបៀបវារៈ ដែលត្រូវសម្រេចដោយមហាសន្និបាតភាគហ៊ុនិក។ ភាគហ៊ុនិកអាចទាញយកឯកសារសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក និងកំណត់ហេតុមហាសន្និបាតភាគហ៊ុនិក តាមរយៈគេហទំព័រ www.ppwsa.com.kh។

- ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោត អនុម័តលើបេក្ខភាពអភិបាលឯករាជ្យ នៅក្នុងមហាសន្និបាតភាគហ៊ុនិកដោយ អនុវត្តតាមសេចក្តីណែនាំរបស់ រ.ទ.ស.ភ. សម្រាប់ការចូលរួមបោះឆ្នោតជ្រើសតាំងអភិបាលឯករាជ្យ។

- ភាគហ៊ុនិកឯកជនអាចស្នើបេក្ខភាព និងបោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជននៅក្នុងមហាសន្និបាតភាគហ៊ុនិក ដោយអនុវត្តតាមសេចក្តីណែនាំរបស់ រ.ទ.ស.ភ. សម្រាប់ការចូលរួមបោះឆ្នោតជ្រើសតាំងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន។

- ភាគហ៊ុនិកមានសិទ្ធិទទួលភាគលាភ ដែលប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ. ទៅតាមសមាមាត្រភាគហ៊ុនដែលខ្លួនកាន់កាប់។

- ភាគហ៊ុនិកត្រូវបានការពារ ដោយមិនត្រូវឱ្យមានជាប់ពាក់ព័ន្ធជាមួយនឹងការជួញដូរផ្ទៃក្នុង ឬស៊ែហ្វ៍ដៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ របស់ រ.ទ.ស.ភ. មិនអាចធ្វើការជួញដូរភាគហ៊ុនរបស់ រ.ទ.ស.ភ. ក្នុងរយៈពេល៖
    - ១០ថ្ងៃ នៃថ្ងៃធ្វើការ មុនការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ រហូតដល់ ០១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ។
    - ០៧ថ្ងៃ នៃថ្ងៃធ្វើការ មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រហូតដល់ ០១ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

# ផ្នែកទី៣:
# អភិបាលកិច្ចសាជីវកម្ម (ត)

## ១- ភាគហ៊ុនិក (ត)

### ខ- ការបែងចែកប្រភេទភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ០៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១.២៤០ | ៤.៣៨៤.៤៤១ | ៥,០៤១១% |
| | | នីតិបុគ្គល | ៧ | ១.៤៥៤.៩៥១ | ១,៦៧២៩% |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣៣៩ | ៧.២០៦.៥៨៣ | ៨,២៨៦០% |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ០៥% ដល់ តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៧៣.៩២៧.១៨៧ | ៨៥% |
| | មិនមាន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

### គ- អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់ រ.ទ.ស.ភ.

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ១ | ៧.៥៩៩ | ០,០៥៨២% |
| បុគ្គលិកជាន់ខ្ពស់ | ១៣ | ១៤៥.៨៨៩ | ១,១១៨៣% |
| និយោជិត | ៤៧៤ | ៩៩៤.៣៥៨ | ៧,៦២២០% |
| សរុប | ៤៨៨ | ១.១៤៧.៨៤៦ | ៨,៧៩៨៥% |

### ឃ- ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ដោយបញ្ជាក់អំពីអត្តសញ្ញាណ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. ពុំមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នោះទេ។

### ង- អត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី០៥(ប្រាំ)ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. ពុំមានភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ដែលស្ថិតនៅក្នុងស្ថានភាពអសាធនភាពនោះទេ។

## ច- កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

- កាលបរិច្ឆេទ: ២៤/មេសា/២០១៤
- ប្រភេទកិច្ចប្រជុំ: សាមញ្ញ
- របៀបវារៈ : របាយការណ៍លទ្ធផលផលិតកម្ម-អាជីវកម្ម ឆ្នាំ២០១៣ និងទិសដៅអាជីវកម្ម ឆ្នាំ២០១៤

## ឆ- គោលនយោបាយភាគលាភ

### ឆ.១- គោលនយោបាយភាគលាភរបស់ រ.ទ.ស.ភ

ក្រោយពីបានអនុម័តលើគណនី បើពិនិត្យឃើញថាមានចំណេញ ក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាចសម្រេចផ្ទេរទឹកប្រាក់ទាំងនោះដើម្បី៖

១- ការទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅ

២- បន្ទាប់ពីបានទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើមានប្រាក់ចំណេញនោះប្រាក់ចំណេញនេះត្រូវបែងចែកសម្រាប់៖

ក- ថ្លែងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិត តាមលក្ខខណ្ឌ៖

- ក្នុងករណីប្រាក់ចំណេញនៅសល់មានចំនួនពី៥% ដល់១០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ. សរុបក្នុងឆ្នាំ នោះការថ្លែងសរសើរត្រូវស្មើនឹងមួយខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី១០% ដល់២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ. សរុបក្នុងឆ្នាំ នោះការថ្លែងសរសើរត្រូវស្មើនឹងពីរខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និង និយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ. សរុបក្នុងឆ្នាំ នោះការថ្លែងសរសើរត្រូវស្មើនឹងបីខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។

ខ- ចំនួន២% សម្រាប់ប្រាក់សោធននិវត្ត និងអសមត្ថភាពវិជ្ជាជីវៈ។

គ- បង្កើតភាគបម្រុងតាមច្បាប់ ៥%។

ឃ-បង្កើតភាគបម្រុងសេរីចំនួន ៥%។

ង- មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រតិបត្តិការចំណាយនោះ។

៣- ចំនួនប្រាក់ដែលនៅសល់បន្ទាប់ពីការបែងចែកខាងលើនេះត្រូវ៖

ក- ដកប្រាក់រក្សាទុកដើម្បីធ្វើការវិនិយោគនាពេលខាងមុខ ដែលចំនួននេះត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។

ខ- ប្រាក់នៅសល់ក្រោយពីការរក្សាទុកសម្រាប់ធ្វើការវិនិយោគត្រូវធ្វើការបែងចែក ៨៥% ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ១៥% ទៅភាគហ៊ុនិកដែលជាវិនិយោគិនសាធារណៈ។

### ឆ.២- ព័ត៌មានប្រវត្តិសាស្ត្រអំពីការបែងចែកភាគលាភ

| **ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ** | **២០១៣** | **២០១២** |
|---|---:|---:|
| ចំណេញសុទ្ធ | ៣៨.០៨៨.០៣០.០០០រៀល | ៣៤.៩២០.៩៦១.០០០រៀល |
| ភាគលាភជាសាច់ប្រាក់សរុប | ៤.៧៦១.០០៣.៧៥០រៀល | ២.៤០៩.១៥៦.៥៨៧,៤០រៀល |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | គ្មាន | គ្មាន |
| ភាគលាភផ្សេងទៀត | គ្មាន | គ្មាន |
| អនុបាតចំណាយភាគលាភ (%) | ១២,៥០% | ៧% |
| ទិន្នផលភាគលាភ (%) | * ១,០២% | ** ០,៤៥% |
| ភាគលាភក្នុងមួយមូលបត្រកម្មសិទ្ធិ | ៥៤,៧៤រៀល | ២៧,៧០រៀល |

** ផ្អែកលើថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣* *** ផ្អែកលើថ្លៃបិទទីផ្សារប្រចាំថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២*

## ៣- អង្គការលេខ




*អង្គការលេខគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤*





# ផ្នែកទី៣:
# អភិបាលកិច្ចសាជីវកម្ម (ត)

## ៣- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា

### ក- សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម សឹម ណារ៉ា | ប្រធានក្រុមប្រឹក្សាភិបាល | ២៤/០២/២០១៤ | ២៤/០២/២០១៧ |
| ២ | ឯកឧត្តម ស៊ឹម ស៊ីថា | សមាជិកក្រុមប្រឹក្សាភិបាល | ២៧/០៧/២០១២ | ២៧/០៧/២០១៥ |
| ៣ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល | ២៤/០២/២០១៤ | ២៤/០២/២០១៧ |
| ៤ | ឯកឧត្តម ឃួង ស្រេង | សមាជិកក្រុមប្រឹក្សាភិបាល | ២៥/០៨/២០១៤ | ២៥/០៨/២០១៧ |
| ៥ | លោកស្រី ងិន ចន្ទ្រា | សមាជិកក្រុមប្រឹក្សាភិបាល | ១៣/០២/២០១៤ | ១៣/០២/២០១៧ |
| ៦ | លោក ចាង យុនហ្វេង | អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន | ២០/០២/២០១៣ | ២០/០២/២០១៦ |
| ៧ | លោក អោម សេង បូរ៉ា | អភិបាលឯករាជ្យ | ២០/០២/២០១៣ | ២០/០២/២០១៦ |

### ខ- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល៖

- កំណត់គម្រោងអភិវឌ្ឍន៍សហគ្រាស ដោយអនុលោមតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល យោងតាមសំណើរបស់អគ្គនាយក
- កំណត់គម្រោងថវិកាប្រចាំឆ្នាំ និងកម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់សម្រេចកម្មវិធីវិនិយោគ
- អនុម័តលើរបាយការណ៍គណនេយ្យ (របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលលម្អិត)
- កំណត់នូវរចនាសម្ព័ន្ធចាត់តាំង ចំនួនក្របខ័ណ្ឌ ការបែងចែកមុខងារទូទៅ និងប្រាក់បៀវត្សរបស់និយោជិត តាមសំណើរបស់អគ្គនាយក
- អនុញ្ញាតឲ្យបើក ឬសម្រេចឲ្យបិទសកម្មភាពរបស់ការិយាល័យភ្នាក់ងារ ឬតំណាង
- អនុញ្ញាតឲ្យទិញអចលនទ្រព្យគ្រប់ប្រភេទ ដោយគោរពតាមប្រកាស លេខ៩៩៧ សហវ.ទរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងលទ្ធកម្មនៅសហគ្រាសសាធារណៈ
- ជ្រើសរើសស្នងការគណនី និងកំណត់នូវលាភការជូនចំពោះស្នងការគណនី
- សម្រេចយល់ព្រមលើកិច្ចសន្យា ឬសន្ធិសញ្ញាផ្សេងៗ
- ធ្វើការពិនិត្យក្នុងចន្លោះពេលទៀតទាត់មួយ លើទិសដៅដែលបានកំណត់ឲ្យសហគ្រាស និងលើកឡើងនូវបណ្តាវិធាន ការកែសម្រួល
- លើកសំណើសុំកែប្រែលក្ខន្តិកៈ។

# ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម សឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

## តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៦៧ និងបានទទួលបរិញ្ញាបត្រវិស្វករគីមី នៅវិទ្យាស្ថានជាន់ខ្ពស់បច្ចេកវិទ្យាគីមី ទីក្រុងសូហ្វីយ៉ា ប្រទេសប៊ុលហ្គារី ក្នុងឆ្នាំ១៩៩៣ និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអាជីវកម្មនៅសាកលវិទ្យាល័យ Swinburne University of Technology ទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ២០០២។ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១៣ ឯកឧត្តមបានបម្រើការងារឲ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅនាយកដ្ឋានផែនការ នាយកដ្ឋានសហប្រតិបត្តិការ និងការងារអាស៊ាន និងអគ្គនាយកដ្ឋានឧស្សាហកម្ម។ ឯកឧត្តមបានបម្រើការងារឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ចាប់ពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤។ **ឯកឧត្តម សឹម ណារ៉ា** ជាប្រធានក្រុមប្រឹក្សាភិបាលអាណត្តិទី៥ នៃ រ.ទ.ស.ភ. ចាប់ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន។



**ឯកឧត្តម ស៊ឹម ស៊ីថា**
សមាជិកក្រុមប្រឹក្សាភិបាល

## អគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦១ និងបានទទួលជាវិស្វករ សំណង់ស៊ីវិលឧស្សាហកម្ម នៅវិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត (រាជធានីភ្នំពេញ ព្រះរាជាណា-ចក្រកម្ពុជា)ក្នុងឆ្នាំ១៩៨៩។ លោកទទួលបានបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យ គ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០០៧។ ក្នុងឆ្នាំ២០១៤ លោកបានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតដោយជោគជ័យ លើជំនាញ គ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យអាស៊ី អឺរ៉ុប រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ លោកជាអនុប្រធានអង្គភាព រដ្ឋាករទឹកខេត្ត ព្រះសីហនុពីខែកុម្ភៈ ឆ្នាំ១៩៩៦ ដល់ខែ មិថុនា ឆ្នាំ២០០៣។ ចាប់ពីខែមិថុនាឆ្នាំ២០០៣ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ លោកមានតួនាទីជា ប្រធានអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ លោកជាអគ្គនាយក រ.ទ.ស.ភ. និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃ រ.ទ.ស.ភ. អាណត្តិទី៥ ចាប់ពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន។



**ឯកឧត្តម មុី វ៉ាន់**
សមាជិកក្រុមប្រឹក្សាភិបាល

## តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៦៩ និងបានទទួល អនុបណ្ឌិតគោលនយោបាយសេដ្ឋកិច្ច នៃសកលវិទ្យាល័យ D'AUVERGNE ប្រទេសបារាំង នៅឆ្នាំ១៩៩៩។ ឯកឧត្តមបានទទួលបណ្ឌិតសេដ្ឋកិច្ចពាណិជ្ជកម្មនៃសកលវិទ្យាល័យ PRESTON សហរដ្ឋអាមេរិក នៅឆ្នាំ២០០៩។ ឯកឧត្តម បានបម្រើការងារឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។ **ឯកឧត្តម មុី វ៉ាន់** ចូលជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៥ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន។



**ឯកឧត្តម ឃួង ស្រេង**
សមាជិកក្រុមប្រឹក្សាភិបាល

## តំណាងសាលារាជធានីភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៦៦ និងបានទទួលសញ្ញាបត្រម៉ាស៊ីនកប៉ាល់ នៅរដ្ឋរុស្ស៊ី សហភាពសូវៀត នៅឆ្នាំ១៩៩២។ នៅឆ្នាំ១៩៩៧ ឯកឧត្តមបានទទួលបរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០០៤ ឯកឧត្តមបានទទួលអនុបណ្ឌិតវិទ្យាសាស្ត្រនយោបាយ នៅឆ្នាំ២០០៧ ឯកឧត្តមទទួលបានបណ្ឌិតវិទ្យាសាស្ត្រនយោបាយ។ ឆ្នាំ២០១១ ដល់ឆ្នាំ២០១២ ថ្នាក់បណ្ឌិត និក្ខេបបទ "នីតិព្រហ្មទណ្ឌនៃកម្ពុជា"។ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ១៩៩៩ ឯកឧត្តមជាមន្ត្រីការិយាល័យផែនការហិរញ្ញវត្ថុខណ្ឌទួលគោក។ ឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៨ ឯកឧត្តមជាអភិបាលរងខណ្ឌទួលគោក។ ឆ្នាំ២០០៩ ដល់ឆ្នាំ២០១២ ឯកឧត្តមជាអនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម។ ចាប់ពីឆ្នាំ២០១២ មកដល់បច្ចុប្បន្ន ឯកឧត្តម ជាអភិបាលរងរាជធានីភ្នំពេញ។ **ឯកឧត្តម ឃួង ស្រេង** ចូលជាសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៥ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន។



**លោកស្រី ខិន ចន្ទ្រា**
សមាជិកក្រុមប្រឹក្សាភិបាល

## តំណាងនិយោជិត រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៦០។ នាឆ្នាំ២០០៧ លោកស្រីបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ លោកស្រីបម្រើការងារនៅមន្ទីរពាណិជ្ជកម្មរាជធានី ឋានៈជាប្រធានអគារស្បៀង។ លោកស្រីបានចូលបម្រើការនៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅឆ្នាំ១៩៩៣។ ជាបន្តបន្ទាប់ លោកស្រីបានកាន់តំណែងជា ប្រធានការិយាល័យហិរញ្ញវត្ថុ និងជាអនុប្រធាននាយកដ្ឋានអាជីវកម្ម។ ឆ្នាំ២០១២ លោកស្រី ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានអាជីវកម្ម។ ចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន លោកស្រី ត្រូវបានតែងតាំងជាអគ្គនាយករងទទួលបន្ទុកការងារអាជីវកម្ម។



**លោក ចាង យុនហ្វេង**
សមាជិកក្រុមប្រឹក្សាភិបាល

## អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន

ជនជាតិចិន សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៧១។ នៅឆ្នាំ១៩៩៥ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគីមីវិទ្យា នៅសកលវិទ្យាល័យបច្ចេកទេស តាលានបទពិសោធន៍ការងារ។ ពីឆ្នាំ២០០៣-២០០៨ លោកជានាយកគ្រប់គ្រងទូទៅនៃ Cambodia of China State Farms Group។ ពីឆ្នាំ២០០៨-២០១០ លោកជាប្រធានក្រុមប្រឹក្សាភិបាល នៃ Union Resource Investment Group Co., Ltd។ ពីឆ្នាំ២០១០ ដល់បច្ចុប្បន្ន លោកជាប្រធានក្រុមប្រឹក្សាភិបាល នៃ Golden Fortune (Cambodia) Securities Plc / Golden Fortune Investment Group Co., Ltd / Golden Fortune Real Estate Co., Ltd និងGolden Fortune Mining Investment Co., Ltd។ លោកបានចូលជាសមាជិកក្រុមប្រឹក្សាភិបាល (ជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន) អាណត្តិទី៥ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន។



**លោក អោម សេងបូ៉ា**
សមាជិកក្រុមប្រឹក្សាភិបាល

## អភិបាលឯករាជ្យ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៧៧។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់គ្រងគណនេយ្យ អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម និងលោកទទួលបានបណ្ឌិតកិត្តិយស គ្រប់គ្រងពាណិជ្ជកម្ម។ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ លោកជាអគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Vision Fund Cambodia។ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៩ លោកជាសមាជិកសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា។ បច្ចុប្បន្នលោកជាអគ្គនាយក Garuna Fund និងអ្នកសម្របសម្រួលវិនិយោគ HG Capital Partners and Blue Energy Partners។ លោកជាប្រធានក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុនប្រឹក្សាផ្តល់យោបល់ Aplus Consultiing។ លោកជាប្រធានក្រុមប្រឹក្សាភិបាល របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍អគ្គនាយក និងសហគ្រិន នៃ Aplus School For Professionals។ លោកជាសមាជិកក្រុមប្រឹក្សាភិបាល ឯករាជ្យរបស់ AEON Microfinance។ លោកចូល ជាសមាជិកក្រុមប្រឹក្សាភិបាល (ជាអភិបាលឯករាជ្យ) អាណត្តិទី៥ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន។

# ផ្នែកទី៣:
# អភិបាលកិច្ចសាជីវកម្ម (ត)

## ៣- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា (ត)

### ឃ- សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល បានជួបប្រជុំចំនួន០៥លើក ឆ្នាំ២០១៤នេះដោយៈ

នៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៤

- បានពិនិត្យលើសំណើសុំពិនិត្យ-អនុម័តលើរបាយការណ៍លទ្ធផលហិរញ្ញវត្ថុឆ្នាំ២០១៣(ក្រោយសវនកម្ម) និងសំណើសុំគោលការណ៍ បែងចែកប្រាក់ចំណេញ ឆ្នាំ២០១៣ និងបែងចែកភាគលាភដល់ភាគហ៊ុនិក (ឯកភាពទាំងស្រុង)
- បានពិនិត្យលើសំណើសុំពិនិត្យ-អនុម័តលើពិធីមហាសន្និបាតភាគហ៊ុនិកលើកទី២ (អនុម័តជាឯកច្ឆ័ន្ទ)
- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០១៤ (ឯកភាពទាំងស្រុង)
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្ម អនុវត្តត្រីមាសទី១ ឆ្នាំ២០១៤ (ឯកភាពលើរបាយការណ៍)
- បានពិនិត្យលើរបាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី១ ឆ្នាំ២០១៤ (ឯកភាពលើការចំណាយ)
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងអភិវឌ្ឍន៍ទឹកស្អាតក្រុងកែប (ឯកភាពទទួលជ្រាបព័ត៌មាន)
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងផ្គត់ផ្គង់ទឹកស្អាតកោះពេជ្រ (ឯកភាពទទួលជ្រាបជាព័ត៌មាន)
- បានពិនិត្យលើរបាយការណ៍លទ្ធផលផ្សេងៗ (អនុម័តឯកភាពលើសំណើតែងតាំងអគ្គនាយករង)

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤

- បានពិនិត្យនូវរបាយការណ៍លទ្ធផលការងារត្រីមាសទី២-ឆមាសទី១ និងផែនការត្រីមាសទី៣ ឆ្នាំ២០១៤ (ឯកភាពទាំងស្រុងលើខ្លឹមសាររបាយការណ៍)
- បានពិនិត្យលើសំណើសុំពិនិត្យ-អនុម័តបន្ថែមថវិកា សម្រាប់ទូទាត់បញ្ចប់គម្រោងសាងសង់រោងចក្រ ប្រព្រឹត្តកម្មទឹកស្អាត និរោធជំហាន១ ក្រោមថវិកាផ្ទាល់ របស់ រ.ទ.ស.ភ. (អនុម័តឯកភាពជាគោលការណ៍ចំណាយបន្ថែម)
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី២ ឆ្នាំ២០១៤ (ឯកភាពលើរបាយការណ៍លទ្ធផល)
- បានពិនិត្យលើរបាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី២ ឆមាសទី១ និង ផែនការត្រីមាស ទី៣ ឆ្នាំ២០១៤ (ឯកភាពលើចំណាយ)
- បានពិនិត្យលើរបាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី១ ឆ្នាំ២០១៤ (ឯកភាពទទួលជ្រាបជារបាយការណ៍)
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងអភិវឌ្ឍន៍ទឹកស្អាតក្រុងកែប (ឯកភាពទទួលជ្រាបជាព័ត៌មាន)
- បានពិនិត្យលើរបាយការណ៍ស្តីពីគម្រោងផ្គត់ផ្គង់ទឹកស្អាតកោះពេជ្រ (ឯកភាពទទួលជ្រាបជាព័ត៌មាន)
- បានពិនិត្យលើរបាយការណ៍លទ្ធផលផ្សេងៗ
  ១.ឯកភាពទទួលជ្រាបជាពត៌មានអំពីការងារវិនិយោគនៅខេត្តពោធិ៍សាត់
  ២.អនុម័ត-ឯកភាពតាមសំណើរលើការកែសម្រួលរចនាសម្ព័ន្ធចាត់តាំងរបស់ រ.ទ.ស.ភ.
  ៣.ឯកភាពទទួលជ្រាបជាព័ត៌មានលើការបែងចែកភាគលាភ

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤

- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារឆ្នាំ២០១៤ (៨ខែបូក៤ខែប៉ាន់ស្មាន) និងសំណើសុំពិនិត្យ-អនុម័ត លើគម្រោងផែនការឆ្នាំ២០១៥ (ឯកភាពលើរបាយការណ៍លទ្ធផលការងារឆ្នាំ២០១៤)
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្ម អនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ និងសំណើសុំពិនិត្យ-អនុម័ត លើគម្រោងកិច្ចលទ្ធកម្ម ឆ្នាំ២០១៥ (ឯកភាពទាំងស្រុង លើរបាយការណ៍)
- បានពិនិត្យលើរបាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ និងលើគម្រោង ប្រើប្រាស់មូលនិធិ សម្រាប់ឆ្នាំ២០១៥ (ឯកភាពទាំងស្រុង លើរបាយការណ៍)
- បានពិនិត្យលើការកែសម្រួលលក្ខន្តិកៈបុគ្គលិក រ.ទ.ស.ភ. (ឯកភាពទាំងស្រុង)
- បានពិនិត្យលើការយកវិភាគទាន១០% នៃថ្លៃប្រើប្រាស់ទឹកស្អាតរបស់ប្រជាជនក្នុងក្រុងតាខ្មៅ (អនុម័តថាដោយ រ.ទ.ស.ភ. ជាអ្នកអនុវត្ត ពុំមែនជាអ្នកសម្រេចគោលការណ៍ ដូច្នេះ រ.ទ.ស.ភ. ជម្រាបទៅមន្ទីសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាលវិញ ឲ្យស្នើសុំគោលការណ៍ ពីក្រសួងអណាព្យាបាលរបស់ រ.ទ.ស.ភ. តាមរយៈក្រសួងអណាព្យាបាលរបស់ខ្លួន)
- បានពិនិត្យរបាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី២ ឆ្នាំ២០១៤(ឯកភាពទទួលជ្រាបជាព័ត៌មាន)
- សំណើសុំពិនិត្យ និងកំណត់ទីតាំងស្ថានីយបូមទឹកល្អក់ ក្តីតាកុយដើម្បីទប់ស្កាត់ ផលប៉ះពាល់ ដល់ការផលិតទឹកស្អាតរបស់រោងចក្រនិរោធ (ឯកភាពទទួលជ្រាបជាព័ត៌មាន)
- ឯកភាពទទួលជ្រាបជាព័ត៌មាន អំពីការស្នើសុំប្តូរវិនិយោគពីរោងចក្រផលិតសាច់ជូរ មកផលិតPAC របស់ក្រុមហ៊ុន ណារី ឈាងថុង

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤

- បានពិនិត្យលើរបាយការណ៍លទ្ធផលការចូលរួមដេញថ្លៃគម្រោងទឹកស្អាតសែនមនោរម្យ របស់សាខាសេវាកម្មទឹកស្អាត និងអនាម័យ (ឯកភាពទទួលជ្រាបជាព័ត៌មាន)
- បានពិនិត្យលើសំណើសុំពិនិត្យលទ្ធភាពក្នុងការតែងតាំងអគ្គនាយករង ទទួលបន្ទុកការងារអាជីវកម្ម (អនុម័តឯកភាព)
- វិភាគទានលូ ទឹកស្អុយ១០% ក្នុងរាជធានីភ្នំពេញ (ឯកភាព)

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤

- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារ១០ខែ បូក២ខែប៉ាន់ស្មានឆ្នាំ២០១៤ និងផែនការត្រីមាសទី១ឆ្នាំ២០១៥ (ឯកភាពទាំងស្រុង លើរបាយការណ៍)
- បានពិនិត្យលើរបាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្ត ត្រីមាសទី៤ ឆ្នាំ២០១៤(ឯកភាពទាំងស្រុងលើរបាយការណ៍)
- បានពិនិត្យលើរបាយការណ៍លទ្ធផល ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គម អនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៤ (ឯកភាពទាំងស្រុង លើរបាយការណ៍)
- បានពិនិត្យលើរបាយការណ៍លទ្ធផលការងារសវនកម្មផ្ទៃក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ (ឯកភាពទទួលជ្រាបជាព័ត៌មាន)
- បានពិនិត្យលើសំណើសុំគោលការណ៍ លុបចេញពីបញ្ជីឆ្នាំ២០១៤ នូវអចលនទ្រព្យខូច-បាត់បង់គុណភាព និងធ្វើសំវិធានធន សន្និធិឃ្លាំងនូវ សម្ភារមិន ប្រើប្រាស់ និងប្រកាសលក់ឡៃឡុង (ឯកភាពជាឯកច្ឆ័ន្ទ)
- បានពិនិត្យលើសំណើសុំពិនិត្យ-សម្រេចលើការបោះផ្សាយពាណិជ្ជកម្មពី រ.ទ.ស.ភ. ក្នុងសៀវភៅ myINVESTORguide បានពិនិត្យលើរបាយការណ៍ស្តីពីផលប៉ះពាល់ទៅលើរោងចក្រផលិតទឹកស្អាតនិរោធ (ឯកភាពមិនចុះផ្សាយ)

## ង- ការបណ្តុះបណ្តាលអភិបាល

ក្នុងឆ្នាំ២០១៤ នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានការបណ្តុះបណ្តាលអភិបាលនោះទេ។

## ច- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំទាន់បានបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាលនៅឡើយទេ។

# ផ្នែកទី៣: អភិបាលកិច្ចសាជីវកម្ម (ត)

## ៤- បុគ្គលិកជាន់ខ្ពស់

### ក- សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា | អគ្គនាយក<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ២ | ឯកឧត្តម នេត មុន្នី | មន្ត្រីត្រួតពិនិត្យរដ្ឋ |
| ៣ | លោក រស់ គឹមលាង | អគ្គនាយករង<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៤ | លោក ឡុង ណារ៉ូ | អគ្គនាយករង<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៥ | លោក សំរិទ្ធ សុវិទ្យា | អគ្គនាយករង<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៦ | បណ្ឌិត ជាវិសុទ្ធ | អគ្គនាយករង<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៧ | លោក កែវ សុវណ្ណរិទ្ធ | អគ្គនាយករង<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៨ | លោក ចាន់ ពិសិដ្ឋ | អគ្គនាយករង<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ៩ | លោកស្រី ងិន ចន្ទ្រា | អគ្គនាយករង<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១០ | លោក ឡាច បដ្ឋណា | ទីប្រឹក្សាអគ្គនាយក<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១១ | លោក ស៊ឹម ខេងលីន | ទីប្រឹក្សាអគ្គនាយក<br>រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| ១២ | លោក ជា សតិភទ្ទ | ប្រធាននាយកដ្ឋាន ផែនការ និងគម្រោង |
| ១៣ | លោក ម៉ាណូរ៉ាវីន | ប្រធាននាយកដ្ឋាន ផលិតកម្ម និងផ្គត់ផ្គង់ទឹក |
| ១៤ | លោក ឱម អដ្ឋរស | ប្រធាននាយកដ្ឋាន អាជីវកម្ម |
| ១៥ | លោកស្រី រឿន ណារី | ប្រធាននាយកដ្ឋាន រដ្ឋបាល និងធនធានមនុស្ស |
| ១៦ | លោក គឹម អេង ឡូយលួង | ប្រធានសវនកម្មផ្ទៃក្នុង |

# បុគ្គលិកជាន់ខ្ពស់



**ឯកឧត្តម ស៊ឹម ស៊ីថា**
អគ្គនាយក

## អគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦១ និងបានទទួលជាវិស្វករ សំណង់ស៊ីវិលឧស្សាហកម្ម នៅវិទ្យាស្ថានបច្ចេកវិទ្យាជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត (រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា) ក្នុងឆ្នាំ១៩៨៩។ ឯកឧត្តម ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម នៅសកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០០៧។ ក្នុងឆ្នាំ២០១៤ ឯកឧត្តម បានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតដោយជោគជ័យ លើជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម ជាអនុប្រធានអង្គភាព រដ្ឋាករទឹកខេត្ត ព្រះសីហនុពីខែកុម្ភៈ ឆ្នាំ១៩៩៦ ដល់ខែមិថុនា ឆ្នាំ២០០៣។ ចាប់ពីខែមិថុនា ឆ្នាំ២០០៣ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ ឯកឧត្តម មានតួនាទីជាប្រធានអង្គភាពរដ្ឋាករទឹកខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ **ឯកឧត្តម ស៊ឹម ស៊ីថា** ជាអគ្គនាយក រ.ទ.ស.ភ. និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃ រ.ទ.ស.ភ. អាណត្តិទី៥ ចាប់ពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ រហូត មកដល់បច្ចុប្បន្ន។



**ឯកឧត្តម នេត មុន្នី**
មន្ត្រីត្រួតពិនិត្យរដ្ឋ

## មន្ត្រីត្រួតពិនិត្យរដ្ឋ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តមកើតនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៥ និងបានទទួលសញ្ញាបត្រ សាលាកម្រិតសិក្សាទី៣ តាខ្មៅ ក្នុងឆ្នាំ១៩៨៤។ ឯកឧត្តមបានទទួលបរិញ្ញាបត្រសេដ្ឋកិច្ចរោងចក្រ នៅសាលាវិស្វករ បច្ចេកទេសគមនាគមន៍ នៃប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ១៩៨៨ និងបានទទួលអនុបណ្ឌិត សេដ្ឋកិច្ចហិរញ្ញវត្ថុ នៅសកលវិទ្យាល័យឡុងដុង (កម្ពុជា និងអង់គ្លេស) ក្នុងឆ្នាំ១៩៩៧។ **ឯកឧត្តម នេត មុន្នី** បានបម្រើការងារឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីជាប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងជាមន្ត្រីត្រួតពិនិត្យរដ្ឋ នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ន។



**លោក រស់ គឹមលាង**
អគ្គនាយករង

## អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៦២។ លោកបានទទួលបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច នាឆ្នាំ១៩៩២ លើជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច។ នាឆ្នាំ២០០៣ លោកបានទទួលអនុបណ្ឌិត លើជំនាញហិរញ្ញវត្ថុ ពីសកលវិទ្យាល័យឆាលស្តាតនៃប្រទេសអូស្ត្រាលី (Chales Sturt University of Australia)។ លោកចូលបម្រើការនៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាប់ពីឆ្នាំ១៩៨០ និងមានតួនាទីជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧ រហូតដល់ចុងឆ្នាំ២០១១។ ចាប់ពីខែធ្នូ ឆ្នាំ២០១១ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ លោកមានតួនាទីជាអគ្គនាយករង រ.ទ.ស.ភ. ទទួលបន្ទុកហិរញ្ញកិច្ច និងផ្សារមូលបត្រ។ ចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន លោកជាអគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច និងផ្សារមូលបត្រ និងទទួលខុសត្រូវបន្ថែមជា ប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ។



**លោក ឡុង ណារ៉ូ**
អគ្គនាយករង

## អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៦។ នាឆ្នាំ១៩៨៩ លោកបានទទួលសញ្ញាបត្រវិស្វករ ជំនាញ Mechanical នៅសាលាវិស្វកម្ម សម្រាប់ Plant and Construction George Dimidroff នៃប្រទេសអាល្លឺម៉ង់។ នៅឆ្នាំ២០០៦ លោកបានទទួលអនុបណ្ឌិត ជំនាញគ្រប់គ្រងទូទៅ ពីសកលវិទ្យាល័យឆាលស្តាតនៃប្រទេសអូស្ត្រាលី (Chales Sturt University of Australia) ។ លោកចូលបម្រើការនៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៩១ ជាអនុប្រធានរោងចក្រភូមិព្រែក។ ជាបន្តបន្ទាប់ លោកបានកាន់តំណែងជាប្រធានការិយាល័យសិក្សាគម្រោងជាប្រធាននាយកដ្ឋានបច្ចេកទេស និងគម្រោង និងនៅឆ្នាំ២០០២ លោកជាអគ្គនាយករងនៃ រ.ទ.ស.ភ. ទទួលបន្ទុកនាយកដ្ឋានបច្ចេកទេសផែនការ និងនាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ចាប់ពីឆ្នាំ២០១២ មកទល់បច្ចុប្បន្ន លោកអគ្គនាយករងនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញទទួលបន្ទុកសាខាសេវាកម្ម ទឹកស្អាត និងអនាម័យ។



**លោក សំរិទ្ធ សុវិទ្យា**
អគ្គនាយករង

## អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៦៤។ លោកបានបញ្ចប់ការសិក្សា ថ្នាក់អនុបណ្ឌិត ជំនាញមេកានិចឧស្សាហកម្មធុនស្រាលនៃមហាវិទ្យាល័យម៉ាស៊ីន និងបរិក្ខារ ឧស្សាហកម្ម នៅទីក្រុងលេនីនក្រាត សហភាពសូវៀត នាឆ្នាំ១៩៩១។ បន្ទាប់មកទៀត លោកបានទទួលសញ្ញាបត្រអនុបណ្ឌិត លើជំនាញគ្រប់គ្រងទូទៅ ពីសកលវិទ្យាល័យឆាលស្តាតនៃប្រទេសអូស្ត្រាលី (Charles Sturt University of Australia) នាឆ្នាំ២០០៣។ លោកបានចូលបម្រើការនៅ រ.ទ.ស.ភ.នាឆ្នាំ១៩៩២ ហើយនៅឆ្នាំ២០០៣ លោកមានឋានៈជាប្រធាននាយកដ្ឋានផែនការ និងគម្រោង។ ចាប់ពីខែធ្នូ ឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន លោកជាអគ្គនាយករង រ.ទ.ស.ភ. ទទួលបន្ទុកការងារផែនការ និងវិនិយោគ ។



**បណ្ឌិត ជា វិសុទ្ធ**
អគ្គនាយករង

## អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៦០។ នាខែកក្កដា ១៩៨៤ លោកបានបញ្ចប់បរិញ្ញាបត្រនៅមហាវិទ្យាល័យភាសា Leipzig នៃប្រទេសអាល្លឺម៉ង់។ នាខែកុម្ភៈ ១៩៨៩ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិត នៅមហាវិទ្យាល័យបច្ចេកវិទ្យា Dresden ប្រទេសអាល្លឺម៉ង់ លើមុខជំនាញវិស្វកម្មគ្រប់គ្រងទឹក (Water Management Engineering)។ លោកបានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតដោយជោគជ័យ លើជំនាញអនាម័យ និងផ្គត់ផ្គង់ទឹកស្អាត នៅមហាវិទ្យាល័យ Dresden ប្រទេសអាល្លឺម៉ង់ នាខែមីនា ឆ្នាំ១៩៩៤។ លោកចូលបម្រើការនៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៨៩។ នៅឆ្នាំ១៩៩៧ លោកមានតួនាទីជាជំនួយការអគ្គនាយក។ ចាប់ពីឆ្នាំ២០១២ រហូតមកទល់បច្ចុប្បន្ន លោកត្រូវបានតែងតាំងជាលេខាធិការសហគ្រាស របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។



**លោក កែវ សុវណ្ណរិទ្ធ**
អគ្គនាយករង

## អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៧ មករា ១៩៦៩។ លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់នាឆ្នាំ១៩៩៥ ជំនាញដោះស្រាយបញ្ហា និងការរីកចម្រើនរបស់ក្រុមហ៊ុន នៅសកលវិទ្យាល័យ ស្ថាបត្យកម្ម និងសំណង់ នៃអតីតសហភាពសូវៀត។ ចាប់ពីឆ្នាំ១៩៩៦ លោកជាមន្ត្រី នៃមន្ទីររៀបចំក្រុង និងសំណង់ រាជធានីភ្នំពេញ។ នាឆ្នាំ២០០០ មកទល់បច្ចុប្បន្ន លោក បានចូលបម្រើការនៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាអគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទទួលបន្ទុកការងារផលិតកម្ម និងផ្គត់ផ្គង់ទឹក ។



**លោក ចាន់ ពិសិដ្ឋ**
អគ្គនាយករង

## អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៧៦។លោកបានទទួលបរិញ្ញាបត្រ នាឆ្នាំ១៩៩៩ ជំនាញអក្សរសាស្ត្រ និងមនុស្សសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បន្ទាប់មកទៀតលោកបានទទួលសញ្ញាបត្រអនុបណ្ឌិត លើជំនាញ គ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យពាណិជ្ជសាស្ត្រភ្នំពេញ នាឆ្នាំ២០០៥។ លោកបានចូលបម្រើការនៅ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅការិយាល័យកិច្ចការទឹក (នាយកដ្ឋានទឹកស្អាត) ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០១។ ពីឆ្នាំ២០០៣ មកដល់ឆ្នាំ២០០៩ លោកជាអនុប្រធានការិយាល័យកិច្ចការទឹក ដល់ឆ្នាំ២០០៩ លោកទទួលបានការតែងតាំងជាប្រធានការិយាល័យកិច្ចការទឹក នៃនាយកដ្ឋានទឹកស្អាត។ ចាប់ពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន លោកបានចូលបម្រើការនៅ រ.ទ.ស.ភ. ជាអគ្គនាយករងទទួលបន្ទុករដ្ឋបាល និងធនធានមនុស្ស។



**លោកស្រី ខិន ចន្ទ្រា**
អគ្គនាយករង

## អគ្គនាយករង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៦០។ នាឆ្នាំ២០០៧ លោកស្រីបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ លោកស្រីបម្រើការងារនៅមន្ទីរពាណិជ្ជកម្មរាជធានី ឋានៈជាប្រធានអគារស្បៀង។ លោកស្រីបានចូលបម្រើការនៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅឆ្នាំ១៩៩៣។ ជាបន្តបន្ទាប់លោកស្រីបានកាន់តំណែងជា ប្រធានការិយាល័យហិរញ្ញវត្ថុ និងជាអនុប្រធាននាយកដ្ឋានអាជីវកម្ម។ ឆ្នាំ២០១២ លោកស្រី ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានអាជីវកម្ម។ ចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន លោកស្រី ត្រូវបានតែងតាំងជាអគ្គនាយករងទទួលបន្ទុកការងារអាជីវកម្ម។



**លោក ឡាច បដ្ឋណា**
ទីប្រឹក្សាអគ្គនាយក

## ទីប្រឹក្សាអគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៤ និងបានទទួលសញ្ញាបត្រមធ្យមសិក្សាភាគII នៅវិទ្យាល័យព្រះមុនីវង្ស ក្រុងបាត់ដំបង ឆ្នាំ១៩៧៤។ ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨១ លោកជាគណនេយ្យករ ក្រុមហ៊ុនឧស្សាហផល មន្ទីរពាណិជ្ជកម្មរដ្ឋធានីភ្នំពេញ ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៩ លោកជាប្រធានការិយាល័យគណនេយ្យ ក្រុមហ៊ុនសណ្ឋាគារ និងភោជនីយដ្ឋានមន្ទីរពាណិជ្ជកម្មរដ្ឋធានីភ្នំពេញ។ ចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៣ លោកជាអនុប្រធានការិយាល័យគណនេយ្យ នៃមន្ទីរពាណិជ្ជកម្ម រាជធានី ភ្នំពេញ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៧ ជាប្រធានការិយាល័យគណនេយ្យ នៃ រ.ទ.ស.ភ. ពីឆ្នាំ ១៩៩៧ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣ លោកជាអនុប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ រ.ទ.ស.ភ. ចាប់ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៤ លោកជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ រ.ទ.ស.ភ.។ លោកជា ទីប្រឹក្សាអគ្គនាយក រ.ទ.ស.ភ. ទទួលបន្ទុកជំនួយការលើការងារ គណនេយ្យ និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៤ រហូតដល់បច្ចុប្បន្ន។



**លោក ស៊ឹម ខេងលីន**
ទីប្រឹក្សាអគ្គនាយក

## ទីប្រឹក្សាអគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៤៧ និងបានទទួលបរិញ្ញាបត្រផ្នែកគណិតវិទ្យា នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ១៩៧៥។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាប្រធាននាយកដ្ឋាន អាជីវកម្ម ចាប់ពីឆ្នាំ១៩៩៧ រហូតដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២។ លោកជាទីប្រឹក្សាអគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទទួលបន្ទុកជំនួយការលើការងារអាជីវកម្ម ចាប់ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន។



**លោក ជា សតិភទ្ទ**
ប្រធាននាយកដ្ឋាន

## ប្រធាននាយកដ្ឋានផែនការ និងគម្រោង

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៦៥ និងបានទទួលសញ្ញាបត្រថ្នាក់ឧត្តមសិក្សា នៅសហភាពសូវៀត ក្នុងឆ្នាំ១៩៩១។ លោកបានបម្រើការងារឲ្យ រ.ទ.ស.ភ. មានតួនាទីជាអ្នកសិក្សា និងគូសប្លង់បំពង់ចាស់នៃប្រព័ន្ធបណ្តាញ ក្នុងរាជធានីភ្នំពេញ។ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦ លោកទទួលខុសត្រូវដាក់បំពង់ចែកចាយ និងបំពង់មេនាំទឹក ក្នុងរាជធានីភ្នំពេញ។ ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០០ លោកជា សមាជិកអង្គភាពលទ្ធកម្ម។ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៣ លោកជាអ្នកត្រួតពិនិត្យការងារដាក់បំពង់មេនាំទឹក ក្នុងរាជធានីភ្នំពេញ។ ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៦ លោកមានតួនាទី ជាប្រធានការិយាល័យ បណ្តាញមេ។ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១៣ លោកជាអនុប្រធាននាយកដ្ឋានផែនការ និង បច្ចេកទេស។ ចាប់ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន លោកទទួលបានការតែងតាំងជាប្រធាននាយកដ្ឋានផែនការ និងគម្រោង។



**លោក ម៉ា ណូរ៉ាទីន**
ប្រធាននាយកដ្ឋាន

## ប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៣។ នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ លើជំនាញផ្នែកវារីសាស្រ្តនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ បន្ទាប់មក នៅឆ្នាំ២០០៨ លោកទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិត ជំនាញ Socio-Environmental Engineering នៅប្រទេសជប៉ុន។ លោកចូលបម្រើការនៅ រ.ទ.ស.ភ. នៅឆ្នាំ១៩៩៧ និងទទួលការតែងតាំងជាប្រធានការិយាល័យសិក្សាគម្រោង នាឆ្នាំ២០០៣។ នៅឆ្នាំ២០០៨ បានទទួលការតែងតាំងជាអនុប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក ហើយចាប់ពីឆ្នាំ២០១២ រហូតដល់បច្ចុប្បន្នជាប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក។



**លោក ឱម អដ្ឋរស**
ប្រធាននាយកដ្ឋាន

## ប្រធាននាយដ្ឋាន អាជីវកម្ម

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០១ខែធ្នូ ឆ្នាំ១៩៦១។ នាឆ្នាំ១៩៨៥ លោកបានទទួលសញ្ញាបត្រកម្មករជំនាញ នៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈប្រទេសសហភាពសង្គមនិយមសូវៀត។ ឆ្នាំ១៩៨៧ លោកបានទទួលសញ្ញាបត្រទុតិយភូមិ នៅវិទ្យាល័យបាក់ទូកបំពេញវិជ្ជាក្រៅម៉ោងធ្វើការ។ ឆ្នាំ១៩៩៣ លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកផ្គត់ផ្គង់ទឹក និងប្រព័ន្ធកាកសំណល់ នៅវិទ្យាស្ថានស្ថាបត្យកម្ម និងកាកសំណល់ប្រទេសសហភាពសង្គមនិយមសូវៀត។ លោកបានបម្រើការងារឲ្យ រ.ទ.ស.ភ. ជាបុគ្គលិកតបណ្តាញចូលផ្ទះ នៅឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨២។ ឆ្នាំ១៩៨៥ លោកជាបុគ្គលិកជួសជុល នៅរោងជាងយន្តសាស្រ្ត។ ឆ្នាំ១៩៨៧ លោកជាបុគ្គលិក នៅការិយាល័យផែនការ និងបច្ចេកទេស។ ឆ្នាំ១៩៩៣ លោកជាមន្រ្តីបច្ចេកទេស នៅការិយាល័យបណ្តាញចូលផ្ទះ។ ឆ្នាំ១៩៩៧ លោកជាអនុប្រធានការិយាល័យបណ្តាញចូលផ្ទះ។ លោកត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានអាជីវកម្មចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន។



**លោកស្រី រឿន ណារី**
ប្រធាននាយកដ្ឋាន

## ប្រធាននាយកដ្ឋាន រដ្ឋបាល និងធនធានមនុស្ស

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៦៧។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ នាឆ្នាំ២០០៤ ជំនាញផ្នែកគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យបៀលប្រាយ។ នៅឆ្នាំ២០១១ លោកស្រីបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិត ផ្នែកច្បាប់នៅសាកលវិទ្យាល័យឯកទេសនៃកម្ពុជា។ នាឆ្នាំ១៩៨៦ លោកស្រីជាបុគ្គលិកមន្ទីរផែនការក្រុងភ្នំពេញ។ លោកស្រីចូលបម្រើការនៅ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាប់ពីឆ្នាំ ១៩៩១ មានតួនាទីជាអនុប្រធានការិយាល័យធនធានមនុស្ស នៅឆ្នាំ១៩៩៧ និងជាប្រធានការិយាល័យធនធានមនុស្ស នៅឆ្នាំ២០០៣។ ចាប់ពីឆ្នាំ២០០៨ រហូតមកទល់បច្ចុប្បន្ន លោកស្រីទទួលបានការតែងតាំងជាប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស។



**លោក គឹម អេង ឡុយលួង**
ប្រធានសវនកម្មផ្ទៃក្នុង

## ប្រធានសវនកម្មផ្ទៃក្នុង

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៥៥ និងបានទទួលសញ្ញាបត្រថ្នាក់ឧត្តមសិក្សា ជាវិស្វករសេដ្ឋកិច្ចពាណិជ្ជកម្ម នៅវិទ្យាស្ថានវិទ្យាសាស្រ្តសេដ្ឋកិច្ចក្រសួងអប់រំក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៩០។ នាឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ លោកជា ប្រធានការិយាល័យគណនេយ្យ មន្ទីរទិញដូរគ្រឿងឧបភោគ-បរិភោគ នៃមន្ទីរពាណិជ្ជកម្ម រាជធានីភ្នំពេញ។ នាឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៥ លោកជាអនុប្រធានការិយាល័យ ផែនការស្ថិតិទទួលស្ថិតិ ក្រុមហ៊ុនឧបភោគ បរិភោគនៃមន្ទីរពាណិជ្ជកម្ម រាជធានីភ្នំពេញ។ នាឆ្នាំ ១៩៩៤ ដល់ឆ្នាំ២០០៨ លោកជាអនុប្រធានការិយាល័យគណនេយ្យ ទទួលបន្ទុកបូកសរុប និងគ្រប់គ្រងបំណុលឥណទានពីបរទេស របស់ រ.ទ.ស.ភ.។ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ លោកជា ប្រធានការិយាល័យគណនេយ្យ រ.ទ.ស.ភ.។ ចាប់ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៣ រហូតដល់បច្ចុប្បន្ន លោកទទួលបានការតែងតាំងជាប្រធានសវនកម្មផ្ទៃក្នុងនៃ រ.ទ.ស.ភ.។

## ខ- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

### ឯកឧត្តម ស៊ឹម ស៊ីថា (អគ្គនាយក)

- រៀបចំការប្រជុំក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវលេខាធិការកិច្ច
- ទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ហើយធ្វើឲ្យសម្រេចនូវគោលនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំគម្រោងការងារសហគ្រាស ហើយដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆ្នាំ អំពីសកម្មភាព ធ្វើតុល្យការហិរញ្ញវត្ថុ ប្រចាំត្រីមាស ឆ្នាំ និងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ប្រើប្រាស់ និងចាត់ចែងនិយោជិត រ.ទ.ស.ភ. ក្នុងកម្រិតក្របខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល និងស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងលក្ខន្តិកៈបុគ្គលិកនៃ រ.ទ.ស.ភ.
- ជ្រើសរើសតែងតាំង ដកហូតមុខងារ ឬបណ្ដេញចោលនូវបុគ្គលិក និងអនុវត្តសិទ្ធិអំណាចតាមឋានានុក្រមរៀបចំកិច្ចសន្យា និងចុះហត្ថលេខាលើសន្និសញ្ញាស្របតាម សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- មានសិទ្ធិផ្ដល់អំណាច និងសិទ្ធិចុះហត្ថលេខារបស់ខ្លួនទៅឲ្យនាយកមួយរូប ឬច្រើនរូប ឬទៅឲ្យភ្នាក់ងារដទៃណាមួយដែលខ្លួនជ្រើសរើស
- ជារួម អគ្គនាយក មានមុខងារដឹកនាំ និងគ្រប់គ្រងរាល់ការងារចាំបាច់ទាំងអស់សម្រាប់ធានាដំណើរការជាប្រក្រតីរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

### ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ)

- ត្រួតពិនិត្យលើ រ.ទ.ស.ភ. ជាពិសេសលើទិដ្ឋភាពហិរញ្ញវត្ថុ
- បំពេញការតព្វកិច្ចរបស់ រ.ទ.ស.ភ. ដែលមានចែងក្នុងច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន
- អនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- តាមដានការប្រព្រឹត្តទៅ និងការអភិវឌ្ឍន៍របស់ រ.ទ.ស.ភ.

### លោក រស់ គីមលាង (អគ្គនាយករង)

- ទទួលបន្ទុកហិរញ្ញកិច្ច និងទីផ្សារមូលបត្រ និងជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- ជាជំនួយការអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងជាជំនួយការអគ្គនាយកលើកិច្ចការផ្សារមូលបត្រ កិច្ចការអាជីវកម្ម កិច្ចការផែនការអាជីវកម្ម-វិនិយោគប្រចាំឆ្នាំ និងការងារសវនកម្មផ្ទៃក្នុង។

### លោក ឡុង ណារ៉ូ (អគ្គនាយករង)

- ទទួលបន្ទុកសាខា សេវាកម្មទឹកស្អាត និងអនាម័យ
- ជាជំនួយការអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រង សាខាសេវាកម្មទឹកស្អាត និងអនាម័យ ព្រមទាំងធ្វើការទាក់ទង ស្វែងរកទីផ្សារការងារសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ក្នុង និងក្រៅប្រទេស។

### លោក សំរិទ្ធ សុវិទ្យា (អគ្គនាយករង)

- ទទួលបន្ទុកផែនការនិងវិនិយោគ
- ជាជំនួយការអគ្គនាយកក្នុងការដឹកនាំ និងគ្រប់គ្រងនាយកដ្ឋានផែនការ និងគម្រោង និងជាជំនួយការអគ្គនាយកលើកិច្ចការធ្វើផែនការវិនិយោគប្រចាំឆ្នាំ ការងារបច្ចេកទេស ព្រមទាំងការងារសហប្រតិបត្តិការជាមួយអ្នកផ្ដល់ជំនួយ និងហិរញ្ញប្បទាន។

### បណ្ឌិត ជា វិសុទ្ធ (អគ្គនាយករង)

- ទទួលបន្ទុកលេខាធិការសហគ្រាស
- ជាជំនួយការអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងលេខាធិការដ្ឋាន។

# ផ្នែកទី៣៖
# អភិបាលកិច្ចសាជីវកម្ម (ត)

## ៤- បុគ្គលិកជាន់ខ្ពស់

### ខ- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់ (ត)

លោក កែវ សុវណ្ណរិទ្ធ (អគ្គនាយករង)

- ទទួលបន្ទុកផលិតកម្ម និងផ្គត់ផ្គង់ទឹក
- ជាជំនួយការអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងនាយកដ្ឋានផលិតកម្មនិងផ្គត់ផ្គង់ទឹក ព្រមទាំងតាមដាន និងធ្វើការវិភាគលក្ខណៈសេដ្ឋកិច្ច នៃការងារផលិតកម្ម និងថែទាំប្រព័ន្ធចែកចាយទឹក រួមទាំងការងារកាត់បន្ថយទឹកបាត់បង់។

លោក ចាន់ ពិសិដ្ឋ (អគ្គនាយករង)

- ទទួលបន្ទុករដ្ឋបាល និងធនធានមនុស្ស

ជាជំនួយការអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស។

លោកស្រី ងិន ចន្ទ្រា (អគ្គនាយករង)

- ទទួលបន្ទុកការងារអាជីវកម្ម
- ជាជំនួយការអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងនាយកដ្ឋានអាជីវកម្ម

លោក ឡាច បដ្ឋណា (ទីប្រឹក្សាអគ្គនាយក)

- ទទួលបន្ទុកលើការងារ គណនេយ្យ និងហិរញ្ញវត្ថុ

លោក ស៊ឹម ខេងលីន (ទីប្រឹក្សាអគ្គនាយក)

- ទទួលបន្ទុកលើការងារ អាជីវកម្ម

លោក ជា សតិភទ្ទ (ប្រធាននាយកដ្ឋាន ផែនការ និងគម្រោង)

- ជាសេនាធិការជូនអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងដោយផ្ទាល់លើ នាយកដ្ឋានផែនការ និងគម្រោង

លោក ម៉ា ណូរ៉ារីន (ប្រធាននាយកដ្ឋាន ផលិតកម្ម និងផ្គត់ផ្គង់ទឹក)

- ជាសេនាធិការជូនអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងដោយផ្ទាល់លើ នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក

លោក ឱម អង្គរស (ប្រធាននាយកដ្ឋាន អាជីវកម្ម)

- ជាសេនាធិការជូនអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងដោយផ្ទាល់លើ នាយកដ្ឋានអាជីវកម្ម

លោកស្រី រឿន ណារី (ប្រធាននាយកដ្ឋាន រដ្ឋបាល និងធនធានមនុស្ស)

- ជាសេនាធិការជូនអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងដោយផ្ទាល់លើ នាយករដ្ឋបាល និងធនធានមនុស្ស

លោក គឹម អេង ឡូយលួង (ប្រធានសវនកម្មផ្ទៃក្នុង)

- ជាសេនាធិការជូនអគ្គនាយក ក្នុងការដឹកនាំ និងគ្រប់គ្រងដោយផ្ទាល់លើ សវនកម្មផ្ទៃក្នុង

### គ- ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់

ក្នុងឆ្នាំ២០១៤ នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់នោះទេ។

## ៥- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

### ក- បណ្តឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុន ដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាល របស់ រ.ទ.ស.ភ. ធ្លាប់ជាអភិបាល បុគ្គលិកជាន់ខ្ពស់ ឬជាកម្មសិទ្ធិករ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. មិនមានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ធ្លាប់មានការពាក់ព័ន្ធនឹងបណ្តឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ រ.ទ.ស.ភ. ធ្លាបជាអភិបាល ឬជាសហកម្មសិទ្ធិករនោះទេ។

### ខ- ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនិតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. មិនមានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនិតិវិធីតុលាការនោះទេ។

### គ- ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ច ចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឲ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិត ទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះនៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. មិនមានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ទទួលការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ច ដោយហាមឃាត់មិនឲ្យចូលរួច ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះនៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយនោះទេ។

### ឃ- ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឲ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិត ទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. មិនមានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ទទួលការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឲ្យចូលរួច ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅ លើសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយនោះទេ។

# ផ្នែកទី៣:
# អភិបាលកិច្ចសាជីវកម្ម (ត)

## ៦- លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក- ឈ្មោះ តំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការដែលទទួលបាន

| ល.រ | ឈ្មោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ | មុខដំណែងក្នុង រ.ទ.ស.ភ. | ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់ មធ្យមប្រចាំខែ ឆ្នាំ២០១៤ (ពាន់រៀល) | ចំនួនសរុប "ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់មិនបូក បញ្ចូលប្រាក់សោធននិវត្តន៍" (ពាន់រៀល) |
|---|---|---|---|---|
| ១ | ឯកឧត្តម ស៊ឹម ស៊ីថា | អគ្គនាយក | ១៧.៩០៣ | ២១៤.៨៣២ |
| ២ | លោក រស់ គឹមលាង | អគ្គនាយករង | ១០.៦៨៨ | ១២៨.២៦០ |
| ៣ | លោក ឡុង ណារ៉ូ | អគ្គនាយករង | ១០.៤០២ | ១២៤.៨២៣ |
| ៤ | លោក សំរិទ្ធ សុរិទ្យា | អគ្គនាយករង | ១០.៥៤៥ | ១២៦.៥៤២ |
| ៥ | បណ្ឌិត ជាវិសុទ្ធ | អគ្គនាយករង | ១០.៦៨៨ | ១២៨.២៦០ |
| ៦ | លោក កែវ សុវណ្ណរិទ្ធ | អគ្គនាយករង | ៩.៣៣៩ | ១១២.០៦៨ |
| ៧ | លោក ចាន់ ពិសិដ្ឋ | អគ្គនាយករង | ៩.២១១ | ១១០.៥៣០ |
| ៨ | លោកស្រី ងិន ចន្ទ្រា | អគ្គនាយករង | ១៤.៨៩៧ | ១៧៨.៧៦២ |
| ៩ | លោក ឡាច បដ្ឋណា | ទីប្រឹក្សាអគ្គនាយក | ៦.៣៨០ | ៧៦.៥៥៨ |
| ១០ | លោក ស៊ឹម ខេងលីន | ទីប្រឹក្សាអគ្គនាយក | ៣.៤០១ | ៤០.៨១០ |
| ១១ | លោក ជា សតិភទ្ទ | ប្រធាននាយកដ្ឋានផែនការ និងគម្រោង | ៧.៦៣៤ | ៩១.៦០៨ |
| ១២ | លោក ម៉ាណូរ៉ារីន | ប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក | ៩.១២៧ | ១០៩.៥២០ |
| ១៣ | លោក ឱម អដ្ឋរស | ប្រធាននាយកដ្ឋានអាជីវកម្ម | ៤.៧៦១ | ៥៧.១៣១ |
| ១៤ | លោកស្រី រឿន ណារី | ប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស | ៩.៦៦៩ | ១១៦.០៣៣ |
| ១៥ | លោក គឹម អេងឡុយលួង | ប្រធានសវនកម្មផ្ទៃក្នុង | ៧.០០៧ | ៨៤.០៨៦ |

## ខ- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឲ្យអភិបាលមិនប្រតិបត្តិ

រ.ទ.ស.ភ. មានអភិបាលមិនប្រតិបត្តិចំនួន ៥រូប ដែលជាសមាជិកក្រុមប្រឹក្សាភិបាល តំណាង ស្ថាប័ន-ក្រសួង ដែលមិនប្រតិបត្តិការងារប្រចាំថ្ងៃនៅក្នុង រ.ទ.ស.ភ. និងតែងតាំងដោយអនុក្រិត្យ។

ដែលចំនួនប្រាក់បំណាច់ ឬលាភការសរុបមានចំនួន ៣៤២.០៣៤ពាន់រៀល

## គ- ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឲ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់

រ.ទ.ស.ភ. មានអភិបាលសរុបទាំងអស់ចំនួន ៧រូប និងបុគ្គលិកជាន់ខ្ពស់ចំនួន ១៥រូប រួមទាំងមន្ត្រីត្រួតពិនិត្យផ្ទៃ។ ខាងក្រោមគឺចំនួនសរុប (ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់មិនបូកបញ្ចូលប្រាក់សោធននិវត្តន៍)៖

- អភិបាលទាំងអស់ ៣៥០.៨៦៥ពាន់រៀល
- បុគ្គលិកជាន់ខ្ពស់ទាំងអស់ ១.៦៩៩.៨២២ពាន់រៀល

## ឃ- ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល និងបុគ្គលិកជាន់ខ្ពស់

ប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល និងបុគ្គលិកជាន់-ខ្ពស់ មានដូចខាងក្រោម៖

- អភិបាលទាំងអស់ ៤១៨.៣៧៧ពាន់រៀល
- បុគ្គលិកជាន់ខ្ពស់ទាំងអស់ ៤១៨.៣៧៧ពាន់រៀល

## ង- ការបង្កើនប្រាក់បំណាច់ ឬលាភការសរុប ក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ រ.ទ.ស.ភ. នៅក្នុងឆ្នាំសារពើពន្ធ ឬអនាគត

ក្រុមប្រឹក្សាភិបាលបានអនុម័ត និងឯកភាពជាគោលការណ៍ក្នុងការតម្លើងប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់មុខងារចំនួន ២០% ជូនអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ រ.ទ.ស.ភ. នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ។

# ផ្នែកទី៣:
# អភិបាលកិច្ចសាជីវកម្ម (ត)

## ៧- ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក- គោលការណ៍នៃក្រមសីលធម៌

### ក.១- សេចក្តីផ្តើម

ស្របតាមលក្ខខណ្ឌតម្រូវរបស់គណៈកម្មការមូលបត្រកម្ពុជា (ហៅកាត់ថា "គ.ម.ក.") និងសម្រាប់ជាការប្តេជ្ញាចិត្ត ជម្រុញឲ្យមានស្តង់ដារសីលធម៌ល្អបំផុត ក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា "ក្រុមហ៊ុន") បានអនុម័តក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ (តទៅហៅថា "ក្រមសីលធម៌") ដើម្បី៖

- លើកទឹកចិត្តឲ្យមានភាពស្មោះត្រង់ និងឥរិយាបថប្រកបដោយសីលធម៌ ក្នុងការធ្វើអាជីវកម្ម ក្នុងគោលបំណងជានាឲ្យបាននូវសមភាព និងជៀសវាងអំពើទំនាស់ផលប្រយោជន៍។
- លើកទឹកចិត្តក្នុងការផ្តល់ព័ត៌មានចាំបាច់នានា ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន ឲ្យបានពេញលេញច្បាស់លាស់ ត្រឹមត្រូវ និងទាន់ពេល។
- លើកទឹកចិត្តដល់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន។
- ធានាការពារផលប្រយោជន៍ អាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុន រួមបញ្ចូលទាំងកាលានុវត្តភាពអាជីវកម្ម ទ្រព្យសកម្មទាំងទ្រព្យអរូបិយ និងព័ត៌មានសម្ងាត់ របស់ក្រុមហ៊ុន។
- បញ្ចៀសនូវកិរិយាមិនត្រឹមត្រូវ ឬទង្វើផ្ទាំផ្ទួងទាំងឡាយ។

អាជីវកម្មរបស់ក្រុមហ៊ុន ត្រូវស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំទូទៅរបស់ក្រុមប្រឹក្សាភិបាល ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មានការទទួលខុសត្រូវជាចម្បងក្នុងការ វិនិច្ឆ័យពីអាជីវកម្មតាមបែបបទដែលខ្លួនជឿជាក់ថា វាផ្តល់ផលប្រយោជន៍ ល្អបំផុត សម្រាប់ក្រុមហ៊ុន និងសម្រាប់ភាគហ៊ុននិកទាំងអស់របស់ក្រុមហ៊ុន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវយល់ច្បាស់ពីក្រមសីលធម៌នេះ ហើយត្រូវប្រកាន់ខ្ជាប់នូវ គោលការណ៍ និងវិធាន ដែលមានចែងនៅក្នុងក្រមសីលធម៌នេះ។

### ក.២- និយមន័យ

នៅក្នុងបរិបទនៃក្រមសីលធម៌នេះ ពាក្យខាងក្រោមត្រូវបានឲ្យនិយមន័យដូចតទៅ៖

- **ច្បាប់ និងបទបញ្ញត្តិជាធរមាន៖** សំដៅដល់រាល់ច្បាប់ និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា រួមមានជាអាទិ៍ ច្បាប់ អនុក្រឹត្យ ប្រកាស វិធាន និងគោលការណ៍ណែនាំរបស់ អាជ្ញាធរមានសមត្ថកិច្ច ដូចជា គ.ម.ក. និងក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា (ហៅកាត់ថា **"ផ.ម.ក"**) ដែលច្បាប់និងបញ្ញត្តិ ទាំងនោះត្រូវអនុវត្តទៅលើក្រុមហ៊ុន អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន។

- **អភិបាល៖** សំដៅដល់សមាជិកក្រុមប្រឹក្សាភិបាល រួមបញ្ចូលទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ និងអភិបាលឯករាជ្យ។

- **បុគ្គលិកជាន់ខ្ពស់៖** សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានរហូតដល់អគ្គនាយក រួមទាំងលេខាធិការក្រុមហ៊ុន និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ ផ្សេងទៀតក្នុងក្រុមហ៊ុនដែលកំណត់ដោយ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

## ក.៣- ការអនុវត្តច្បាប់ និង បទបញ្ញត្តិជាធរមាន

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវអនុវត្ត និងព្យាយាមធ្វើឲ្យក្រុមហ៊ុនអនុវត្ត តាមច្បាប់ និងបទបញ្ញត្តិជាធរមាន។ ប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ណាមួយ បានដឹងព័ត៌មានដែលខ្លួនជឿជាក់ថា ក្រុមហ៊ុន អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬនិយោជិកណាមួយបានបំពានច្បាប់ និងបទបញ្ញត្តិជាធរមាន អភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលបានដឹងត្រូវផ្តល់ព័ត៌មាននេះជូនអគ្គនាយក ប្រធានក្រុមប្រឹក្សាភិបាល ប្រធានគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុង។

## ក.៤- អំពើទំនាស់ផលប្រយោជន៍

បន្ថែមលើបទបញ្ញត្តិទាំងឡាយនៃមាត្រា ១៣៤ ១៣៥ ១៣៦ និងមាត្រា ១៣៨ នៃច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែលអាចកើតមាន ជាមួយក្រុមហ៊ុន។

ជាទូទៅ ទំនាស់ផលប្រយោជន៍កើនឡើង នៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬផលប្រយោជន៍របស់សមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះបានជ្រៀតចូលក្នុង ឬអាចជះឥទ្ធិពលធ្ងន់ធ្ងរដល់៖

(ក) ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ក្រុមហ៊ុន ។

(ខ) លទ្ធភាពរបស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ផ្សេងៗទៀត ក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហើយត្រូវធ្វើសេចក្តី ប្រកាសជាសាធារណៈពីប្រតិបត្តិការ ឬទំនាក់ទំនងណាមួយដែលខ្លួនគិតថានឹងនាំឲ្យ កើតមានទំនាស់ផលប្រយោជន៍ជាមួយក្រុមហ៊ុន តាមការកំណត់របស់ គ.ម.ក. ឬ ផ.ម.ក. ។

អភិបាលឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួន ជាលាយលក្ខណ៍អក្សរ ទៅក្រុមហ៊ុន ឬស្នើឲ្យមានសេចក្តីប្រកាសដែលបានដាក់ចូលទៅក្នុងកំណត់ហេតុ នៃកិច្ចប្រជុំប្រឹក្សាភិបាល ក្នុងករណីដែល៖

(ក) អភិបាល ឬបុគ្គលិកជាន់ខ្ពល់នោះ ជាភាគីនៃកិច្ចសន្យា ឬជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនឬ

(ខ) អភិបាល ឬបុគ្គលិកជាន់ខ្ពល់នោះ មានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬនីតិបុគ្គល ដែលជាភាគីក្នុងកិច្ចសន្យា ឬភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុន ។

ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមទាំង ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់សហគ្រាសសាធារណៈអភិបាលឯករាជ្យ មិនត្រូវមានផលប្រយោជន៍ ណាមួយនៅក្នុងក្រុមហ៊ុន ដែលធ្វើឲ្យប៉ះពាល់ឯករាជ្យភាពរបស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពីមួយ (១) ភាពហ៊ុននៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនឡើយ ។

## ក.៥- កាលានុវត្តភាពអាជីវកម្ម

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ ជាអទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន នៅពេលសមស្រប ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវជៀសវាង៖

(ក) ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដែលខ្លួនបានដឹងក្នុងពេលអនុវត្តតួនាទី និង ការទទួលខុសត្រូវរបស់ខ្លួននៅក្នុងក្រុមហ៊ុន ។

(ខ) ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ក្រុមហ៊ុន ឬឋានៈ និងមុខតំណែងរបស់ខ្លួន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។

(គ) ប្រកួតប្រជែងជាមួយក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលនឹងកំណត់ពីទង្វើដែលផ្ទុយពីខ្លឹមសារនៃប្រការនេះ ដោយពិចារណាលើអង្គហេតុ និងស្ថានការណ៍ដែលពាក់ព័ន្ធទាំងឡាយនៃទង្វើនោះ ។

# ផ្នែកទី៣:
# អភិបាលកិច្ចសាជីវកម្ម (ត)

## ៧- ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក- គោលការណ៍នៃក្រមសីលធម៌ (ត)

### ក.៦- ទំនាក់ទំនងដោយស្មើភាព

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និង បុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើឲ្យមានភាពស្មើគ្នាក្នុងទំនាក់ទំនង រវាងគ្នា និងអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និង និយោជិតរបស់ក្រុមហ៊ុន ។

អភិបាល និង បុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកផលប្រយោជន៍ពីបុគ្គលណាម្នាក់ដោយមិនស្មោះត្រង់ ដោយប្រើប្រាស់ឧបាយកល ការលាក់បាំង ការបំភ័ន្ត ព័ត៌មានសំខាន់ ការបង្ហាញហេតុការណ៍ដែលខុសពីការពិត ឬដោយអំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម ។

ការប្រើប្រាស់ ព័ត៌មានអំពីសិទ្ធ ព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ក្រុមហ៊ុន ឬការបញ្ចុះបញ្ចូលអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ក្រុមហ៊ុនទាំងអតីត និងបច្ចុប្បន្ន ឲ្យទម្លាយនូវព័ត៌មានទាំងនោះ ត្រូវបានហាមឃាត់ដាច់ខាត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយសុចរិត និងដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិកទាំងអស់របស់ក្រុមហ៊ុន។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកផលប្រយោជន៍ពីមុខដំណែងរបស់ខ្លួនជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពីតតិយជន ដោយសារមុខដំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ។

### ក.៧- ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជំរុញឲ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់ឲ្យបានត្រឹមត្រូវ ដោយមានការទទួលខុសត្រូវ នូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន រួមទាំងទ្រព្យរូបិយ និងទ្រព្យអរូបិ។

ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធបញ្ញា ឧបករណ៍ ប្រភពធនធានប្រពន្ធ័ព័ត៌មានវិទ្យា និងទ្រព្យដទៃទៀតដែលជាកម្មសិទ្ធរបស់ក្រុមហ៊ុន ឬទ្រព្យដែលក្រុមហ៊ុនជួលពីគេ ឬទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ក្រុមហ៊ុន ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្មស្របច្បាប់ របស់ក្រុមហ៊ុនតែប៉ុណ្ណោះ ។

### ក.៨- បណ្តឹងពាក់ពន្ធ័នឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម (ប្រសិនបើមាន) ឬសវនករផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រូវទទួលខុសត្រូវក្នុងការរៀបចំនីតិវិធីសមស្របមួយសម្រាប់ទទួលពាក្យបណ្តឹង និងរក្សាទុកនូវពាក្យបណ្តឹង និងពិនិត្យលើពាក្យបណ្តឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងសវនកម្ម។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ អាចដាក់ពាក្យបណ្តឹងពីបញ្ហាខាងលើ ទៅគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ក្រុមហ៊ុន ។ ការស្នើសុំឲ្យពិនិត្យបណ្តឹងជាសម្ងាត់ អាចធ្វើឡើងបានតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន។

### ក.៩- ការលើកទឹកចិត្តឲ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឲ្យក្រុមហ៊ុនប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងលើកទឹកចិត្តនិយោជិតឲ្យរាយការណ៍ ពីកស្តុតាងនៃទង្វើខុសច្បាប់ ឬអសីលធម៌ ទៅនាយកដ្ឋាន ឬបុគ្គលដែលមានសមត្ថកិច្ចនៅក្នុងក្រុមហ៊ុន ។

### ក.១០- ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវអនុវត្ត និងប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន បទបញ្ជាផ្ទៃ ក្នុង និងគោលនយោបាយរបស់ក្រុមហ៊ុន ពាក់ពន្ធ័នឹងការលក់-ទិញភាគហ៊ុន របស់ក្រុមហ៊ុន ។

## ក.១១- ការរក្សាការសម្ងាត់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ក្រុមហ៊ុន ដែលខ្លួនបានដឹង លើកលែងតែក្នុងករណីដែលក្រុមហ៊ុន អនុញ្ញាតឲ្យផ្តល់ព័ត៌មាន ឬក៏ការផ្តល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា «ព័ត៌មានសម្ងាត់» រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈដែលអាចត្រូវបានប្រើដោយគូ ប្រកួតប្រជែងរបស់ក្រុមហ៊ុន ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឲ្យប៉ះពាល់ដល់ក្រុមហ៊ុន ឬអតិថិជនរបស់ក្រុមហ៊ុន ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយនឹងអគ្គនាយក ឬប្រធានក្រុមប្រឹក្សាភិបាល ប្រសិន បើអភិបាល ឬបុគ្គលិកជាន់ ខ្ពស់នោះ គិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសំងាត់នោះ។

## ក.១២- ការផ្តល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់ខ្ពស់តម្រូវឲ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ក្រុមហ៊ុន ដើម្បីឲ្យសេចក្តីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្តល់ព័ត៌មានដែលត្រូវចុះបញ្ជី ជាមួយអាជ្ញាធររដ្ឋ រួមបញ្ចូលទាំង **គ.ម.ក.** អាចរៀបចំធ្វើឡើងដោយ អនុលោមតាមច្បាប់ និងបទបញ្ញត្តិជាធរមាន រួមទាំងគោលការណ៍ណែនាំរបស់ **គ.ម.ក.** និង**ផ.ម.ក.**។

ម៉្យាងវិញទៀត ក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬគ្រប់គ្រង ការចុះបញ្ជីឯកសារជាមួយ គ.ម.ក. និង/ឬ ផ.ម.ក. ឬការជូនដំណឹងជាសាធារណៈផ្សេងទៀតរបស់ក្រុមហ៊ុន ពាក់ព័ន្ធអាជីវកម្មទូទៅលទ្ធផល លក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុ ត្រូវពិភាក្សាជាមួយនិងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធ ហើយចាត់វិធាន ការសមស្របសម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មាន ដើម្បីផ្តល់ការព័ត៌មាន ធ្វើបានពេញលេញ ច្បាស់លាស់ ត្រឹមត្រូវ ទាន់ពេលវេលា និងអាចយល់បាន។

ក្នុងទំហំដែលពាក់ព័ន្ធនឹងនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ក្រុមហ៊ុន អភិបាល និងបុគ្គលិកជាន់ខ្ពស់ម្នាក់ៗ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ព័ត៌មានរបស់ក្រុមហ៊ុន ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត
  ឬធ្វើឲ្យអ្នកដ៏ទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ក្រុមហ៊ុនប្រាប់អ្នកដ៏ទៃ ទោះបីជាអ្នកនោះនៅក្នុង ឬនៅក្រៅក្រុមហ៊ុន រួមទាំងសវនកងករាជ និយ័តកររបស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងៗទៀត។

## ក.១៣- វិសោធនកម្ម និងការលើកលែង

ក្រមសីលធម៌នេះអាចត្រូវបានធ្វើវិសោធនកម្ម ឬលើកលែងមិនអនុវត្តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាននេះ ច្បាប់ និងបទបញ្ញត្តិជាធរមាន។ ជាវិធានទូទៅ ក្រុមប្រឹក្សាភិបាលនឹងមិនផ្តល់ការលើកលែងមិនអនុវត្ត ប្រការណាមួយនៃក្រមសីលធម៌នវឡើយ ប្រសិនបើគ្មានមូលហេតុសមស្រប និងចាំបាច់នោះទេ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឲ្យបានច្បាស់ ខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារតាមក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មានកាតព្វកិច្ចយល់ដឹងពីក្រមសីលធម៌នេះ និងស្វែងរកការពន្យល់ និងការផ្តល់ប្រឹក្សាបន្ថែម ទាក់ទងនឹងការបកស្រាយ ខ្លឹមសារ និងលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌នេះ ជាពិសេសនៅពេលមានហេតុការណ៍ណាមួយដែលអាចមានទំនាស់ជាមួយនឹង ក្រមសីលធម៌នេះ។

ក្រុមប្រឹក្សាភិបាលត្រូវចាត់វិធានការណ៍សមស្រប ក្នុងករណីដែលមានការបំពានក្រមសីលធម៌នេះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ អាចសាកសួរដោយផ្ទាល់ទៅអគ្គនាយក ទាក់ទងនឹងការអនុវត្តន៍ ឬការបកស្រាយក្រមសីលធម៌នេះ។

## ខ- ការអនុវត្តក្រមសីលធម៌

ក្រមសីលធម៌នេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលប្រសើក្រុមហ៊ុន នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១០១២ និងមានអនុភាពអនុវត្តចាប់ពីក្រុមហ៊ុនទទួលបានការយល់ព្រម ឲ្យមានការបោះផ្សាយលក់មូលប័ត្រកម្មសិទ្ធជាសាធារណៈដោយ គ.ម.ក. និងត្រូវបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដោយ គ.ម.ក. និងត្រូវបានចុះបញ្ជីលក់មូលប័ត្រនៅ ផ.ម.ក.។

# ផ្នែកទី៤: បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

## ១- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

- ឈ្មោះ: រដ្ឋដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សញ្ជាតិ: ខ្មែរ
- អាសយដ្ឋាន : ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- លេខអត្តសញ្ញាណវិនិយោគ (ប្រសិនមាន): គ្មាន
- បរិមាណ: ៧៣.៩២៧.១៨៧
- ភាគរយ: ៨៥%

## ២- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ គ្មានភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននោះទេ។**

# ផ្នែកទី៥: ព័ត៌មានអំពីការជួញដូរមូលបត្ររបស់បុគ្គលបោះផ្សាយ

## ១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០១៣ | ២០១២ |
|---|---|---|
| ចំណេញសុទ្ធ | ៣៨.០៨៨.០៣០.០០០រៀល | ៣៤.៤២០.៩៦១.០០០រៀល |
| ភាគលាភជាសាច់ប្រាក់សរុប | ៤.៧៦១.០០៣.៧៥០រៀល | ២.៤០៩.១៥៦.៥៨៧,៤០រៀល |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | គ្មាន | គ្មាន |
| ភាគលាភផ្សេងទៀត | គ្មាន | គ្មាន |
| អនុបាតចំណាយភាគលាភ (%) | ១២,៥០% | ៧% |
| ទិន្នផលភាគលាភ (%) | * ១,០២% | * * ០,៤៥% |
| ភាគលាភក្នុងមួយមូលបត្រកម្មសិទ្ធិ | ៥៤,៧៤រៀល | ២៧,៧០រៀល |

** ផ្អែកលើថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣*

** * ផ្អែកលើថ្លៃបិទទីផ្សារប្រចាំថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២*

# ២- ថ្លៃ និងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ (រៀល) | អតិបរមា | ៥.១២០ | ៥.១០០ | ៥.០៨០ | ៥.០០០ | ៤.៩៨០ | ៤.៨៤០ | ៤.៧៨០ | ៤.៦០០ | ៤.៥៤០ | ៥.០០០ | ៥.០០០ | ៤.៧០០ |
| | អប្បបរមា | ៥.០០០ | ៥.០០០ | ៤.៨២០ | ៤.៦៨០ | ៤.៧០០ | ៤.៧០០ | ៤.៦០០ | ៤.៣០០ | ៤.៤៤០ | ៤.៥២០ | ៤.៨០០ | ៤.២២០ |
| | មធ្យម | ៥.០៦០ | ៥.០៥០ | ៤.៩៥០ | ៤.៨៤០ | ៤.៨៤០ | ៤.៧៧០ | ៤.៦៩០ | ៤.៤៥០ | ៤.៤៩០ | ៤.៧៦០ | ៤.៩០០ | ៤.៤៦០ |
| បរិមាណជួញដូរ (ភាគហ៊ុន) | អតិបរមា | ៦.៥៧៦ | ៤.២០៣ | ៥.០០០ | ២.៤៥៩ | ១០.៩៤៨ | ៤១.៨៧៣ | ៥១.២៩៦ | ៦.៤៧៦ | ៥.៤៦៩ | ៦.៣២១ | ២២.៥៧០ | ៩.២៥១ |
| | អប្បបរមា | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | មធ្យម | ៣.២៨៨ | ២.១០២ | ២.៥០០ | ១.២២៩,៥ | ៥.៤៧៤ | ២០.៩៣៧ | ២៥.៦៤៨ | ៣.២៣៨ | ២.៧៣៤,៥ | ៣.១៦០,៥ | ១១.២៨៥ | ៤.៦២៥,៥ |

# ផ្នែកទី៦៖

# របាយការណ៍សវនកម្មរបស់សវនកម្មផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
អង្គភាពសវនកម្មផ្ទៃក្នុង

## របាយការណ៍ស្តីពីការកែតម្រូវនូវចំណុចខ្វះខាតលើអនុលោមភាព និងប្រតិបត្តិការ តាមបណ្តានាយកដ្ឋាន និងអង្គភាពមួយចំនួនក្នុង រ.ទ.ស.ភ ឆ្នាំ២០១៤

**១. ការិយាល័យទំនាក់ទំនងអតិថិជន និងបណ្តាញចូលផ្ទះ** (**ត្រីមាសទី០១**)

- **ការិយាល័យទំនាក់ទំនងអតិថិជន**
  - ការងារគ្រប់គ្រងស្តុកសម្ភារបរិក្ខា មិនទាន់មាននិយោជិតប្រចាំការសម្រាប់បើកសម្ភារឲ្យជាង និងកត់ត្រាក្នុងសាលប័ត្រឃ្លាំងប្រចាំថ្ងៃ។
  - ការងារគ្រប់គ្រងជង្គាប់ប្លុំបេនាឡិកាទឹក ពុំមានហត្ថលេខាអ្នកប្រគល់ - ទទួលមុនយកទៅប្រើប្រាស់។
  - ការងារផ្តត់ផ្គង់ទឹកឡើងវិញ និងការតភ្ជាប់បណ្តាញទឹក មិនទាន់មានបែបបទឯកសារគ្រប់គ្រាន់ស្នើសុំពីអតិថិជន។
  - ការដោះដូរនាឡិកាទឹកមានអាយុកាលចាប់ពី ១២ឆ្នាំ ពុំបានរៀបចំឯកសារតាមខែ, ត្រីមាស និងឆ្នាំ។
  - ការិយាល័យទំនាក់ទំនងអតិថិជន គួរបានធ្វើបច្ចុប្បន្នភាពលើបែបបទដំណើរការស្តង់ដា (SOP) ឲ្យបានរៀងរាល់មួយឆ្នាំម្តង។

**សវនដ្ឋានបានធ្វើការកែលម្អ ទៅលើចំណុចខ្វះចន្លោះខាងលើ ក្រោយពីសវនករបានធ្វើការត្រួតពិនិត្យឡើងវិញ នៅថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៥។**

- **ការិយាល័យបណ្តាញចូលផ្ទះ**
  - ការពិនិត្យ និងវាយតម្លៃលើអតិថិជន ដែលមានចំណូលទាបពុំទាន់មានតម្លាភាពដោយពុំបានឆ្លងសុំការឯកភាពពី **អគ្គនាយកនាយិការង**។
  - ការផ្តល់សេវាជូនអតិថិជនអនុវត្តពុំទាន់បានសមស្រប ទៅតាមគោលការណ៍កំណត់ជាធរមានរបស់ រ.ទ.ស.ភ លើការសុំតបណ្តាញទឹករបស់អតិថិជន។
  - ការិយាល័យបណ្តាញចូលផ្ទះ គួរបានធ្វើបច្ចុប្បន្នភាពលើបែបបទដំណើរការស្តង់ដា (SOP) ឲ្យបានរៀងរាល់មួយឆ្នាំម្តង។

**សវនដ្ឋានបានធ្វើការកែលម្អ ទៅលើចំណុចខ្វះចន្លោះខាងលើក្រោយពី សវនករបានធ្វើការត្រួតពិនិត្យឡើងវិញ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥។**

## ការិយាល័យចំណូលទាំង ១០ (ត្រីមាសទី០២)

- ការគណនាថ្លៃទឹក លើគណនីដែលអតិថិជនសុំបើកប្រើប្រាស់ទឹកឡើងវិញ នៅមិនទាន់មានភាពសមស្រប តាមគោលការណ៍កំណត់របស់ រ.ទ.ស.ភ គឺត្រូវប្រកាសវិក័យប័ត្រជាពីរដំណាក់កាលៈ
  - ១- ពីថ្ងៃសុំផ្អាក ដល់ថ្ងៃសុំបើកប្រើប្រាស់ (គិតថ្លៃថែរក្សានាឡិកា)
  - ២- ពីថ្ងៃសុំបើកប្រើប្រាស់ ដល់ថ្ងៃអានលេខជាក់ស្តែង (គិតថ្លៃថែទាំនាឡិកា និងថ្លៃប្រើប្រាស់ទឹក)។
- គួរមានកម្មវិធីត្រួតពិនិត្យចុះធ្នក់ ការអានលេខនាឡិកាទឹករបស់ភ្នាក់ងារទៅលើអតិថិជន ដែលប្រើប្រាស់ទឹកច្រើនក្នុងគោលបំណងឲ្យមានសុក្រឹត្យភាពធ្វើវិក័យបត្រ។
- ការិយាល័យចំណូល គួរបានធ្វើបច្ចុប្បន្នភាពលើបែបបទ ដំណើរការ ស្តង់ដា (SOP) ឲ្យបានរៀងរាល់មួយឆ្នាំម្តង។

**សវនដ្ឋានបានធ្វើការកែលម្អ ទៅលើចំណុចខ្វះចន្លោះខាងលើក្រោយពី សវនករបានធ្វើការត្រួតពិនិត្យឡើងវិញ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥។**

ចំពោះអតិថិជនធំៗ ដែលបានប្រើប្រាស់ទឹកលើសពីគោលការណ៍កំណត់ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាំបាច់ត្រូវអញ្ជើញអតិថិជនមកបង់ប្រាក់កក់ធានាបន្ថែម លើការប្រើប្រាស់ទឹកសវនដ្ឋានបានអនុវត្តតាមអនុសាសន៍ របស់សវនករជាបណ្តើរៗ។

## អង្គភាពលទ្ធកម្ម (ត្រីមាសទី០៣)

- ការលក់ឯកសារដេញថ្លៃ ផ្គត់ផ្គង់សម្ភារគ្រប់ប្រភេទពុំទាន់មានភាពសមស្របដោយពុំទាន់មានបង្កាន់ដៃបង់ប្រាក់ចេញពីបេឡារបស់ រ.ទ.ស.ភ។
- ការបើកឯកសារដេញថ្លៃមួយចំនួន គណកម្មការពុំបានចុះហត្ថលេខាលើពាក្យដេញថ្លៃគ្រប់សមាជិកទេ ការអនុវត្តខាងលើពុំទាន់មានភាពសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈ តម្រូវឲ្យគ្រប់សមាជិកបានចុះហត្ថ-លេខាគ្រប់គ្នា។

**សវនដ្ឋានបានធ្វើការកែលម្អ ទៅលើចំណុចខ្វះចន្លោះខាងលើក្រោយពីសវនករបានធ្វើការត្រួតពិនិត្យឡើងវិញ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥។**

## សាខាសេវាកម្មទឹកស្អាត និងអនាម័យ (ត្រីមាសទី០៤)

### ក- លទ្ធផលនៃការអង្កេតវិជ្ជមាន

ការត្រួតពិនិត្យនៅសាខាសេវាកម្មទឹកស្អាត និងអនាម័យ សវនករពិនិត្យឃើញជារួមថាៈ

+ អភិបាលកិច្ចរបស់ប្រធានសាខាប្រតិបត្តិ ដោយអនុលោមតាមស្តង់ដារ ការងារ, បទបញ្ញត្តិផ្សេងៗ និងបទបញ្ជាផ្ទៃក្នុង របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានកំណត់ជាធរមាន ប្រកបដោយក្រមសីលធម៌បានល្អប្រសើរគួរឲ្យកត់សម្គាល់ ។
+ មន្ត្រី-និយោជិតទាំងអស់មានឆន្ទៈមោះមុតក្នុងការងារ, គោរពវិន័យបានល្អ, រៀបចំចងក្រងឯកសារបានល្អប្រសើរ និងធ្វើរបាយការណ៍បូកសរុបការងារប្រចាំវគ្គ ,ឆមាស និងឆ្នាំបានទៀងទាត់ និងទាន់ពេលវេលា។

### ខ- លទ្ធផលការងារសវនកម្មនៅសាខាសេវាកម្មទឹកស្អាតនិង អនាម័យ

ទន្ទឹមនឹងនេះសាខាសេវាកម្មទឹកស្អាត និងអនាម័យក៏នៅមានចំណុចកង្វះខាតខ្លះៗលើការគ្រប់គ្រង និងប្រតិបត្តិដែលត្រូវកែលម្អដូចខាងក្រោម ៖

**ក/- ការគ្រប់គ្រងធនធានមនុស្ស**

+ ការិយាល័យប្រឹក្សាបច្ចេកទេស និងគ្រប់គ្រងគម្រោង ជាអ្នកតាមដានរបាយការណ៍បច្ចេកទេសលម្អិត និងកត់ត្រានូវលទ្ធផលការងារតាមក្រុមនីមួយៗរបស់ការិយាល័យអនុវត្តសំណង់ទូទៅ ចាប់

**ក/- ការគ្រប់គ្រងធនធានមនុស្ស**

+ ការិយាល័យប្រឹក្សាបច្ចេកទេស និងគ្រប់គ្រងគម្រោង ជាអ្នកតាមដានរបាយការណ៍បច្ចេកទេសលម្អិត និងកត់ត្រានូវលទ្ធផលការងារតាមក្រុមនីមួយៗរបស់ការិយាល័យអនុវត្តសំណង់ទូទៅ ចាប់ផ្តើមពីថ្ងៃចុះអនុវត្ត រហូតដល់ថ្ងៃបញ្ចប់គម្រោង ដើម្បីដាក់ឆ្លងប្រធាន ឬអនុប្រធានសាខាពិនិត្យ និងសម្រេច។
+ ផ្នែករដ្ឋបាល គណនេយ្យ ទីផ្សារ និងអន្តរាគមន៍ ជាអ្នកតាមដាន និងប្រមូលរាល់សក្ខីប័ត្រចំណាយទាំងអស់ក្នុងការដាក់បំពង់ ដើម្បីរៀបចំរបាយការណ៍លម្អិតដាក់ឆ្លងជូនថ្នាក់ ដឹកនាំសាខាពិនិត្យ និងសម្រេច។

**ខ/- ការងារទូទាត់គម្រោង**

សាខាសេវាកម្មទឹកស្អាត និងអនាម័យ គួរពន្លឿនដំណើរការទូទាត់ ក្រោយពីបញ្ចប់ការដ្ឋានដាក់បំពង់ទាំងឯកសារ បច្ចេកទេស និងសក្ខីប័ត្រពាក់ព័ន្ធចំណាយផ្សេងៗទៀតប្រព្រឹត្តទៅទាន់ពេលវេលា ដូចមានចែងក្នុង SOP ស្តីពីការទូទាត់គម្រោងលើការងារដាក់បំពង់ ដើម្បីជៀសវាងការអូសបន្លាយយូរឆ្លងឆ្នាំ។

**គ/- ការងារគ្រប់គ្រងឯកសារទូទាត់**

ក្រោយពីបានធ្វើការទូទាត់បញ្ចប់គម្រោង ជាមួយការិយាល័យគណនេយ្យ សាខាចាំបាច់ត្រូវថតចម្លង (COPY) ០១ច្បាប់ដើម្បីរក្សាទុកជា ឯកសារក្នុងសាម៉ីសាខារបស់ខ្លួន។

**ឃ/- ការងារ ស្តង់ដានីតិវិធីប្រតិបត្តិការ (SOP)**

សាខាត្រូវធ្វើបច្ចុប្បន្នភាព យ៉ាងហោចណាស់មួយឆ្នាំម្តង លើបែបបទស្តង់ដារ និតិវិធីការងារ ដើម្បីធានាបាននូវការអនុវត្ត ភាពជាក់លាក់មួយជូនដល់អង្គភាពប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាពខ្ពស់។

ភ្នំពេញ,ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥

**ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង**

**សេង_គាគារ**


PPWSA - Navision Attain - [Main Menu]
File Edit View Tools Window Help
General Ledger
Fixed Assets
Sales & Receivables
Purchases & Payables
Inventory
Resources
Jobs
Human Resources
Payroll
Water Billing
House Connection
Help
NAVISION ATTAIN
ATTAIN
start



# ផ្នែកទី៧:

# របាយការណ៍សវនកម្ម ដែលធ្វើសវនកម្មដោយ សវនករឯករាជ្យ

## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

# របាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

### របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា "រ.ទ.ស.ភ.") មានសេចក្តីសោមនស្ស សូមបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចហើយ សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ. គឺការផលិត និងការផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងតំបន់ជុំវិញ រួមទាំងតាខ្មៅ ព្រមទាំងធ្វើសកម្មភាពដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ នៅលើទំព័រទី៧៤។

### ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឲ្យមានការភាន់ច្រឡំដល់ការកំណត់ តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. នោះទេ។

### វិធីសាស្រ្តកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលអាចបណ្តាលឲ្យមានការភាន់ ច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្រ្តកំណត់តម្លៃ ដែលបានអនុវត្តកន្លង មកទៅលើទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. នោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន :

ក) បន្ទុកណាមួយលើទ្រព្យសកម្មរបស់រ.ទ.ស.ភ. ដែលបានកើតឡើងដោយសារការដាក់បញ្ចាំ សម្រាប់ធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក ឬ

ខ) បំណុលយថាភាពណាមួយ កើតឡើងចំពោះ រ.ទ.ស.ភ. ចាប់តាំងពីដំណាច់ឆ្នាំមក។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ. ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀត ដែលត្រូវបានទាមទារឲ្យសង ឬអាចត្រូវបានទាមទារឲ្យ សង ក្នុងអំឡុងពេល១២ខែ បន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ រ.ទ.ស.ភ. ក្នុងការបំពេញកាតព្វកិច្ចសងបំណុល របស់ខ្លួន នៅថ្ងៃកំណត់សង នោះទេ។

### ការផ្លាស់ប្តូរហេតុការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬ របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. ដែលធ្វើឲ្យចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានកំហុសឆ្គង ធ្ងន់ធ្ងរនោះទេ។

### ប្រតិបត្តិការមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ មិនបានទទួលរងនូវឥទ្ធិពល ធ្ងន់ធ្ងរ ដែលកើតចេញពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។

### ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក្រៅពីព្រឹត្តិការណ៍ផ្សេងៗដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ មិនមានការកើតឡើង នូវប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតាចាប់ពីដំណាច់ឆ្នាំ២០១៤ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលនាំឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. សម្រាប់ដំណាច់ឆ្នាំដែលបានរាយការណ៍នេះទេ។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការធានាថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវនូវគ្រប់ ទិដ្ឋភាពជាសារវន្តទាំងអស់នៃ ស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

១) អនុវត្តគោលការណ៍គណនេយ្យដែលសមស្រប ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល ហើយបន្ទាប់មក ត្រូវអនុវត្តវាជាប្រចាំ។

២) គោរពតាមតម្រូវការរបស់ CIFRS ក្នុងការលាតត្រដាងព័ត៌មាន ហើយប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឲ្យមានភាពពិត និងត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណយ៉ាងសមស្របនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣) ថែរក្សាបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យ រ.ទ.ស.ភ. អាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលអនុលោមទៅតាម CIFRS និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលមានប្រសិទ្ធភាព។

៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាព លើកលែងតែមានការសន្មតថា រ.ទ.ស.ភ. មិនមានលក្ខណៈសមស្របក្នុងការបន្តប្រតិបត្តិការនៅពេលអនាគតដែលអាចប៉ាន់ស្មានបាន និង

៥) គ្រប់គ្រង និងដឹកនាំ រ.ទ.ស.ភ. ឲ្យមានប្រសិទ្ធភាព ហើយប្រាកដថាការសម្រេចចិត្តលើបញ្ហាសំខាន់ៗទាំងអស់ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ ហើយការចូលរួមរាល់ការសម្រេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលជានាអះអាងថា រ.ទ.ស.ភ. បានអនុវត្តតាមរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ សមាជិកក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ. មានសមាសភាគដូចខាងក្រោម៖

| | | |
|---|---|---|
| ឯកឧត្តម | ស៊ឹម ណារ៉ា | តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| ឯកឧត្តម | ម៉ី វ៉ាន់ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ឯកឧត្តម | ឃួង ស្រេង | តំណាងសាលារាជធានីភ្នំពេញ |
| ឯកឧត្តម | ស៊ឹម ស៊ីថា | អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| លោកស្រី | ងិន ចន្ទ្រា | តំណាងបុគ្គលិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| លោក | សេង បូរ៉ា | សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ |
| លោក | ចាង យុនហ្វេង | តំណាងសមាជិកក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ តំណាងវិនិយោគិនសាធារណៈ |

**របាយការណ៍ក្រុមប្រឹក្សាភិបាល**

តាងនាមក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ យើងខ្ញុំសូមជានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយនេះ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**តាងនាមក្រុមប្រឹក្សាភិបាល**

**ឯកឧត្តម ស៊ឹម ស៊ីថា**
អគ្គនាយក

**លោក សេ គឹមលាង**
អគ្គនាយករង និងជាប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

**ឯកឧត្តម ស៊ឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥

# របាយការណ៍សវនករឯករាជ
# ជូនភាគហ៊ុនិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ព្រមទាំងសេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗទៀត។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនូវរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឲ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្ម នៃកម្ពុជា។ ស្តង់ដារទាំងនេះតម្រូវឲ្យយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការសវនកម្ម និងធ្វើសវនម្មដើម្បីទទួលបានការធានាអះអាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

ការធ្វើសវនកម្មរួមមានការអនុវត្តនីតិវិធីដើម្បីទទួលបាននូវភស្តុតាងសវនកម្ម អំពីចំនួនទឹកប្រាក់ និងការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យទៅលើការវិនិច្ឆ័យរបស់សវនករ ដោយរួមបញ្ចូលទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនេះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ រ.ទ.ស.ភ ដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំនីតិវិធីសវនកម្មដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈ ប៉ុន្តែពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ រ.ទ.ស.ភ នោះទេ។ ការធ្វើសវនកម្ម រួមបញ្ចូលទាំងការវាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ដែលគណៈគ្រប់គ្រងបានធ្វើឡើង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

*PricewaterhouseCoopers (Cambodia) Ltd.*
*35 Sihanouk Boulevard, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia*
*T: +855 (0)23 860 606, F: +855(0)23 211 594, www.pwc.com/kh*

pwc

**មតិយោបល់**

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ជ. ក្រុមហ៊ុន PricewaterhouseCoopers(Cambodia) Ltd.

**គុយ លីម**
**នាយក**

ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទៈ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ក- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤)

| | **កំណត់សម្គាល់** | **៣១ ធ្នូ ២០១៤**<br>*ពាន់រៀល*<br>(បានធ្វើសវនកម្ម) | **៣១ ធ្នូ ២០១៣**<br>*ពាន់រៀល*<br>(បានធ្វើសវនកម្ម) |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ង.៦ | ៨៧៤.៧៤២.៦៦៥ | ៨៣៥.៥៥២.៦៩០ |
| ទ្រព្យសកម្មអរូបី | ង.៧ | ២.៨៥៧.៦១៧ | ៣.២៩២.៣៣១ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ង.៩ | ៤៩២.៥៤០ | ៥៧៨.៣២៤ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | ង.១០ | - | ៧.០១៥.០១៣ |
| | | <u>៨៧៨.០៩២.៨២២</u> | <u>៨៤៦.៤៣៨.៣៥៨</u> |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ង.១១ | ៤០.៥០១.៨៦០ | ៣៥.០៨៣.៣៦៣ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ង.១២ | ៣០.៦២៤.៩០៥ | ២៩.៧៧១.០៨៣ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ង.៩ | ៩៧.៣៦៥ | ៨១.៤៧៥ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | ង.១០ | ៥.៤៤០.៦៤៩ | - |
| ពន្ធលើប្រាក់ចំណេញត្រូវទទួល | ង.១៣ | - | ២.៧៥៥.៧០៤ |
| ការវិនិយោគរយៈពេលខ្លី | ង.១៤ | ១៩៦.៣៣១.៣៣១ | ១៧៤.២៧៨.០១៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ង.១៥ | ១៤.៩៦២.១៤១ | ១០.៥៦៨.៧១៥ |
| | | <u>២៨៧.៩៥៨.២៥១</u> | <u>២៥២.៥៣៨.៣៥៨</u> |
| **ទ្រព្យសកម្មសរុប** | | <u>១.១៦៦.០៥១.០៧៣</u> | <u>១.០៩៨.៩៧៦.៧១៦</u> |
| **មូលធន និងបំណុល** | | | |
| **មូលធនរបស់ភាគហ៊ុនិក** | | | |
| មូលធនភាគហ៊ុន | ង.១៦ | ៥៤១.២២៧.២៨២ | ៥៤១.២២៧.២៨២ |
| ទុនបម្រុង | ង.១៧ | ១៤៩.១៩៣.៤៣៧ | ១១៥.៨៦៦.៣២០ |
| ចំណេញរក្សាទុក | | ៤៥.៧៤៧.៩០៩ | ៣៨.០៨៨.០២៨ |
| **មូលធនសរុប** | | <u>៧៣៦.១៦៨.៦២៨</u> | <u>៦៩៥.១៨១.៦៣០</u> |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| កាតព្វកិច្ចសោធននិវត្តន៍ | ង.១៨ | ៣០.២៤៦.១៦០ | ២៨.៣៦២.២២៤ |
| បំណុលពន្ធពន្យារលើប្រាក់ចំណេញ | ង.១៩ | ២៥.៥៧២.៩៦៨ | ២៤.៤៧២.៨២៧ |
| ប្រាក់កម្ចី | ង.២០ | ២៥១.២៥៦.៥១៧ | ២២៨.២៦២.២៤៧ |
| ប្រាក់កក់របស់អតិថិជន | | ៣៦.២៨៣.៨៤៥ | ៣១.២១៥.១៧៣ |
| ប្រាក់ធានាប្រតិបត្តិការ | | ៦៩៥.៥៣០ | - |
| ជំនួយពន្យាពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ង.២១ | ៣២.៥៧០.៩១៨ | ៣៤.៩៣០.៨៩០ |
| | | <u>៣៧៦.៦២៥.៩៣៨</u> | <u>៣៤៧.២៤៣.៣៦១</u> |
| **បំណុលរយៈពេលខ្លី** | | | |
| ប្រាក់កម្ចី | ង.២០ | ២៨.៨៣៧.២៤៩ | ២៦.៦៩១.៨១៧ |
| បំណុលពន្ធលើប្រាក់ចំណេញ | ង.១៣ | ២.៩០៩.២៨៨ | - |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ង.២២ | ២១.៥០៩.៩៧០ | ២៩.៨៥៩.៩០៨ |
| | | <u>៥៣.២៥៦.៥០៧</u> | <u>៥៦.៥៥១.៧២៥</u> |
| **បំណុលសរុប** | | <u>៤២៩.៨៨២.៤៤៥</u> | <u>៤០៣.៧៩៥.០៨៦</u> |
| **មូលធន និង បំណុលសរុប** | | <u>១.១៦៦.០៥១.០៧៣</u> | <u>១.០៩៨.៩៧៦.៧១៦</u> |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី៧៧ ដល់ទំព័រទី១១៥ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបនេះ។

# ក- របាយការណ៍លទ្ធផលលម្អិត (នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤)

| បរិយាយ | កំណត់សម្គាល់ | ៣១ ធ្នូ ២០១៤ ពាន់រៀល (បានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៣ ពាន់រៀល (បានធ្វើសវនកម្ម) |
|---|---|---|---|
| **ចំណូល** | | | |
| ការលក់ | ង.២៣ | ១៤៦.៨៥៧.៣៤៨ | ១៣៦.៣៩៩.៨៤៣ |
| កម្រៃពីសេវាសាងសង់ | ង.២៤ | ២០០.៦៣១ | ៧.២៤៩.៣៩២ |
| ចំណូលផ្សេងៗ | ង.២១ | ៩.៤៨៤.៨៧០ | ៧.៩៣០.៩៧២ |
| | | ១៥៦.៥៤២.៨៤៩ | ១៥១.៥៨០.២០៧ |
| **ចំណាយ** | | | |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | | (៣៤.០៤៣.៧៥៦) | (២៤.៥២៣.៨៦៣) |
| ចំណាយ អគ្គិសនី | | (២៨.៦៤៧.៣៣៤) | (២៧.៤០៦.៣៩៧) |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ | ង.២៥ | (២៤.៥៧០.៣០០) | (១៩.៨៤៧.៨៨៦) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | ង.២៦ | (៤.៦៩១.០៦៣) | (៣.៣១៨.០៩៧) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្តាញទៅតាមគេហដ្ឋាន | ង.២៧ | (៦.៨២៩.៨៦៥) | (៥.៦៦៨.៨៣៨) |
| ចំណាយជួសជុល និងថែទាំ | | (៤.៥៣៦.៧០៨) | (៤.៦៩៣.១២៨) |
| ចំណាយសេវាសាងសង់ | | (៩៤.០៣៤) | (៦.៦៤៩.៥៦៨) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (១០.៦២៦.០១០) | (៦.៦៤៩.៩៦៧) |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ-សុទ្ធ | ង.២៨ | ២.១៤៧.៧៩៩ | (១.២៨៩.៥៣៣) |
| | | (១១១.៨៩១.២៧១) | (១០០.០៤៧.២៧៧) |
| **ចំណេញប្រតិបត្តិការ** | | ៤៤.៦៥១.៥៧៨ | ៥១.៥៣២.៩៣០ |
| ចំណូលការប្រាក់ | | ២៣.០៦៧.៨០២ | ៨.៥៩២.១២២ |
| ចំណាយការប្រាក់ | | (១១.៦៦៣.០៤២) | (១២.០៣៨.២៤៩) |
| ចំណូល/(ចំណាយ) ការប្រាក់-សុទ្ធ | ង.២៩ | ១១.៤០៤.៧៦០ | (៣.៤៤៦.១២៧) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | ៥៦.០៥៦.៣៣៨ | ៤៨.០៨៦.៨០៣ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ង.៣០ | (១០.០៥១.៨១១) | (៩.៣៤១.២៧៤) |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | ៤៦.០០៤.៥២៧ | ៣៨.៧៤៥.៥២៩ |
| **ចំណូលលម្អិតផ្សេងៗ** | | | |
| ខ្ទង់គណនីដែលមិនបានបែងចែកចំណេញ ឬខាត៖ | | | |
| ចំណេញពីការវាយតម្លៃហានិភ័យកាតព្វកិច្ចសោធននិវត្តន៍ | | (២៥៦.៦១៦) | (៦៥៧.៤៩៩) |
| **លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ** | | ៤៥.៧៤៧.៩១១ | ៣៨.០៨៨.០៣០ |
| **ចំណេញរបស់ភាគហ៊ុនិក** | | ៤៦.០០៤.៥២៧ | ៣៨.៧៤៥.៥២៩ |
| **លទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិក** | | ៤៥.៧៤៧.៩១១ | ៣៨.០៨៨.០៣០ |

ចំណេញក្នុង១ភាគហ៊ុន(ជាប្រាក់រៀល) របស់ភាគហ៊ុនិករង្វាករទឹកក្នុងការិយបរិច្ឆេទនេះ មានដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន (basic earnings per share) | ៣១ | ៥២៦,០០ | ៤៣៧,៩៣ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ (diluted earnings per share) | ៣១ | ៥២៦,០០ | ៤៣៧,៩៣ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី៧៧ ដល់ទំព័រទី១១៥ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបនេះ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## គ- របាយការណ៍បម្រែបម្រួលមូលធន (សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤)

### ដែលជារបស់ភាគហ៊ុនិក

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

*(បានធ្វើសវនកម្ម)*

| | មូលធនភាគហ៊ុន<br>*ពាន់រៀល* | ទុនបម្រុង<br>*ពាន់រៀល* | ចំណេញរក្សាទុក<br>*ពាន់រៀល* | សរុប<br>*ពាន់រៀល* |
|---|---|---|---|---|
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ | ៥៤១.២២៧.២៨២ | ៨៣.៨៥៤.៥១៤ | ៣៤.៤២០.៩៦១ | ៦៥៩.៥០២.៧៥៧ |
| ចំណេញក្នុងឆ្នាំ | - | - | ៣៨.៧៤៥.៥២៩ | ៣៨.៧៤៥.៥២៩ |
| ការខាតដែលបណ្តាលមកពីការវាយតម្លៃ | | | | |
| ហានិភ័យកាតព្វកិច្ចសោធននិវត្តន៍ | - | - | (៦៥៧.៤៩៩) | (៦៥៧.៤៩៩) |
| លទ្ធផលលម្អិតសរុប | - | - | ៣៨.០៨៨.០៣០ | ៣៨.០៨៨.០៣០ |
| ការផ្ទេរទៅគណនីមូលធនភាគហ៊ុន(កំណត់សម្គាល់ ង.១៧) | - | ៣២.០១១.៨០៦ | (៣២.០១១.៨០៦) | - |
| ភាគលាភបានបង់(កំណត់សម្គាល់ ង.១៧) | - | - | (២.៤០៩.១៥៧) | (២.៤០៩.១៥៧) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ | ៥៤១.២២៧.២៨២ | ១១៥.៨៦៦.៣២០ | ៣៨.០៨៨.០២៨ | ៦៩៥.១៨១.៦៣០ |

### ដែលជារបស់ភាគហ៊ុនិក

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

*(បានធ្វើសវនកម្ម)*

| | មូលធនភាគហ៊ុន<br>*ពាន់រៀល* | ទុនបម្រុង<br>*ពាន់រៀល* | ចំណេញរក្សាទុក<br>*ពាន់រៀល* | សរុប<br>*ពាន់រៀល* |
|---|---|---|---|---|
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ | ៥៤១.២២៧.២៨២ | ១១៥.៨៦៦.៣២០ | ៣៨.០៨៨.០២៨ | ៦៩៥.១៨១.៦៣០ |
| ចំណេញក្នុងឆ្នាំ | - | - | ៤៦.០០៤.៥២៧ | ៤៦.០០៤.៥២៧ |
| ការខាតដែលបណ្តាលមកពីការវាយតម្លៃ | | | | |
| ហានិភ័យកាតព្វកិច្ចសោធននិវត្តន៍ | - | - | (២៥៦.៦១៦) | (២៥៦.៦១៦) |
| លទ្ធផលលម្អិតសរុប | - | - | ៤៥.៧៤៧.៩១១ | ៤៥.៧៤៧.៩១១ |
| ការផ្ទេរទៅគណនីមូលធនភាគហ៊ុន(កំណត់សម្គាល់ ង.១៧) | - | ៣៣.៣២៧.១១៧ | (៣៣.៣២៧.១១៧) | - |
| ភាគលាភបានបង់(កំណត់សម្គាល់ ង.១៧) | - | - | (៤.៧៦០.៩១៣) | (៤.៧៦០.៩១៣) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | ៥៤១.២២៧.២៨២ | ១៤៩.១៩៣.៤៣៧ | ៤៥.៧៤៧.៩០៩ | ៧៣៦.១៦៨.៦២៨ |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី៧៧ ដល់ទំព័រទី១១៥ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបនេះ។

# ឃ- របាយការណ៍លំហូរសាច់ប្រាក់ (នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤)

| | កំណត់សម្គាល់ | ៣១ ធ្នូ ២០១៤ *ពាន់រៀល* (បានធ្វើសវនកម្ម) | ៣១ ធ្នូ ២០១៣ *ពាន់រៀល* (បានធ្វើសវនកម្ម) |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| សាច់ប្រាក់បានពីប្រតិបត្តិការ | ង.៣២ | ៨៨.៣៥៧.៨០៤ | ៨២.៣៤១.៦៧១ |
| ពន្ធលើប្រាក់ចំណេញបានបង់ | ង.១៣ | (៣.២៨៦.៦៧៨) | (៦.៨១១.៣៧៥) |
| កាតព្វកិច្ចសោធននិវត្តន៍បានបង់ | ង.១៨ | (៨៦៦.៦៤៨) | (៦៨៩.៨០១) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ** | | **៨៤.២០៤.៤៧៨** | **៧៤.៨៤០.៤៩៥** |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ង.៦ | (៨៦.៥៦៩.១៨១) | (៨៦.៩៣៧.៨៦៥) |
| ការធ្វើមូលធនកម្មការប្រាក់ចំណាយលើការសាងសង់ | ង.៦ | (៣៦៧.៦៤៩) | (៣.១៧៦.៦៨២) |
| ការទិញទ្រព្យសកម្មអរូបី | ង.៧ | (៨៤៩.៩៩៥) | (២.៤៨៣.០០២) |
| ទឹកប្រាក់សំណងពីឥណទានផ្ដល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ៨២.៣៨៤ | ៣៦.០៩១ |
| ការវិនិយោគរយៈពេលខ្លី | ង.១៤ | (២២.០៥៣.៣១៣) | (២៦.២៦៩.៣៩៩) |
| ការប្រាក់បានទទួល | | ៨.៦៦៩.៩៤៩ | ៦.៧៨៥.៩១២ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | **(១០១.០៨៧.៨០៥)** | **(១១២.០៤៤.៩៤៥)** |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភបានបង់ | | (៤.៧៦០.៩១៣) | (២.៤០៩.១៥៧) |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ៦២.៥៨៥.៧៦៦ | ៥៥.៤៥២.៨៨០ |
| ការប្រាក់បានបង់ | | (១២.៥២៦.២០៣) | (៥.៦៦៧.១៩៤) |
| ការបង់សងប្រាក់កម្ចី | | (២៤.០២១.៨៩៣) | (១៣.៥៧៩.៤០១) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន** | | **២១.២៧៦.៧៥៣** | **៣៣.៧៩៧.១២៨** |
| **កំណើន/(តំហយ) សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ៤.៣៩៣.៤២៦ | (៣.៤០៧.៣២២) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ១០.៥៦៨.៧១៥ | ១៣.៩៧៦.០៣៧ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ង.១៥ | **១៤.៩៦២.១៤១** | **១០.៥៦៨.៧១៥** |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយពីទំព័រទី៧៧ ដល់ទំព័រទី១១៥ ជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបនេះ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤)

### ង.១- ព័ត៌មានទូទៅ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា"រ.ទ.ស.ភ.") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ. ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច និងមានលេខ ចុះបញ្ជី Co.០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

បេសកម្មរបស់ រ.ទ.ស.ភ. គឺការផលិត និងការចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ។ កម្មវត្ថុអាជីវកម្មរបស់ រ.ទ.ស.ភ. គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការជួសជុល និងថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ។
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើនផលិតកម្ម-សេវាកម្ម និងធានាគុណភាពទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវ-ការសម្រាប់ជីវភាពរស់នៅ អាជីវកម្ម-សេវាកម្ម និងឧស្សាហកម្ម។
- ធ្វើអាជីវកម្ម-សេវាកម្ម និងការងារផ្សេងៗទៀតដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោមតាមច្បាប់។
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ. ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ធានាឲ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម។

ដើម្បីបំពេញបេសកកម្មនេះ រ.ទ.ស.ភ. ត្រូវបានអនុញ្ញាតឲ្យអនុវត្តសកម្មភាពប្រតិបត្តិការលើទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ព្រមទាំង ប្រតិបត្តិការពាណិជ្ជកម្ម និងហិរញ្ញវត្ថុចាំបាច់ផ្សេងទៀត ដូចជា៖

- ការផលិត និងការចែកចាយទឹកស្អាតនៅរាជធានីភ្នំពេញទាំងមូល និងនៅតាមតំបន់ជាយក្រុង
- ការពង្រីក ការកែលម្អ និងការស្តារនីតិសម្បទាប្រព័ន្ធផលិតកម្ម និងបណ្តាញចែកចាយនិង
- ប្រកបអាជីវកម្មលើបណ្តាញចែកចាយទឹកដែលមានស្រាប់ និងបណ្តាញចែកចាយទឹកនាពេលអនាគត។

ការិយាល័យចុះបញ្ជីរបស់ រ.ទ.ស.ភ. មានទីតាំងស្ថិតនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេបត្រូវបានក្រុមប្រឹក្សាភិបាលអនុម័តឲ្យចេញផ្សាយនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។

ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាសង្ខេប ត្រូវបានត្រួតពិនិត្យ ប៉ុន្តែមិនត្រូវបានធ្វើសវនកម្មទេ។

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

#### ង.២.១- មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នាគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. ដែលបានបង្ហាញជាប្រាក់រៀល ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS")។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាម CIFRS តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗមួយចំនួន ហើយក៏តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យនេះដែរ។ ផ្នែកដែលទាក់ទងទៅនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ង.៤។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ង.២.២- ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ

ង.២.២.១- ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយដែលបានចេញ ផ្សាយរួច ដែលចូលជាធរមានសម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដែល រ.ទ.ស.ភ. បានអនុវត្តមានដូចខាងក្រោម៖

រ.ទ.ស.ភ. បានប្រើប្រាស់ស្តង់ដារ វិសោធនកម្ម និងបំណកស្រាយរបស់ CIFRS ដែលចូលជាធរមានទាំងអស់ ដែលត្រូវអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤។ មិនមានស្តង់ដារគណនេយ្យ វិសោធនកម្ម ឬបំណកស្រាយ ដែលមានផលប៉ះពាល់ជាសារវន្តលើ រ.ទ.ស.ភ. ទេ។

ង.២.២.២- ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយ ដែលចូលជាធរមានសម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដែល រ.ទ.ស.ភ. មិនទាន់បានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ មិនមានស្តង់ដារគណនេយ្យ វិសោធនកម្ម ឬបំណកស្រាយ ដែលមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. ទេ លើកលែងតែស្តង់ដារមួយចំនួនដូចខាងក្រោម៖

- CIFRS 7 *ស្តីពី* "ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ" ស្តង់ដារនេះមានវិសោធនកម្មចំនួនពីរ៖

- កិច្ចសន្យាសេវាកម្ម

ប្រសិនបើអង្គភាពមួយផ្ទេរទ្រព្យសកម្មហិរញ្ញវត្ថុទៅឲ្យភាគីទីបី ក្រោមលក្ខខណ្ឌដែលអនុញ្ញាតឲ្យភាគី អ្នកផ្ទេរឈប់កត់ត្រាទ្រព្យសកម្ម CIFRS 7 តម្រូវឲ្យលាតត្រដាងនូវរាល់ទំនាក់ទំនងបន្តគ្រប់ប្រភេទទាំងអស់ ដែលអង្គភាពនោះអាចនៅមានចំពោះទ្រព្យសកម្មដែលបានផ្ទេរ។ ស្តង់ដារនេះផ្តល់នូវគោលការណ៍ណែនាំអំពីអត្ថន័យរបស់ "ទំនាក់ទំនងបន្ត (continuing involvement)"។ វិសោធនកម្មនេះគឺសម្រាប់ពេលអនាគត ប៉ុន្តែក៏មានជម្រើសអាចអនុវត្តត្រលប់ក្រោយបានដែរ។ ជាលទ្ធផលមានវិសោធនកម្មបន្ទាប់មួយទៀតលើ CIFRS 1 ដែលផ្តល់នូវការលើកលែងដូចគ្នា ចំពោះអ្នកអនុវត្តស្តង់ដារនេះលើកដំបូង។

- របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា

វិសោធនកម្មបញ្ជាក់ថាការលាតត្រដាងបន្ថែម ដែលតម្រូវដោយវិសោធនកម្ម CIFRS 7 ស្តីពី "ការលាតត្រដាងពីការកាត់កងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ" គឺមិនមានតម្រូវការដាក់លាក់ឲ្យអនុវត្តចំពោះការិយបរិច្ឆេទក្នុងគ្រាទាំងអស់ទេ លើកលែងតែមានការតម្រូវរបស់ CIAS 34។ វិសោធនកម្មនេះ តម្រូវឲ្យអនុវត្តត្រលប់ក្រោយ។ រ.ទ.ស.ភ. មិនទាន់បានវាយតម្លៃផលប៉ះពាល់ទាំងស្រុងរបស់ CIFRS 7 នៅឡើយទេ។

- CIAS 19 ស្តីពី "អត្ថប្រយោជន៍បុគ្គលិក"

វិសោធនកម្មបញ្ជាក់ថា នៅពេលកំណត់អត្រាអប្បហារសម្រាប់កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកក្រោយពេលឈប់ពីការងារ កត្តាដែលសំខាន់ជាងគេគឺអាស្រ័យលើរូបិយវត្ថុដែលកត់ត្រាបំណុលនោះ មិនមែនអាស្រ័យលើប្រទេសដែលអនុវត្តគោលការណ៍នេះនោះទេ។ ការវាយតម្លៃថាតើមាន ឬគ្មានទីផ្សារក្នុងសញ្ញាបណ្ណសាជីវកម្មដែលមានគុណភាពខ្ពស់ គឺអាស្រ័យទៅលើសញ្ញាបណ្ណសាជីវកម្មជារូបិយវត្ថុណាមួយ មិនមែនអាស្រ័យលើសញ្ញាបណ្ណសាជីវកម្មក្នុងប្រទេសណាមួយនោះទេ។ ស្រដៀងគ្នានេះដែរ ប្រសិនបើមិនមានសញ្ញាបណ្ណសាជីវកម្មដែលមានគុណភាពខ្ពស់ជារូបិយវត្ថុណាមួយ គេគួរតែប្រើប្រាស់សញ្ញាបណ្ណរដ្ឋជារូបិយប័ណ្ណ ពាក់ព័ន្ធណាមួយជំនួសវិញ។ វិសោធនកម្មនេះត្រូវបានអនុវត្តត្រលប់ក្រោយ ប៉ុន្តែត្រូវបានកម្រិតនៅត្រឹមការចាប់ផ្តើមការិយបរិច្ឆេទដំបូងបំផុតដែលបានបង្ហាញ។ រ.ទ.ស.ភ. មិនទាន់បានវាយតម្លៃផលប៉ះពាល់ទាំងស្រុងរបស់ CIAS 19 នៅឡើយទេ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.២- ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយផ្សេងៗ (ត)

ង.២.២.២- ស្តង់ដារគណនេយ្យថ្មី ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម និងបំណកស្រាយ ដែលចូលជាធរមានសម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ ដែល រ.ទ.ស.ភ. មិនទាន់បានអនុវត្តក្នុងការរៀបចំរបាយ-ការណ៍ហិរញ្ញវត្ថុ។ មិនមានស្តង់ដារគណនេយ្យ វិសោធនកម្ម ឬបំណកស្រាយ ដែលមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. ទេ លើកលែងតែស្តង់ដារមួយចំនួនដូចខាងក្រោម៖

- CIAS 34 ស្តីពី "របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា"

វិសោធនកម្មបញ្ជាក់អំពីអត្ថន័យនៃការយោងក្នុងស្តង់ដារទៅនឹង "ព័ត៌មានដែលបានលាតត្រដាងនៅកន្លែងដទៃទៀតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា"។ វិសោធនកម្មនេះក៏បានកែប្រែ CIAS 34 ដោយតម្រូវឲ្យមានការយោងពីរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ទៅនឹងទីតាំងរបស់ព័ត៌មាននោះ។ វិសោធនកម្មនេះតម្រូវឲ្យអនុវត្តត្រលប់ក្រោយ។ រ.ទ.ស.ភ. មិនទាន់បានវាយតម្លៃផលប៉ះពាល់ទាំងស្រុងរបស់ CIAS 34 នៅឡើយទេ។

- CIFRS 9 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ"

ស្តង់ដារនេះបញ្ជាក់ពីការធ្វើចំណាត់ថ្នាក់ ការវាស់វែង និងការកត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ CIFRS 9 ត្រូវបានចេញផ្សាយនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ និងខែតុលា ឆ្នាំ២០១០។ ស្តង់ដារនេះជំនួសផ្នែកខ្លះនៃស្តង់ដារ CIAS 39 ស្តីពី "ការកត់ត្រា និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ" ដែលពាក់ព័ន្ធទៅនឹងការចាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ។ CIFRS 9 តម្រូវឲ្យចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុជាពីរចំណាត់ថ្នាក់វាស់វែងដូចតទៅ៖ គឺចាត់ថ្នាក់តាមក្រុមដែលវាស់វែងតាមតម្លៃសមស្រប និងក្រុមវាស់វែងតាមថ្លៃដើមដករំលស់។ ការកំណត់គឺត្រូវធ្វើឡើងនៅក្នុងការកត់ត្រាបឋម។ ការធ្វើចំណាត់ថ្នាក់គឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់អង្គភាព ក្នុងការគ្រប់គ្រងឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន និងលក្ខណៈនៃលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យានៃឧបករណ៍នោះ។ ចំពោះបំណុលហិរញ្ញវត្ថុវិញ ស្តង់ដារនេះនៅរក្សាតម្រូវការភាគច្រើនរបស់ CIAS 39។ ការកែប្រែចម្បងគឺក្នុងករណីដែលតម្លៃសមស្របត្រូវជ្រើសរើសយកមកប្រើសម្រាប់បំណុលហិរញ្ញវត្ថុ ផ្នែកនៃការផ្លាស់ប្តូរតម្លៃសមស្រប ហានិភ័យឥណទានផ្ទាល់របស់អង្គភាព ត្រូវកត់ត្រានៅក្នុងចំណូលលម្អិតផ្សេងៗ ជាជាងនៅក្នុងចំណេញ-ខាត លុះត្រាតែវាបង្កើតឲ្យមានភាពមិនស៊ីសង្វាក់គ្នាផ្នែកគណនេយ្យ។ បច្ចុប្បន្ននេះគណៈគ្រប់គ្រង កំពុងតែធ្វើការវាយតម្លៃអំពីផលប៉ះពាល់ នៃការអនុវត្តស្តង់ដារនេះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### ង.២.៣- ការរាយការណ៍តាមផ្នែក

ផ្នែកប្រតិបត្តិការត្រូវបានរាយការណ៍ក្នុងបែបបទដែលស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍ផ្ទៃក្នុង ដែលបានផ្តល់ជូនប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃពីលទ្ធផលនៃប្រតិបត្តិការតាមផ្នែក ត្រូវបានកំណត់ថាជាក្រុមគណៈគ្រប់គ្រង (រាប់ទាំងអគ្គនាយក និងអគ្គនាយករងទាំងអស់) ដែលធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រ។

### ង.២.៤- ការប្តូររូបិយប័ណ្ណ

- រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែល រ.ទ.ស.ភ. ធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ រ.ទ.ស.ភ. រក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោលរបស់ រ.ទ.ស.ភ.។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀល ដែលជារូបិយប័ណ្ណសម្រាប់បង្ហាញរបស់ រ.ទ.ស.ភ.។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.៤- ការប្តូររូបិយប័ណ្ណ (ត)

- **ប្រតិបត្តិការ និងសមតុល្យ**

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជារូបិយប័ណ្ណគោល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល តាមអត្រានាដំណាច់ឆ្នាំ ត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។ ខាតនិងចំណេញពីការប្តូររូបិយប័ណ្ណដែលពាក់ព័ន្ធនឹងគណនីសាច់ប្រាក់និងសាច់ប្រាក់សមមូល និងគណនីប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ ក្រោមខ្ទង់ "ខាតពីការប្តូររូបិយប័ណ្ណ-សុទ្ធ" និងខ្ទង់ "ចំណូលការប្រាក់ និងចំណាយការប្រាក់"។

### ង.២.៥- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានរាយការណ៍តាមថ្លៃដើម ឬតាមចំនួនដែលបានព្រមព្រៀងគ្នាជាបឋម (នៅពេលផ្ទេរពីរាជរដ្ឋាភិបាលកម្ពុជាមក) ដករំលស់បង្គរ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យសម្បត្តិទាំងអស់នោះ។

ចំណាយបន្តបន្ទាប់មកទៀតត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម ឬត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារនោះ នឹងហូរចូលមកក្នុង រ.ទ.ស.ភ. ហើយចំណាយទាំងនោះអាចត្រូវបានវាស់វែងយ៉ាងគួរឲ្យជឿជាក់ប៉ុណ្ណោះ។ តម្លៃយោងនៃផ្នែកដែលត្រូវបានជំនួសឡើងវិញ ត្រូវបានឈប់កត់ត្រា។ ចំណាយទៅលើរាល់ការជួសជុល និងថែទាំផ្សេងៗ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗក្នុងឆ្នាំដែលប្រតិបត្តិការនោះបាន កើតឡើង។

ដីធ្លី មិនត្រូវបានគេធ្វើរំលស់ទេ។ រំលស់លើទ្រព្យសកម្មផ្សេងៗ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីជម្រុះចោលថ្លៃដើមនៃទ្រព្យសកម្ម ឲ្យនៅត្រឹមតម្លៃសំណល់របស់វា លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន ដូចខាងក្រោម៖

| | |
|---|---|
| សំណង់លើដីកាន់កាប់ | ៥០ឆ្នាំ |
| គ្រឿងយន្ត | ១០,១៥ និង២០ឆ្នាំ |
| បំពង់បង្ហូរទឹក | ១៥,៣៥,៤០ និង៥០ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | ៧ ឆ្នាំ |
| បរិក្ខារមន្ទីរពិសោធន៍ | ៧ ឆ្នាំ |
| រ៉ាន និងឧបករណ៍ប្រើប្រាស់ផ្សេងៗ | ៧ ឆ្នាំ |
| មធ្យោបាយដឹកជញ្ជូន | ៧ ឆ្នាំ |
| បរិក្ខារអគ្គីសនី | ៧ ឆ្នាំ |
| នាឡិកាទឹក | ៥ ឆ្នាំ |

តម្លៃសំណល់និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនិងកែតម្រូវតាមការសមស្រប នៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ។

ចំណេញខាតពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់លក់បានជាមួយនឹងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។

ទ្រព្យសកម្មដែលរំលស់អស់ទាំងស្រុង ត្រូវបានរក្សាទុកក្នុងបញ្ជីគណនេយ្យរហូតដល់ពេលលែងប្រើប្រាស់តទៅទៀត ហើយទ្រព្យសកម្មទាំងនេះមិនត្រូវបានកត់ត្រារំលស់បន្ថែមទៀតទេ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.៦- ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមានកម្មវិធីគណនេយ្យ និងកម្មវិធីបណ្តាញ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងថយចុះតម្លៃបង្គរ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបីទាំងនេះត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញ និងយកកម្មវិធីនោះមកប្រើប្រាស់។ ទ្រព្យសកម្មអរូបីត្រូវបានធ្វើរំលស់ដោយវិធីសាស្ត្ររំលស់ថេរ លើអាយុកាលប្រើប្រាស់របស់វាក្នុងរយៈពេល៧ឆ្នាំ។

### ង.២.៧- ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មរបស់ រ.ទ.ស.ភ. ដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរាល់ការថយចុះតម្លៃ នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈនានា ចង្អុលបង្ហាញថាតម្លៃយោងនឹងមិនអាចស្រង់មកវិញបាន។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមតម្លៃយោងរបស់ទ្រព្យសកម្ម ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងគេ រវាងតម្លៃសមស្របនៃទ្រព្យសកម្ម ដកចំណាយលើការលក់ និងតម្លៃនៅអាចប្រើប្រាស់បានរបស់វា។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់ដោយឡែករបស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់)។ ការថយចុះតម្លៃនៃទ្រព្យសកម្មត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុក្រៅពីកេរ្តិ៍ឈ្មោះអាជីវកម្មដែលមានការថយចុះតម្លៃ ត្រូវបានត្រួតពិនិត្យដើម្បីរកមើលលទ្ធភាពក្នុងការកត់ត្រាការថយចុះតម្លៃត្រលប់ទៅវិញ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។

### ង.២.៨- ទ្រព្យសកម្មហិរញ្ញវត្ថុ

ការធ្វើចំណាត់ថ្នាក់៖ ឥណទាន និងគណនីត្រូវទទួលគឺជាទ្រព្យសកម្មហិរញ្ញវត្ថុមិននិទស្សន៍ ដែលមានកាលកំណត់សងប្រាក់ថេរ ឬអាចកំណត់បាន ហើយមិនបានដាក់លក់នៅលើទីផ្សារសកម្មទេ។ ទ្រព្យសកម្មទាំងនេះត្រូវបានបញ្ចូលទៅក្នុងគណនីទ្រព្យសកម្មរយៈពេលខ្លី លើកលែងតែទ្រព្យសកម្មទាំងឡាយណាដែលមានកាលកំណត់លើសពី១២ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ នោះវាត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលវែង។ ថ្នាក់ឥណទាន និងគណនីត្រូវទទួលរួមមាន "ឥណទានត្រូវទទួល" "គណនីអតិថិជនពាណិជ្ជកម្ម" និង "គណនីសាច់ប្រាក់និងសាច់ប្រាក់សមមូល" នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (កំណត់សម្គាល់ ង.២.៩, ង.២.១១ និងង.២.១២)។

### ង.២.៩- ឥណទានត្រូវទទួល

គណនីឥណទានត្រូវទទួលត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប កាត់កងនឹងចំណាយប្រតិបត្តិការ ប្រសិនបើមាន ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ដែលមានប្រសិទ្ធភាព ដកសំវិធានធនសម្រាប់ការថយចុះតម្លៃ។

### ង.២.១០- សន្និធិ

សន្និធិត្រូវបានកត់ត្រាតាមតម្លៃមួយណាដែលទាបជាងគេ (ថ្លៃដើមក្នុងការទិញ និងថ្លៃដើមផ្សេងៗទៀតក្នុងការនាំយកសន្និធិនោះមកកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា) ធៀបនឹងតម្លៃសុទ្ធដែលអាចលក់បាន។ តម្លៃសុទ្ធដែលអាចលក់បានគឺជាតម្លៃលក់ប៉ាន់ស្មាននៅក្នុងដំណើរការអាជីវកម្មធម្មតា ដកចំណាយក្នុងការលក់ផ្សេងៗ។

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.១០- សន្និធិ (ត)

សន្និធិរួមមាន វត្ថុធាតុដើម វត្ថុប្រើប្រាស់ គ្រឿងបន្លាស់ និងសន្និធិដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាតដទៃទៀត ត្រូវបានវាយតម្លៃតាមថ្លៃដើមជាក់ស្តែង ក្នុងការយកសន្និធិនោះមកប្រើប្រាស់ទៅតាមគោលបំណងដែលបានគ្រោងទុក ដកសំវិធានធនសម្រាប់សន្និធិខូចខាត សន្និធិប្រើប្រាស់លែងបាន និងសន្និធិដែលមានចលនាយឺតយ៉ាវ ដោយប្រើមូលដ្ឋានមធ្យមភាគ។ គ្រឿបន្លាស់ និងសន្និធិដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ដែលមានអាយុកាលប្រើប្រាស់លើសពី១ឆ្នាំ ត្រូវបានធ្វើមូលធនកម្មជាទ្រព្យសម្បត្តិរោងចក្រ និងបរិក្ខារ ក្នុងពេលយកវាមកប្រើប្រាស់។

### ង.២.១១- គណនីអតិថិជនពាណិជ្ជកម្ម

គណនីអតិថិជនពាណិជ្ជកម្ម គឺជាទឹកប្រាក់ជំពាក់ដោយអតិថិជននៅតាមផ្ទះ អតិថិជនប្រើប្រាស់ក្នុងលក្ខណៈអាជីវកម្ម និងគ្រឹះស្ថានរដ្ឋ។ ប្រសិនបើ រ.ទ.ស.ភ រំពឹងថានឹងប្រមូលប្រាក់បានក្នុងរយៈពេលមួយឆ្នាំ ឬតិចជាង គណនីអតិថិជនពាណិជ្ជកម្មនោះត្រូវបានកត់ត្រាជាគណនីអតិថិជនពាណិជ្ជកម្មរយៈពេលខ្លី។ ប្រសិនបើលើសពីមួយឆ្នាំ វាត្រូវបានចាត់ទុកជាគណនីអតិថិជនពាណិជ្ជកម្មរយៈពេលវែង។

គណនីអតិថិជនពាណិជ្ជកម្ម ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ដែលមានប្រសិទ្ធភាព ដកសំវិធានធនសម្រាប់ការថយចុះតម្លៃ។

### ង.២.១២- សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ សាច់ប្រាក់នៅធនាគារ ការវិនិយោគរយៈពេលខ្លី និងការវិនិយោគដែលអាចបង្វិលទៅជាសាច់ប្រាក់បានភ្លាមៗ ដែលមានអាយុកាលបីខែ ឬក៏តិចជាង។

### ង.២.១៣- ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

រ.ទ.ស.ភ វាយតម្លៃនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីរកមើលថាតើមានភស្តុតាងជាក់ស្តែងបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុទោល ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុមមានការថយចុះតម្លៃដែរឬទេ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ទោល ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុមមានការថយចុះតម្លៃ ហើយការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រូវបានកើតឡើងតែក្នុងករណីដែលមានភស្តុតាងជាក់ស្តែងអំពីការថយចុះតម្លៃ ដែលជាលទ្ធផលនៃព្រឹត្តិការណ៍មួយឬច្រើនបានកើតឡើងបន្ទាប់ពីការកត់ត្រាទ្រព្យសកម្មដំបូង("ព្រឹត្តិការណ៍ខាតបង់") ហើយព្រឹត្តិការណ៍ខាតបង់នោះ (ឬព្រឹត្តិការណ៍ច្រើន) មានផលប៉ះពាល់លើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតនៃទ្រព្យសកម្មហិរញ្ញវត្ថុទោល ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុម ដែលអាចប៉ាន់ស្មានគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។

ភស្តុតាងនៃការថយចុះតម្លៃអាចរាប់បញ្ចូលនូវសញ្ញាណនានា ដែលកូនបំណុលឬក្រុមកូនបំណុលកំពុងតែជួបប្រទះផលវិបាកផ្នែកហិរញ្ញវត្ថុជាសារវន្ត ការខកខានមិនបានសងបំណុល ឬការសងបំណុលយឺតយ៉ាវ ទាំងការសងប្រាក់ដើមនិងការប្រាក់ កម្រិតដែលកូនបំណុលទាំងនោះនឹងក្ស័យធន ឬការរៀបចំរចនាសម្ព័ន្ធផ្នែកហិរញ្ញវត្ថុឡើងវិញ និងនៅពេលដែលមានទិន្នន័យដែលអាចសង្កេតបាន ចង្អុលបង្ហាញថាមានតំហយចុះដែលអាចវាស់វែងបានក្នុងលំហូរសាច់ប្រាក់ ប៉ាន់ស្មាននាពេលអនាគត ដូចជាការប្រែប្រួលក្នុងការសងបំណុល ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលមានការពាក់ព័ន្ធជាមួយនឹងការខកខានក្នុងការសងប្រាក់ជាដើម។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.១៣- ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ចំពោះគណនីឥណទាននិងគណនីអតិថិជន ចំនួននៃការខាតបង់ត្រូវបានវាស់វែងទៅតាមតម្លៃលម្អៀង រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត (មិនរាប់បញ្ចូលការខាតពីឥណទាននាពេលអនាគតដែលមិនទាន់បានកើតឡើង) ដោយធ្វើអប្បហារតាមអត្រាការប្រាក់មានប្រសិទ្ធភាពដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ តម្លៃយោងរបស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយ ហើយចំនួននៃការខាតត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។ ប្រសិនបើនៅពេលក្រោយមកទៀត ចំនួននៃការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃមានការថយចុះ ហើយការថយចុះនោះអាចពាក់ព័ន្ធយ៉ាងជាក់ស្តែងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីកត់ត្រាការថយចុះតម្លៃរួចហើយ (ដូចជាការកែលម្អអត្រាឥណទានរបស់កូនបំណុល) ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃដែលបានទទួលស្គាល់រួចហើយ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។

### ង.២.១៤- មូលធនភាគហ៊ុន

ភាគហ៊ុនធម្មតាត្រូវបានចាត់ថ្នាក់ជាមូលធន។

ចំណាយបន្ថែមដែលទាក់ទិនទៅនឹងការចេញផ្សាយភាគហ៊ុនថ្មី ត្រូវបានបង្ហាញនៅក្នុងគណនីមូលធន ចាត់ទុកជាការកាត់បន្ថយពីសាច់ប្រាក់ទទួលបានបន្ទាប់ពីកាត់កងជាមួយពន្ធ។

### ង.២.១៥- គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម

គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្មជាកាតព្វកិច្ចបង់ប្រាក់សម្រាប់ការទិញទំនិញ ឬសេវាកម្មផ្សេងៗពីអ្នកផ្គត់ផ្គង់ ក្នុងដំណើរការអាជីវកម្មធម្មតា។ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្មត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី ប្រសិនបើការសងប្រាក់ត្រូវផុតកំណត់ក្នុងរយៈពេល១ឆ្នាំ ឬតិចជាង។ ប្រសិនបើលើសពី១ឆ្នាំ វាត្រូវបានចាត់ទុកជាបំណុលរយៈពេលវែង។

គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

### ង.២.១៦- ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការដែលបានកើតឡើង ហើយបន្ទាប់មកវាត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់ ហើយភាពលម្អៀងរវាងសាច់ប្រាក់ (ដកចំណាយប្រតិបត្តិការ) និងតម្លៃដែលត្រូវបង្វិលសងវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ លើរយៈពេលនៃប្រាក់កម្ចី ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធិភាព។

ប្រាក់កម្ចីត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី លើកលែងតែ រ.ទ.ស.ភ. មានសិទ្ធិដោយឥតលក្ខខណ្ឌក្នុងការពន្យារការទូទាត់បំណុល យ៉ាងហោចណាស់១២ខែ បន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ង.២.១៧- បន្ទុកប្រាក់កម្ចី

បន្ទុកប្រាក់កម្ចីជាក់លាក់និងទូទៅដែលបានចំណាយផ្ទាល់ក្នុងការទិញ ការសាងសង់ ហើយជាទ្រព្យសកម្មដែលត្រូវចំណាយពេលវេលាចាំបាច់សម្រាប់បញ្ចប់ ដើម្បីអាចប្រើប្រាស់តាមការគ្រោងទុករបស់គេ ឬសម្រាប់លក់ ត្រូវបានកត់ត្រាបន្ថែមទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ពេលទ្រព្យសកម្មនោះ មានភាពរួចរាល់សម្រាប់ការប្រើប្រាស់ ឬសម្រាប់លក់បាន។

បន្ទុកប្រាក់កម្ចីផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ ក្នុងការិយបរិច្ឆេទដែលវាកើតឡើង។

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.១៨- ប្រាក់កក់របស់អតិថិជន

មុនពេលតភ្ជាប់បណ្តាញ រ.ទ.ស.ភ បានប្រមូលប្រាក់កក់ពីអតិថិជន អាស្រ័យទៅតាមទំហំនាឡិកាទឹក ហើយត្រូវបានកត់ត្រាក្នុងគណនីប្រាក់កក់របស់អតិថិជនទៅតាមចំនួនដែលទទួលបាន ក្រោមខ្ទង់បំណុលរយៈពេលវែង។

### ង.២.១៩- ពន្ធលើប្រាក់ចំណេញក្នុងគ្រា និងពន្ធពន្យារលើប្រាក់ចំណេញ

ចំណាយពន្ធប្រចាំការិយបរិច្ឆេទ រួមមានពន្ធលើប្រាក់ចំណេញក្នុងគ្រា និងពន្ធពន្យារលើប្រាក់ចំណេញ។ ពន្ធត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ លើកលែងតែពន្ធនោះទាក់ទិននឹងគណនីមួយចំនួនដែលបានកត់ត្រាក្នុងគណនីចំណូលលម្អិតផ្សេងៗ ឬកត់ត្រាដោយផ្ទាល់ក្នុងគណនីមូលធន។ ក្នុងករណីនេះ ពន្ធត្រូវបានកត់ត្រាក្នុងគណនី ចំណូលលម្អិតផ្សេងៗ ឬកត់ត្រាដោយផ្ទាល់ក្នុងគណនីមូលធន។

ចំណាយពន្ធលើប្រាក់ចំណេញក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធដែលបានអនុម័តជាស្ថាពរ ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ជាកន្លែងដែល រ.ទ.ស.ភ បង្កើតប្រាក់ចំណេញជាប់ពន្ធ។ គណៈគ្រប់គ្រងវាយតម្លៃពីមួយគ្រាទៅមួយគ្រាអំពីស្ថានភាព ដែលបានកត់ត្រានៅក្នុងលិខិតប្រកាសពន្ធ ទាក់ទិនទៅនឹងសភាពការណ៍ផ្សេងៗដែលបទប្បញ្ញត្តិពន្ធត្រូវធ្វើបំណកស្រាយ។ រ.ទ.ស.ភ កត់ត្រាសំវិធានធនតាមការសមស្រប ដោយផ្អែកលើមូលដ្ឋាននៃចំនួនដែលរំពឹងថានឹងត្រូវបង់ជូនអគ្គនាយកដ្ឋានពន្ធដារ។

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានកត់ត្រាតាមលម្អៀងបណ្តោះអាសន្ន ដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារលើប្រាក់ចំណេញត្រូវកំណត់ដោយប្រើអត្រាពន្ធដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងត្រូវបានរំពឹងថានឹងត្រូវអនុវត្ត នៅពេលដែលពន្ធពន្យារលើប្រាក់ចំណេញពាក់ព័ន្ធត្រូវទទួលបាន ឬនៅពេលដែលបំណុលពន្ធពន្យារលើប្រាក់ចំណេញត្រូវទូទាត់។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់ទូទាត់ជាមួយនឹងលម្អៀងបណ្តោះអាសន្នបាន។

### ង.២.២០- អត្ថប្រយោជន៍បុគ្គលិក

(ក) **កាតព្វកិច្ចរយៈពេលខ្លី**

បំណុលសម្រាប់ប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍ រួមទាំងអត្ថប្រយោជន៍មិនមែនសាច់ប្រាក់ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ និងច្បាប់សម្រាកឈឺបង្ករ ដែលរំពឹងថានឹងត្រូវទូទាត់ក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ការិយបរិច្ឆេទដែលបុគ្គលិកបានបម្រើការងារ រហូតដល់ដំណាច់ការិយបរិច្ឆេទរាយការណ៍ ហើយត្រូវបានវាស់វែងទៅតាមចំនួនដែលរំពឹងថាត្រូវបង់នៅពេលទូទាត់បំណុល។ បំណុលសម្រាប់អត្ថប្រយោជន៍រយៈពេលខ្លីត្រូវបានកត់ត្រាក្នុងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ។

(ខ) **កាតព្វកិច្ចសោធននិវត្តន៍**

រ.ទ.ស.ភ. ប្រតិបត្តិគម្រោងសោធននិវត្តន៍ដែលជាគម្រោងអត្ថប្រយោជន៍កំណត់ ដែលភាគីទាំងពីរ គឺភាគី រ.ទ.ស.ភ. និងភាគីបុគ្គលិក ត្រូវបង់វិភាគទានថេរចូលទៅក្នុងគណនីសាច់ប្រាក់ផ្ទៃក្នុង ក្រោមឈ្មោះរបស់ រ.ទ.ស.ភ ៖

- វិភាគទានរបស់បុគ្គលិក ៧% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់ពួកគេ (៦% មុនខែតុលា ឆ្នាំ២០០៧)
- វិភាគទានរបស់ រ.ទ.ស.ភ ៥% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក បូកបន្ថែម២% នៃប្រាក់ចំណេញប្រចាំឆ្នាំ

-ចាប់ពីឆ្នាំ២០១១ រ.ទ.ស.ភ បានផ្ទេរទឹកប្រាក់បន្ថែមចូលទៅក្នុងគណនីសាច់ប្រាក់ផ្ទៃក្នុងដើម្បីឲ្យចំនួនទឹកប្រាក់ទាំងអស់ដែលបានផ្ទេរទៅក្នុងគណនីសាច់ប្រាក់ផ្ទៃក្នុង ដែលបម្រុងទុកសម្រាប់ទូទាត់អត្ថប្រយោជន៍បុគ្គលិក សមមាត្រទៅនឹងចំណាយសរុបដែលបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗក្នុងឆ្នាំ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.២០- អត្ថប្រយោជន៍បុគ្គលិក (ត)

ការបង់ជូនបុគ្គលិកដែលមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍នេះ ផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម៖

- បុគ្គលិកដែលបានបម្រើការងារពី១០ឆ្នាំ ទៅ១៩ឆ្នាំ រហូតដល់អាយុចូលនិវត្តរបស់ពួកគេ នឹងត្រូវទទួលបានការទូទាត់កាតព្វកិច្ចសោធននិវត្តន៍មួយដង គឺស្មើនឹង២០០% នៃចំណែកវិភាគទានសោធននិវត្តន៍បង្គររបស់ពួកគេ។
- បុគ្គលិកដែលបានបម្រើការងារលើសពី២០ឆ្នាំ រហូតដល់អាយុចូលនិវត្តរបស់ពួកគេ នឹងត្រូវទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែ ស្មើនឹង២៩% នៃប្រាក់បៀវត្សរ៍ចុងក្រោយរបស់ពួកគេ និង១% បន្ថែមទៀតក្នុងមួយឆ្នាំ នៅពេលដែលពួកគេបានបំពេញការងារចាប់ពីឆ្នាំទី២១ រហូតដល់ពួកគេទទួលមរណភាព។

បុគ្គលិកដែលបានលាឈប់មុនអាយុចូលនិវត្ត នឹងត្រូវទទួលបានការទូទាត់មួយដង ដូចខាងក្រោម៖

i) ១២០%នៃវិភាគទានបង្គររបស់ពួកគេ ចំពោះបុគ្គលិកទាំងឡាយណា ដែលបានបម្រើការងាររយៈពេល១០ឆ្នាំ និង១%រៀងរាល់ឆ្នាំបន្ថែមទៀតនៃវិភាគទានបង្គររបស់ពួកគេ ក្នុងចន្លោះពីឆ្នាំទី១១ រហូតដល់ឆ្នាំទី២០។

ii) ១៣៥% នៃវិភាគទានបង្គររបស់ពួកគេ ចំពោះបុគ្គលិកទាំងឡាយណា ដែលបានបម្រើការងាររយៈពេល២១ឆ្នាំ និង១%រៀងរាល់ឆ្នាំបន្ថែមទៀតនៃវិភាគទានបង្គររបស់ពួកគេ ក្នុងចន្លោះពីឆ្នាំទី២២ រហូតដល់ឆ្នាំទី៣០។

iii) ១៥៥%នៃវិភាគទានបង្គររបស់ពួកគេ ចំពោះបុគ្គលិកទាំងឡាយណាដែលបានបម្រើការងាររយៈពេល៣១ឆ្នាំ និង១%រៀងរាល់ឆ្នាំបន្ថែមទៀតនៃវិភាគទានបង្គររបស់ពួកគេ បន្ទាប់ពីឆ្នាំទី៣១។

បំណុលដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ទាក់ទងនឹងគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ គឺជាតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ដែលបានកំណត់ គិតត្រឹមដំណាច់ការិយបរិច្ឆេទរាយការណ៍ ដកតម្លៃសមស្របនៃទ្រព្យតម្កល់។ កាតព្វកិច្ចសោធននិវត្តន៍ត្រូវបានគណនាដោយប្រើវិធីសាស្ត្រ projected unit credit។ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ត្រូវបានកំណត់ដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាការប្រាក់តម្កល់មធ្យមនៃមូលនិធិដែលបានផ្ញើនៅធនាគារ ដែលបម្រុងទុកសម្រាប់បង់អត្ថប្រយោជន៍សោធននិវត្តន៍ នាកាលបរិច្ឆេទវាយតម្លៃ ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណសាជីវកម្មដែលមានគុណភាពខ្ពស់ និងមិនមានសញ្ញាប័ណ្ណរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។ ចំណេញ និងខាតពីការគណនាហានិភ័យដែលកើតពីនិយ័តកម្ម និងបម្រែបម្រួលក្នុងការសន្មតការគណនាហានិភ័យត្រូវបានកត់ត្រាជាបន្ទុក ឬកត់ត្រាខាងឥណទានក្នុងគណនីចំណូលលម្អិតផ្សេងៗ ក្នុងការិយបរិច្ឆេទដែលវាកើតឡើង។ ថ្លៃដើមសេវាកម្មក្នុងអតីតកាលត្រូវបានកត់ត្រាភ្លាមក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។

(គ) គម្រោងប្រាក់រង្វាន់

រ.ទ.ស.ភ. កត់ត្រាបំណុល និងចំណាយសម្រាប់ប្រាក់រង្វាន់ ដោយអាស្រ័យទៅតាមប្រាក់ចំណេញរបស់ខ្លួនប្រចាំឆ្នាំនីមួយៗ តាមរូបមន្តដូចខាងក្រោម៖

- ប្រាក់បៀវត្សរ៍១ខែសម្រាប់បុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធពី ៥% ទៅ ១០% នៃចំណាយប្រតិបត្តិការ
- ប្រាក់បៀវត្សរ៍២ខែសម្រាប់បុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធលើសពី១០% ទៅ ២០% នៃចំណាយប្រតិបត្តិការ
- ប្រាក់បៀវត្សរ៍៣ខែសម្រាប់បុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធលើសពី ២០% នៃចំណាយប្រតិបត្តិការ។

ជាធម្មតា ការផ្តល់ប្រាក់រង្វាន់នេះត្រូវធ្វើឡើងក្នុងខែមេសា ឬឧសភា ក្នុងឆ្នាំបន្ទាប់។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ង.២.២១- សំវិធានធន និងបំណុលយថាភាព

សំវិធានធនត្រូវបានកត់ត្រានៅពេលដែល រ.ទ.ស.ភ. មានកាតព្វកិច្ចតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ចប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាតម្រូវឲ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចទាំងនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានគួរឲ្យជឿជាក់បាន។ សំវិធានធនមិនត្រូវបានកត់ត្រាសម្រាប់ការខាតបង់ពីប្រតិបត្តិការនាពេលអនាគតទេ។ សំវិធានធនត្រូវបានវាស់វែងតាមចំណាយរំពឹងទុកដើម្បីទូទាត់កាតព្វកិច្ច។ ប្រសិនបើតម្លៃពេលវេលានៃទឹកប្រាក់ មានចំនួនជាសារវន្ត នោះសំវិធានធនត្រូវវាស់វែងតាមតម្លៃបច្ចុប្បន្នរបស់វា ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងអំពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននូវតម្លៃពេលវេលានៃទឹកប្រាក់ និងហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ចទាំងនោះ។ កំណើនសំវិធានធនដោយសារពេលវេលាកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។ បំណុលយថាភាពគឺជាកាតព្វកិច្ចមួយដែលអាចកើតឡើងពីព្រឹត្តិការណ៍អតីតកាល ហើយបំណុលនោះនឹងត្រូវបញ្ជាក់ដោយ ភាពកើតមាន ឬមិនកើតមាននៃហេតុការណ៍មិនពិតប្រាកដនាពេលអនាគតមួយ ឬច្រើន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រង ទាំងស្រុងរបស់ រ.ទ.ស.ភ.។ បំណុលយថាភាពក៏អាចជាកាតព្វកិច្ចនាពេលបច្ចុប្បន្ន ដែលកើតមកពី ព្រឹត្តិការណ៍អតីតកាល ដែលមិនទាន់បានកត់ត្រា ដោយសារមិនមានភាពប្រាកដថានឹងមានលំហូរធនធានសេដ្ឋកិច្ចចេញ ឬចំនួននៃកាតព្វកិច្ចនោះមិនអាច វាស់វែងគួរឲ្យជឿជាក់បាន។ បំណុលយថាភាពមិនត្រូវបានកត់ត្រាទេ ប៉ុន្តែវាត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ របាយការណ៍ហិរញ្ញវត្ថុ។ នៅពេលមានបម្រែបម្រួលនៃលំហូរចេញអាចកើតមានឡើង ហើយលំហូរចេញនោះមានភាពប្រាកដប្រជា បំណុលយថាភាពនឹងត្រូវបានកត់ត្រាជាសំវិធានធន។

### ង.២.២២- ការទទួលស្គាល់ប្រាក់ចំណូល

ប្រាក់ចំណូលត្រូវបានវាស់វែងតាមតម្លៃសមស្របនៃគណនីអតិថិជនដែលបានទទួល ឬត្រូវទទួល ហើយប្រាក់ចំណូលនេះគឺជាចំនួនគណនីអតិថិជនសម្រាប់ការផ្គត់ផ្គង់ទំនិញ ដែលបានរាយការណ៍តាមចំនួនសុទ្ធកាត់កងនឹងអប្បហារការបង្វិលសងវិញ និងអាករលើតម្លៃបន្ថែម។ ប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ចប្រាកដជាហូរចូលមកក្នុង រ.ទ.ស.ភ. ហើយប្រាក់ចំណូលនោះអាចត្រូវបានវាស់វែងយ៉ាងគួរឲ្យទុកចិត្តបាន។ លក្ខណៈវិនិច្ឆ័យជាក់លាក់ក្នុងការកត់ត្រាដូចខាងក្រោមនេះ ត្រូវតែបំពេញឲ្យបានមុនពេលប្រាក់ចំណូលត្រូវបានទទួលស្គាល់៖

ការលក់ទឹកស្អាត

ប្រាក់ចំណូលដែលទទួលបានពីការផ្គត់ផ្គង់ទឹកស្អាត ត្រូវបានរាយការណ៍តាមតម្លៃទទួលបានសុទ្ធ ក្រោយកាត់កងជាមួយនឹងអប្បហារ វិភាជន៍ និងឥណទាន ហើយត្រូវបានទទួលស្គាល់តាមបរិមាណទឹកដែលបានផ្គត់ផ្គង់ជូនអតិថិជនរបស់ រ.ទ.ស.ភ. ។

ប្រាក់ចំណូលបានមកពីការតភ្ជាប់បណ្តាញទឹកជូនអតិថិជនតាមផ្ទះ

ប្រាក់ចំណូលបានមកពីការតភ្ជាប់បណ្តាញទឹក ជូនអតិថិជនតាមផ្ទះ ត្រូវបានទទួលស្គាល់នៅពេលបញ្ចប់ការតបណ្តាញទឹកនោះ។

ថ្លៃផ្លាស់ប្តូរនាឡិកាទឹក

រ.ទ.ស.ភ. គិតថ្លៃ ៥០រៀលក្នុង១មីលីម៉ែត្រក្នុងមួយខែនៃទំហំនាឡិកាពីអតិថិជន សម្រាប់ការថែទាំនាឡិកាទឹក នៅក្នុងវដ្តនៃការគិតប្រាក់ ហើយត្រូវបានកត់ត្រាជាប្រាក់ចំណូល។ ការគិតប្រាក់នេះត្រូវបានប្រើសម្រាប់ចំណាយក្នុងការផ្លាស់ប្តូរនាឡិកាទឹកនៅពេលប្រើប្រាស់លែងកើត។ ចំណាយត្រូវបានកត់ត្រាជាបន្ទុក ក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២- សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

#### ង.២.២២- ការទទួលស្គាល់ប្រាក់ចំណូល (ត)

កម្រៃពីសេវាសាងសង់

ចំណូលនៃកម្រៃពីសេវាសាងសង់ ត្រូវបានកត់ត្រាដោយផ្អែកទៅតាមភាគរយដែលបានបញ្ចប់សេវានោះ ក្នុងរយៈពេលនៃកិច្ចសន្យាសាងសង់ ប្រហាក់ប្រហែលនឹងសេវាដែលបានបំពេញ។

#### ង.២.២៣- ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាតនិងចំណូលលម្អិតផ្សេងៗ តាមមូលដ្ឋានសមាមាត្រពេលវេលា ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

#### ង.២.២៤- ជំនួយពន្យារ និងរំលស់

ជំនួយដែលបានមកពីរដ្ឋាភិបាល និងពីទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗត្រូវបានកត់ត្រាតាមតម្លៃកំណត់ ដែលមានការធានាសមហេតុផលថាជាជំនួយនឹងត្រូវបានទទួល ហើយ រ.ទ.ស.ភ. នឹងអនុវត្តទៅតាមលក្ខខណ្ឌទាំងអស់ដែលមានភ្ជាប់នឹងជំនួយនោះ។ ជំនួយត្រូវបានពន្យារ និងកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាតនិងចំណូលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទចាំបាច់ ដើម្បីធ្វើឲ្យមានសមាមាត្រទៅនឹងថ្លៃដើមដែលនឹងត្រូវទូទាត់។

ជំនួយពន្យារដែលទាក់ទិននឹងថ្លៃដើមរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ផ្តល់ដោយម្ចាស់ជំនួយ ត្រូវបានកត់ត្រាតាមថ្លៃដើមនៅពេលទទួលបាន។ ជំនួយពន្យារត្រូវបានចាត់ថ្នាក់នៅក្រោមបំណុលរយៈពេលវែង និងត្រូវបានកត់ត្រាខាងខ្ចង់ឥណទាននៅក្នុងរបាយការណ៍ចំណេញ-ខាតនិងចំណូលលម្អិតផ្សេងៗ តាមមូលដ្ឋានថេរ ដើម្បីផ្គូរផ្គងនឹងអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មនោះ។

អត្ថប្រយោជន៍នៃឥណទានរបស់រដ្ឋាភិបាលតាមអត្រាប្តូររូបិយប័ណ្ណក្រោមតម្លៃទីផ្សារ ត្រូវបានចាត់ទុកជាអំណោយរបស់រដ្ឋាភិបាល មានដូចជាបម្រែបម្រួលដែលមានអំណោយផលល្អ រវាងតម្លៃរូបិយប័ណ្ណរបស់ឥណទាន (សិទ្ធិក្នុងការដកប្រាក់ជាពិសេស "SDR") និងរូបិយប័ណ្ណទូទាត់សងវិញរបស់ រ.ទ.ស.ភ. ជាប្រាក់រៀល។-

#### ង.២.២៥- ការបែងចែកភាគលាភ

ការបែងចែកភាគលាភជូនភាគហ៊ុនិករបស់ រ.ទ.ស.ភ. ត្រូវបានកត់ត្រាជាបំណុលក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. ក្នុងការិយបរិច្ឆេទដែលក្រុមប្រឹក្សាភិបាលបានអនុម័តភាគលាភនោះ។

### ង.៣- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

#### ង.៣.១- កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ

រ.ទ.ស.ភ. ត្រូវប្រឈមមុខនឹងហានិភ័យអត្រាការប្រាក់ ហានិភ័យឥណទាន ហានិភ័យការប្តូររូបិយប័ណ្ណ និងហានិភ័យសន្ទនីយ។ រ.ទ.ស.ភ. គ្រប់គ្រង និងសន្ទតហានិភ័យទាំងនេះ ដោយការតាមដានអត្រាការប្រាក់លើទីផ្សារ ប្រវត្តិឥណទាននៃភាគីដៃគូរបស់ខ្លួន អត្រាប្តូររូបិយប័ណ្ណ និងលំហូរសាច់ប្រាក់។ បច្ចុប្បន្ននេះ រ.ទ.ស.ភ. មិនបានប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ (derivative financial instruments) ដើម្បីការពារហានិភ័យអត្រាការប្រាក់ និងហានិភ័យការប្តូររូបិយប័ណ្ណរបស់ខ្លួននោះទេ។

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៣- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ង.៣.១- កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

*(ក) ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់គឺជាហានិភ័យដែលបម្រែបម្រួលការប្រាក់លើទីផ្សារនាពេលអនាគត នឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ រ.ទ.ស.ភ.។ ហានិភ័យអត្រាការប្រាក់ពាក់ព័ន្ធជាចម្បងទៅនឹង គណនីប្រាក់កម្ចី ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ និងការវិនិយោគរយៈពេលខ្លី។

ហានិភ័យអត្រាការប្រាក់របស់ រ.ទ.ស.ភ. កើតឡើងពីប្រាក់កម្ចីរយៈពេលវែង។ ប្រាក់កម្ចីដែល រ.ទ.ស.ភ. បានខ្ចីក្នុងអត្រាការប្រាក់អថេរ បណ្តាលឲ្យមានហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់របស់ រ.ទ.ស.ភ។ ប្រាក់កម្ចីដែលមានការប្រាក់ថេរ នឹងធ្វើឲ្យ រ.ទ.ស.ភ មានហានិភ័យអត្រាការប្រាក់លើតម្លៃសមស្រប។

ហានិភ័យចម្បងនៃប្រាក់កម្ចីរបស់ រ.ទ.ស.ភ. ចំពោះហានិភ័យអត្រាការប្រាក់នៃលំហូរសាច់ប្រាក់ កើតឡើងតាមរយៈប្រាក់កម្ចីលេខ CKH ១០៧៥ ០៣S ពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AfD) (អត្រាការប្រាក់អថេរ) និងចំពោះហានិភ័យអត្រាការប្រាក់នៃតម្លៃសមស្រប កើតឡើងតាមរយៈប្រាក់កម្ចីលេខ CKH ៦០០០ ០១G ពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AfD) និងប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់ឲ្យតាមរយៈកម្ចីពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន (JICA) និងពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) (អត្រាការប្រាក់ថេរ) (កំណត់សម្គាល់២០)។

រ.ទ.ស.ភ មិនមានការផ្តោះប្តូរអត្រាការប្រាក់ ឬការការពារផ្សេងទៀតទេ (Swaps or other hedges) ដោយសារគណៈគ្រប់គ្រងជឿជាក់ថា ហានិភ័យអត្រាការប្រាក់នឹងមិនមានឥទ្ធិពលជាសារវន្តនោះទេ។

រ.ទ.ស.ភ បានធ្វើការពិចារណាទៅលើបម្រែបម្រួលនៅក្នុងអត្រាការប្រាក់លើរយៈពេលបីឆ្នាំ និងបានសន្និដ្ឋានថា បម្រែបម្រួល ១% គឺមានលក្ខណៈសមហេតុផល។

ប្រសិនបើអត្រាការប្រាក់នៃប្រាក់កម្ចីដែលមានអត្រាការប្រាក់អថេរមានអត្រាកើនឡើង ឬថយចុះ ១% ហើយរាល់ជាតុអថេរផ្សេងៗទៀត មានភាពមិនប្រែប្រួល នោះប្រាក់ចំណេញប្រចាំឆ្នាំក្រោយបង់ពន្ធអាចថយចុះ ឬកើនឡើង ៥៣០.៣០១.៣៧២ រៀល (២០១៣ ៖ ៦៨០.៩៩៩.៨៤៨ រៀល)។

រ.ទ.ស.ភ. បានរក្សាអត្រាការប្រាក់ថេរលើវិនិយោគរយៈពេលខ្លី និងឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់។ ការធ្វើបែបនេះមានភាពស៊ីសង្វាក់គ្នាជាមួយប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពី AfD (លេខ CKH៦០០០ ០១G) ដែលមានអត្រាការប្រាក់ថេរដែរ។

*(ខ) ហានិភ័យការប្តូររូបិយប័ណ្ណ*

រ.ទ.ស.ភ. ប្រឈមមុខនឹងហានិភ័យការប្តូររូបិយប័ណ្ណ ក្នុងនោះរូបិយប័ណ្ណចម្បងគេគឺប្រាក់អឺរ៉ូ និងប្រាក់ដុល្លារអាមេរិក ដោយសារប្រាក់កម្ចីពី AfD គឺទទួលបានជាប្រាក់អឺរ៉ូ និងប្រាក់កម្ចីពី JICA គឺទទួលបានជាប្រាក់ដុល្លារអាមេរិក ហើយត្រូវបានធ្វើការទូទាត់សងវិញជាប្រាក់ដុល្លារអាមេរិក ក៏ប៉ុន្តែ រ.ទ.ស.ភ កត់ត្រាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ដែលជារូបិយប័ណ្ណគោល។ ដើម្បីការពារ រ.ទ.ស.ភ. ពីការប្រឈមមុខធ្ងន់ធ្ងរចំពោះហានិភ័យនៃការប្តូររូបិយប័ណ្ណ គណៈគ្រប់គ្រងបានប្តូរសាច់ប្រាក់ និងសាច់ប្រាក់សមមូលមួយផ្នែកទៅជាប្រាក់ដុល្លារអាមេរិក (ដែលប្រើប្រាស់ច្រើននៅកម្ពុជា) ហើយរក្សាផ្នែកនៅសល់ជាប្រាក់រៀល សំរាប់តម្រូវការទុនបង្វិលរបស់ខ្លួន។

ខាងក្រោម គឺបង្ហាញពីភាពប្រែប្រួលចំពោះអត្រាប្តូរប្រាក់ដុល្លារអាមេរិក និងឧបករណ៍ហិរញ្ញវត្ថុប្រាក់អឺរ៉ូ។ រូបិយ-ប័ណ្ណទាំងពីរនេះ គឺជារូបិយប័ណ្ណចម្បងដែលជាឧបករណ៍ហិរញ្ញវត្ថុ ដែល រ.ទ.ស.ភ. បានកំណត់។ រ.ទ.ស.ភ. បានពិចារណាទៅលើបម្រែបម្រួលក្នុងរូបិយប័ណ្ណលើរយៈពេលបីឆ្នាំ និងបានសន្និដ្ឋានថា អត្រាបម្រែបម្រួល ៥% និង ៣% សម្រាប់ប្រាក់អឺរ៉ូ និងប្រាក់ដុល្លារអាមេរិក គឺមានភាពសមហេតុផល។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៣- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ង.៣.១- កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

**(ខ) ហានិភ័យការប្តូររូបិយប័ណ្ណ "ត"**

ប្រសិនបើប្រាក់អឺរ៉ូធ្លាក់ចុះឬកើនឡើង៥%ធៀបនឹងប្រាក់រៀល នោះប្រាក់ចំណេញប្រចាំឆ្នាំក្រោយបង់ពន្ធនឹងត្រូវកើនឡើង ឬថយចុះ ៥,៥៣ន់លានរៀល (២០១៣ ៖ ៤,៩៣ន់លានរៀល) ដែលជាលទ្ធផលបណ្តាលមកពីចំណេញ/ខាតពីការប្តូរប្រាក់កម្ចី ដែលទទួលបានជាប្រាក់អឺរ៉ូ។

ប្រសិនបើប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ ឬកើនឡើង ៣% ធៀបនឹងប្រាក់រៀល នោះប្រាក់ចំណេញប្រចាំឆ្នាំក្រោយបង់ពន្ធនឹងត្រូវកើនឡើង ឬថយចុះ ២,៧៣ន់លានរៀល (២០១៣ ៖ ២,៤៣ន់លានរៀល) ដែលជាលទ្ធផលបណ្តាលមកពីចំណេញ/ខាតពីការប្តូរប្រាក់កម្ចីដែលទទួលបានជាប្រាក់ដុល្លារអាមេរិក។

**(គ) ហានិភ័យឥណទាន**

រ.ទ.ស.ភ. ប្រឈមមុខនឹងហានិភ័យឥណទាន ដែលពាក់ព័ន្ធជាចម្បងទៅនឹងគណនីអតិថិជនពាណិជ្ជកម្ម សាច់ប្រាក់នៅធនាគារ វិនិយោគទុនរយៈពេលខ្លី ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ និងឥណទានផ្តល់ឲ្យបុគ្គលិក។

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជនពាណិជ្ជកម្ម រ.ទ.ស.ភ. តម្រូវឲ្យអតិថិជនតម្កល់ប្រាក់កក់មុននឹងតភ្ជាប់បណ្តាញជូន។ ចំពោះគ្រឹះស្ថានរដ្ឋ មិនតម្រូវឲ្យមានប្រាក់កក់ទេ ដោយសារ រ.ទ.ស.ភ ជឿជាក់ថា ខ្លួនអាចប្រមូលប្រាក់ពីស្ថាប័នទាំងនោះតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ដែលជាប្រភពហិរញ្ញវត្ថុនៃគ្រឹះស្ថានរដ្ឋទាំងនោះ) ជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ. និងក៏ជាម្ចាស់ភាគហ៊ុនផងដែរ។ គោលការណ៍កាត់កងប្រាក់កក់ ត្រូវបានអនុវត្តទៅលើអតិថិជនដែលមិនបានទូទាត់សងបំណុលរបស់ពួកគេទៅតាមខសន្យា និងលក្ខខណ្ឌនៃកិច្ចសន្យាជាវទឹក។

ហានិភ័យឥណទានអតិបរមារបស់ រ.ទ.ស.ភ. ចំពោះគណនីអតិថិជនពាណិជ្ជកម្ម ត្រូវបានកំណត់ឲ្យនៅត្រឹមតម្លៃយោងនៃគណនីអតិថិជននោះ ដកសំវិធានធនគណនីអតិថិជនសង្ស័យប៉ាន់ស្មាន ផ្អែកតាមការត្រួតពិនិត្យលើចំនួនដែលនៅមិនទាន់ទូទាត់នាដំណាច់ឆ្នាំ។ ការប្រមូលប្រាក់ពីអតិថិជនតាមផ្ទះ និងអតិថិជនជាលក្ខណៈអាជីវកម្មមានរយៈពេល១ខែ និងចំពោះគ្រឹះស្ថានរដ្ឋមានរយៈពេល១ឆ្នាំ។

ដើម្បីកាត់បន្ថយហានិភ័យឥណទាននៃសាច់ប្រាក់នៅធនាគារ និងវិនិយោគរយៈពេលខ្លី (ប្រាក់បញ្ញើមានកាលកំណត់នៅធនាគារ) រ.ទ.ស.ភ. បានបែងចែកការផ្ញើប្រាក់បញ្ញើទាំងនេះនៅធនាគារផ្សេងៗគ្នា និងជ្រើសរើសតែធនាគារធំៗក្នុងស្រុកមួយចំនួនដែលមានឈ្មោះល្បី និងកំពុងធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។

រដ្ឋាករទឹកខេត្តពោធិ៍សាត់គឺជាភាគីពាក់ព័ន្ធរបស់ រ.ទ.ស.ភ. ហើយឥណទានដែល រ.ទ.ស.ភ. បានផ្តល់ឲ្យក៏មិនមានចំនួនធំដុំដែរ ដូចនេះប្រសិនបើមានការមិនសងបំណុល ហានិភ័យឥណទាននៃការខកខានមិនសងបំណុល គឺស្ថិតនៅក្នុងកម្រិតអប្បរមា។

ហានិភ័យអតិបរមារបស់ រ.ទ.ស.ភ. ចំពោះឥណទានផ្តល់ឲ្យបុគ្គលិក សម្រាប់គម្រោងចំណែកភាគហ៊ុនរបស់បុគ្គលិកត្រូវបានកម្រិតឲ្យនៅត្រឹមចំនួនឥណទានដែលបានផ្តល់ឲ្យបុគ្គលិកម្នាក់ៗ។

***(ឃ) ហានិភ័យសន្ទនីយ***

រ.ទ.ស.ភ. ប្រឈមមុខនឹងហានិភ័យសន្ទនីយ ដែលកើតពីការបង្វិលសាច់ប្រាក់ទូទៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ហានិភ័យសន្ទនីយរួមមានហានិភ័យដែលអាចធ្វើឲ្យ រ.ទ.ស.ភ. មិនមានលទ្ធភាពបង្វិលសាច់ប្រាក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួនឲ្យទាន់ពេលវេលា។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.៣- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ង.៣.១- កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ (ត)

***(ឃ) ហានិភ័យសន្ទនីយ (ត)***

| | ក្រោម ១ ឆ្នាំ ពាន់រៀល | ពី ១-២ ឆ្នាំ ពាន់រៀល | ពី ២-៥ ឆ្នាំ ពាន់រៀល | លើសពី ៥ ឆ្នាំ ពាន់រៀល | មិនមាន កាលកំណត់ ពាន់រៀល |
|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | | | | | |
| ប្រាក់កម្ចី | ៣៣.៤២៦.៣៧២ | ៣៦.០០៤.២៩៤ | ៨២.០៣៤.៨២៧ | ១៩៦.៣៧១.៧០៤ | - |
| ប្រាក់កក់របស់អតិថិជន | - | - | - | - | ៣៦.២៨៣.៨៤៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ២២.២០៩.៩២៤ | - | - | - | - |
| | ៥៥.៦៣៦.២៩៦ | ៣៦.០០៤.២៩៤ | ៨២.០៣៤.៨២៧ | ១៩៦.៣៧១.៧០៤ | ៣៦.២៨៣.៨៤៥ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | | | | | |
| ប្រាក់កម្ចី | ៣០.៣៩០.៣៦៤ | ៣៧.០៨៣.៧៨៥ | ១០៦.៣៣៤.៨៤៩ | ១៥៩.៥៨៦.៣៨៥ | - |
| ប្រាក់កក់របស់អតិថិជន | - | - | - | - | ៣១.២១៥.១៧៣ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ២៩.៧៧២.៣៩៤ | - | - | - | - |
| | ៦០.១៦២.៧៥៨ | ៣៧.០៨៣.៧៨៥ | ១០៦.៣៣៤.៨៤៩ | ១៥៩.៥៨៦.៣៨៥ | ៣១.២១៥.១៧៣ |

### ង.៣.២ ការគ្រប់គ្រងហានិភ័យដើមទុន

ទិសដៅរបស់ រ.ទ.ស.ភ. ក្នុងការគ្រប់គ្រងដើមទុន គឺដើម្បីការពារលទ្ធភាពរបស់ខ្លួនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីផ្តល់ផលប្រយោជន៍ជូនភាគហ៊ុនិក និងភាគីពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុត ដើម្បីកាត់បន្ថយចំណាយដើមទុន។

រ.ទ.ស.ភ. មិនមានគោលការណ៍ជាក់លាក់ នៃអនុបាតបំណុលធៀបនឹងដើមទុននោះទេ។ គោលការណ៍របស់ រ.ទ.ស.ភ. គឺរក្សាសាច់ប្រាក់ និងសាច់ប្រាក់សមមូលឲ្យបានគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការរបស់ខ្លួន និងប្រើប្រាស់កញ្ចប់ឥណទានដើម្បីបង់ការចំណាយវិនិយោគ។ រ.ទ.ស.ភ. តាមដានដើមទុន តាមមូលដ្ឋានអនុបាតបំណុលធៀបនឹងដើមទុន។ អនុបាតនេះត្រូវបានគណនាដោយយកបំណុលសុទ្ធ ចែកនឹងដើមទុនសរុប។ បំណុលសុទ្ធ ត្រូវបានគណនាដោយយកប្រាក់កម្ចីសរុប (រាប់ទាំងប្រាក់កម្ចីរយៈពេលខ្លី និងប្រាក់កម្ចីរយៈពេលវែងនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ) ដកនឹងសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី។ ដើមទុនសរុបត្រូវបានគណនាដោយយកមូលធន ដែលបានបង្ហាញនៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ បូកនឹងបំណុលសុទ្ធ។ អនុបាតបំណុលធៀបនឹងដើមទុនមានដូចខាងក្រោម៖

| | ២០១៤ ពាន់រៀល | ២០១៣ ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីសរុប | ២៨០.០៩៣.៧៦៦ | ២៥៤.៩៥៤.០៦៤ |
| ដក៖ សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី | (២១១.២៩៣.៤៧២) | (១៨៤.៨៤៦.៧៣៣) |
| បំណុលសុទ្ធ | ៦៨.៨០០.២៩៤ | ៧០.១០៧.៣៣១ |
| **មូលធនសរុប** | ៧៣៦.១៦៨.៦២៨ | ៦៩៥.១៨១.៦៣០ |
| **ដើមទុនសរុប** | ៨០៤.៩៦៨.៩២២ | ៧៦៥.២៨៨.៩៦១ |
| **អនុបាតបំណុលធៀបនឹងដើមទុន** | ៨,៥៥% | ៩,១៦% |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៣- ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ង.៣.៣- ការប៉ាន់ស្មានតម្លៃសមស្រប

វិធីសាស្រ្ត និងការសន្មត ដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

(ក) សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី - តម្លៃយោងនៃគណនីទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារវាមានរយៈពេលខ្លី។

(ខ) គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់ - តម្លៃយោងដកសំវិធានធនដែលបណ្តាលមកពីការថយចុះតម្លៃ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងមានរយៈពេលខ្លី។

(គ) ប្រាក់កម្ចី - តម្លៃសមស្របនៃប្រាក់កម្ចីត្រូវប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យានាពេលអនាគត ដោយប្រើអត្រាប្រាក់កម្ចីនាដំណាច់ឆ្នាំ។

### ង.៤- ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ រ.ទ.ស.ភ. ធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដោយគិតពីអនាគតកាល។ តាមនិយម-ន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រដូចគ្នានឹងលទ្ធផលពិតជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលមានហានិភ័យធំ អាចបណ្តាលឲ្យមាននិយ័តកម្មជាសារវន្តលើតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានបង្ហាញដូចខាងក្រោម៖

**(ក) ពន្ធ**

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ក៏ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះ មានបំណកស្រាយផ្សេងៗគ្នា ហើយការកំណត់ចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីការធ្វើអធិការកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។

គណៈគ្រប់គ្រងជឿជាក់ថាខ្លួនបានកត់ត្រាសំវិធានធនគ្រប់គ្រាន់សម្រាប់បំណុលពន្ធ ដោយផ្អែកទៅលើបំណកស្រាយរបស់ខ្លួនចំពោះបទប្បញ្ញត្តិពន្ធដារ ក៏ប៉ុន្តែអាជ្ញាធរពាក់ព័ន្ធអាចធ្វើការបកស្រាយខុសគ្នាពីនេះ ហើយផលប៉ះពាល់អាចមានទំហំជាសារវន្ត។

**(ខ) ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ**

គណនេយ្យកម្មនៃគណនីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ គឺទាក់ទិននឹងការប្រើប្រាស់ការប៉ាន់ស្មានក្នុងការកំណត់អាយុកាលប្រើប្រាស់រំពឹងទុក និងតម្លៃសំណល់នៃទ្រព្យសកម្មទាំងនោះ។ ការកំណត់អាយុកាលប្រើប្រាស់ និងតម្លៃសំណល់នៃទ្រព្យសកម្មគឺផ្អែកលើការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង។ ក្នុងការវិនិច្ឆ័យ រ.ទ.ស.ភ. បានវាយតម្លៃលើកត្តាមួយចំនួនក្នុងចំណោមកត្តាជាច្រើនមានដូចជា ការប្រើប្រាស់រំពឹងទុកនៃទ្រព្យសកម្ម ស្ថានភាពសំណឹកជាក់ស្តែងដែលបានគិតទុកជាមុន ដោយអាស្រ័យទៅលើកត្តាប្រតិបត្តិការ និងកត្តាបរិស្ថាន ព្រមទាំងភាពហួសសម័យ ទាំងផ្នែកបច្ចេកទេស និងពាណិជ្ជកម្ម ដែលកើតពីបម្រែបម្រួល ឬការកែលម្អផ្នែកបច្ចេកវិទ្យា។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.៤- ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ (ត)

**(គ) កាតព្វកិច្ចសោធននិវត្តន៍**

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍គឺអាស្រ័យទៅតាមកត្តាមួយចំនួន ដែលត្រូវបានកំណត់តាមមូលដ្ឋានដែលពាក់ព័ន្ធនឹងការគណនាហានិភ័យ ដោយប្រើប្រាស់ការសន្មតមួយចំនួន។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយសុទ្ធសម្រាប់ប្រាក់សោធននិវត្តន៍ រួមមានអត្រាអប្បហារ អត្រាកំណើនប្រាក់បៀវត្សរ៍ អត្រាមរណៈ និងអត្រាបោះបង់ការងារ។ បម្រែបម្រួលណាមួយលើការសន្មតទាំងនេះ នឹងធ្វើឲ្យប៉ះពាល់ដល់តម្លៃយោងរបស់កាតព្វកិច្ចសោធននិវត្តន៍នេះ។

ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណ និងសញ្ញាប័ណ្ណរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា រ.ទ.ស.ភ. បានប្រើប្រាស់អត្រាការប្រាក់តម្កល់មធ្យមនៃមូលនិធិដែលបានផ្ញើនៅធនាគារ ដែលបម្រុងទុកសម្រាប់សោធននិវត្តន៍ ជាអត្រាអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ចេញប៉ាន់ស្មាននាពេលអនាគត ដែលតម្រូវឲ្យមានសម្រាប់ការទូទាត់កាតព្វកិច្ចសោធន-និវត្តន៍។ ព័ត៌មានបន្ថែមទៀតត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ង.១៨។

នៅពេលដែលអត្រាអប្បហារដែលបានប្រើប្រាស់ខុសពីការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ១០% នៃអត្រាបច្ចុប្បន្ននោះតម្លៃយោងនៃកាតព្វកិច្ចសោធននិវត្តន៍ អាចនឹងត្រូវផ្លាស់ប្តូរប្រហាក់ប្រហែលនឹងចំនួនខាងក្រោម៖

| បម្រែបម្រួលនៃអត្រាអប្បហារ | ផលប៉ះពាល់លើកាតព្វកិច្ចសោធននិវត្តន៍ ខ្ពស់ជាង/(ទាបជាង) | |
|---|---|---|
| | ២០១៤ | ២០១៣ |
| | ពាន់រៀល | ពាន់រៀល |
| ទាបជាងអត្រាបច្ចុប្បន្ន ១០% | ១.៩១១.៧៦៦ | ១.៨១១.៥៧៩ |
| ខ្ពស់ជាងអត្រាបច្ចុប្បន្ន ១០% | (១.៧៤៦.៩៦៣) | (១.៦៥៤.៤៣៥) |

**(ឃ) ចំណូលបង្គរក្នុងការលក់ទឹកស្អាត**

ការកត់ត្រាប្រាក់ចំណូលបង្គរក្នុងការលក់ទឹកស្អាត គឺផ្អែកទៅលើបរិមាណទឹកដែលបានផលិត បរិមាណទឹកដែលបានចេញវិក្កយបត្រ ការបាត់បង់ទឹកមធ្យម និងតម្លៃមធ្យមតាមប្រភេទអតិថិជន។ គណៈគ្រប់គ្រងប្រើប្រាស់ស្ថិតិនៃអត្រាបាត់បង់ទឹក និងតម្លៃមធ្យមពីបទពិសោធន៍ក្នុងគ្រាមុន ដែលអាចមិនឆ្លុះបញ្ចាំងយ៉ាងសុក្រឹតអំពីអត្រាជាក់ស្តែង និងស្ថានភាពបច្ចុប្បន្ន។

## ង.៥- ព័ត៌មានប្រតិបត្តិការតាមផ្នែក

រ.ទ.ស.ភ. ផលិតទឹកស្អាតដើម្បីផ្គត់ផ្គង់ជូនប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានី។ ដើម្បីគាំទ្រដល់អាជីវកម្មក្នុងការចែកចាយទឹកស្អាតនេះ រ.ទ.ស.ភ. ត្រូវការភ្ជាប់នាឡិកាទឹកជាសេវាគាំទ្រ។ ប្រាក់ចំណូលដែលបានមកពីការភ្ជាប់នាឡិកាទឹក (ដែលជាសេវាគាំទ្រដល់ការលក់ទឹកស្អាត) មានចំនួនតិចជាង១០%នៃប្រាក់ចំណូលសរុប ចំណែកឯការលក់ទឹកស្អាតមានចំនួនប្រមាណ ៨៨% នៃប្រាក់ចំណូលសរុបរបស់ រ.ទ.ស.ភ.។

រ.ទ.ស.ភ. មានប្រតិបត្តិការតាមផ្នែកតែមួយដែលត្រូវរាយការណ៍គឺ ការលក់ទឹកស្អាត។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការ (ក្រុមគណៈគ្រប់គ្រង) ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងដែលបានរាយការណ៍អំពីលទ្ធផលនៃការលក់ទឹកស្អាតទាំងមូល ដើម្បីវាយតម្លៃអំពីលទ្ធផល និងការបែងចែកធនធាន។ ប្រធានអ្នកសម្រេចចិត្តផ្នែកប្រតិបត្តិការវាយតម្លៃអំពីលទ្ធផលនៃប្រតិបត្តិការតាមផ្នែក ដោយផ្អែកទៅលើទំហំប្រាក់ចំណូលដុល ចំណេញមុនបង់ពន្ធ និងចំណេញសុទ្ធធៀបនឹងការិយបរិច្ឆេទមុនៗ។

ប្រាក់ចំណូលទាំងអស់បានមកពីអតិថិជនខាងក្រៅ។ រ.ទ.ស.ភ. មានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ហើយរាល់ការលក់ទឹកស្អាតទាំងអស់មានប្រភពចេញពីរាជធានីភ្នំពេញ និងតំបន់ជុំវិញ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៦- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីធ្លី<br>ពាន់រៀល | សំណង់<br>លើដីកាន់កាប់<br>ពាន់រៀល | គ្រឿងម៉ាស៊ីន<br>ពាន់រៀល | បំពង់បង្ហូរទឹក<br>ពាន់រៀល | បរិក្ខារ<br>មន្ទីរពិសោធន៍<br>ពាន់រៀល | សង្ហារឹម និង<br>បរិក្ខារការិយាល័យ<br>ពាន់រៀល | បរិក្ខារអគ្គិសនី<br>ពាន់រៀល | យានយន្ត<br>ពាន់រៀល | វ៉ាន និងឧបករណ៍<br>ប្រើប្រាស់ផ្សេងៗ<br>ពាន់រៀល | នាឡិកាទឹក<br>ពាន់រៀល | ការងារកំពុង<br>ដំណើរការ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣** | | | | | | | | | | | | |
| ថ្លៃដើម | ៧៣.៦៤៣.១៨៤ | ១៥៦.៧៤៤.០២២ | ៥៨.៨០០.៩២៧ | ៣៣៥.៥២៤.៥៣១ | ៩១៣.១១៨ | ៧.៦៣៤.៧៨៥ | ៦០.២៧០.៩៥២ | ១៦.៤៦៧.៥៣៣ | ៨.៦០០.៨២៧ | ៤.១៨១.៥៦៥ | ២៣៥.៣៨៤.២១៦ | ៩៥៨.១៦៥.៦៦០ |
| រំលស់បង្គរ | - | (៣២.៧៤០.០០៦) | (២៨.០៩៨.៣៧៣) | (៨៦.៩៩៤.៩៩៨) | (៨១៥.៤០៤) | (៤.៨៧៥.៩៨៤) | (៤៨.៩៩៩.៧១០) | (៧.៧២៦.៨៦០) | (២.៦៤៨.៧៤៦) | (៣.៦០៤.៥៣០) | - | (២១៦.៥០៤.៦១១) |
| តម្លៃចុះបញ្ជីសុទ្ធ | ៧៣.៦៤៣.១៨៤ | ១២៤.០០៤.០១៦ | ៣០.៧០២.៥៥៤ | ២៤៨.៥២៩.៥៣៣ | ៩៧.៧១៤ | ២.៧៥៨.៨០១ | ១១.២៧១.២៤២ | ៨.៧៤០.៦៧៣ | ៥.៩៥២.០៨១ | ៥៧៧.០៣៥ | ២៣៥.៣៨៤.២១៦ | ៧៤១.៦៦១.០៤៩ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៧៣.៦៤៣.១៨៤ | ១២៤.០០៤.០១៦ | ៣០.៧០២.៥៥៤ | ២៤៨.៥២៩.៥៣៣ | ៩៧.៧១៤ | ២.៧៥៨.៨០១ | ១១.២៧១.២៤២ | ៨.៧៤០.៦៧៣ | ៥.៩៥២.០៨១ | ៥៧៧.០៣៥ | ២៣៥.៣៨៤.២១៦ | ៧៤១.៦៦១.០៤៩ |
| ការទិញបន្ថែម | - | ៧១៩.០០២ | ៦៥១.០០២ | - | - | ២.០៣៤.៦៥៤ | ៥.៤៥៧ | ៤.១៨៣.៥២២ | ៧៩៤.៣៣១ | ៣៣៦.៨២៦ | ១០៩.៣២០.៣៦១ | ១១៨.០៤៥.១៥៥ |
| ការផ្ទេរ | - | ៧៨.៦៤៩.៣៥១ | ១១.១៤៤.៨៣០ | ១១២.០១៥.៣៤៤ | - | ១.០១៩.៦៦០ | ៦៦.៦២៩.៩២០ | - | ៣.៤៤៦.១៥២ | ១៨.៧៦៧ | (២៧២.៩២៤.០២៤) | - |
| ការលក់ចេញ | - | (៧០.៧០០) | - | - | - | (១៩.៧៨៥) | - | - | (១១៥) | (៣.៦៦២) | - | (៩៤.២៦២) |
| រំលស់ | - | (៤.១៣៣.៨៩៩) | (៣.១៦៤.៤៨២) | (៨.៩៦២.១៨៧) | (៣៤.៥៦៤) | (៨៦៩.៦៣៦) | (៣.៦៩៣.៣៨៦) | (២.០៨៤.៣៧៨) | (៨៧៥.៣០៣) | (២៤១.៤១៧) | - | (២៤.០៥៩.២៥២) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៧៣.៦៤៣.១៨៤ | ១៩៩.១៦៧.៧៧០ | ៣៩.៣៣៣.៩០៤ | ៣៥១.៥៨២.៦៩០ | ៦៣.១៥០ | ៤.៩២៣.៦៩៤ | ៧៤.២១៣.២៣៣ | ១០.៨៣៩.៨១៧ | ៩.៣១៧.១៤៦ | ៦៨៧.៥៤៩ | ៧១.៧៨០.៥៥៣ | ៨៣៥.៥៥២.៦៩០ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣** | | | | | | | | | | | | |
| ថ្លៃដើម | ៧៣.៦៤៣.១៨៤ | ២៣៦.០៤១.៦៧៥ | ៧០.៥៩៦.៧៥៩ | ៤៤៧.៥៣៩.៨៧៥ | ៩១៣.១១៨ | ១០.៦៦៩.៣១៤ | ១២៦.៩០៦.៣២៩ | ២០.៦៥១.០៥៥ | ១២.៨៤១.១៩៥ | ៤.៥៣៣.៤៩៦ | ៧១.៧៨០.៥៥៣ | ១.០៧៦.១១៦.៥៥៣ |
| រំលស់បង្គរ | - | (៣៦.៨៧៣.៩០៥) | (៣១.២៦២.៨៥៥) | (៩៥.៩៥៧.១៨៥) | (៨៤៩.៩៦៨) | (៥.៧៤៥.៦២០) | (៥២.៦៩៣.០៩៦) | (៩.៨១១.២៣៨) | (៣.៥២៤.០៤៩) | (៣.៨៤៥.៩៤៧) | - | (២៤០.៥៦៣.៨៦៣) |
| តម្លៃចុះបញ្ជីសុទ្ធ | ៧៣.៦៤៣.១៨៤ | ១៩៩.១៦៧.៧៧០ | ៣៩.៣៣៣.៩០៤ | ៣៥១.៥៨២.៦៩០ | ៦៣.១៥០ | ៤.៩២៣.៦៩៤ | ៧៤.២១៣.២៣៣ | ១០.៨៣៩.៨១៧ | ៩.៣១៧.១៤៦ | ៦៨៧.៥៤៩ | ៧១.៧៨០.៥៥៣ | ៨៣៥.៥៥២.៦៩០ |

## ង.៦- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | ដីធ្លី ពាន់រៀល | សំណង់ លើដីកាន់កាប់ ពាន់រៀល | គ្រឿងម៉ាស៊ីន ពាន់រៀល | បំពង់បង្ហូរទឹក ពាន់រៀល | បរិក្ខារ មន្ទីរពិសោធន៍ ពាន់រៀល | សង្ហារឹម និង បរិក្ខារការិយាល័យ ពាន់រៀល | បរិក្ខារអគ្គិសនី ពាន់រៀល | យានយន្ត ពាន់រៀល | វ៉ាន និងឧបករណ៍ ប្រើប្រាស់ផ្សេងៗ ពាន់រៀល | នាឡិកាទឹក ពាន់រៀល | ការងារកំពុង ដំណើរការ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៤** | | | | | | | | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៧៣.៦៤៣.១៨៤ | ១៩៩.១៦៧.៧៧០ | ៣៩.៣៣៣.៩០៤ | ៣៥១.៥៨២.៦៩០ | ៦៣.១៥០ | ៤.៩២៣.៦៩៤ | ៧៤.២១៣.២៣៣ | ១០.៨៣៩.៨១៧ | ៩.៣១៧.១៤៦ | ៦៨៧.៥៤៩ | ៧១.៧៨០.៥៥៣ | ៨៣៥.៥៥២.៦៩០ |
| ការទិញបន្ថែម | - | - | ៩៥១.៣០៧ | - | - | ១.១៦៧.២១៧ | - | ២.៣៧២.៨២០ | ១.៤៥១.២៥៥ | ១៣០.៤២០ | ៧០.៨៩៨.៤១១ | ៧៦.៩៧១.៤៣០ |
| ការផ្ទេរ | - | ៣.០១៨.៥៨៩ | ១៤២.៩៧៥ | ៤៤.១៤៧.៤៧៩ | - | ២១២.១៨៨ | - | ១.៧០២.៣២៩ | ៦៧.៩៩៤ | ៥០.៣៩១ | (៤៩.៣៤១.៩៤៥) | - |
| ការលក់ចេញ | - | (២៨៦.០១២) | (១.៣៥៧) | (១.៧៩៥.៩៧៤) | - | (២.២៩៧) | - | - | - | (១៤.០៥៩) | - | (២.០៩៩.៦៩៩) |
| ការជម្រះចេញពីបញ្ជី | - | - | - | - | - | - | - | - | - | - | (២.៩២២.៧១១) | (២.៩២២.៧១១) |
| រំលស់ | - | (៦.២៩២.៤៥៦) | (៣.៧៨៣.៥០០) | (១១.៥៩៩.០៣៩) | (៣០.៥៥៣) | (១.០៣៤.៤៤០) | (៦.១៨២.៤២០) | (២.៤៤៤.៨៤៨) | (១.១២៤.៦២២) | (២៦៧.១៦៧) | - | (៣២.៧៥៩.០៤៥) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៧៣.៦៤៣.១៨៤ | ១៩៥.៦០៧.៨៩១ | ៣៦.៦៤៣.៣២៩ | ៣៨២.៣៣៥.១៥៦ | ៣២.៥៩៧ | ៥.២៦៦.៣៦២ | ៦៨.០៣០.៨១៣ | ១២.៤៧០.១១៨ | ៩.៧១១.៧៧៣ | ៥៨៧.១៣៤ | ៩០.៤១៤.៣០៨ | ៨៧៤.៧៤២.៦៦៥ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | | | | | | | | | | | | |
| ថ្លៃដើម | ៧៣.៦៤៣.១៨៤ | ២៣៨.៧៧៤.២៥២ | ៧១.៦៨៩.៦៨៤ | ៤៨៩.៨៩១.៣៨០ | ៩១៣.១១៨ | ១២.០៤៦.៤២២ | ១២៦.៩០៦.៣២៩ | ២៤.៧២៦.២០៤ | ១៤.៣៦០.៤៤៤ | ៤.៧០០.២៤៨ | ៩០.៤១៤.៣០៨ | ១.១៤៨.០៦៥.៥៧៣ |
| រំលស់បង្គរ | - | (៤៣.១៦៦.៣៦១) | (៣៥.០៤៦.៣៥៥) | (១០៧.៥៥៦.២២៤) | (៨៨០.៥២១) | (៦.៧៨០.០៦០) | (៥៨.៨៧៥.៥១៦) | (១២.២៥៦.០៨៦) | (៤.៦៤៨.៦៧១) | (៤.១១៣.១១៤) | - | (២៧៣.៣២២.៩០៨) |
| តម្លៃចុះបញ្ជីសុទ្ធ | ៧៣.៦៤៣.១៨៤ | ១៩៥.៦០៧.៨៩១ | ៣៦.៦៤៣.៣២៩ | ៣៨២.៣៣៥.១៥៦ | ៣២.៥៩៧ | ៥.២៦៦.៣៦២ | ៦៨.០៣០.៨១៣ | ១២.៤៧០.១១៨ | ៩.៧១១.៧៧៣ | ៥៨៧.១៣៤ | ៩០.៤១៤.៣០៨ | ៨៧៤.៧៤២.៦៦៥ |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៦- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

ការផ្ទៀងផ្ទាត់ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារបន្ថែម ទៅនឹងលំហូរសាច់ប្រាក់មានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ការទិញបន្ថែម | ៧៦.៩៧១.៤៣០ | ១១៨.០៤៥.១៥៥ |
| កំណើនគណនីផ្គត់ផ្គង់ និងប្រាក់ជានាប្រតិបត្តិការ | ៩.៩៦៥.៤០០ | ១.៦៥៤.១៩២ |
| សាច់ប្រាក់បានប្រើសម្រាប់ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៨៦.៩៣៦.៨៣០ | ១១៩.៦៩៩.៣៤៧ |
| ដក៖ | | |
| ការធ្វើមូលធនកម្មការប្រាក់ចំណាយលើទ្រព្យសកម្ម | (៣៦៧.៦៤៩) | (៣.១៧៦.៦៨២) |
| ជំនួយពន្យាររបស់រដ្ឋាភិបាល និងជំនួយផ្សេងៗ | - | (២៩.៥៨៤.៨០០) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (តាមលំហូរសាច់ប្រាក់) | ៨៦.៥៦៩.១៨១ | ៨៦.៩៣៧.៨៦៥ |

### ង.៧- ទ្រព្យសកម្មអរូបី

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | | |
| ថ្លៃដើម | ៤.៨១៦.៥៩១ | ២.៣៤៦.៧២៤ |
| រំលស់បង្គរ | (១.៥២៤.២៦០) | (១.០៦៤.២៦៩) |
| តម្លៃចុះបញ្ជីសុទ្ធ | ៣.២៩២.៣៣១ | ១.២៨២.៤៥៥ |
| ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ | | |
| សមតុល្យដើមគ្រា | ៣.២៩២.៣៣១ | ១.២៨២.៤៥៥ |
| ការទិញបន្ថែម | ៨៤៩.៩៩៥ | ២.៤៨៣.០០២ |
| រំលស់ | - | (៨.៥១៤) |
| តម្លៃចុះបញ្ជីសុទ្ធ | (១.២៨៤.៧០៩) | (៤៦៤.៦១២) |
| | ២.៨៥៧.៦១៧ | ៣.២៩២.៣៣១ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | | |
| ថ្លៃដើម | ៥.៦៦៦.៥៨៦ | ៤.៨១៦.៥៩១ |
| រំលស់បង្គរ | (២.៨០៨.៩៦៩) | (១.៥២៤.២៦០) |
| តម្លៃចុះបញ្ជីសុទ្ធ | ២.៨៥៧.៦១៧ | ៣.២៩២.៣៣១ |

ទ្រព្យសកម្មអរូបីរួមមានកម្មវិធីគណនេយ្យ និងបណ្តាញ ដែលត្រូវធ្វើរំលស់ក្នុងរយៈពេល៥ឆ្នាំ។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.៨- ឧបករណ៍ហិរញ្ញវត្ថុ

**(ក) ឧបករណ៍ហិរញ្ញវត្ថុតាមប្រភេទ**

| | ៣១ ធ្នូ ២០១៤ (ពាន់រៀល) | ៣១ ធ្នូ ២០១៣ (ពាន់រៀល) |
|---|---|---|
| ទ្រព្យសកម្មក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | |
| ការវិនិយោគរយៈពេលខ្លី | ១៩៦.៣៣១.៣៣១ | ១៧៤.២៧៨.០១៨ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ៣០.២៧១.១២៩ | ២៩.១៨៥.៧១១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៤.៩៦២.១៤១ | ១០.៥៦៨.៧១៥ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | ៥.៤៤០.៦៤៩ | ៧.០១៥.០១៣ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៥៨៩.៩០៥ | ៦៥៩.៧៩៩ |
| | ២៤៧.៥៩៥.១៥៥ | ២២១.៧០៧.២៥៦ |
| បំណុលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | | |
| បំណុលហិរញ្ញវត្ថុផ្សេងៗតាមថ្លៃដើមដករំលស់ | | |
| ប្រាក់កម្ចី | ២៨០.០៩៣.៧៦៦ | ២៥៤.៩៥៤.០៦៤ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ២២.២០៩.៩២៤ | ២៩.៧៧២.៣៩៤ |
| ប្រាក់កក់របស់អតិថិជន | ៣៦.២៨៣.៨៤៥ | ៣១.២១៥.១៧៣ |
| | ៣៣៨.៥៨៧.៥៣៥ | ៣១៥.៩៤១.៦៣១ |

**(ខ) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ**

គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនហួសកាលកំណត់សង និងមិនថយចុះតម្លៃ អាចត្រូវបានវាយតម្លៃដោយយោងទៅតាមអត្រាឥណទានខាងក្រៅ (ប្រសិនបើមាន) ឬយោងទៅតាមព័ត៌មានអតីតកាលអំពីអត្រាខកខានមិនបានសងបំណុលរបស់ភាគីជាដៃគូ។

| | ៣១ ធ្នូ ២០១៤ (ពាន់រៀល) | ៣១ ធ្នូ ២០១៣ (ពាន់រៀល) |
|---|---|---|
| គណនីអតិថិជនពាណិជ្ជកម្ម | | |
| ក្រុម ១ | ៥.២២២.៣៣៦ | ៤.៥៧៤.១៤៨ |
| ក្រុម ២ | ៩១៧.៨៧៤ | ១.២៤៣.៦២៧ |
| | ៦.១៤០.២១០ | ៥.៨១៧.៧៧៥ |
| ការវិនិយោគរយៈពេលខ្លី | | |
| មិនមានចំណាត់ថ្នាក់** | ១៩៦.៣៣១.៣៣១ | ១៧៤.២៧៨.០១៨ |
| | ១៩៦.៣៣១.៣៣១ | ១៧៤.២៧៨.០១៨ |
| សាច់ប្រាក់នៅធនាគារ | | |
| មិនមានចំណាត់ថ្នាក់** | ១១.៨២១.៨៣៩ | ៩.២១១.៧៤៩ |
| D* | ១.៦៧៩.៧០២ | ៧៧៧.៩៥២ |
| | ១៣.៥០១.៥៤១ | ៩.៩៨៩.៧០១ |

ក្រុម ១ - អតិថិជនថ្មី និងអតិថិជនចាស់ពីការលក់ទឹកស្អាត (តិចជាង១ខែ)។ អតិថិជននេះគឺជាអតិថិជនដែលមិនមែនអង្គភាពរដ្ឋាភិបាល ហើយមិនត្រូវបានកំណត់ចំណាត់ថ្នាក់ដោយភ្នាក់ងារជាតិឬអន្តរជាតិទេ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៨- ឧបករណ៍ហិរញ្ញវត្ថុ (ត)

| | ២០១៤ (ពាន់រៀល) | ២០១៣ (ពាន់រៀល) |
|---|---|---|
| គណនីអតិថិជនពីអ្នកប្រើប្រាស់តាមផ្ទះ | ២.៨៨១.៦៩២ | ២.៥៧៦.២៧៨ |
| គណនីអតិថិជនពីការប្រើប្រាស់ក្នុងលក្ខណៈពាណិជ្ជកម្ម | ២.៣៣៣.០៧៦ | ១.៩៩៤.០០៩ |
| អ្នកចែកចាយទឹកស្អាត | ៧.៥៦៨ | ៣.៨៦១ |
| | ៥.២២២.៣៣៦ | ៤.៥៧៤.១៤៨ |

ក្រុម ២ - អតិថិជនចាស់ពីការលក់ទឹកស្អាត (តិចជាង១ឆ្នាំ) ដែលមិនមានប្រវត្តិមិនសងប្រាក់ក្នុងអតីតកាល។ អតិថិជននេះគឺជាអង្គភាពរដ្ឋាភិបាល ដែលមិនត្រូវបានកំណត់ចំណាត់ថ្នាក់ដោយភ្នាក់ងារជាតិឬអន្តរជាតិទេ។

D* - សមតុល្យនេះគឺជាសាច់ប្រាក់បានផ្ញើនៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ ធនាគារ អេស៊ីលីដា ភីអិលស៊ីត្រូវបានកំណត់ចំណាត់ថ្នាក់ D ដោយ Standard & Poor's នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១១។ ចំណាត់ថ្នាក់ D នេះ ត្រូវបានផ្តល់សម្រាប់ Bank Fundamental Strength Rating នៃរូបិយប័ណ្ណក្នុងស្រុកគឺប្រាក់រៀល។

មិនមានចំណាត់ថ្នាក់** - ចំពោះធនាគារក្នុងស្រុកដទៃទៀតដែល រ.ទ.ស.ភ បានដាក់ប្រាក់បញ្ញើរបស់ខ្លួន មិនមានការផ្តល់ចំណាត់ថ្នាក់ពីភ្នាក់ងារណាមួយទេ។

### ង.៩- ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់

| | ២០១៤ (ពាន់រៀល) | ២០១៣ (ពាន់រៀល) |
|---|---|---|
| ឥណទានរយៈពេលខ្លី | ៩៧.៣៦៥ | ៨១.៤៧៥ |
| ឥណទានរយៈពេលវែង ដែលមានកាលកំណត់សង៖ | | |
| ពី១ឆ្នាំ ទៅ ២ឆ្នាំ | ១១១.១២៦ | ៩៥.៤៥៤ |
| ពី២ឆ្នាំ ទៅ ៥ឆ្នាំ | ៣៨១.៤១៤ | ៣៥៨.៨៨២ |
| លើសពី៥ឆ្នាំឡើងទៅ | - | ១២៣.៩៨៨ |
| | ៤៩២.៥៤០ | ៥៧៨.៣២៤ |
| ឥណទានសរុបផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៥៨៩.៩០៥ | ៦៥៩.៧៩៩ |

ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ដោយអនុលោមតាមកិច្ចព្រមព្រៀងឥណទានដែលបានចុះហត្ថលេខាដោយ រ.ទ.ស.ភ. និងរដ្ឋាករទឹកខេត្តពោធិ៍សាត់ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៨ ក្នុងទឹកប្រាក់ចំនួន ១.១៥៦ លានរៀល (២៨៣.១៩២ ដុល្លារអាមេរិក)។ គោលបំណងនៃឥណទាននេះគឺដើម្បីធ្វើហិរញ្ញប្បទានសម្រាប់ការស្តាបនាបណ្តាញផ្គត់ផ្គង់ទឹកមេនៅស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ដែលត្រូវស្ថាបនានិងបញ្ចប់ដោយ រ.ទ.ស.ភ. ក្នុងខែមេសា ឆ្នាំ២០០៩។ ឥណទាននេះមិនមានការធានាទេ និងមានអត្រាការប្រាក់៥%ក្នុងមួយឆ្នាំ។ យោងតាមតារាងសងប្រាក់ដែលបានចែងក្នុងមាត្រា G នៃកិច្ចព្រមព្រៀងឥណទាន រដ្ឋាករទឹកខេត្តពោធិ៍សាត់ត្រូវសងរំលស់ឥណទាននេះក្នុងរយៈពេល ១២០ខែ។ ប៉ុន្តែយោងតាមលិខិតស្នើសុំរបស់រដ្ឋាករទឹកខេត្តពោធិ៍សាត់ លេខ ០៥ ឧថរ.រទ.ពស IME.WS.PS ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៣ តារាងសងប្រាក់នេះត្រូវបានកែសម្រួលទៅជាសងរំលស់ចំនួន ១២៦ខែវិញ ដោយពន្យារការសងប្រាក់ដើមពីខែមករា ទៅខែមិថុនា ឆ្នាំ២០១៣ (ចាប់ផ្តើមសងប្រាក់ឡើងវិញនៅខែកក្កដា ឆ្នាំ២០១៣)។ ការសងការប្រាក់នៅតែធ្វើឡើងតាមមូលដ្ឋាន ប្រចាំខែដដែល។ លិខិតស្នើសុំនេះត្រូវបានអនុម័តដោយ រ.ទ.ស.ភ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣។

តម្លៃសមស្របនៃឥណទានរយៈពេលវែង ផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ មានដូចខាងក្រោម៖

| | ២០១៤ (ពាន់រៀល) | ២០១៣ (ពាន់រៀល) |
|---|---|---|
| តម្លៃយោង | ៥៨៩.៩០៥ | ៦៥៩.៧៩៩ |
| តម្លៃសមស្រប | ៤៩៨.៩១១ | ៥៦៨.៨៦៧ |

តម្លៃសមស្របនៃឥណទានគឺផ្អែកលើលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចី ៨,៥០% (២០១៣៖ ៨,៥០%)។

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.១០- ឥណទានផ្តល់ឲ្យបុគ្គលិក

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តភាគហ៊ុនដែលនឹងបោះផ្សាយលក់ចំនួន ១០% បម្រុងសម្រាប់បុគ្គលិករបស់ រ.ទ.ស.ភ។ កាលបរិច្ឆេទបែងចែកចំនួនភាគហ៊ុនជូនបុគ្គលិកនីមួយៗ ត្រូវបានកំណត់នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ ដែលត្រូវបានចាត់ទុកថាជាកាលបរិច្ឆេទផ្តល់គម្រោងភាគហ៊ុនរបស់បុគ្គលិក។ ទឹកប្រាក់ឥណទានសរុបមានចំនួន ៨.២១៨លានរៀល ត្រូវបានផ្តល់ឲ្យខ្ចីនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១២ ។ រ.ទ.ស.ភ. ផ្តល់ឥណទានដល់បុគ្គលិក និងមន្ត្រីជាន់ខ្ពស់ដើម្បីទិញភាគហ៊ុនទាំងនេះក្នុងរយៈពេលបីឆ្នាំដោយមិនគិតការប្រាក់។ នៅថ្ងៃផុតកំណត់បុគ្គលិកត្រូវសងឥណទាននេះវិញទាំងស្រុងជូន រ.ទ.ស.ភ។ យោងតាមកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ បុគ្គលិកទាំងអស់ត្រូវបានអនុញ្ញាតឲ្យជួញដូរភាគហ៊ុនរបស់ខ្លួនបាន នៅពេលដែលពួកគេសងឥណទាននេះរួចរាល់។

តម្លៃសមស្របនៃឥណទានផ្តល់ឲ្យបុគ្គលិកគឺផ្អែកទៅលើលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាការប្រាក់មធ្យមគឺ ១៤,៤០% ក្នុងមួយឆ្នាំ។ គណៈគ្រប់គ្រងបានវាយតម្លៃថាអត្រាការប្រាក់ ១៤,៤០% នេះ គឺជាអត្រាដ៏សមហេតុផល ពោលគឺវាសមមូលនឹងអត្រាដែលបុគ្គលិកអាចខ្ចីពីធនាគារពាណិជ្ជបាន ចំពោះរូបិយវត្ថុជាប្រាក់រៀលសម្រាប់រយៈពេលបីឆ្នាំ។ មិនមានការប្រែប្រួលក្នុងអត្រានេះនៅធនាគារពាណិជ្ជទេ។

នៅថ្ងៃប្រគល់ប្រាក់កម្ចី និយ័តកម្មលើតម្លៃសមស្របនៃសមតុល្យឥណទានចំនួន ២.៧២៩លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ ដោយសារតម្លៃសមស្របរបស់ឥណទានត្រូវបានកាត់បន្ថយដោយអត្រាអនុគ្រោះ (មិនយកការប្រាក់) ហើយអត្ថប្រយោជន៍នេះត្រូវបានផ្តល់ជូនបុគ្គលិក។

ឥណទាននេះនឹងដល់កាលកំណត់ក្នុងខែមេសា ឆ្នាំ២០១៥។ ក៏ប៉ុន្តែ តម្លៃភាគហ៊ុនបានធ្លាក់ចុះ។ គណៈគ្រប់គ្រងបានសម្រេចចិត្តកត់ត្រាសំវិធានធនសម្រាប់ការថយចុះតម្លៃ ដែលមានទឹកប្រាក់ចំនួន ២,៦០៩លានរៀល ក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្មើនឹងកម្រិតតម្លៃភាគហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដោយសារគណៈគ្រប់គ្រងរំពឹងថាយ៉ាងហោចណាស់ក៏បុគ្គលិកអាចលក់ និងទូទាត់ឥណទាននេះបានដែរ។

### ង.១១- សន្និធិ

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| បំពង់ចែកចាយទឹក និងបរិក្ខារភ្ជាប់ | ២៩.៩៥២.៧២១ | ២៣.៨៤០.២៥៧ |
| នាឡិកាទឹក | ៣.១៩៦.០៣៦ | ៧.៥៣២.២៨២ |
| គ្រឿងបន្លាស់ និងឧបករណ៍ផ្សេងៗ | ១.៥៨១.៨៩០ | ១.៨៧៧.១០៩ |
| សារធាតុគីមី | ៨៣៦.៧១២ | ២០៣.៨៩៥ |
| ធុងស្តុកទឹក និងកញ្ចប់ផ្សេងៗ | ១០០.២១៦ | ១០០.២១៦ |
| សន្និធិកំពុងបញ្ជូនមក ( * ) | ១.៩១០.៥០៧ | - |
| វត្ថុធាតុដើមផ្សេងៗ | ២.៩២៣.៧៧៨ | ១.៤៨៩.៦០៤ |
| | ៤០.៥០១.៨៦០ | ៣៥.០៤៣.៣៦៣ |

ថ្លៃដើមសន្និធិដែលបានកត់ត្រាជាចំណាយមានទឹកប្រាក់ចំនួន ២.៨៩៦លានរៀល សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និង ១០.៣៥៤លានរៀល សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

រ.ទ.ស.ភ. បានកត់ត្រាសំវិធានធនចំនួន ៦៥២លានរៀល ក្នុងឆ្នាំ២០១៤ សម្រាប់សន្និធិប្រើការលែងកើតក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។

( * ) សន្និធិកំពុងបញ្ជូនមកគឺបំពង់ទីប ដែលបានមកដល់កំពង់ផែនៃប្រទេសកម្ពុជា។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.១២- គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| គណនីអតិថិជនពីអ្នកប្រើប្រាស់តាមផ្ទះ | ២.៨៨១.៦៩២ | ២.៥៧៦.២៧៨ |
| គណនីអតិថិជនពីអ្នកប្រើប្រាស់ក្នុងលក្ខណៈអាជីវកម្ម | ២.៣៣៣.០៧៦ | ១.៩៩៤.០០៩ |
| គណនីអតិថិជនពីគ្រឹះស្ថានសាធារណៈ (ក) | ៩១៧.៨៧៤ | ១.២៤៣.៦២៧ |
| គណនីអតិថិជនពីសេវាសាងសង់ | - | ៦៩៥.៥០៩ |
| គណនីអតិថិជនពីអ្នកចែកចាយទឹកស្អាត | ៧.៥៦៨ | ៣.៨៦១ |
| គណនីអតិថិជនពាណិជ្ជកម្ម | ៦.១៤០.២១០ | ៦.៥១៣.២៨៤ |
| | | |
| ចំណូលបង្ករពីការលក់ទឹកស្អាត (ខ) | ១៨.២៣៩.៩២៧ | ១៨.៧៦៧.០២៦ |
| ការប្រាក់ត្រូវទទួល | ៤.៤៣២.៤៨៦ | ៣.៦៤២.៥០៣ |
| បុរេប្រទានឲ្យអ្នកផ្គត់ផ្គង់ | ១.៦២០ | ៩.០៥៣ |
| អាករលើតម្លៃបន្ថែមត្រូវទទួល-សុទ្ធ | ៣១០.៨៧៧ | ៥៧៣.៥០៩ |
| គណនីអតិថិជនផ្សេងៗ | ១.៤៩៩.៧៨៤ | ២៦៥.៧០៨ |
| | ២៤.៤៨៤.៦៩៤ | ២៣.២៥៧.៧៩៩ |
| | ៣០.៦២៤.៩០៥ | ២៩.៧៧១.០៨៣ |

អតិថិជនរបស់ រ.ទ.ស.ភ. រួមមានអតិថិជនតាមផ្ទះក្នុងស្រុក អតិថិជនប្រើប្រាស់ជាលក្ខណៈអាជីវកម្ម និងស្ថាប័នរដ្ឋាភិបាល។ រយៈពេលនៃការប្រមូលប្រាក់ពីអតិថិជនតាមផ្ទះក្នុងស្រុក និងអតិថិជនប្រើប្រាស់ជាលក្ខណៈអាជីវកម្ម គឺមានរយៈពេលតិចជាងមួយខែ និងស្ថាប័នរដ្ឋាភិបាល មានរយៈពេលមួយឆ្នាំ។ គណៈគ្រប់គ្រងជឿជាក់ថា គណនីអតិថិជនទាំងអស់នឹងត្រូវសងមកវិញ។

ដោយសារគណនីអតិថិជនទាំងនេះមានរយៈពេលខ្លី ដូចនេះតម្លៃសមស្របរបស់វាគឺប្រហាក់ប្រហែលនឹងតម្លៃយោងដកសំវិធានធន។ តម្លៃយោងនៃគណនីអតិថិជនពាណិជ្ជកម្មទាំងអស់គឺកត់ត្រាជាប្រាក់រៀល ហើយគណនីអតិថិជនផ្សេងៗទៀតភាគច្រើនកត់ត្រាជាប្រាក់រៀលដែរ។

ហានិភ័យឥណទានអតិបរមាគិតត្រឹមកាលបរិច្ឆេទរាយការណ៍នេះ គឺជាតម្លៃយោងនៃគណនីអតិថិជននីមួយៗដែលបានពណ៌នាខាងលើ ដកប្រាក់កក់របស់អតិថិជនដែលទទួលបានមុនការតភ្ជាប់នាឡិកាទឹក។

(ក) គណនីអតិថិជនពីគ្រឹះស្ថានរដ្ឋបាលសាធារណៈ គឺមានការហួសកាលកំណត់សង ប៉ុន្តែមិនចាត់ទុកជាថយចុះតម្លៃទេ។ អាយុកាលរបស់គណនីអតិថិជន មានរយៈពេល ១ឆ្នាំ។ គណនីអតិថិជនទាំងនេះពាក់ព័ន្ធនឹងស្ថាប័នរដ្ឋាភិបាល ដែលពុំមានប្រវត្តិមិនសងប្រាក់នាពេលថ្មីៗនេះទេ។

(ខ) ចំណូលបង្ករពីការលក់ទឹកស្អាត គឺជាការផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជន ដែលមិនទាន់បានចេញវិក្កយបត្រនៅឡើយ គិតត្រឹមដំណាច់ឆ្នាំ។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.១៣- ពន្ធលើប្រាក់ចំណេញ(ត្រូវបង់)/ត្រូវទទួល

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ២.៧៥៥.៧០៤ | (៨៩៣.៨១៧) |
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ (កំណត់សម្គាល់៣០) | (៨.៩៥១.៦៧០) | (៣.១៦១.៨៥៤) |
| ពន្ធបានបង់ក្នុងឆ្នាំ | ៣.២៨៦.៦៧៨ | ៦.៨១១.៣៧៥ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | (២.៩០៩.២៨៨) | ២.៧៥៥.៧០៤ |

ការបង់ពន្ធលើប្រាក់ចំណេញត្រូវបានបង់សម្រាប់ឆ្នាំមុន និងពន្ធផ្សេងៗទៀតក្នុងឆ្នាំ។

## ង.១៤- ការវិនិយោគរយៈពេលខ្លី

ការវិនិយោគរយៈពេលខ្លីគឺជាប្រាក់បញ្ញើមានកាលកំណត់ ដែលបានផ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងរយៈពេលពី៤ខែទៅ១២ខែ ហើយទទួលបានការប្រាក់ចន្លោះពី ៤,០០% ទៅ ៥,០០% ក្នុងមួយឆ្នាំ (២០១៣ ៖ ចន្លោះពី ៤,០០% ទៅ ៥,០០% ក្នុងមួយឆ្នាំ) ។

នៅក្នុងគណនីការវិនិយោគរយៈពេលខ្លីនេះ រួមមានប្រាក់បញ្ញើដែលមានទឹកប្រាក់ចំនួន ១៨ ពាន់លានរៀល (២០១៣ ៖ ១៦ពាន់លានរៀល) ដែលបានរៀបចំជាពិសេសសម្រាប់បង់អត្ថប្រយោជន៍សោធននិវត្តន៍ ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះពេលចូលនិវត្តន៍។ មិនមានលក្ខខណ្ឌដែលថា រ.ទ.ស.ភ មិនអាចប្រើប្រាស់ការវិនិយោគរយៈពេលខ្លី សម្រាប់គោលបំណងផ្សេងទៀតនោះទេ។

## ង.១៥- សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ១.៤៦០.៦០០ | ៥៧៩.០១៤ |
| សាច់ប្រាក់នៅធនាគារ | ១៣.៥០១.៥៤១ | ៩.៩៨៩.៧០១ |
| | ១៤.៩៦២.១៤១ | ១០.៥៦៨.៧១៥ |

នៅក្នុងគណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានទឹកប្រាក់ចំនួន ៥១៩ លានរៀល (២០១៣ ៖ ១៩៨ លានរៀល) ដែលបានរៀបចំទុកសម្រាប់បង់អត្ថប្រយោជន៍សោធននិវត្តន៍ ជូនបុគ្គលិកដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះពេលចូលនិវត្តន៍។ មិនមានលក្ខខណ្ឌដែលថា រ.ទ.ស.ភ មិនអាចប្រើប្រាស់សាច់ប្រាក់ និងសាច់ប្រាក់សមមូល សម្រាប់គោលបំណងផ្សេងទៀតនោះទេ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.១៦. មូលធនភាគហ៊ុន

| | ចំនួនភាគហ៊ុន ធម្មតា ខ្ទង់ពាន់ | ចំនួនភាគហ៊ុន ប្រភេទ"ក" ខ្ទង់ពាន់ | ភាគហ៊ុនធម្មតា ពាន់រៀល | បុព្វលាភ ភាគហ៊ុន ពាន់រៀល | ភាគហ៊ុន ប្រភេទ "ក" ពាន់រៀល | ដើមទុន ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ | ៨៦.៩៧៣ | ៣៩១.១០១ | ៨៦.៩៧៣.១៦២ | ៦៣.១៥៣.១៧៨ | ៣៩១.១០០.៩៤២ | - | ៥៤១.២២៧.២៨២ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | ៨៦.៩៧៣ | ៣៩១.១០១ | ៨៦.៩៧៣.១៦២ | ៦៣.១៥៣.១៧៨ | ៣៩១.១០០.៩៤២ | - | ៥៤១.២២៧.២៨២ |

(ក) នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យបំបែកដើមទុនដែលមានទាំងអស់ចំនួន ៤៦៥.០២៨.១២៩.០០០រៀល ទៅជាភាគហ៊ុនធម្មតាចំនួន ៧៣.៩២៧.១៨៧ភាគហ៊ុន និងភាគហ៊ុនប្រភេទ "ក" ចំនួន ៣៩១.១០០.៩៤២ភាគហ៊ុន ដែលក្នុង១ហ៊ុនមានតម្លៃចារិក១.០០០រៀល។ ភាគហ៊ុនប្រភេទ "ក" មិនបានទទួលការប្រាក់ ឬភាគលាភទេ ហើយមានសិទ្ធិ និងលក្ខខណ្ឌដូចមានលម្អិតនៅក្នុងមាត្រា ១២.២ នៃលក្ខន្តិកៈបុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ។

(ខ) នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានចុះបញ្ជីក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដោយជោគជ័យ។ រ.ទ.ស.ភ. គឺជាក្រុមហ៊ុនដំបូងគេក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ភាគហ៊ុនធម្មតាសរុបមានចំនួន ៨៦.៩៧៣.១៦២ភាគហ៊ុន ដែលមានតម្លៃចារិក១.០០០រៀលក្នុង១ភាគហ៊ុន។ ថ្លៃដើមក្នុងការចេញផ្សាយភាគហ៊ុនថ្មីចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន មានទឹកប្រាក់ចំនួន ៦.០០០លានរៀល ត្រូវបានកាត់កងជាមួយនឹងបុព្វលាភភាគហ៊ុន។ រាល់ភាគហ៊ុនដែលបានចេញផ្សាយទាំងអស់ ត្រូវបានបង់ប្រាក់រួចរាល់ទាំងស្រុង។ សេចក្តីលម្អិតអំពីភាគហ៊ុនធម្មតាមានដូចខាងក្រោម៖

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.១៦- មូលធនភាគហ៊ុន (ត)

| | ចំនួនភាគហ៊ុន | % |
|---|---|---|
| ភាគហ៊ុនិក | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ត្រូវរក្សាទុក១ឆ្នាំ) | ៧៣.៩២៧.១៨៧ | ៨៥% |
| ភាគហ៊ុនិកដទៃទៀត | ១១.៧៤១.៦០៦ | ១៤% |
| គម្រោងភាគហ៊ុនរបស់បុគ្គលិក (ត្រូវរក្សាទុក៣ឆ្នាំ) (ក) | ១.៣០៤.៣៦៩ | ១% |
| | ៨៦.៩៧៣.១៦២ | ១០០% |

(ក) យោងតាមកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ បុគ្គលិកទាំងអស់ត្រូវបានអនុញ្ញាតឲ្យជួញដូរភាគហ៊ុនរបស់ខ្លួនបាន នៅពេលដែលពួកគេសងឥណទានរួចរាល់។

## ង.១៧- ទុនបម្រុង

| | ទុនបម្រុង ដើមទុន ពាន់រៀល | ទុនបម្រុង តាមច្បាប់ ពាន់រៀល | ទុនបម្រុង ទូទៅ ពាន់រៀល | ទុនបម្រុង សម្រាប់ការអភិវឌ្ឍ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ | ១.៦៤៨.៤៣៥ | ៩.៤៧៨.០៨៧ | ៩.៤៧៨.០៨៧ | ៦៣.២៤៩.៩០៥ | ៨៣.៨៥៤.៥១៤ |
| ការបន្ថែម | - | ១.៧២១.០៤៩ | ១.៧២១.០៤៩ | ២៨.៥៦៩.៧០៨ | ៣២.០១១.៨០៦ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ | ១.៦៤៨.៤៣៥ | ១១.១៩៩.១៣៦ | ១១.១៩៩.១៣៦ | ៩១.៨១៩.៦១៣ | ១១៥.៨៦៦.៣២០ |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ | ១.៦៤៨.៤៣៥ | ១១.១៩៩.១៣៦ | ១១.១៩៩.១៣៦ | ៩១.៨១៩.៦១៣ | ១១៥.៨៦៦.៣២០ |
| ការបន្ថែម | - | ១.៩០៤.៤០១ | ១.៩០៤.៤០១ | ២៩.៥១៨.៣១៥ | ៣៣.៣២៧.១១៧ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | ១.៦៤៨.៤៣៥ | ១៣.១០៣.៥៣៧ | ១៣.១០៣.៥៣៧ | ១២១.៣៣៧.៩២៨ | ១៤៩.១៩៣.៤៣៧ |

យោងតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ. ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩ ត្រង់មាត្រា២៩ បានចែងថាប្រាក់ចំណេញរបស់ រ.ទ.ស.ភ. បន្ទាប់ពីកាត់កងនឹងការខាតយោងពីឆ្នាំមុន (ប្រសិនបើមាន) អាចត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- សម្រាប់ប្រាក់រង្វាន់របស់គណៈគ្រប់គ្រង និងបុគ្គលិក
- សម្រាប់ទុនបម្រុងតាមច្បាប់ ៥%
- សម្រាប់ទុនបម្រុងទូទៅ ៥% និង
- សមតុល្យនៅសល់សម្រាប់ទុនបម្រុងសម្រាប់ការអភិវឌ្ឍ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.១៧- ទុនបម្រុង (ត)

(ក) ដោយចូលជាធរមានពីដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ តទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយល់ព្រមតាមសំណើពី រ.ទ.ស.ភ. តាមរយៈលិខិតលេខ ២២៥៤ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨ ដែលបានស្នើសុំបែងចែកប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួនចំនួន ១០% ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក៏ប៉ុន្តែចាប់ពីឆ្នាំ២០១២ទៅ បន្ទាប់ពី រ.ទ.ស.ភ បានចុះបញ្ជីរួចហើយ ការបែងចែកភាគលាភនឹងត្រូវអនុវត្តតាមលក្ខន្តិកៈថ្មីរបស់ រ.ទ.ស.ភ. ចុះថ្ងៃទី២៧ខែមិថុនា ឆ្នាំ២០១២។ ការបែងចែកភាគលាភមានដូចខាងក្រោម៖

គោលការណ៍ភាគលាភនឹងត្រូវកំណត់ដោយស្របទៅតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការបែងចែកប្រាក់ចំណេញ ដូចខាងក្រោម៖

១. ការទូទាត់ការខាតក្នុងឆ្នាំកន្លងទៅ

២. បន្ទាប់ពីបានទូទាត់ការបង់ក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើនៅមានប្រាក់ចំណេញ នោះប្រាក់ចំណេញនោះត្រូវបែងចែកដូចខាងក្រោម៖

   i. ផ្តល់ជារង្វាន់ជូនគណៈគ្រប់គ្រងនិងបុគ្គលិក តាមលក្ខខណ្ឌដូចខាងក្រោម៖
      - ផ្តល់ជូននូវប្រាក់បៀវត្សរ៍១ខែចំពោះបុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធចាប់ពី៥% ទៅ១០%នៃចំណាយប្រតិបត្តិការ។
      - ផ្តល់ជូននូវប្រាក់បៀវត្សរ៍២ខែចំពោះបុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធលើសពី១០% ទៅ២០%នៃចំណាយប្រតិបត្តិការ។
      - ផ្តល់ជូននូវប្រាក់បៀវត្សរ៍៣ខែចំពោះបុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធច្រើនជាង២០% នៃចំណាយប្រតិបត្តិការ។

   ii. ២% សម្រាប់ប្រាក់សោធននិវត្តន៍និងអសមត្ថភាពវិជ្ជាជីវៈ

   iii. ៥% សម្រាប់ទុនបម្រុងតាមច្បាប់

   iv. ៥% សម្រាប់ទុនបម្រុងទូទៅ

   v. ៥% សម្រាប់មូលនិធិសង្គម ដែលនឹងត្រូវកត់ត្រាជាចំណាយក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង

៣. ចំនួនទឹកប្រាក់ដែលនៅសល់បន្ទាប់ពីការបែកចែកខាងលើនេះ ត្រូវបន្តបែងចែកដូចខាងក្រោមទៀត៖

   i. បម្រុងសម្រាប់ការវិនិយោគនាពេលអនាគត (ប្រាក់ចំណេញរក្សាទុក) ដែលទឹកប្រាក់នេះត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល

   ii. ទឹកប្រាក់នៅសល់ក្រោយពីទុនបម្រុងសម្រាប់ការវិនិយោគ ត្រូវបែងចែកជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ៨៥% និង ១៥%ទៀតជូនវិនិយោគិនសាធារណៈ។

ភាគលាភសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដែលមានតម្លៃ៥៤,៧៤រៀលក្នុងមួយភាគហ៊ុន និងមានទឹកប្រាក់ភាគលាភសរុបចំនួន៤.៧៦១លានរៀល ត្រូវបានអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ និងបានបង់រួចរាល់ទាំងស្រុងក្នុងខែឧសភា ឆ្នាំ២០១៤។

(ខ) ការប្រើគណនីទុនបម្រុងសម្រាប់បង់សកម្មភាពសង្គម គឺអនុលោមតាមលិខិតលេខ២៤៨៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០។ សកម្មភាពសង្គមនេះទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត សម្រាប់ក្រុមយោធានៅតាមបណ្តាខេត្តមួយចំនួន។ សកម្មភាពនេះត្រូវបានបន្តរហូតដល់ឆ្នាំ២០១១ ដោយយោងតាមលិខិតរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ លេខ២២១០សហវ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.១៨- កាតព្វកិច្ចសោធននិវត្តន៍

ចំនួនទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ | ៣០.២៤៦.១៦០ | ២៨.៣៦២.២២៤ |
| តម្លៃសមស្របនៃទ្រព្យតម្កល់ | - | - |
| ស្ថានភាពអធន (Unfunded status) | ៣០.២៤៦.១៦០ | ២៨.៣៦២.២២៤ |
| បំណុលសុទ្ធដែលបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៣០.២៤៦.១៦០ | ២៨.៣៦២.២២៤ |

បម្រែបម្រួលនៅក្នុងកាតព្វកិច្ចអត្ថប្រយោជន៍ដែលបានកំណត់ក្នុងឆ្នាំនេះ មានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ២៨.៣៦២.២២៤ | ២៦.១៦៥.២៣៥ |
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ១.១៧៧.១៥០ | ១.០៨១.៥៤៧ |
| ចំណាយការប្រាក់ | ១.៣១៦.៨១៨ | ១.១៤៧.៧៤៤ |
| អត្ថប្រយោជន៍បានបង់ | (៨៦៦.៦៤៨) | (៦៨៩.៨០១) |
| ខាតពាក់ព័ន្ធនឹងការគណនាហានិភ័យ | ២៥៦.៦១៦ | ៦៥៧.៤៩៩ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ៣០.២៤៦.១៦០ | ២៨.៣៦២.២២៤ |

ទឹកប្រាក់ដែលបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗមានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ចំណាយលើសេវាកម្មបច្ចុប្បន្ន | ១.១៧៧.១៥០ | ១.០៨១.៥៤៧ |
| ចំណាយការប្រាក់ | ១.៣១៦.៨១៨ | ១.១៤៧.៧៤៤ |
| ចំនួនទឹកប្រាក់សរុបដែលបានកត់ត្រាក្នុងគណនីប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និង ចំណាយពាក់ព័ន្ធ (កំណត់សម្គាល់ ង.២៥) | ២.៤៩៣.៩៦៨ | ២.២២៩.២៩១ |

ទឹកប្រាក់ដែលរំពឹងថាត្រូវបង់ក្នុងរយៈពេល១២ខែមានចំនួន ១.០៧០លានរៀល សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ និង ៨៦៧លានរៀល សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.១៨- កាតព្វកិច្ចសោធននិវត្តន៍ (ត)

ការសន្មតការគណនាហានិភ័យសំខាន់ៗ មានដូចខាងក្រោម៖

| | ២០១៤ | ២០១៣ |
|---|---|---|
| មធ្យមភាគនៃការរំពឹងទុកនៃចំនួនឆ្នាំបម្រើការងារ | ២០ | ១៨ |
| អត្រាអប្បហារ | ៤,៦៤% | ៤,៦៤% |
| អត្រាកំណើនប្រាក់បៀវត្សរ៍ | អាស្រ័យទៅតាមគោលការណ៍របស់ រ.ទ.ស.ភ(ក) | |
| អត្រាមរណៈ | (ខ) | |

**(ក) អត្រាកំណើនប្រាក់បៀវត្សរ៍**

បុគ្គលិកត្រូវបានបែងចែកជា១១ថ្នាក់ ហើយថ្នាក់នីមួយៗមាន២៥កាំ។ គេរំពឹងថាបុគ្គលិកម្នាក់ៗ នឹងត្រូវឡើងឋានៈទៅកាំបន្ទាប់ជារៀលរាល់ឆ្នាំ។ ការដំឡើងប្រាក់បៀវត្សរ៍ ត្រូវគិតទៅលើបម្រែបម្រួលនៃសន្ទស្សន៍មធ្យមភាគប្រចាំថ្នាក់នីមួយៗ គុណនឹងចំនួនប្រាក់បៀវត្សរ៍ក្នុងមួយសន្ទស្សន៍។

ចំនួនប្រាក់បៀវត្សរ៍ក្នុងមួយសន្ទសន្សន៍គឺ ៥.៥៨៣ រៀល (២០១៣ ៖ ៥.៥៨៣ រៀល)។ ខាងក្រោមនេះគឺជាបម្រែបម្រួលនៃសន្ទស្សន៍មធ្យមភាគប្រចាំថ្នាក់នីមួយៗ។

| ថ្នាក់ | បម្រែបម្រួលនៃសន្ទស្សន៍មធ្យមភាគប្រចាំថ្នាក់ |
|---|---|
| ១ | ៥ |
| ២ | ៧ |
| ៣ | ៨ |
| ៤ | ១០ |
| ៥ | ១២ |
| ៦ | ១៣ |
| ៧ | ១៤ |
| ៨ | ១៥ |
| ៩ | ១៦ |
| ១០ | ១៧ |
| ១១ | ១៨ |

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.១៨- កាតព្វកិច្ចសោធននិវត្តន៍ (ត)

**(ខ) អត្រាមរណៈ**

ដោយសារមិនមានអត្រាមរណៈត្រូវបានចេញផ្សាយនៅក្នុងប្រទេសកម្ពុជា រ.ទ.ស.ភ. បានប្រើប្រាស់តារាងអត្រាអាយុកាលរំពឹងទុកនៃមរណៈរបស់ប្រទេសថៃឆ្នាំ២០០៨ ហើយបានកែសម្រួលដើម្បីឲ្យសមស្របទៅនឹងអាយុកាលរំពឹងទុករបស់ប្រជាជនកម្ពុជា។ តារាងអត្រាមរណៈរបស់ប្រទេសថៃឆ្នាំ២០០៨ គឺជាតារាងអត្រាមរណៈដែលបានចេញផ្សាយចុងក្រោយគេបំផុតនៅក្នុងប្រទេសថៃ។

តារាងខាងក្រោមនេះ បង្ហាញពីតារាងអត្រាមរណៈគំរូ ដែល រ.ទ.ស.ភ. បានប្រើប្រាស់៖

| អាយុ | អត្រាមរណៈ (%ប្រចាំឆ្នាំ) | |
|---|---|---|
| | ស្ត្រី | បុរស |
| ២០ | ០,៥៨២ | ០,៦៦៤ |
| ៣០ | ០,៥៩៨ | ០,៧០៥ |
| ៤០ | ០,៦១៨ | ០,៧៥៩ |
| ៥០ | ០,៧៤២ | ១,០០៨ |
| ៦០ | ១,១១៣ | ១,៥៨៩ |

## ង.១៩- បំណុលពន្ធពន្យារលើប្រាក់ចំណេញ

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ទ្រព្យសកម្មពន្ធពន្យារលើប្រាក់ចំណេញ៖ | | |
| ទ្រព្យសកម្មពន្ធពន្យារលើប្រាក់ចំណេញដែលត្រូវសងមកវិញ បន្ទាប់ពីរយៈពេលលើសពី១២ខែ | (៩.០៧៩.៨០០) | (៦.៦០៤.២៧០) |
| ទ្រព្យសកម្មពន្ធពន្យារលើប្រាក់ចំណេញដែលត្រូវសងមកវិញ ក្នុងរយៈពេល១២ខែ | (១.០៤២.៣៦៩) | (៧៧១.១៩៦) |
| | (១០.១២២.១៦៩) | (៧.៣៧៥.៤៦៦) |
| បំណុលពន្ធពន្យារលើប្រាក់ចំណេញ៖ | | |
| បំណុលពន្ធពន្យារលើប្រាក់ចំណេញដែលត្រូវសងមកវិញ បន្ទាប់ពីរយៈពេលលើសពី១២ខែ | ៣៥.៦៩៥.១៣៧ | ៣១.៨៤៨.២៩៣ |
| បំណុលពន្ធពន្យារលើប្រាក់ចំណេញដែលត្រូវសងមកវិញ ក្នុងរយៈពេល១២ខែ | - | - |
| | ៣៥.៦៩៥.១៣៧ | ៣១.៨៤៨.២៩៣ |
| បំណុលពន្ធពន្យារលើប្រាក់ចំណេញ(សុទ្ធ) | ២៥.៥៧២.៩៦៨ | ២៤.៤៧២.៨២៧ |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.១៩- បំណុលពន្ធពន្យារលើប្រាក់ចំណេញ (ត)

បម្រែបម្រួលគណនីពន្ធពន្យារ មានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ២៤.៤៧២.៨២៧ | ១៨.២៩៣.៤០៧ |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាតនិងចំណូលលម្អិតផ្សេងៗ (កំណត់សម្គាល់ ង.៣០) | ១.១០០.១៤១ | ៦.១៧៩.៤២០ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ២៥.៥៧២.៩៦៨ | ២៤.៤៧២.៨២៧ |

បម្រែបម្រួលទ្រព្យសកម្មពន្ធពន្យារលើប្រាក់ចំណេញ និងបំណុលពន្ធពន្យារក្នុងឆ្នាំ ដោយមិនកាត់កងសមតុល្យគ្នាក្នុងយុត្តាធិការតែមួយ មានដូចខាងក្រោម៖

### ទ្រព្យសកម្មពន្ធពន្យារ៖

| | អត្ថប្រយោជន៍សោធននិវត្តន៍<br>ពាន់រៀល | សំវិធានធនសន្និធិលែងប្រើប្រាស់<br>ពាន់រៀល | សំវិធានធនបំណុលសង្ស័យ<br>ពាន់រៀល | ប្រាក់រង្វាន់<br>ពាន់រៀល | (ចំណេញ)/ខាតពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣** | ៥.២០១.៥៦៣ | ៦៥.០៥៦ | ១.១១១ | ៤៣០.៨០០ | ៣៩៩.៤៩៨ | ៦.០៩៨.០២៨ |
| កត់ត្រាខាងខ្ទង់ឥណទាន ជាចំណេញ-ខាត ក្នុងរបាយការណ៍ចំណេញ-ខាត និង ចំណូលលម្អិតផ្សេងៗ | ៤៥៣.៥៤៩ | ៨២.៤៣៧ | - | ៣៣.៦៨៤ | ៧០៧.៧៦៨ | ១.២៧៧.៤៣៨ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | ៥.៦៥៥.១១២ | ១៤៧.៤៩៣ | ១.១១១ | ៤៦៤.៤៨៤ | ១.១០៧.២៦៦ | ៧.៣៧៥.៤៦៦ |
| កត់ត្រាខាងខ្ទង់ឥណទាន/(កត់ត្រាជាបន្ទុក) ជាចំណេញ-ខាត ក្នុងរបាយការណ៍ចំណេញ-ខាតនិងចំណូលលម្អិតផ្សេងៗ | ៣៩៤.១២០ | (១១៧.០០០) | ៥២១.៧៤៧ | ១៤៩.៤៦៣ | ១.៧៩៨.៣៧៣ | ២.៧៤៦.៧០៣ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | ៦.០៤៩.២៣២ | ៣០.៤៩៣ | ៥២២.៨៥៨ | ៦១៣.៩៤៧ | ២.៩០៥.៦៣៩ | ១០.១២២.១៦៩ |

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.១៩- បំណុលពន្ធពន្យារលើប្រាក់ចំណេញ (ត)

**បំណុលពន្ធពន្យារ៖**

| | វិលស់តាមវិធីពន្លឿនពន្ធ<br>ពាន់រៀល |
|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ | ២៤.៣៩១.៤៣៥ |
| កត់ត្រាជាបន្ទុក ជាចំណេញ-ខាត ក្នុងរបាយការណ៍ចំណេញ-ខាតនិងចំណូលលម្អិតផ្សេងៗ | ៧.៤៥៦.៨៥៨ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ | ៣១.៨៤៨.២៩៣ |
| កត់ត្រាជាបន្ទុក ជាចំណេញ-ខាត ក្នុងរបាយការណ៍ចំណេញ-ខាតនិងចំណូលលម្អិតផ្សេងៗ | ៣.៨៤៦.៨៤៤ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | ៣៥.៦៩៥.១៣៧ |

## ង.២០- ប្រាក់កម្ចី

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីពី៖ | | |
| AfD ឥណទានលេខ១០៧៥ ០៣S | ៦៤.៧១៩.៩០៥ | ៨៣.១១១.៦៩៤ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - JICA | ១១២.០០០.២៩០ | ៩៩.០០០.៩៥១ |
| AfD ឥណទានលេខ ៦០០០ ០១G | ២៥.២២៨.៧១៧ | ៣៥.១៩៥.៨៥១ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ធនាគារអភិវឌ្ឍន៍អាស៊ី ( ADB) | ៣៤.៥០២.៦៣៥ | ៣៧.៦៤៥.៥៦៨ |
| AfD ឥណទានលេខ១១២១ ០១F | ៤៣.៦៤២.២១៩ | - |
| | ២៨០.០៩៣.៧៦៦ | ២៥៤.៩៥៤.០៦៤ |

កាលបរិច្ឆេទសងប្រាក់កម្ចីនេះមានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីរយៈពេលខ្លី | | |
| ដល់កំណត់សងក្នុងរយៈពេល១ឆ្នាំ | ២៨.៨៣៧.២៤៩ | ២៦.៦៩១.៨១៧ |
| ប្រាក់កម្ចីរយៈពេលវែង | | |
| ដល់កំណត់សងក្នុងរយៈពេលពី១ឆ្នាំទៅ២ឆ្នាំ | ២៧.១០១.៣៦១ | ២៧.៤៨១.៥៩៧ |
| ដល់កំណត់សងក្នុងរយៈពេលពី២ឆ្នាំទៅ៥ឆ្នាំ | ៨៨.៥៩២.៦១៩ | ៨២.៤៤៤.៧៩០ |
| ដល់កំណត់សងក្នុងរយៈពេលលើសពី៥ឆ្នាំឡើងទៅ | ១៣៥.៥៦២.៥៣៧ | ១១៨.៣៣៥.៨៦០ |
| | ២៥១.២៥៦.៥១៧ | ២២៨.២៦២.២៤៧ |
| | ២៨០.០៩៣.៧៦៦ | ២៥៤.៩៥៤.០៦៤ |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២០- ប្រាក់កម្ចី (ត)

តម្លៃយោង និងតម្លៃសមស្របនៃប្រាក់កម្ចីរយៈពេលវែងមានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| តម្លៃយោង | ២៥១.២៥៦.៥១៧ | ២២៨.២៦២.២៤៧ |
| តម្លៃសមស្រប | ២៣៦.១២៧.៥៤៤ | ១៨៦.៩៧៥.៦៣៩ |

តម្លៃសមស្របនៃឥណទានទាំងនេះគឺផ្អែកទៅលើលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាប្រាក់កម្ចីសម្រាប់ឆ្នាំ២០១៤ គឺ ៨,៥០% (២០១៣ ៖ ៨,៥០%)។

ប្រាក់កម្ចីទទួលបានជារូបិយប័ណ្ណផ្សេងៗ មានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ប្រាក់អឺរ៉ូ | ១៣៣.៥៩០.៨៤១ | ១១៨.៣០៧.៥៤៥ |
| ប្រាក់ដុល្លារអាមេរិក | ១១២.០០០.២៩០ | ៩៩.០០០.៩៥១ |
| | ២៤៥.៥៩១.១៣១ | ២១៧.៣០៨.៤៩៦ |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២០-ប្រាក់កម្ចី (ត)

| លក្ខខណ្ឌឥណទាន | ឥណទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារអភិវឌ្ឍន៍អាស៊ី) | ឥណទានពី AfD ក្រោមកិច្ចព្រមព្រៀង ឥណទានលេខ CKH៦០០០ ០១G | ឥណទានពី AfD ក្រោមកិច្ចព្រមព្រៀង ឥណទានលេខ CKH១០៧៥០៣S | ឥណទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (JICA ឥណទាន លេខ CP-P៩) | ឥណទានពី AfD ក្រោមកិច្ចព្រមព្រៀង ឥណទានលេខ CKH១១២១ ០១F |
|---|---|---|---|---|---|
| ការបរិច្ចេទកិច្ចព្រមព្រៀង | ថ្ងៃទី០៥ ខែឧសភាឆ្នាំ១៩៩៧ | ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ វិសោធនកម្មថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩ និងថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១០ | ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៩ | ថ្ងៃទី១៨ ខែឧសភាឆ្នាំ២០១០ | ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ |
| គម្រោង | គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យទឹកស្អាតនៅតាមខេត្ត និងជុំវិញទីក្រុង។ | គម្រោងពង្រីករោងចក្រផលិតទឹកស្អាតនៅជ្រោយចង្វារ (ជំហានទី២) និងគម្រោងពង្រីកបណ្តាញចែកចាយរបស់ រ.ទ.ស.ភ។ | ការសាង់សង់រោងចក្រផលិតទឹកស្អាតថ្មីទី១ នៅសង្កាត់និរោធ និងពង្រីកការបញ្ជូន និងការចែកចាយបណ្តាញ ទាក់ទិនទៅនឹងការផលិតទឹកស្អាតបន្ថែម (កញ្ចប់ថវិការង ក)។ | ការរចនាម៉ូត និងការស្ថាបនារោងចក្រផលិតទឹកស្អាត និងការបញ្ជូននៅសង្កាត់និរោធ (កញ្ចប់ថវិការង ខ)។ | ការសាងសង់រោងចក្រផលិតទឹកស្អាតថ្មីទី២ នៅសង្កាត់និរោធ និងពង្រីកការបញ្ជូន និងធ្វើឲ្យប្រព័ន្ធបញ្ជូននិងប្រព័ន្ធចែកចាយកាន់តែមានភាពប្រសើរឡើង។ |
| អត្រាការប្រាក់ | ៦,៥% ក្នុង១ឆ្នាំ។ | EURIBOR ដក ១,៣៥%។ អត្រាការប្រាក់មិនត្រូវតិចជាង ០,២៥% ឬលើស៥,២១% ទេ។ អត្រាអណ្តែតត្រូវបានប្តូរទៅជាអត្រាថេរ នៅដំណាច់ការិយបរិច្ឆេទសងប្រាក់ ១,៤៩% ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១។ | EURIBOR ដក ១,៣៥%។ អត្រាការប្រាក់មិនត្រូវតិចជាង ០,២៥% ឬលើស៥,២១% ទេ។ អត្រាអណ្តែតត្រូវបានប្តូរទៅជាអត្រាថេរ នៅដំណាច់ការិយបរិច្ឆេទសងប្រាក់ ០,៨៨% ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៣។ | ៧,៣៥% ក្នុងមួយឆ្នាំ។ | អត្រា EURIBOR ៦ខែ ដក ០,៥៩% ក្នុងមួយឆ្នាំ (មិនត្រូវលើស៥,១៩% ក្នុងមួយឆ្នាំទេ ហើយអត្រាការប្រាក់អប្បបរមាគឺ ០,២៥% ក្នុងមួយឆ្នាំ)។ |
| ការធានា | គ្មាន | លិខិតធានាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ | លិខិតធានាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ | គ្មាន | គ្មាន |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២០-ប្រាក់កម្ចី (ត)

| លក្ខខណ្ឌឥណទាន | ឥណទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារអភិវឌ្ឍន៍អាស៊ី) | ឥណទានពី AfD ក្រោមកិច្ចព្រមព្រៀង ឥណទានលេខ CKH៦០០០ ០១G | ឥណទានពី AfD ក្រោមកិច្ចព្រមព្រៀង ឥណទានលេខ CKH១០៧៥០៣S | ឥណទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (JICA ឥណទាន លេខ CP-P៩) | ឥណទានពី AfD ក្រោមកិច្ចព្រមព្រៀង ឥណទានលេខ CKH១១២១ ០១F |
|---|---|---|---|---|---|
| តារាងការសងប្រាក់ | បង់រំលស់ប្រចាំឆមាស នៅរៀងរាល់ថ្ងៃទី១៥ ខែមករា និងថ្ងៃទី១៥ ខែកក្កដា នៃឆ្នាំនីមួយៗ ដោយចាប់ផ្តើមពីឆ្នាំ២០១២ តទៅ។ | បង់រំលស់១៧ដំណាក់កាល ប្រចាំឆមាស ហើយត្រូវចាប់ផ្តើមសងពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ | បង់រំលស់១៦ដំណាក់កាល ប្រចាំឆមាសចាប់ផ្តើមពី ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៣ និងបញ្ចប់នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១។ | បង់រំលស់២៤ដំណាក់កាល ប្រចាំឆមាស ចាប់ផ្តើមនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៤ និងបញ្ចប់នៅថ្ងៃទី២០ខែមីនា ឆ្នាំ២០២៦។ | បង់រំលស់២៤ដំណាក់កាល ប្រចាំឆមាស (រាប់ទាំងរយៈពេលអនុគ្រោះចំនួន៤ឆ្នាំ)។ |
| កញ្ចប់ទឹកប្រាក់បម្រុង | គ្មាន | គ្មាន | គ្មាន | ទឹកប្រាក់អតិបរមា ១០៥.៨៩៤ លានរៀល | ទឹកប្រាក់អតិបរមា ១០.៧៤២ លានរៀល |
| ព័ត៌មានផ្សេងៗ | ហានិភ័យការប្តូររូបិយប័ណ្ណកើតពីការប្រែប្រួលរវាងតម្លៃរូបិយប័ណ្ណឥណទានជាSDR និងរូបិយប័ណ្ណនៃការសងប្រាក់របស់ រ.ទ.ស.ភ ជាប្រាក់រៀល នឹងត្រូវធានាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អត្រាប្តូរប្រាក់ (រៀល/SDR) ត្រូវបានកំណត់នៅថ្ងៃចុះកិច្ចសន្យា។ | ប្រតិបត្តិការត្រូវបានធ្វើឡើងជាប្រាក់អឺរ៉ូ (ទាំងការដកប្រាក់ និងការសងប្រាក់)។ | ប្រតិបត្តិការត្រូវបានធ្វើឡើងជាប្រាក់អឺរ៉ូ (ទាំងការដកប្រាក់ និងការសងប្រាក់)។ | ប្រតិបត្តិការត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក (ទាំងការដកប្រាក់ និងការសងប្រាក់)។ | ប្រតិបត្តិការត្រូវបានធ្វើឡើងជាប្រាក់អឺរ៉ូ (ទាំងការដកប្រាក់ និងការសងប្រាក់)។ |

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.២១- ចំណូលផ្សេងៗ

**ចំណូលផ្សេងៗរួមមាន៖**

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| រាជរដ្ឋាភិបាល និងជំនួយផ្សេងៗ (ក) | ២.៣៥៩.៩៧២ | ២.៨១៧.៦៨៧ |
| គ្រឿងបន្លាស់ និងការលក់នាឡិកាទឹក | ៥.៥៧៨.៤២៤ | ៣.៧៤៤.១២៥ |
| ចំណូលពីការផាកពិន័យ | ២៨៨.៧១២ | ១៨៨.៤៩៨ |
| ចំណូលផ្សេងៗ | ១.២៥៧.៧៦២ | ១.១៨០.៦៦២ |
| | ៩.៤៨៤.៨៧០ | ៧.៩៣០.៩៧២ |

**(ក) រាជរដ្ឋាភិបាល និងជំនួយផ្សេងៗ**

| | ជំនួយរបស់<br>រាជរដ្ឋាភិបាល<br>ពាន់រៀល | ជំនួយរបស់<br>AfD<br>ពាន់រៀល | ជំនួយរបស់<br>JICA<br>ពាន់រៀល | ជំនួយផ្សេងៗ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ | ៥.៧៦៩.៩៨០ | ៤១៣.៦០១ | - | ៩៣០.៤៤៧ | ៧.១១៤.០២៨ |
| ជំនួយទទួលបានបន្ថែម | - | ១.០៤៩.៧៤៩ | ២៩.៥៨៤.៨០០ | - | ៣០.៦៣៤.៥៤៩ |
| រំលស់ | (២២៤.២២៦) | (១.៤៦៣.៣៥០) | (១.០៥៤.៣៤០) | (៧៥.៧៧១) | (២.៨១៧.៦៨៧) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ | ៥.៥៤៥.៧៥៤ | - | ២៨.៥៣០.៤៦០ | ៨៥៤.៦៧៦ | ៣៤.៩៣០.៨៩០ |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤(*) | ៥.៥៤៥.៧៥៤ | - | ២៨.៥៣០.៤៦០ | ៨៥៤.៦៧៦ | ៣៤.៩៣០.៨៩០ |
| រំលស់ | (២២៦.៨៩៩) | - | (២.១០៨.៦៧៩) | (២៤.៣៩៤) | (២.៣៥៩.៩៧២) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | ៥.៣១៨.៨៥៥ | - | ២៦.៤២១.៧៨១ | ៨៣០.២៨២ | ៣២.៥៧០.៩១៨ |

រំលស់លើជំនួយពន្យារពីរាជរដ្ឋាភិបាល និងជំនួយផ្សេងៗ ត្រូវបានកត់ត្រាជាចំណូលផ្សេងៗ នៅក្នុងរបាយការណ៍ចំណេញ-ខាត និងចំណូលលម្អិតផ្សេងៗ។

**ជំនួយពីរាជរដ្ឋាភិបាល**

(*) ជំនួយពីរាជរដ្ឋាភិបាលកើតមកពីការចំណេញលើលម្អៀងនៃអត្រាថេរដែលបានប្រើដើម្បីប្តូរប្រាក់ (រៀល/SDR) ក្រោមកិច្ចព្រមព្រៀងឥណទានបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រ.ទ.ស.ភ. ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៧ ដែលមានទឹកប្រាក់សរុបចំនួន ៩.៦៩៥.០០០SDR ពីធនាគារអភិវឌ្ឍន៍អាស៊ី។ រ.ទ.ស.ភ. បានសម្រេចរក្សាទុកចំណេញពីការប្តូរប្រាក់នេះក្នុងបញ្ជីរបស់ រ.ទ.ស.ភ. ថាជាជំនួយ (ដោយសារមិនមានតម្រូវការឲ្យបង្វិលប្រាក់ចំណេញនេះទៅវិញទេ) ហើយប្រាក់ចំណេញនេះនឹងត្រូវរំលស់ដោយផ្អែកលើគោលការណ៍ដូចគ្នានឹងជំនួយពន្យារផ្សេងៗដែរ។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២២- ចំណូលផ្សេងៗ

**(ក) ជំនួយពន្យារពីរាជរដ្ឋាភិបាល និងជំនួយផ្សេងៗ**

**ជំនួយពី AfD**

តាមរយៈអនុសញ្ញាដែលបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង AfD ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រ.ទ.ស.ភ បានចុះកិច្ចព្រមព្រៀងទទួលជំនួយនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៣។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងផ្តល់ឧបត្ថម្ភធនដល់ រ.ទ.ស.ភ នូវជំនួយដែលមានទឹកប្រាក់ចំនួន ៥.០០០.០០០ អឺរ៉ូ (ប្រមាណ ២៣.៣១៤លានរៀល) ដើម្បីធ្វើហិរញ្ញប្បទានដល់ការពង្រីកបណ្តាញផ្គត់ផ្គង់ទឹកបរិភោគ នៅតំបន់ភ្នំពេញ និងតំបន់ ពាក់ព័ន្ធ។

**ជំនួយពី JICA**

ជំនួយពី JICA គឺជំនួយលើកគម្រោងអនុវត្តថាមពលស្អាត ដោយប្រព័ន្ធប្រតិបត្តិការអគ្គិសនីតាមប្រព័ន្ធសូឡា។

**ជំនួយផ្សេងៗ**

ជំនួយផ្សេងៗគឺជាការឧបត្ថម្ភជាទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ របស់ Association Internationale des Maires Francophones (AIMF) និងក្រុមហ៊ុន KUBOTA Construction Co., Ltd.។

### ង.២២- គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម | ១១.១៧៦.៤៣៤ | ៦.៧២២.៦៥០ |
| ប្រាក់ធានាដំណើរការប្រតិបត្តិការ | ២២៧.៩៩៩ | ១៥.០៤៤.៩៣០ |
| បង្គរប្រាក់លើកទឹកចិត្តបុគ្គលិក | ៣.៧៩៧.៣៩៩ | ៣.៣០០.៨៤០ |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | ៣.៧៣២.១៣៣ | ២.៨៤៩.៥៩៧ |
| ចំណូលមិនទាន់កត់ត្រាបាន (ក) | ៨៧១.៤៣៤ | ២១.២៦៦ |
| ចំណូលពន្យារ (ខ) | ៥.២៧៨ | ៩៩.១២៤ |
| ពន្ធត្រូវបង់ផ្សេងៗ | ១៦៧.២៨៤ | ១៥៨.៤៩៩ |
| គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ១.៥៣២.០០៩ | ១.៦៦៣.០០២ |
| | ២១.៥០៩.៩៧០ | ២៩.៨៥៩.៩០៨ |

(ក) ចំណូលនេះគឺជាសាច់ប្រាក់ដែលបានទទួលមុន សម្រាប់សេវាសាងសង់ ទាក់ទិនទៅនឹងការពង្រីកប្រព័ន្ធចែកចាយទឹកស្អាត ដែល រ.ទ.ស.ភ. បានសាងសង់ជូនក្រុមហ៊ុនសំណង់ ក្នុងខេត្តកំពង់ចាម និងខេត្តបាត់ដំបង។

(ខ) ចំណូលពន្យារនេះគឺជាសាច់ប្រាក់ដែលបានទទួលជាមុនពីធនាគារពិភពលោក (WB) និង Maries de Paris សម្រាប់ការភ្ជាប់បណ្តាញថ្មីទៅតាមផ្ទះប្រជាពលរដ្ឋក្រីក្រ។

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.២៣- ការលក់

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ | ៦៨.៨០៥.៨៦៨ | ៦៤.២៩២.០១៤ |
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ៦១.៥៥៩.៦២០ | ៥៦.៨៤៥.០២០ |
| ការលក់ទឹកស្អាតជូនគ្រឹះស្ថានសាធារណៈ | ៦.៨០៥.៦៣១ | ៦.២៣១.២២២ |
| ការលក់ទឹកស្អាតជូនអាជ្ញាធរស្វយ័តនានា | ៣៦២.៦៦៥ | ៣៣៦.៨៩៥ |
| ការលក់ទឹកស្អាតជូនអ្នកចែកចាយ | ១៧៩.២៨៧ | ១៦៧.១៤៥ |
| ចំណូលពីថ្លៃបង្គ្រប់ក្នុងការលក់ទឹកស្អាត | ៣២.៦៩៣ | ៣១.៧៤៣ |
| ដកៈ ការលុបចោលវិក្កយបត្រ | (៧២៧.៧០១) | (៤៥៧.៩៥២) |
| | ១៣៧.០១៨.០៦៣ | ១២៧.៤៤៦.០៨៧ |
| ចំណូលបានពីការភ្ជាប់បណ្តាញទៅតាមផ្ទះ | ៧.១៦០.៨៥០ | ៦.៣៩៧.៩៨៨ |
| ចំណូលបានពីការផ្លាស់ប្តូរនាឡិកាទឹក | ២.៤៣០.៤៩៩ | ២.២៤៥.០៩៥ |
| ចំណូលបានពីការលក់គ្រឿងបន្លាស់ និងការលក់នាឡិកា | ២៤៧.៩៣៦ | ៣១០.៦៧៣ |
| | ១៤៦.៨៥៧.៣៤៨ | ១៣៦.៣៩៩.៨៤៣ |

## ង.២៤- កម្រៃពីសេវាសាងសង់

កម្រៃនេះគឺជាកម្រៃបានមកពីសេវាសាងសង់ ទាក់ទិនទៅនឹងការប្តូរ និងការពង្រីកប្រព័ន្ធចែកចាយទឹក ដែល រ.ទ.ស.ភ. បានសាងសង់ជូនក្រុមហ៊ុនសំណង់មួយ។

## ង.២៥- ចំណាយលើប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សរ៍បុគ្គលិក | ១០.១០៦.៣៥៣ | ៨.១១៩.៤៦៤ |
| ប្រាក់លើកទឹកចិត្ត | ៥.១៦៤.៧៧៤ | ៤.១៤១.៥០៣ |
| ប្រាក់រង្វាន់ | ៣.០៦៩.៧៣៣ | ២.៥៨០.៤៦៥ |
| ចំណាយអត្ថប្រយោជន៍សោធននិវត្តន៍ (កំណត់សម្គាល់ ង.១៨) | ២.៤៩៣.៩៦៨ | ២.២២៩.២៩១ |
| ប្រាក់ឈ្នួលសម្រាប់អ្នកម៉ៅការ | ៩២៤.៥៧២ | ៥៨២.៣៣៣ |
| ចំណាយផ្សេងៗពាក់ព័ន្ធនឹងបុគ្គលិក | ២.៨១០.៩០០ | ២.១៩៤.៨៣០ |
| | ២៤.៥៧០.៣០០ | ១៩.៨៤៧.៨៨៦ |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.២៦- ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ក្លរ (Chlorine) | ២.៤១២.១៣០ | ១.៦៦៤.៤៧៩ |
| ប៉ូលី អាលុយមីញ៉ូម ក្លរីដ (Poly Aluminium Chloride) | ២.០៥៦.៧៥៦ | ១.៣៨៦.០៤៥ |
| សាច់ជូរ (Alum) | ១៦.៨១៣ | ១៥៤.៥១០ |
| កំបោរ (Lime) | ១.៣៩២ | ១.១៥៥ |
| វត្ថុធាតុដើមផ្សេងទៀត | ២០៣.៩៧២ | ១១១.៩០៨ |
| | ៤.៦៩១.០៦៣ | ៣.៣១៨.០៩៧ |

### ង.២៧- ចំណាយវត្ថុធាតុដើមសម្រាប់ការភ្ជាប់បណ្តាញទៅតាមគេហដ្ឋាន

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| វត្ថុធាតុដើមសម្រាប់ការភ្ជាប់បណ្តាញទៅតាមគេហដ្ឋាន | ៣.៧៧៨.៧៧៦ | ៣.៣៥៤.៨៤៤ |
| ការផ្លាស់ប្តូរនាឡិការទឹកសម្រាប់អ្នកប្រើប្រាស់ | ២.៤៣៤.០០៨ | ១.៥៩៦.៩២០ |
| ថ្លៃដើមបំពង់ចែកចាយទឹក | ១៥៤.០៩៨ | ២០៤.០៩៤ |
| ថ្លៃដើមផ្សេងៗ | ៤៦២.៩៨៣ | ៥១២.៩៨០ |
| | ៦.៨២៩.៨៦៥ | ៥.៦៦៨.៨៣៨ |

### ង.២៨- ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ - សុទ្ធ

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ចំណេញពីការប្តូររូបិយប័ណ្ណ | ៤.៨៥៦.៩១៨ | ៦៥៤.៣៥៧ |
| ខាតពីការប្តូររូបិយប័ណ្ណ | (២.៧០៩.១១៩) | (១.៩៤៣.៨៩០) |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ - សុទ្ធ | ២.១៤៧.៧៩៩ | (១.២៨៩.៥៣៣) |

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ២៩. ចំណូល/(ចំណាយ)ការប្រាក់ - សុទ្ធ

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ចំណូលការប្រាក់៖ | | |
| ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ៩.៤៤១.២៣១ | ៧.៦១៥.៦៦៣ |
| ចំណូលហិរញ្ញប្បទានអនុគ្រោះឲ្យបុគ្គលិកកត់ត្រាត្រលប់វិញ (Unwind) | ១.០៣៤.៣៧៤ | ៩៤១.៧៤៥ |
| ចំណេញសុទ្ធពីការប្តូររូបិយប័ណ្ណរបស់ប្រាក់កម្ចី | ១២.៥៦១.០០៦ | - |
| ចំណូលការប្រាក់ពីឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៣១.១៩១ | ៣៤.៧១៤ |
| | ២៣.០៦៧.៨០២ | ៨.៥៩២.១២២ |
| ចំណាយការប្រាក់៖ | | |
| ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (១២.០៣០.៦៩១) | (៩.៨០១.៣៥៣) |
| ខាតសុទ្ធពីការប្តូររូបិយប័ណ្ណរបស់ប្រាក់កម្ចី | - | (៥.៤១៣.៥៧៨) |
| ចំណាយការប្រាក់ដែលបានធ្វើមូលធនកម្មលើទ្រព្យសកម្ម | ៣៦៧.៦៤៩ | ៣.១៧៦.៦៨២ |
| | (១១.៦៦៣.០៤២) | (១២.០៣៨.២៤៩) |
| (ចំណូល)/ចំណាយការប្រាក់ - សុទ្ធ | ១១.៤០៤.៧៦០ | (៣.៤៤៦.១២៧) |

(ក) ចំណូលការប្រាក់គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើផ្សេងៗដែលផ្ញើនៅក្នុងធនាគារក្នុងស្រុកក្នុងឆ្នាំ។

(ខ) ចំណាយការប្រាក់គឺជាការប្រាក់លើប្រាក់កម្ចីពី AfD និងប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)និង JICA។

### ង.៣០- ចំណាយពន្ធលើប្រាក់ចំណេញ

(ក) **ចំណាយពន្ធលើប្រាក់ចំណេញ**

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ (កំណត់សម្គាល់ ង.១៣) | ៨.៩៥១.៦៧០ | ៣.១៦១.៨៥៤ |
| ពន្ធពន្យារលើប្រាក់ចំណេញ (កំណត់សម្គាល់ ង.១៩) | ១.១០០.១៤១ | ៦.១៧៩.៤២០ |
| | ១០.០៥១.៨១១ | ៩.៣៤១.២៧៤ |

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៣០- ចំណាយពន្ធលើប្រាក់ចំណេញ (ត)

**(ខ) ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញ និងចំណេញគណនេយ្យ**

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ចំណេញគណនេយ្យមុនបង់ពន្ធលើប្រាក់ចំណេញ | ៥៦.០៥៦.៣៣៨ | ៤៨.០៨៦.៨០៣ |
| ចំណាយពន្ធក្នុងអត្រា ១៨% (២០១៣៖១៨%) | ១០.០៩០.១៤១ | ៨.៦៥៥.៦២៥ |
| ការប្រែប្រួលអត្រាពន្ធ (*) | (១៦៥.៧២១) | ៦៣២.៧៣៦ |
| ចំនួនពន្ធនៃចំណាយដែលមិនអាចកាត់កងបាន | ១២៧.៣៩១ | ៥២.៩១៣ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១០.០៥១.៨១១ | ៩.៣៤១.២៧៤ |

យោងតាមច្បាប់សារពើពន្ធ វ.ទ.ស.ភ មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ តាមចំនួនមួយណាដែលខ្ពស់ជាងរវាងពន្ធលើប្រាក់ចំណេញក្នុងអត្រា ១៨% (២០១៣៖១៨%) នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា ១% នៃចំណូលសរុប។ ការកាត់បន្ថយអត្រាពន្ធលើប្រាក់ចំណេញចំនួន ២% គឺជាការលើកទឹកចិត្តដែលផ្តល់ដោយគណៈកម្មការមូលបត្រកម្ពុជា សម្រាប់ការចុះបញ្ជីក្នុងការជួញដូរមូលបត្រក្នុងរយៈពេលបីឆ្នាំ។ អត្រានេះនឹងត្រលប់ទៅអត្រាដើម ២០% វិញ ចាប់ពីឆ្នាំ២០១៥ទៅ។

ពន្ធលើប្រាក់ចំណេញត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទបញ្ញត្តិពន្ធដារ ក៏ប៉ុន្តែបទបញ្ញត្តិទាំងអស់នេះ អាចមានភាពប្រែប្រួលពីមួយគ្រាទៅមួយគ្រា ហើយការកំណត់ចុងក្រោយលើចំនួនពន្ធលើប្រាក់ចំណេញ នឹងត្រូវធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានពន្ធដារ។

(*) ការប្រែប្រួលអត្រាពន្ធត្រូវបានគណនាតាមមូលដ្ឋានលម្អៀងបណ្តោះអាសន្ននៃគណនេយ្យ និងមូលដ្ឋានពន្ធដែលទាក់ទិនទៅនឹងពន្ធពន្យារទ្រព្យសកម្ម និងបំណុល ដែលរំពឹងថានឹងត្រូវកត់ត្រានិងទូទាត់ បន្ទាប់ពីការិយបរិច្ឆេទការលើកទឹកចិត្តលើអត្រាពន្ធដែលត្រូវអនុវត្តតាមអត្រា២០%។

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៣១-.ចំណេញក្នុងមួយភាគហ៊ុន

(ក) **ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន** (basic earnings per share)

ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ម្ចាស់ភាគហ៊ុនរបស់ រ.ទ.ស.ភ ចែកនឹងចំនួនភាគហ៊ុនមធ្យម (weighted average) ដែលបានបោះផ្សាយក្នុងឆ្នាំ។

| | ២០១៤ | ២០១៣ |
|---|---|---|
| ប្រាក់ចំណេញរបស់ភាគហ៊ុនិក (ពាន់រៀល) | ៤៥.៧៤៧.៩១១ | ៣៨.០៨៨.០៣០ |
| ចំនួនភាគហ៊ុនមធ្យម | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| ចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន (រៀល) | ៥២៦,០០ | ៤៣៧,៩៣ |

(ខ) **ចំណេញក្នុងមួយភាគហ៊ុនថយចុះ** (diluted earnings per share)

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រ.ទ.ស.ភ មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ។ ដូចនេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនជាមូលដ្ឋាន។

# របាយការណ៍ហិរញ្ញវត្ថុ (ត)

## ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

### ង.៣២- សាច់ប្រាក់បានពីប្រតិបត្តិការ

| | កំណត់សម្គាល់ | ២០១៤ ពាន់រៀល | ២០១៣ ពាន់រៀល |
|---|---|---|---|
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | ៥៦.០៥៦.៣៣៨ | ៤៨.០៨៦.៨០៣ |
| និយ័តកម្ម៖ | | | |
| រំលស់ទ្រព្យសកម្មរូបី | ង.៦ | ៣២.៧៥៩.០៤៥ | ២៤.០៥៩.២៥២ |
| រំលស់ទ្រព្យសកម្មអរូបី | ង.៧ | ១.២៨៤.៧០៩ | ៤៦៤.៦១២ |
| រំលស់លើជំនួយពន្យារពីរាជរដ្ឋាភិបាល និងជំនួយផ្សេងៗ | ង.២១ | (២.៣៥៩.៩៧២) | (២.៨១៧.៦៨៧) |
| ខាតពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ និងទ្រព្យសកម្មអរូបី និងការជម្រះចេញពីបញ្ជី | | ៥.០២២.៤១០ | ១០២.៧៧៦ |
| ចំណាយកាតព្វកិច្ចសោធននិវត្តន៍ | ង.១៨ | ២.៤៩៣.៩៦៨ | ២.២២៩.២៩១ |
| ចំណាយការប្រាក់ | ង.២៩ | ១១.៦៦៣.០៤២ | ១២.០៣៨.២៤៩ |
| ចំណូលការប្រាក់ | ង.២៩ | (២៣.០៦៧.៨០២) | (៨.៥៩២.១២២) |
| ការថយចុះតម្លៃនៃឥណទានផ្តល់ឲ្យបុគ្គលិក | | ២.៦០៨.៧៣៨ | - |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | |
| សន្និធិ | | (៥.៤១៨.៤៩៧) | ២៤.៦២៩.៤៦៨ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | | (៦៣.៨៣៩) | (៦៣៥.៥៣៧) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | | ២.៣១០.៩៩២ | (២១.៧០១.៣៦៩) |
| សាច់ប្រាក់បានពីជំនួយរបស់រដ្ឋាភិបាលនិងជំនួយផ្សេងៗ | | - | ១.០៤៩.៧៤៩ |
| ប្រាក់កក់របស់អតិថិជន | | ៥.០៦៨.៦៧២ | ៣.៤២៨.១៨៦ |
| សាច់ប្រាក់បានពីប្រតិបត្តិការ | | ៨៨.៣៥៧.៨០៤ | ៨២.៣៤១.៦៧១ |

### ង.៣៣- ចំណាយមូលធនទាក់ទងនឹងការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ចំណាយមូលធនទាក់ទងនឹងការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ សម្រាប់ដំណាច់ការិយបរិច្ឆេទរាយការណ៍ប៉ុន្តែមិនទាន់បានកើតឡើងនៅឡើយ មានដូចខាងក្រោម៖

| | ២០១៤ ពាន់រៀល | ២០១៣ ពាន់រៀល |
|---|---|---|
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ៨០.៥៤១.៧៣៧ | - |
| សេវាប្រឹក្សា | ៤.២១៤.១៥០ | ១.៤៩៧ |
| បំពង់ដែកស្វិត បរិក្ខារភ្ជាប់ និងបរិក្ខារផ្សេងៗ | ៣៤២.១៧៥ | - |
| ការសាងសង់អាងស្តុកទឹក | ៦.៥១៩ | ៦.៤៩៨ |
| | ៨៥.១០៤.៥៨១ | ៧.៩៩៥ |

# ង- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤) "ត"

## ង.៣៤- ប្រតិបត្តិការភាគីពាក់ព័ន្ធ

**(ក) សមតុល្យភាគីពាក់ព័ន្ធសំខាន់ៗ**

រដ្ឋាករទឹកខេត្តពោធិ៍សាត់ និង រ.ទ.ស.ភ ស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូចនេះប្រតិបត្តិការជាមួយរដ្ឋាករទឹកខេត្តពោធិ៍សាត់ ត្រូវបានចាត់ទុកជាប្រតិបត្តិការភាគីពាក់ព័ន្ធ។

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៤៦.៥០៧.៩២៥ | ១៣៦.៦៤៦.៥១៩ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | ៥.៤៤០.៦៤៩ | ៧.០១៥.០១៣ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៥៨៩.៩០៥ | ៦៥៩.៧៩៩ |

**(ខ) ប្រតិបត្តិការភាគីពាក់ព័ន្ធសំខាន់ៗ**

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ការប្រាក់លើប្រាក់កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០.៤៥៤.៣៦៥ | ៥.៩៩៦.៤១២ |
| ការប្រាក់បានពីឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៣១.១៩១ | ៣៤.៧១៤ |

**(គ) ការទូទាត់**

ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ មានដូចខាងក្រោម៖

| | ២០១៤<br>ពាន់រៀល | ២០១៣<br>ពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សរ៍ និងចំណាយពាក់ព័ន្ធផ្សេងៗ | ១.៩១៥.៦០០ | ១.៨៥១.១៨២ |
| អត្ថប្រយោជន៍សោធននិវត្តន៍ | ៤៧៥.១២៣ | ២១៥.៥១៥ |
| | ២.៣៩០.៧២៣ | ២.០៦៦.៦៩៧ |

## ង.៣៥- ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

### ពន្ធដារ

នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ អនុក្រឹតលេខ០១.អនក្រ.បក ត្រូវបានចេញផ្សាយ។ អនុក្រឹតបានចែងថាក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រជាសាធារណៈនាពេលបច្ចុប្បន្ន និងពេលអនាគត នឹងត្រូវទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធ៥០ភាគរយ លើប្រាក់ចំណេញសម្រាប់រយៈពេលបីឆ្នាំ មានសុពលភាពចាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនបានចុះបញ្ជីលក់មូលបត្រជាសាធារណៈ។ គណៈគ្រប់គ្រងកំពុងតែសិក្សាអំពីផលប៉ះពាល់ ហើយអាចនឹងកត់ត្រាឥណទានពន្ធក្នុងឆ្នាំ២០១៥ ប្រសិនបើមាន។

### ភាគលាភ

ភាគលាភដែលមានតម្លៃ ១០៥,២០រៀលក្នុងមួយភាគហ៊ុន និងមានទឹកប្រាក់ភាគលាភសរុបចំនួន ៩.១៤៩លានរៀល ត្រូវបានស្នើ និងត្រូវបានអនុម័តក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។ របាយការណ៍ហិរញ្ញវត្ថុនេះ មិនបានឆ្លុះបញ្ចាំងពីភាគលាភត្រូវបង់នេះទេ។

# ផ្នែកទី៨:
# ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

## ១- ប្រតិបត្តិការជាមួយភាគហ៊ុនិក ដោយបញ្ជាក់ពីឈ្មោះភាគហ៊ុនិក ប្រភេទប្រតិបត្តិការ និងកាលបរិច្ឆេទ

ក្នុងឆ្នាំ២០១៤ រ.ទ.ស.ភ. ពុំមានប្រតិបត្តិការណាមួយជាមួយភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នោះទេ។

## ២- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទេ។

## ៣- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទេ។

## ៤- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ រ.ទ.ស.ភ. ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះ កើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ រ.ទ.ស.ភ.

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទេ។

## ៥- ប្រតិបត្តិការសំខាន់ៗជាមួយ បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយអភិបាល

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទេ។

## ៦- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវា ដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយ ដល់ រ.ទ.ស.ភ.

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទេ។

## ៧- ប្រតិបត្តិការសំខាន់ៗជាមួយ ភាគីជាប់ពាក់ព័ន្ធផ្សេងទៀត

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទេ។





# ផ្នែកទី៩:
# ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ដោយគណៈគ្រប់គ្រងរបស់ រ.ទ.ស.ភ. ហើយការពិភាក្សាខាងក្រោមនេះគួរតែអានជាមួយនឹង របាយការណ៍ហិរញ្ញវត្ថុក្រោយសវនកម្មសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដូចមានបង្ហាញក្នុងផ្នែកទី៧ នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបានសវនកម្ម ដោយសវនករឯករាជ្យ សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ របស់ រ.ទ.ស.ភ. ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបានជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ រ.ទ.ស.ភ. តែប៉ុណ្ណោះ។

## ១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

រ.ទ.ស.ភ. គឺជាសហគ្រាសសាធារណៈ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងគ្រប់គ្រង ផ្នែកហិរញ្ញវត្ថុ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បេសកកម្មចម្បងរបស់ រ.ទ.ស.ភ. គឺផលិតទឹក ផ្គត់ផ្គង់ និងចែកចាយទឹកស្អាតសម្រាប់ប្រជាពលរដ្ឋ ដែលរស់នៅរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ ក្នុងនោះរួមមានប្រជាជនប្រើប្រាស់ទឹកស្អាតសម្រាប់ជីវភាព ពាណិជ្ជកម្ម ឧស្សាហកម្ម និងស្ថាប័នរដ្ឋ។ ដើម្បីបំពេញបេសកកម្មនេះ រ.ទ.ស.ភ. បានអនុវត្តសកម្មភាពប្រតិបត្តិការលើទ្រព្យរោងចក្រ និងហត្ថបករណ៍របស់ខ្លួន ព្រមទាំងប្រតិបត្តិការរដ្ឋបាល ពាណិជ្ជកម្ម និងហិរញ្ញវត្ថុផ្សេងៗ ដូចជាការចែកចាយទឹកក្នុងក្រុងភ្នំពេញ ជាយក្រុង និងការពង្រីក និងការកែលម្អប្រព័ន្ធផលិតកម្ម និងបណ្តាញចែកចាយ។

ដោយមានការអនុញ្ញាតពីក្រសួងឧស្សាហម្ម រ៉ែ និងថាមពល ក្នុងឆ្នាំ២០០៤ ទ្រព្យសកម្ម និងប្រតិបត្តិការរបស់រដ្ឋាករទឹកតាខ្មៅ ដែលស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងឧស្សាហម្ម រ៉ែ និងថាមពល ត្រូវបានផ្ទេរឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ រ.ទ.ស.ភ.។ រ.ទ.ស.ភ. ប្រើទ្រព្យសម្បត្តិទាំងនេះ ដើម្បីផ្គត់ផ្គង់ និងបែងចែកទឹកស្អាតសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងតាខ្មៅនៃខេត្តកណ្តាល។

រ.ទ.ស.ភ. មានទីតាំងនៅក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតបួន អាងតម្កល់ទឹកបួនកន្លែង។ ដើម្បីបំពេញតម្រូវការកើនឡើង នៃការប្រើប្រាស់ទឹកស្អាត នាឆ្នាំ២០០៩ រ.ទ.ស.ភ. បានបង្កើនសមត្ថភាពប្រព្រឹត្តិកម្មទឹកស្អាតរបស់រោងចក្រជ្រោយចង្វារ ទ្វេដង ពី៦៥.០០០ម៉ែត្រគូប/ថ្ងៃ ទៅ១៣០.០០០ម៉ែត្រគូប/ថ្ងៃ។ ក្នុងពេលនោះដែរ រ.ទ.ស.ភ. ក៏បានសាងសង់អាងតម្កល់ទឹកស្អាតមួយជំនួស អាងចាស់នៅទីក្រុងតាខ្មៅផងដែរ ដែលអាចផ្ទុកទឹកស្អាតបាន ១.៥០០ម៉ែត្រគូប។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. មាននិយោជិតសរុបចំនួន ៨៥១នាក់ បណ្តាញមេនាំទឹក និងបណ្តាញចែកចាយទឹកស្អាតសរុបប្រមាណ ២.៣១២គីឡូម៉ែត្រ និងបានធ្វើប្រព្រឹត្តិកម្មទឹកស្អាតសរុបចំនួន ១៤៩.៥៥២.០៩៥ម៉ែត្រ ដើម្បីផ្គត់ផ្គង់ជូនប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញតាមរយៈ ២៧០.៨១២បណ្តាញ។ ឆ្នាំ២០១០ រ.ទ.ស.ភ មានផ្ទៃសេវាគ្របដណ្តប់ប្រមាណជា ៩០%លើខណ្ឌទាំង៨ របស់រាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ ដោយមិនរាប់បញ្ចូល២០ឃុំ ដែលជាសង្កាត់ថ្មីរបស់រាជធានីភ្នំពេញនោះទេ។ ខណ្ឌ័ទាំង៨របស់រាជធានីភ្នំពេញរួមមាន ខណ្ឌដូនពេញ ៧មករា ចំការមន ទួលគោកឬស្សីកែវ ដង្កោ មានជ័យ សែនសុខ។ តាមរយៈការពង្រីករាជធានីភ្នំពេញ ដោយបង្កើតជាសង្កាត់ថ្មីនេះ ក៏ជាសក្តានុពលមួយនៃការពង្រីកផ្ទៃសេវា និងការភ្ជាប់បណ្តាញទឹករបស់ រ.ទ.ស.ភ. នាពេលអនាគតផងដែរ។ ក្នុងឆ្នាំ២០១០ រ.ទ.ស.ភ បានសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតនិរោធន៍ដំហាន១ ដែលមានសមត្ថភាពប្រព្រឹត្តិកម្មទឹកស្អាតបានចំនួន១៣០.០០០ម៉ែតគូប/ថ្ងៃ។ គម្រោងវិនិយោគនេះ

## ១- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

បញ្ចប់ក្នុងបញ្ចប់ក្នុងឆ្នាំ២០១៣ ជាមួយគ្នានោះ គម្រោងវិនិយោគលើរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតនិរោធន៍ជំហាន២ នឹងចាប់ផ្តើមបន្តដែលមានសមត្ថភាពប្រព្រិត្តិកម្មទឹកស្អាតបានទ្វេរដងពីសមត្ថភាពដើម ១៣០.០០០ម៉ែតគូប/ថ្ងៃទៅ ២៦០.០០០ ម៉ែត្រគុប/ថ្ងៃដោយរំពឹងថានឹងអាច បំពេញតម្រូវការប្រើប្រាស់ទឹកស្អាតសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០។

រ.ទ.ស.ភ. រក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុជាប្រាក់រៀលដែលជារូបិយប័ណ្ណគោលរបស់ខ្លួន។ ចំពោះប្រតិបត្តការ រូបិយប័ណ្ណអន្តរជាតិផ្សេងៗត្រូវបានបង្ហាញជាប្រាក់រៀល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការជាមធ្យមប្រចាំ ថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា។

### ក- ការវិភាគចំណូល

រ.ទ.ស.ភ. មានចំណូល ៣ប្រភេទធំៗ គឺចំណូលបានមកពីការលក់ទឹក ច្បាប់ជាវទឹក និងចំណូលផ្សេងៗ។

- <u>ចំណូលបានមកពីការលក់ទឹករួមមាន:</u> ចំណូលពីការប្រើប្រាស់ប្រភេទជីវភាព អាជីវកម្ម ឧស្សាហកម្ម អង្គភាពរដ្ឋ និងអ្នកលក់ទឹកបន្ត។ ចំណូលទាំងនេះត្រូវបានរាយការណ៍តាមតម្លៃទទួលបានសុទ្ធ ក្រោយការកាត់កងជាមួយអប្បហារវិភាជន៍ និង ឥណទាន ហើយត្រូវបានទទួលស្គាល់តាមបរិមាណទឹក ដែលបានផ្គត់ផ្គង់ ជូនអតិថិជនរបស់ខ្លួន។ ការធ្វើវិក្កយបត្រនៃការប្រើប្រាស់ទឹក ត្រូវបានធ្វើឡើងក្នុងរយៈពេលរៀងរាល់២ខែម្តង។
- <u>ចំណូលបានពីសេវាសាងសង់:</u> គឺជាចំណូលបានមកពីសេវាសាងសង់ ទាក់ទិនទៅនឹងការប្តូរ និងការពង្រីកប្រព័ន្ធចែកចាយទឹក ដែល រ.ទ.ស.ភ. បានសាងសង់ជូនក្រុមហ៊ុនសំណង់មួយ។
- <u>ចំណូលផ្សេងៗរួមមាន:</u> ចំណូលបានមកពីការថែទាំនាឡិកា លក់សម្ភារៈតបណ្តាញទឹក ការផាកពិន័យពីការប្រើប្រាស់ទឹកពុំមានការអនុញ្ញាតពីរ.ទ.ស.ភ. និងផ្សេងៗ។

- **ចំណូលថែទាំនាឡិកា៖** គឺចំណូលបានពីថ្លៃឈ្នួលថែទាំនាឡិកា ដោយគិតថ្លៃ៥០រៀលក្នុងទំហំនាឡិកា១៥មម ផ្អែកតាមទំហំនាឡិកាជារៀងរាល់ខែ។
  ចំណូលនេះត្រូវបានប្រើប្រាស់សម្រាប់ផ្លាស់ប្តូរនាឡិកាជូនអតិថិជននាពេលអនាគត។
- **ចំណូលពីការលក់សម្ភារៈតបណ្តាញទឹក៖** គឺជាចំណូលទទួលបានពីការលក់នាឡិកាស្ទង់ទឹកបំពង់ និងសម្ភារតភ្ជាប់។
- **ចំណូលពីការផាកពិន័យ៖**
  គឺជាចំណូលទទួលបានពីការផាកពិន័យលើការបង់ថ្លៃប្រើប្រាស់ទឹកយឺតយ៉ាវនិងពិន័យលើបទល្មើសតបណ្តាញទឹកដោយពុំមានការអនុញ្ញាតពីរ.ទ.ស.ភ.។
- **ចំណូលផ្សេងៗ៖** គឺជាចំណូលទទួលបានមកពីការរួមចំណែករបស់អតិថិជនប្រភេទពាណិជ្ជកម្ម និងឧស្សាហកម្ម ក្នុងការវិនិយោគសម្រាប់ ការភ្ជាប់បណ្តាញពិសេសចូលទីតាំងផ្ទាល់របស់ពួកគេ។ ក្រៅពីនោះគឺជាចំណូលដែលទទួលបានពីកម្រៃសេវាលើការទារថ្លៃថែទាំលូទឹកស្អុយរបស់សាលារាជធានីភ្នំពេញ។

➢ **ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបជាមួយដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

| | ២០១៤ (ពាន់រៀល) | ២០១៣ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណូលសរុប | ១៥៦.៥៤២.៨៤៩ | ១៥១.៥៨០.២០៧ | ៤.៩៦២.៦៤២ | ៣,២៧% |

រ.ទ.ស.ភ. មានចំណូលសសរុប ១៥៦.៥៤២.៨៤៩ពាន់រៀល សម្រាប់ឆ្នាំ២០១៤ និង១៥១.៥៨០.២០៧ពាន់រៀល សម្រាប់ឆ្នាំ២០១៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ៤.៩៦២.៦៤២ពាន់រៀល ស្មើនឹង៣,២៧%។ យើងឃើញថាកំណើននេះកើនឡើងដោយសារចំនួនអតិថិជនបានកើនឡើងចំនួន ១៨.៤៩៨បណ្តាញ ពី២៥២.៣១៥បណ្តាញ ទៅ ២៧០.៨១៣បណ្តាញ

# ១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

## ក- ការវិភាគចំណូល (ត)

និងការកើនឡើងនៃការប្រើប្រាស់ទឹកក្នុងមួយបណ្តាញក្នុងមួយខែដែលបានកើនឡើងចំនួន ០,៧២ម៉ែត្រគូប ពី ៤២,០៤ម៉ែត្រគូប ទៅ ៤២,៧៦ម៉ែត្រគូប។ លើសពីនេះ ថ្លៃលក់ទឹកមធ្យមបានកើនឡើងចំនួន ៣,០០រៀល/ម៉ែត្រគូប ពី១.០១៧,០០រៀល/ម៉ែត្រគូប ទៅ១.០២០,០០រៀល/ម៉ែត្រគូប។ មិនតែប៉ុណ្ណោះអត្រាទឹកបាត់បង់ បានចូលរួមបង្កើនចំណូល ព្រោះអត្រានេះបានថយចុះចំនួន ០,០៩% ពី៥,៩៤% មកត្រឹម ៥,៨៥%។ ប៉ុន្តែកំណើនចំណូលនេះទទួលការប៉ះពាល់មួយចំណែកពីការកើនឡើងនៃអត្រាទឹកបាត់បង់ ព្រោះអត្រានេះបានកើនឡើងចំនួន ០.៨៦% ពី៦,៩០% ទៅ ៧,៧៦%។

## ក.២- ការវិភាគចំណូលតាមផ្នែក

ការវិភាគចំណូលតាមផ្នែករបស់ រ.ទ.ស.ភ. មានដូចខាងក្រោម៖

| | ២០១៤ (ពាន់រៀល) | | ២០១៣ (ពាន់រៀល) | |
|---|---|---|---|---|
| ចំណូលថ្លៃលក់ទឹក | ១៤៦.៨៥៧.៣៤៨ | ៩៣,៨១% | ១៣៦.៣៩៩.៨៤៣ | ៨៩,៩៩% |
| កម្រៃពីសេវាសាងសង់ | ២០០.៦៣១ | ០,១៣% | ៧.២៤៩.៣៩២ | ៤,៧៨% |
| ចំណូលផ្សេងៗ | ៩.៤៨៤.៨៧០ | ៦,០៦% | ៧.៩៣០.៩៧២ | ៥,២៣% |

មានតែប្រាក់ចំណូលតាមប្រភេទជាសារវន្តត្រូវបានលើកឡើងសម្រាប់ការវិភាគខាងក្រោម៖

➤ **ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបជាមួយដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

| | ២០១៤ (ពាន់រៀល) | ២០១៣ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ | ៦៨.៨០៥.៨៦៨ | ៦៤.២៩២.០១៤ | ៤.៥១៣.៨៥៤ | ៧,០២% |
| ការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ៦១.៥៥៩.៦២០ | ៥៦.៨៤៥.០២០ | ៤.៧១៤.៦០០ | ៨,២៩% |
| ការលក់ទឹកស្អាតជូនគ្រឹះស្ថានសាធារណៈ | ៦.៨០៥.៦៣១ | ៦.២៣១.២២២ | ៥៧៤.៤០៩ | ៩,២២% |
| ចំណូលបានពីការភ្ជាប់បណ្តាញទៅតាមផ្ទះ | ៧.១៦០.៨៥០ | ៦.៣៩៧.៩៨៨ | ៧៦២.៨៦២ | ១១,៩២% |
| កម្រៃពីសេវាសាងសង់ | ២០០.៦៣១ | ៧.២៤៩.៣៩២ | (៧.០៤៨.៧៦១) | (៩៧,២៣%) |
| ចំណូលផ្សេងៗ | ៥.៥៧៨.៤២៤ | ៣.៧៤៤.១២៥ | ១.៨៣៤.២៩៩ | ៤៨,៩៩% |

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ (ប្រភេទជីវភាព)**

រ.ទ.ស.ភ. មានចំណូលថ្លៃទឹកជីវភាពចំនួន ៦៤.២៩២.០១៤ពាន់រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ៦៨.៨០៥.៨៦៨ពាន់រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់កើនឡើងចំនួន៤.៥១៣.៨៥៤ពាន់រៀលស្មើនឹង ៧,០២%។ យើងឃើញថាកំណើននេះកើនឡើងដោយសារចំនួនអតិថិជនបានកើនឡើងចំនួន ១៥.៧៣៨បណ្តាញពី ២០៩.៩៩៧បណ្តាញទៅ ២២៥.៧៣៥បណ្តាញ ហើយដោយការប្រើប្រាស់ទឹកក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន០,៤៧ម៉ែត្រគូប ពី២៨,២៤ម៉ែត្រគូប ទៅ ២៨,៧១ម៉ែត្រគូប និងការកើនឡើងនៃថ្លៃលក់ទឹកមធ្យមដែលបានកើនឡើងចំនួន ៤,៧២រៀល/ម៉ែត្រគូប ពី៩១១,៩៣រៀល/ម៉ែត្រគូប ទៅ ៩១៦,៦៥រៀល/ម៉ែត្រគូប។ ប៉ុន្តែកំណើនចំណូលនេះទទួលការប៉ះពាល់មួយចំណែកពីការកើនឡើងនៃអត្រាទឹកបាត់បង់ ព្រោះអត្រានេះបានកើនឡើងចំនួន ០.៨៩% ពី៦,៩០% ទៅ ៧,៧៦%។

# ១- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

## ក.២- ការវិភាគចំណូលតាមផ្នែក (ត)

- **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម (ប្រភេទអាជីវកម្ម និងឧស្សាហកម្ម)**

រ.ទ.ស.ភ. មានចំណូលថ្លៃទឹកកប្រភេទអាជីវកម្មនិងឧស្សាហកម្មចំនួន ៥៦.៨៤៥.០២០ពាន់រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ៦១.៥៥៩.៦២០ពាន់រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់កើនឡើង ចំនួន៤.៧១៤.៦០០ពាន់រៀលស្មើនឹង ៨,២៩%។ យើងឃើញថាកំណើននេះកើនឡើងដោយសារ ចំនួនអិថិជនបានកើនឡើងចំនួន ២.៧៤៨បណ្តាញ ពី ៤១.៥១០បណ្តាញទៅ ៤៤.២៥៨បណ្តាញ។ ហើយដោយការប្រើប្រាស់ទឹកក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន៣,៦៧ម៉ែត្រគុប ពី៩៨,២៣ម៉ែត្រគុប ទៅ ១០១,៩០ម៉ែត្រគុប និងការកើនឡើងនៃថ្លៃលក់ទឹកមធ្យម ដែលបានកើនឡើងចំនួន ៧,៤០រៀល/ម៉ែត្រគុប ពី១.១៦៣,៦៤រៀល/ម៉ែត្រគុប ទៅ ១.១៧១,០៤រៀល/ម៉ែត្រគុប។ ប៉ុន្តែកំណើន ចំណូលនេះទទួលការប៉ះពាល់មួយចំណែកពីការកើនឡើងនៃអត្រាទឹកបាត់បង់ ព្រោះអត្រានេះបានកើនឡើងចំនួន ០.៨៩% ពី៦,៩០% ទៅ ៧,៧៦%។

- **ចំណូលពីការលក់ទឹកស្អាតជូនគ្រឹះស្ថានសាធារណៈ (ប្រភេទអង្គភាពរដ្ឋ)**

រ.ទ.ស.ភ. មានចំណូលថ្លៃទឹកប្រភេទអង្គភាពរដ្ឋចំនួន ៦.២៣១.២២២ពាន់រៀលសម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ៦.៨០៥.៦៣១ពាន់រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់កើនឡើងចំនួន ៥៧៤.៤០៩ពាន់រៀល ស្មើនឹង៩,២២%។ យើងឃើញថាកំណើននេះកើនឡើងដោយសារ ចំនួនអិថិជនបានកើនឡើងចំនួន ១០បណ្តាញពី ៧៧៥បណ្តាញទៅ ៧៨៥បណ្តាញ ហើយដោយការប្រើប្រាស់ ទឹកក្នុងមួយបណ្តាញក្នុងមួយខែបានកើនឡើងចំនួន២១,៦៣ម៉ែត្រគុប ពី៦៦១,៣៣ម៉ែត្រគុប ទៅ ៦៨២,៩៥ម៉ែត្រគុប។ ប៉ុន្តែកំណើន ចំណូលនេះទទួលការប៉ះពាល់មួយចំណែកពីការកើនឡើងនៃអត្រាទឹកបាត់បង់ ព្រោះអត្រានេះបានកើន ឡើងចំនួន ០.៨៩% ពី៦,៩០% ទៅ ៧,៧៦%។

- **ចំណូលបានពីការភ្ជាប់បណ្តាញទៅតាមផ្ទះ**

រ.ទ.ស.ភ. មានចំណូលពីការភ្ជាប់បណ្តាញទៅតាមផ្ទះចំនួន ៦.៣៩៧.៩៨៨ពាន់រៀលសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ៧.១៦០.៨៥០ពាន់រៀលសម្រាប់ ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់កើនឡើងចំនួន ៧៦២.៨៦២ពាន់រៀលស្មើនឹង ១១,៩២%។ យើងឃើញថាកំណើននេះកើនឡើងដោយសារ រ.ទ.ស.ភ. បានពង្រីកផ្ទៃសេវានៅតំបន់ជាយក្រុងដើម្បីតបណ្តាញទឹកស្អាតសម្រាប់ប្រជាពលរដ្ឋមានចំណូលទាប ប្រើប្រាស់ទឹកប្រភេទជីវភាពដែលទទួលការឧបត្ថម្ភធនពីដៃគូអភិវឌ្ឍន៍អន្តរជាតិពិសេសធនាគារពិភពលោក (WB) និងមូលនិធិរបស់ រ.ទ.ស.ភ.។ ការពង្រីកផ្ទៃសេវានេះធ្វើឲ្យចំនួនអតិថិជនបានកើនឡើង ១៨.៤៩៨បណ្តាញ ពី ២៥២.៣១៥បណ្តាញ ទៅ ២៧០.៨១៣ បណ្តាញ។

- **កម្រៃពីសេវាសាងសង់**

រ.ទ.ស.ភ. មានកម្រៃពីការសាងសង់ចំនួន ៧.២៤៩.៣៩២ពាន់រៀលសម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ២០០.៦៣១ពាន់រៀលសម្រាប់ ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់ថយចុះចំនួន ៧.០៤៨.៧៦១ពាន់រៀលស្មើនឹង ៩៧,២៣%។

- **ចំណូលផ្សេងៗ**

រ.ទ.ស.ភ. មានចំណូលផ្សេងៗចំនួន ៣.៧៤៤.១២៥ពាន់រៀលសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ៥.៥៧៨.៤២៤ពាន់រៀលសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់កើនឡើងចំនួន១.៨៣៤.២៩៩ពាន់រៀល ស្មើនឹង៤៨,៩៩%។ យើងឃើញថាកំណើននេះបណ្តាលមកពីចំណូលដែលបានមកពីការគ្រឿងបន្លាស់ និងការលក់នាឡិកាទឹក។

# ១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

## ក.៣-ការវិភាគគំលាតចំណេញដុល

រ.ទ.ស.ភ. បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមប្រភេទដូចនេះ ពុំមានការបង្ហាញឲ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឲ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រត្តបត្តិការនឹងលើកយកមកពិភាក្សានៅចំណុចទី ក.៤- ការចំណេញមុនបង់ពន្ធខាងក្រោម។

## ក.៤- ការចំណេញមុនបង់ពន្ធ

ការចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និងចំណូល/(ចំណាយ) ការប្រាក់សុទ្ធ។ ក្នុងការពិភាក្សា និងការវិភាគនៃចំណាយប្រតិបត្តិការ យើងលើកយកចំណាយរំលស់ទ្រព្យសកម្មរូបីអរូបី ចំណាយលើការប្រើប្រាស់អគ្គីសនី និងចំណាយលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួលយកមកពិភាក្សាដូចខាងក្រោម៖

➤ **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបជាមួយដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

| | ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ (ពាន់រៀល) | ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ (ពាន់រៀល) | បម្រែបម្រួល (ពាន់រៀល/ភាគរយ) | |
|---|---|---|---|---|
| ចំណូលសរុប | ១៥៦.៥៤២.៨៤៩ | ១៥១.៥៨០.២០៧ | ៤.៩៦២.៦៤២ | ៣,២៧% |
| ចំណាយ អគ្គីសនី | (២៨.៦៤៧.៣៣៤) | (២៧.៤០៦.៣៩៧) | (១.២៤០.៩៣៧) | ៤,៥៣% |
| ចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយ ពាក់ព័ន្ធ | (២៤.៥៧០.៣០០) | (១៩.៨៤៧.៨៨៦) | (៤.៧២២.៤១៤) | ២៣,៧៩% |
| ចំណាយរំលស់លើ ទ្រព្យសកម្មរូបី និងអរូបី | (៣៤.០៤៣.៧៥៦) | (២៤.៥២៣.៨៦៣) | (៩.៥១៩.៨៩៣) | ៣៨,៨២% |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ-សុទ្ធ | ២.១៤៧.៧៩៩ | (១.២៨៩.៥៣៣) | ៣.៤៣៧.៣៣២ | ២៦៦,៥៦% |
| ចំណូលការប្រាក់ | ២៣.០៦៧.៨០២ | ៨.៥៩២.១២២ | ១៤.៤៧៥.៦៨០ | ១៦៨,៤៨% |
| ចំណាយការប្រាក់ | (១១.៦៦៣.០៤២) | (១២.០៣៨.២៤៩) | (៣៧៥.២០៧) | (០.០៣%) |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | ៥៦.០៥៦.៣៣៨ | ៤៨.០៨៦.៨០៣ | ៧.៩៦៩.៥៣៥ | ១៦,៥៧% |

រ.ទ.ស.ភ. មានចំណេញមុនបង់ពន្ធលើប្រាក់ចំណេញចំនួន ៤៨.០៨៦.៨០៣ពាន់រៀលសម្រាប់ ដំណាច់ឆ្នាំ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ និង ៥៦.០៥៦.៣៣៨ពាន់រៀលសម្រាប់ ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់កើនឡើងចំនួន ៧.៩៦៩.៥៣៥ពាន់រៀល ស្មើនឹង១៦,៥៧%។ ប្រាក់ចំណេញនេះកើនឡើងដោយសារចំណូលសរុបរបស់ រ.ទ.ស.ភ. មានការកើនឡើងចំនួន ៤.៩៦២.៦៤២ពាន់រៀល ស្មើនឹង៣,២៧% និងចំណូលការប្រាក់ មានការកើនឡើងចំនួន១៤.៤៧៥.៦៨០ពាន់រៀល ស្មើនឹង១៦៨,៤៨% (ដោយសារតែការកើនឡើងនៃតម្លៃប្រាក់អឺរ៉ូប្រៀបធៀបជាមួយប្រាក់រៀល ក្នុងឆ្នាំ២០១៤ ដែលបានជះឥទ្ធិពលជាវិជ្ជមានទៅលើប្រាក់កម្ចីដែលទទួលបានជារូបិយប័ណ្ណបរទេសរបស់ រ.ទ.ស.ភ.)។ ប៉ុន្តែកំណើនចំណូលនេះ ត្រូវទទួលរងការប៉ះពាល់ពីការកើនឡើងនៃចំណាយប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធ មានការកើនឡើងចំនួន ៤.៧២២.៤១៤ ពាន់រៀល ស្មើនឹង២៣,៧៩% ចំណាយរំលស់លើទ្រព្យសកម្មរូបី និងអរូបី មានការកើនឡើងចំនួន ៩.៥១៩.៨៩៣ពាន់រៀល ស្មើនឹង៣៨,៨២%។

## ១- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ក.៥- ការចំណេញក្រោយបង់ពន្ធ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារនិងអាករ ដូចនេះ រ.ទ.ស.ភ. មានកាតព្វកិច្ចត្រូវបង់ពន្ធលើប្រាក់ចំណេញជាប់ពន្ធនូវអត្រា ២០%។ ដោយឡែកពន្ធលើប្រាក់ចំណេញដែលជាប់អត្រា២០% បានមកពីលទ្ធផលនៃប្រាក់ចំណេញគណនេយ្យ ទូទាត់ជាមួយនឹងចំណាយដែលមិនអាចកាត់កងបានក្នុងអត្រាពន្ធ ២០%។

➢ **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបជាមួយដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣**

| | **ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ (ពាន់រៀល)** | **ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ (ពាន់រៀល)** | **បម្រែបម្រួល (ពាន់រៀល/ភាគរយ)** | |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ (ក) | ៥៦.០៥៦.៣៣៨ | ៤៨.០៨៦.៨០៣ | ៧.៩៦៩.៥៣៥ | ១៦,៥៧% |
| ចំណាយពន្ធលើប្រាក់ចំណេញ (ខ) | (១០.០៥១.៨១១) | (៩.៣៤១.២៧៤) | (៧១០.៥៣៧) | ៧,៦១% |
| ចំណេញក្នុងឆ្នាំ | ៤៦.០០៤.៥២៧ | ៣៨.៧៤៥.៥២៩ | ៧.២៥៨.៩៩៨ | ១៨,៧៤% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ១៧.៩៣% | ១៩.៤៣% | | |

រ.ទ.ស.ភ មានចំណេញក្នុងឆ្នាំចំនួន ៣៨.៧៤៥.៥២៩ពាន់រៀលសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ និង ៤៦.០០៤.៥២៧ ពាន់រៀល សម្រាប់ដំណាច់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដែលមានទឹកប្រាក់កើនឡើងចំនួន ៧.២៥៨.៩៩៨ពាន់រៀល ស្មើនឹង១៨,៧៤%។ កំណើននេះកើនឡើងជាចម្បងដោយសារចំណេញមុនបង់ពន្ធកើនចំនួន ៧.៩៦៩.៥៣៥ពាន់រៀល ស្មើនឹង ១៦,៥៧%។ ចំណែកកំណើននៃចំណាយពន្ធលើប្រាក់ចំណេញចំនួន ៧១០.៥៣៧ពាន់រៀល ស្មើនឹង ៧,៦១% និងការប្រែប្រួលអត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញគឺដោយសារ ដែលកត្តាចម្បងមកពីការប្រែប្រួលនៃចំណាយមិនអាចកាត់កងបានតាមច្បាប់ពន្ធ។

### ក.៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

- **អត្រាថ្លៃទឹក៖** រ.ទ.ស.ភ. ជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច និងសង្គម។ ដោយហេតុនេះហើយបានជាការកំណត់ថ្លៃលក់ទឹក ត្រូវតែបានអនុម័តពីនាយករដ្ឋមន្ត្រី។ ចាប់តាំងពីឆ្នាំ២០០១ រ.ទ.ស.ភ. ពុំដែលធ្វើការសម្រួល ឬដំឡើងថ្លៃលើការប្រើប្រាស់ទឹកស្អាតទេ។

ផលចំណេញដែលទទួលបានកន្លងមក ក៏ដូចជាកំនើនពីមួយឆ្នាំទៅមួយឆ្នាំ គឺដោយសារ តែមានកត្តាគាំទ្រដូចខាងក្រោម៖

- **អត្រាទឹកបាត់បង់៖** រ.ទ.ស.ភ. បានប្រើប្រាស់នូវយន្តការដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយអត្រាទឹកបាត់បង់ពី ៧២% នៅឆ្នាំ១៩៩៣ ទៅ ៧,៧៦% នៅឆ្នាំ២០១៤។ កត្តានេះជាកត្តាចម្បងដែលធ្វើឲ្យ រ.ទ.ស.ភ. មានចិរភាពហិរញ្ញវត្ថុ និងអភិវឌ្ឍសហគ្រាសរក្សានូវស្ថានភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសហគ្រាសប្រកបដោយនិរន្តភាព។

- **ការបង្កើនចំនួនអតិថិជន៖** ដើម្បីទទួលបាននូវចំណូលពីការលក់ទឹកស្អាត រ.ទ.ស.ភ. បានបង្កើនចំនួនអតិថិជនរបស់ខ្លួន ដោយពង្រីកផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតទៅតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់ទឹកស្អាត ដូចជាការបំពេញផ្ទៃសេវាឲ្យបាន ១០០% នៅក្នុងរាជធានីភ្នំពេញ តំបន់ជុំវិញរាជធានីភ្នំពេញ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច។

# ១-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

## ក.៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ (ត)

**-ការបង្កើនថ្លៃលក់ទឹកមធ្យម៖** តាមរយៈការស្វែងរកអតិថិជន ដែលជាប្រភេទអាជីវកម្ម-ឧស្សាហកម្ម ធ្វើឲ្យថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ. កើនឡើង ដោយសារតេថ្លៃប្រើប្រាស់ទឹករបស់អតិថិជនប្រភេទនេះមានកម្រិតខ្ពស់ជាងអតិថិជនប្រភេទផ្សេងទៀត។

**-ការគ្រប់គ្រងលើការចំណាយប្រតិបត្តិការ៖** រ.ទ.ស.ភ. ធ្វើការគ្រប់គ្រងលើការចំណាយនេះ ពិសេសការចំណាយលើការប្រើប្រាស់ថាមពលអគ្គីសនីដែលជាចំណាយដ៏ធំ និងសំខាន់ក្នុងដំណើរការប្រព្រឹត្តកម្មទឹកស្អាត តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាថ្មីៗ ដូចជាជ្រើសរើសយកការប្រើប្រាស់ម៉ាស៊ីនបូមទឹកដែលអាចប្រែប្រួលទៅតាមសំពាធទឹក។ នៅឆ្នាំ២០១២ រ.ទ.ស.ភ. ចាប់ផ្តើមប្រើប្រាស់វត្ថុធាតុដើមក្នុង ការធ្វើប្រព្រឹត្តកម្មទឹកដែលមានប្រសិទ្ធភាពខ្ពស់ គឺមានតម្លៃទាប ដូចជាការប្រើប្រាស់សារជាតុបណ្តុំកករ (PAC) ជំនួសសាច់ជូរ។

**-ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវដំណើរការកិច្ចលទ្ធកម្ម៖** រ.ទ.ស.ភ. បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ បញ្ញត្តិ និងគោលការណ៍ណែនាំផ្សេងៗ សម្រាប់ដំណើរការកិច្ចលទ្ធកម្មក្នុងការទិញបំពង់ សម្ភារ និងវត្ថុធាតុដើម ដែលដំណើរការនេះឆ្លុះបញ្ចាំងឲ្យឃើញពីតម្លាភាព និងការប្រកួតប្រជែងថ្លៃទំនិញនៅលើទីផ្សារ ដែលជាហេតុធ្វើឲ្យ រ.ទ.ស.ភ. ទទួលបានការទិញនូវតម្លៃទាប តែក៏មិនមើលរំលងនូវគុណភាពនោះដែរ។

**-អត្រាទារប្រាក់៖** នាចុងឆ្នាំ២០១៤ រ.ទ.ស.ភ. មានអត្រាទារប្រាក់ ៩៩,៩០%។ អត្រានេះមិនត្រឹមតែធ្វើឲ្យ រ.ទ.ស.ភ. មានសន្ទនីយភាពខ្ពស់នោះទេ តែក៏ធ្វើឲ្យ រ.ទ.ស.ភ. មានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ទុនបង្វិលរបស់ខ្លួនឲ្យមានប្រសិទ្ធភាពផងដែរ។

**-ការគ្រប់គ្រងសាច់ប្រាក់៖** តាមរយៈអត្រាទារប្រាក់ដែលមានកម្រិតខ្ពស់ខាងលើនេះធ្វើឲ្យ រ.ទ.ស.ភ. មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ដោយទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ក្នុងការគ្រប់គ្រងនេះ រ.ទ.ស.ភ. បានរក្សាទុកនូវសាច់ប្រាក់សម្រាប់ប្រើប្រាស់ជាទុនបង្វិលក្នុងរយៈពេល ២ទៅ៣ខែ ឯសាច់ប្រាក់ដែលទំនេរនោះ រ.ទ.ស.ភ. បានធ្វើការវិនិយោគរយៈពេលខ្លី ដោយដាក់ប្រាក់បញ្ញើមានកាល កំណត់រយៈពេលខ្លីនៅធនាគារពាណិជ្ជ ជាមួយនឹងការទទួលបាននូវអត្រាការប្រាក់ខ្ពស់ តែ រ.ទ.ស.ភ. ក៏បានធ្វើការថ្លឹងថ្លែងពីហានិភ័យ និងផលចំណេញពីអត្រាការប្រាក់ខ្ពស់នេះដែរ។

**-ការជ្រើសរើសយកនូវអ្នកផ្តល់ហិរញ្ញប្បទានដែលផ្តល់អត្រាការប្រាក់ទាប៖** ដោយសារមានតម្រូវការប្រើប្រាស់ទឹកស្អាតកើនឡើងខ្ពស់ ធ្វើឲ្យ រ.ទ.ស.ភ. មានតម្រូវការហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគដូច ជាការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាត ការតបណ្តាញមេនាំទឹក និងបណ្តាញចែកចាយ។ រ.ទ.ស.ភ. បានស្វែងរកដៃគូអភិវឌ្ឍអន្តរជាតិដូចជាទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) ដើម្បីទទួលបាននូវហិរញ្ញប្បទាន ដែលមានអត្រាការប្រាក់ទាប។

**-ស្ថានភាពសេដ្ឋកិច្ច៖** ការប្រែប្រួលនូវស្ថានភាពសេដ្ឋកិច្ចជះឥទ្ធិពលលើមធ្យមភាគនៃការប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែ ដែលធ្វើឲ្យមានការប្រែប្រួលទៅលើកម្រិតនៃថ្លៃលក់ទឹកមធ្យម។

# ២- កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ

## ក- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ដោយយោងទៅតាមការសិក្សានៃតម្រូវការប្រើប្រាស់ទឹកធៀបទៅនឹងកំណើនប្រជាជននៅក្នុងរាជធានីភ្នំពេញ ដោយសារការពង្រីកតំបន់ជុំវិញរាជធានីភ្នំពេញ រ.ទ.ស.ភ. នឹងត្រូវធ្វើការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាត ដែលមានពីរដំណាក់កាលបន្ថែមទៀតនៅនិរោធន៍។ គម្រោងវិនិយោគរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធន៍ដំណាក់កាល១ ដែលមានសមត្ថភាពផលិតទឹកចំនួន ១៣០,០០០ម៉ែត្រគូបក្នុង១ថ្ងៃ ដែលបានដាក់ឲ្យប្រើប្រាស់នូវក្នុងឆ្នាំ២០១៣។ គម្រោងវិនិយោគរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធន៍ដំណាក់កាល២ បានចាប់ផ្តើមសាងសង់បន្ទាប់ពីដំណាក់កាល១ត្រូវបានបញ្ចប់ ដែលមានសមត្ថភាពផលិតបន្ថែមចំនួន ១៣០.០០០ ម៉ែត្រគូប/ថ្ងៃ ដើម្បីបំពេញតម្រូវការទឹកស្អាតចាប់ពីឆ្នាំ២០១៥។

## ២- កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ (ត)

### ខ- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការប្រែប្រួលនៃថ្លៃវត្ថុធាតុដើមសម្រាប់ប្រព្រឹត្តកម្មទឹកស្អាត អាចប៉ះពាល់ដល់ថ្លៃដើមផលិត ប៉ុន្តែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ដោយសារការចំណាយនេះមានអត្រាមិនលើសពី១០% នៃចំណាយប្រព្រឹត្តការ។ ទោះជាយ៉ាងណាក៏ដោយ រ.ទ.ស.ភ. ក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាថ្លៃវត្ថុធាតុដើមសមស្របទៅតាមតម្លៃលើទីផ្សារជាក់ស្តែង ហើយនីតិវិធីនេះក៏ផ្តល់លទ្ធភាពសម្រាប់ រ.ទ.ស.ភ. ទទួលបាននូវតម្លៃប្រកួតប្រជែង ដែលមានតម្លៃទាប។

### គ- ការវិភាគលើពន្ធ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះរ.ទ.ស.ភ. មានកាតព្វកិច្ចត្រូវបង់ពន្ធអាករ ទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ រ.ទ.ស.ភ. មានកាតព្វកិច្ចបង់ពន្ធអាករ ទៅតាមរបបពិត និងជាសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ឃ- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ នេះ គណៈគ្រប់គ្រងយល់ថា រ.ទ.ស.ភ. ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

## ៣- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ រ.ទ.ស.ភ. គឺការលក់ទឹកស្អាត ដែលជាតម្រូវការចាំបាច់របស់ប្រជាជននៅក្នុងរាជធានីភ្នំពេញ។ ចំណូលពីការលក់ទឹកស្អាតនេះ បានចូលរួមចំណែកលើសពី៩០% នៃចំណូលសរុបនៅឆ្នាំ២០១៤ ហើយ រ.ទ.ស.ភ. ក៏ជាអ្នកផ្គត់ផ្គង់ផ្តាច់មុខនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ។ ប្រាក់ចំណូលអាចមានការកើនឡើងអាស្រ័យទៅតាមចំនួនប្រជាពលរដ្ឋដូចជា ការពង្រីករាជធានីភ្នំពេញ និងការធ្វើចំណាកស្រុករបស់ប្រជាជននៅតាមបណ្តាខេត្តមករស់នៅក្នុងរាជធានីភ្នំពេញ។

## ៤- ផលប៉ះពាល់នៃការប្តូរបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity)

### ៤.១- ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

រ.ទ.ស.ភ. បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ "ប្រាក់រៀល"។ ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណគោល តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុលរូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។ រ.ទ.ស.ភ. ខាតលើអត្រាប្តូរប្រាក់ចំនួន ១.២៨៩.៥៣៣ពាន់រៀល នៅឆ្នាំ២០១៣ និងចំណេញលើអត្រាប្តូរប្រាក់ចំនួន ២.១៤៧.៧៩៩ពាន់រៀល នៅឆ្នាំ២០១៤។

### ៤.២- ផលប៉ះពាល់នៃអត្រាការប្រាក់

#### ៤.២.១- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណូលការប្រាក់

ដោយសារនៅប្រទេសកម្ពុជាពុំមានទីផ្សាររូបិយប័ណ្ណ ដូច្នេះ រ.ទ.ស.ភ. មានលទ្ធភាពត្រឹមតែវិនិយោគរយៈពេលខ្លីលើការដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល១ឆ្នាំ នៅធនាគារពាណិជ្ជក្នុងស្រុកតែប៉ុណ្ណោះ។

## ៤- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ (Commodity) "ត"

### ៤.២.២- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណាយការប្រាក់

រ.ទ.ស.ភ. មានប្រភពហិរញ្ញប្បទានពីរ ដែលមានអត្រាការប្រាក់ថេរ និងប្រែប្រួល។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ថេរមាន ហិរញ្ញប្បទានដែលទទួលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)នៅអត្រា៦,៥០% ធនាគារពិភពលោក(WB)នៅអត្រា៨,៥០% និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)នៅអត្រា៧,៣៥%ក្នុងមួយឆ្នាំ។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ប្រែប្រួលមាន ហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD)នៅអត្រាEURIBOR ៦ខែ ដក១,៣៥ពិន្ទុ។ តែអត្រានេះមិនឲ្យទាបជាង០,២៥% និងមិនខ្ពស់ជាង៥,២១%ក្នុងឆ្នាំនោះទេ។ ហិរញ្ញប្បទាននេះនឹងត្រូវប្តូរទៅហិរញ្ញប្បទានដែលមានអត្រាការប្រាក់ថេរ ចាប់ពីខែកញ្ញា ឆ្នាំ២០១៣។

### ៤.២.៣- ផលប៉ះពាល់នៃថ្លៃទំនិញ

តាមរយៈដំណើរការកិច្ចលទ្ធកម្មរបស់ រ.ទ.ស.ភ. ដែលអនុលោមទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន រួមផ្សំនឹងគោលការណ៍ណែនាំផ្សេងៗ ដែលតម្រូវឲ្យ រ.ទ.ស.ភ. ធ្វើកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់សម្ភារ និងវត្ថុធាតុដើមទៅតាមតម្លៃប្រកួតប្រជែង ឬតម្លៃចរចាររួច។ ទោះបីជាមានបម្រែបម្រួលនៃបរិមាណប្រើប្រាស់វត្ថុធាតុដើមក៏ដោយវត្ថុធាតុសម្រាប់ការប្រព្រឹត្តកម្មទឹកមានចំណែកតូចបើប្រៀបធៀបនឹងការចំណាយដំណើរការនៅឆ្នាំនីមួយៗ។ គណៈគ្រប់គ្រងជឿជាក់ថា បម្រែបម្រួលនៃបរិមាណប្រើប្រាស់នេះមិនប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសឡើយ។

## ៥- ផលប៉ះពាល់នៃអតិផរណា

រ.ទ.ស.ភ. បានរក្សានូវថ្លៃលក់ទឹកថេរមិនប្រែប្រួលចាប់តាំងពី២០០១ រហូតដល់បច្ចុប្បន្ន ដោយមិនធ្វើការកែសម្រួលទៅតាមការប្រែប្រួលនៃអតិផរណាឡើយ ហើយនៅតែរក្សាបាននូវចិរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ។

## ៦- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល

ធុរកិច្ចរបស់ រ.ទ.ស.ភ ទទួលការជះឥទ្ធិពលពីគោលនយោបាយមួយចំនួន ដែលកំណត់ដោយរាជរដ្ឋាភិបាលដូចជា៖

- **ថ្លៃលក់ទឹកស្អាត៖** ដោយសារទឹកស្អាតជាតម្រូវការចាំបាច់សម្រាប់ការរស់នៅរបស់ប្រជាជនទូទាំងរាជធានីភ្នំពេញដូច្នេះតម្លៃនេះត្រូវបានកំណត់ដោយរដ្ឋាភិបាល។
- **ការពង្រីកផ្ទៃសេវា៖** ការពង្រីកផ្ទៃសេវាបន្ថែម ដើម្បីផ្គត់ផ្គង់ទឹកស្អាតត្រូវបានរឹតត្បិតដោយបេសកកម្មរបស់ រ.ទ.ស.ភ. ដែលអនុញ្ញាតឲ្យផលិត និងចែកចាយទឹកសម្រាប់ការប្រើប្រាស់របស់សាធារណជននៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ការរឹតត្បិតនេះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រ.ទ.ស.ភ.។
- **ការពង្រីករាជធានីភ្នំពេញ៖** រាជរដ្ឋាភិបាលមានគោលនយោបាយពង្រីករាជធានីភ្នំពេញ ដោយបញ្ចូល ២០ឃុំបន្ថែមទៀតទៅក្នុងតំបន់រាជធានីភ្នំពេញ ដែលធ្វើឲ្យផ្ទៃសេវារបស់ រ.ទ.ស.ភ. ក្នុងការផ្គត់ផ្គង់ទឹកស្អាតក៏ត្រូវពង្រីកបន្ថែមដែរ។
- **ការតព្វកិច្ចរបស់ រ.ទ.ស.ភ. ក្នុងការផ្តល់ហិរញ្ញប្បទានទៅស្ថាប័នដទៃទៀត៖** រ.ទ.ស.ភ. មានកាតព្វកិច្ចត្រូវផ្តល់ហិរញ្ញប្បទាន ទៅរដ្ឋាករទឹកខេត្តពោធិ៍សាត់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក៏ត្រូវជាក្រសួងអាណាព្យាបាលរបស់ រ.ទ.ស.ភ. ផងដែរ។
- **គោលនយោបាយពន្ធលើអចលនទ្រព្យ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ឲ្យអនុវត្តនូវប្រកាសលេខ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពី " ការប្រមូលពន្ធលើអចលនទ្រព្យ " ។ អចលនទ្រព្យរបស់ រ.ទ.ស.ភ. គឺសម្រាប់បម្រើឲ្យប្រព័ន្ធផលិតកម្មទឹកស្អាត ដែលអចលនទ្រព្យប្រភេទនេះត្រូវបានលើកលែងពន្ធតាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៦ សហវ.អពដ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១។

ទោះបីជាមានការរឹតត្បិតដោយគោលនយោបាយខាងលើក៏ដោយ ក៏គណៈគ្រប់គ្រងព្យាយាមរិះរកនូវគ្រប់មធ្យោបាយ ដើម្បីបង្កើនប្រាក់ចំណូលរបស់ រ.ទ.ស.ភ. ដើម្បីរក្សា និងធានាឲ្យបានចីរភាពរបស់ រ.ទ.ស.ភ. ផងដែរ ដូចជាការបង្កើតនូវខ្សែសង្វាក់ធុរកិច្ចថ្មីសម្រាប់ រ.ទ.ស.ភ.។





# ផ្នែកទី១០:
# ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន (ប្រសិនមាន)

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រ.ទ.ស.ភ. ពុំមានព័ត៌មានផ្សេងទៀត ក្រៅពីព័ត៌មានដែលបានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៤ នេះទេ។

# ហត្ថលេខារបស់អភិបាល
# របស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
បានអាន និងឯកភាព



ហត្ថលេខា
**ស៊ឹម ណារ៉ា**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
បានអាន និងឯកភាព



ហត្ថលេខា
**ស៊ឹម ស៊ីថា**
អភិបាល

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
បានអាន និងឯកភាព



ហត្ថលេខា
**ម៉ី វ៉ាន់**
អភិបាល

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
បានអាន និងឯកភាព



ហត្ថលេខា
**ឃួន ស្រេង**
អភិបាល

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
បានអាន និងឯកភាព



ហត្ថលេខា
**ទិន ចន្ទ្រា**
អភិបាល

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
បានអាន និងឯកភាព



ហត្ថលេខា
**ចាន់ យុនហៀង**
អភិបាល

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥
បានអាន និងឯកភាព



ហត្ថលេខា
**អោម សេង បូរ៉ា**
អភិបាល

# ពានរង្វាន់ដែល រ.ទ.ស.ភ. ទទួលបាន ក្នុងឆ្នាំ២០១៤






**ឯកឧត្តម ស៊ឹម ស៊ីថា** អគ្គនាយក រ.ទ.ស.ភ. ទទួលពានរង្វាន់
"THE DIAMOND EYE AWARD FOR QUALITY COMMITMENT AND EXCELLENCE"
ពី Otherways Management Association Club-Paris




ពានរង្វាន់
"INTERNATIONAL TROPHY FOR QUALITY"
ពី Global Trade Leaders' Club




ពានរង្វាន់

"EUROPEAN AWARD FOR BEST PRACTICES"

ពី European Society for Quality Research




ពានរង្វាន់

"INTERNATIONAL EUROPE AWARD FOR QUALITY"

(ទីក្រុងប៉ារីស ប្រទេសបារាំង)




ពានរង្វាន់

Best Quality Leadership Award

(Las Vegas)




ពានរង្វាន់

THE BIZZ

(ទីក្រុងឌុយបៃ ប្រទេសអារ៉ាប់)

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)**

: +៨៥៥(២៣) ៧២៤ ០៤៦

: ADMIN@PPWSA.COM.KH

: WWW.PPWSA.COM.KH

អគារលេខ ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ